# ព្រះ
# ត្រៃបិដកបាលី
## និង
## សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## ខុទ្ទកនិកាយ ជាតក
# នវមភាគ
# ៦០

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០២

សុត្តន្តបិដកេ

ខុទ្ទកនិកាយេ ជាតកំ

នវមោ

៦០

# សុត្តន្តបិដកេ

## ខុទ្ទកនិកាយស្ស ជាតកំ

## នវមោ ភាគោ

---

## បកិណ្ណកនិបាតជាតកំ

## សាលិកេទារជាតកំ[១]

(១) សម្បន្នំ សាលិកេទារំ សុវា ភុញ្ជន្តិ កោសិយ
បដិវេទេមិ តេ ព្រហ្មេ ន នេ វារេតុមុស្សហេ
ឯកោ ច តត្ថ សកុណោ យោ តេសំ សព្វសុន្ទរោ
ភុត្វា សាលឹ យថាកាមំ តុណ្ឌេនាទាយ គច្ឆតិ ។

(២) ឱឌ្ឌេន្តុ កវសំ បាសំ យថា ពជ្ឈេថ សោ ទិជោ
ជីវញ្ច នំ គហេត្វាន អានយេហិ មមន្តិកេ ។

(៣) ឯតេ ភុត្វា បិវិត្វា ច បក្កមន្តិ វិហង្គមា
ឯកោ គណ្ហាសិ តាសេន កឹ បាបំ បកតំ មយា ។

១ ឧ. [illegible] ។

# សុត្តន្តបិដក

## ខុទ្ទកនិកាយ ជាតក

## នវមភាគ

---

## បកិណ្ណកនិបាតជាតក

## សាលិកេទារជាតក

(១) *(បុរសអ្នករក្សាស្រែពោលថា) បពិត្រកោសិយៈ ស្រូវសាលីក្នុងស្រែ បរិបូណ៌ផល ពួកសេកតែងស៊ី បពិត្រព្រាហ្មណ៍ ខ្ញុំសូមជំរាបលោក ខ្ញុំមិនអាចហាមឃាត់សេកទាំងនោះបានឡើយ បណ្តាសេកទាំងនោះ មានសេកមួយ ដែលល្អជាងចំណែកទាំងពួង ជាងសេកទាំងនោះ ស៊ីនូវស្រូវសាលី តាមសេចក្តីប្រាថ្នាហើយ ក៏ពាំស្រូវដោយចំពុះហើរទៅទៀត ។*

(២) *(សាលិយព្រាហ្មណ៍ កោសិយគោត្រពោលថា) អ្នកទាំងឡាយ ចូរដាក់អន្ទាក់ធ្វើដោយកន្ទុយសេះ បក្សីនោះនឹងជាប់ ចូរអ្នកចាប់ពាំទាំងរស់ នាំមកក្នុងសំណាក់នៃអញ ។*

(៣) *(ស្តេចសេកពោលថា) បក្សីទាំងនុ៎ះ ស៊ីផង ផឹកផង ហើយហើរចេញទៅ ឯអាត្មាអញម្នាក់ឯង ជាប់អន្ទាក់ហើយ ឯអាត្មាអញធ្វើ ហើយនូវអំពើលាមកដូចម្តេច ។*

(៦) ឧទរំ នូន អញ្ញេសំ សុវ អច្ចោទរំ តវ
ភុត្វា សាលិំ យថាកាមំ តុណ្ឌេនាទាយ គច្ឆសិ ។
កោដ្ឋំ នុ តត្ថ បូរេសិ សុវ វេរំ នុ តេ មយា
បុដ្ឋោ មេ សម្ម អក្ខាហិ កុហិំ សាលិំ និធេយ្យសិ ។

(៧) ន មេ វេរំ តយា សទ្ធិំ កោដ្ឋោ មយ្ហំ ន វិជ្ជតិ
ឥណំ មុញ្ចាមិ ឥណំ ទម្មិ សម្បត្តោ កោដសិម្ពលឹ
និធិម្បិ តត្ថ និទហាមិ ឯវំ ជានាហិ កោសិយ ។

(៨) កីទិសំ តេ ឥណទានំ ឥណមោក្ខោ ច កីទិសោ
និធិនិធានមក្ខាហិ អថ បាសា បមោក្ខសិ ។

(៩) អជាតបក្ខា តរុណា បុត្តកា មយ្ហំ កោសិយ
តេ មំ ភតា ភរិស្សន្តិ តស្មា តេសំ ឥណំ ទទេ ។
មាតា បិតា ច មេ វុឌ្ឍា ជិណ្ណកា គតយោព្វនា
តេសំ តុណ្ឌេន ហាតូន មុញ្ចេ បុព្វកតំ ឥណំ ។

១ ម. និធិយសំ ។ ឧ. និកហសំ ។



(៦) (ព្រាហ្មណ៍...) ម្នាលសេក ពោះរបស់សត្វស្លាបដទៃ (ជាពោះតូចល្មម) ដោយពិត (ចំណែកខាងពោះ)របស់អ្នក ជាពោះធំក្រៃលែង លុះអ្នកស៊ីស្រូវសាលីតាមសេចក្តីប្រាថ្នាហើយ ក៏កាំយកស្រូវដោយចំពុះហើរទៅ ។ ម្នាលសេក អ្នកចាក់បំពេញជង្រុកក្នុងព្រៃនោះតើឬ ឬក៏អ្នកចងពៀរនឹងយើង ម្នាលសំឡាញ់ យើងសួរហើយ អ្នកចូរប្រាប់ អ្នកកប់ស្រូវសាលីទុកក្នុងទីណា ។ [៩]

(៧) (សេកទូល...) ខ្ញុំមិនចងពៀរជាមួយនឹងអ្នកទេ ជង្រុករបស់ខ្ញុំក៏មិនមានដែរ ខ្ញុំដោះបំណុលផង ឲ្យខ្ចីផង ខ្ញុំហើរទៅដល់ដើមរកា ក៏កប់កំណប់ទុកក្នុងព្រៃរកានោះ បពិត្រកោសិយៈ អ្នកចូរជ្រាបយ៉ាងនេះចុះ ។

(៨) (ព្រាហ្មណ៍...) ការឲ្យខ្ចីរបស់អ្នកដូចម្តេច ការដោះបំណុលដូចម្តេច អ្នកចូរប្រាប់នូវការកប់កំណប់ កាលបើដូច្នោះ អ្នកនឹងរួចចាកអន្ទាក់ ។

(៩) (សេកទូល...) បពិត្រកោសិយៈ ខ្ញុំមានកូនតូចៗ មិនទាន់ដុះស្លាបនៅឡើយ កូនតូចៗទាំងនោះ ដែលខ្ញុំចិញ្ចឹមហើយនឹងចិញ្ចឹមខ្ញុំវិញ ហេតុនោះ ខ្ញុំឲ្យខ្ចីបុលដល់កូនតូចៗទាំងនោះ ។ មួយទៀត ខ្ញុំមានមាតាបិតាចាស់ព្រឹទ្ធ មានវ័យកន្លងហើយ ខ្ញុំនាំ (ស្រូវសាលី) ដោយចំពុះ យកទៅជូនមាតាបិតាទាំងនោះ ខ្ញុំឈ្មោះដោះបំណុលដែលគាត់ធ្វើហើយមុន ។

អញ្ញេបិ តត្ថ សកុណា  ខីណបត្តា សុទុព្វលា
តេសំ បុញ្ញត្ថិកោ ទម្មិ  តំ និធឹ អាហុ បណ្ឌិតា ។
ឦទិសំ មេ ឥណទានំ  ឥណមោក្ខោ ច ឦទិសោ
និធិនិធានមក្ខាមិ  ឯវំ ជានាហិ កោសិយ ។

(៨) ភទ្ទកោ វតាយំ បក្ខី  ទិជោ បរមធម្មិកោ
ឯកច្ចេសុ មនុស្សេសុ  អយំ ធម្មោ ន វិជ្ជតិ ។
ភុញ្ជ សាលឹ យថាកាមំ  សហ សព្វេហិ[១] ញាតិភិ
បុនាបិ សុវ បស្សេមុ  បិយំ មេ តវ ទស្សនំ ។

(៩) ភុត្តញ្ច បីតញ្ច តវស្សមម្ហិ[២]
រតី ច នោ កោសិយ តេ សកាសេ
និក្ខិត្តទណ្ឌេសុ ទទាហិ ទានំ
ជិណ្ណេ ច មាតាបិតរោ ភរស្សុ ។

(១០) លក្ខី វត មេ ឧទបាទិ អជ្ជ
យោហំ អទ្ទស្សំ បវរំ ទិជានំ
សុវស្ស សុត្វាន សុភាសិតានិ
កាហាមិ បុញ្ញានិ អនប្បកានិ ។

១ ម. សព្វេភិ ។ ២ ម. តវស្សមម្ហិ ។



កូនទាំងពួកនោះមានបក្សីទាំងឡាយដទៃទៀត ដែលត្រូវស្លាបអស់ហើយ ថយថយកម្លាំង ខ្ញុំត្រូវការដោយបុណ្យ ក៏ឲ្យផលបក្សីទាំងនោះ បណ្ឌិតទាំងឡាយតែងពោលថា បុញ្ញកម្មនោះជាកំណប់ ។ ការឲ្យខ្ចីរបស់ខ្ញុំយ៉ាងនេះ ការដោះបំណុលរបស់ខ្ញុំយ៉ាងនេះ ខ្ញុំប្រាប់នូវការដាក់កំណប់ បពិត្រកោសិយៈ អ្នកចូរជ្រាបយ៉ាងនេះ ។

(៨) (ព្រាហ្មណ៍...) បក្សីមានគំនិតល្អដូច្នេះ ប្រសើរណាស់តើ ជាសត្វប្រកបដោយធម៌ដ៏ក្រៃលែង មនុស្សពួកខ្លះមិនមានធម៌នេះ ។ អ្នកចូរបរិភោគនូវស្រូវសាលី ជាមួយនឹងពួកញាតិទាំងអស់ តាមប្រាថ្នាចុះ ម្នាលសេក សូមឲ្យយើងឃើញអ្នកទៀត ព្រោះការបានជួបប្រទះនឹងអ្នក(នោះ) ជាទីស្រឡាញ់របស់យើង ។

(៩) (ស្ដេចសេក...) បពិត្រកោសិយៈ ខ្ញុំបានបរិភោគផង ផឹកផង ក្នុងលំនៅអ្នករួចហើយ ខ្ញុំមិនតាបតីនៅក្នុងសំណាក់ នៃអ្នកអស់រាត្រីមួយនេះ អ្នកចូរឲ្យទាន (ដល់សមណព្រាហ្មណ៍) ដែលមានអាជ្ញាដាក់ចុះហើយផង ចូរចិញ្ចឹមមាតាបិតា ដែលចាស់គ្រាំគ្រាផង ។

(១០) (ព្រាហ្មណ៍. . .) លក្ខី (សិរី បុណ្យ ទីពឹងប្រាជ្ញា) បានកើតឡើងហើយ ដល់យើងក្នុងថ្ងៃនេះ ព្រោះយើងបានជួបនឹងស្ដេចសេកដ៏ប្រសើរ ជាងពួកបក្សីទាំងឡាយ យើងនឹងធ្វើបុណ្យឲ្យច្រើន ព្រោះបានស្ដាប់នូវសុភាសិត របស់សេក ។

(១១) សោ កោសិយោ អត្តមនោ ឧទគ្គោ
អន្នញ្ច បានញ្ចាភិសង្ខរិត្វា
អន្នេន បានេន បសន្នចិត្តោ
សន្តប្បយី សមណព្រាហ្មណេ ចាតិ ។

សាលិកេទារជាតកំ បឋមំ ។

---

## ចន្ទកិន្នរជាតកំ

(១២) ឧបនីយតិទំ មញ្ញេ ចន្ទេ លោហិតមទ្ទនេ[1]
អជ្ជាហំ ជហាមិ[2] ជីវិតំ បាណា មេ ចន្ទេ និរុជ្ឈន្តិ ។
ឱសីទិ[3] មេ ទុក្ខំ ហទយំ មេ ឌយ្ហតេ និតម្មាមិ
តវ ចន្ទិយា សោចន្តិយា ន នំ អញ្ញេហិ សោកេហិ ។
តិណមិវ វនមិវ មិលាយាមិ នទី អបរិបុណ្ណាវ[4] សុស្សាមិ
តវ ចន្ទិយា សោចន្តិយា ន នំ អញ្ញេហិ សោកេហិ ។
វស្សមិវ សរេ បាទេ អស្សូនិ វត្តរេ មយ្ហំ
តវ ចន្ទិយា សោចន្តិយា ន នំ អញ្ញេហិ សោកេហិ ។

---

១ ម. លោហិតមទ្ទន ។ ២ ឱ. ចជាមិ វិជហាមិ ។ ម. អជ្ជ ជិហាមិ ។ ៣ ម. ឱសីទិ ។ ៤ ម. អបរិបុណ្ណាវ ។



(១១) *(អភិសម្ពុទ្ធគាថា) សាលិត្តិយព្រាហ្មណ៍ ជាកោសិយគោត្រនោះ មានចិត្តរីករាយ មានចិត្តខ្ពស់ឯក មានចិត្តជ្រះថ្លា បានតាក់តែងនូវបាយនិងទឹក ហើយញ៉ាំងសមណៈនិងព្រាហ្មណ៍ទាំងឡាយ ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ។*

ចប់ សាលិកេទារជាតក ទី ១ ។

---

## ចន្ទកិន្នរជាតក

(១២) *(ចន្ទកិន្នរពោលថា) ម្នាលនាងចន្ទា ជីវិតនេះប្រហែលជាជិតដាច់ហើយ ព្រោះព្រួញប្រឡាក់ដោយឈាម អញនឹងលះបង់នូវជីវិត ក្នុងថ្ងៃនេះឯង ម្នាលនាងចន្ទា ជីវិតរបស់អញនឹងរលត់ ។ ជីវិតរបស់អញជាទុក្ខទៀបចុះហើយ ហ្ឫទ័យរបស់អញក្តៅណាស់ អញលំបាកក្រៃពេក ព្រោះហេតុនាងចន្ទា កំពុងសោក មិនមែនព្រោះការសោកដទៃទេ ។ អញនឹងស្វិតស្រពោនដូចជាស្មៅ (ដែលគេដាក់លើថ្មក្តៅ) ដូចជាដើមឈើ (ដែលកាត់ផ្តាច់ឫសហើយ) អញនឹងរីងស្ងួតដូចជាស្ទឹងដែលមានទឹកមិនពេញ ព្រោះនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃទេ ។ ទឹកភ្នែកទាំងឡាយ របស់អញនេះហូរទៅ ដូចជាភ្លៀងដែលធ្លាក់លើជើងភ្នំហូរទៅ ព្រោះហេតុនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃឡើយ ។*

(១៣) ហតោ ហោ រាជបុត្ត យោ មេ ឥច្ឆិតបតី វរាកិយា

វិទ្ធោ វនមូលស្មឹ សោយំ វិទ្ធោ ឆមា សេតិ ។

ឥមំ មយ្ហំ ហទយសោកំ បដិមុញ្ចតុ រាជបុត្ត តវ មាតា

យោ មយ្ហំ ហទយសោកោ កិម្បុរិសំ អវេក្ខមានាយ ។

ឥមំ មយ្ហំ ហទយសោកំ បដិមុញ្ចតុ រាជបុត្ត តវ ជាយា

យោ មយ្ហំ ហទយសោកោ កិម្បុរិសំ អវេក្ខមានាយ ។

មា ច បុត្តំ មា ច បតឹ អទ្ទក្ខិ រាជបុត្ត តវ មាតា

យោ កិម្បុរិសំ អវធិ អទូសកំ មយ្ហំ កាមាហិ[១] ។

មា ច បុត្តំ មា ច បតឹ អទ្ទក្ខិ រាជបុត្ត តវ ជាយា

យោ កិម្បុរិសំ អវធិ អទូសកំ មយ្ហំ កាមាហិ ។

(១៤) មា ត្វំ ចន្ទេ រោទិ មា សោចិ វនតិមិរមត្តក្ខិ

មម ត្វំ ហោហិសិ ភរិយា រាជកុលេ បូជិតា នារីហិ ។

---

១ ម. កាមា ។



(១៣) (នាងកិន្នរី ពោលថាសាច់) កំលោះណា បាញ់ប្តីដែល

ខ្ញុំជាអ្នកកំព្រាប្រាថ្នាហើយ កំលោះ (នោះ) ពាក្រក់មែន ប្តីរបស់

ខ្ញុំនោះដែលត្រូវសរហើយ ដេកលើផែនដី ទៀបគល់ឈើ ។

ដែលកំលោះ សេចក្តីសោក ក្នុងឫទ័យណានៃខ្ញុំ ដែលកំពុងសំ-

ឡឹងមើលខ្លួនកិន្នរ សូមមាតារបស់អ្នក បានខ្លួនសេចក្តីសោកក្នុងឫ-

ទ័យដូចខ្ញុំនេះដែរ ។ ដែលកំលោះ សេចក្តីសោកក្នុងឫទ័យណា

របស់ខ្ញុំ ដែលកំពុងសំឡឹងមើលខ្លួនកិន្នរ សូមប្រពន្ធរបស់អ្នក

បានខ្លួនសេចក្តីសោក ក្នុងឫទ័យដូចខ្ញុំនេះដែរ ។ ដែលកំលោះ

បុគ្គលណា បានសម្លាប់កិន្នរ ដែលជាសត្វមិនប្រទូស្ត ព្រោះការ

ចង់បានខ្ញុំ សូមកុំឲ្យម្តាយរបស់អ្នក(នោះ)បានឃើញកូនផង សូម

កុំឲ្យបានឃើញប្តីផង ។ ដែលកំលោះ អ្នកណាបានសម្លាប់កិន្នរ

ដែលជាសត្វមិនប្រទូស្ត ព្រោះការចង់បានខ្ញុំ សូមកុំឲ្យប្រពន្ធ

របស់អ្នកនោះ បានឃើញកូនផង សូមកុំឲ្យបានឃើញប្តីផង ។

(១៤) (ព្រះរាជាត្រាស់ថា) ម្នាលនាងចន្ទា មាននៃ្រតដូចងងឹត

ក្នុងព្រៃ នាងកុំយំ កុំសោកឡើយ នាងនឹងបានជាអគ្គ-

មហេសីនៃយើង ដ៏មានស្រីៗទាំងពួងកោតក្រែង ។

(១៥) អបិ នូនាហំ មរិស្សំ នាហំ រាជបុត្ត តវ ហេស្សំ
យោ កិម្បុរិសំ អវធិ អទូសកំ មយ្ហំ កាមាហិ ។

(១៦) អបិ ភីរុកេ អបិ ជីវិតុកាមិកេ កិម្បុរិសី គច្ឆ ហិមវន្តំ
តាលីសតគ្គរភោជនា អញ្ញេ តេ វនា រមិស្សន្តិ ។

(១៧) តេ បព្វតា តា[១] ច កន្ទរា តា ច គិរិគុហាយោ
តត្ថ តំ អបស្សន្តី កិម្បុរិស កថំ អហំ កស្សំ[២] ។
យេសុ បព្វតេសុ មយំ ឯកតោ អភិរមិម្ហា
តត្ថ តំ អបស្សន្តី កិម្បុរិស កថំ អហំ កស្សំ[៣] ។
តេ បណ្ណសន្ថតា រមណីយា វាឡមិគេហិ អនុចិណ្ណា[៤]
តត្ថ តំ អបស្សន្តី កិម្បុរិស កថំ អហំ កស្សំ ។
តេ បុប្ផសន្ថតា រមណីយា វាឡមិគេហិ អនុចិណ្ណា
តត្ថ តំ អបស្សន្តី កិម្បុរិស កថំ អហំ កស្សំ ។

---

១ ម. តានិ ន ទិស្សតិ ។ ២ ឱ. តត្ថេវ ទានិ ។ តត្ថ តំ អបស្សន្តី កិម្បុរិស កថំ អហំ កស្សំ – ៣ ឱ. ម. អយំ គាថា ន ទិស្សតិ ។ ៤ អនុចិណ្ណានិ អទ្ធគតាយ ទិស្សតិ ។



(១៥) (កិន្នរី...) នែរាជបុត្រ អ្នកណាបានសម្លាប់ប្ដីកិន្នរ ដែលជាសត្វមិនប្រទូស្ត ព្រោះការចង់បានអញ អញស្ទើរតែស្លាប់ អញនឹងមិនធ្វើ (ជាប្រពន្ធ) របស់អ្នក(នោះ)ទេ ។

(១៦) (ព្រះរាជា...) ម្នាលនាងកិន្នរី ដែលជាស្រីមានសេចក្ដីខ្លាចផង ចង់រស់នៅផង នាងជាមេព្រៃ មានស្លឹកតាលីសៈ និងស្លឹកក្រស្នាជាភោជន ចូរនាងទៅកាន់ព្រៃហិមវន្តចុះ ពួកព្រៃដទៃនឹងត្រេកត្រអាលចំពោះនាង ។

(១៧) (កិន្នរី...) ភ្នំទាំងឡាយនោះផង ជ្រោះភ្នំទាំងឡាយនោះផង គុហាភ្នំទាំងឡាយនោះផង បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្ដេច ។ យើងទាំងឡាយ ដែលត្រេកត្រអាលជាមួយគ្នា លើភ្នំទាំងឡាយណា បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកលើភ្នំទាំងឡាយនោះ តើនឹងធ្វើដូចម្ដេច ។ ភ្នំទាំងឡាយនោះដេរដាសដោយស្លឹកឈើ គួររីករាយ ដែលពួកម្រឹគសាហាវធ្លាប់ដើរទៅមកញឹកញយ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្ដេច ។ ភ្នំទាំងឡាយនោះ ដេរដាសដោយផ្កាឈើ គួររីករាយ ដែលពួកម្រឹគសាហាវ ធ្លាប់ដើរទៅមកញឹកញយ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្ដេច ។

អញ្ញា សន្តិ តិរីដធមនិយោ កុសុមាភិកិណ្ណាសោតាយោ

តត្ថ តំ អបស្សន្តី កឹបុរិស កថំ អហំ កាសិំ ។

ធីលានិ ហរិតកា បត្តកស្ស ភញ្ជានិ ឥស្សរិយានិ

តត្ថ តំ អបស្សន្តី កឹបុរិស កថំ អហំ កាសិំ ។

ចីតានិ ហរិតកា បត្តកស្ស ភញ្ជានិ ឥស្សរិយានិ

តត្ថ តំ អបស្សន្តី កឹបុរិស កថំ អហំ កាសិំ ។

តម្ពានិ ហរិតកា បត្តកស្ស ភញ្ជានិ ឥស្សរិយានិ

តត្ថ តំ អបស្សន្តី កឹបុរិស កថំ អហំ កាសិំ ។

កុក្កានិ ហរិតកា បត្តកស្ស ភញ្ជានិ ឥស្សរិយានិ

តត្ថ តំ អបស្សន្តី កឹបុរិស កថំ អហំ កាសិំ ។

សេតានិ ហរិតកា បត្តកស្ស ភញ្ជានិ ឥស្សរិយានិ

តត្ថ តំ អបស្សន្តី កឹបុរិស កថំ អហំ កាសិំ ។

ចិត្រានិ ហរិតកា បត្តកស្ស ភញ្ជានិ ឥស្សរិយានិ

តត្ថ តំ អបស្សន្តី កឹបុរិស កថំ អហំ កាសិំ ។



ស្ទឹងលើភ្នំ ទឹកស្ទឹងកើតព្រៃពាំងផ្កាយ មានទឹកដ៏ថ្លាកាលហូរទៅ មានផ្កាឈើរសាត់អណ្តែតទៅតាមខ្សែទឹកក្រោមដើមព្រៃ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលតាំងខ្ពាយនៃភ្នំហិមពាន្ត មានពណ៌ខៀវ គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលតាំងខ្ពាយនៃភ្នំហិមពាន្ត មានពណ៌លឿង គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលតាំងខ្ពាយនៃភ្នំហិមពាន្ត មានពណ៌ក្រហម គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលតាំងខ្ពាយនៃភ្នំហិមពាន្ត មានចុងស្រួច គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលតាំងខ្ពាយនៃភ្នំហិមពាន្ត ដែលមានពណ៌ស គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។ កំពូលតាំងខ្ពាយនៃភ្នំហិមពាន្ត ដ៏វិចិត្រ គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច ។

យស្ស ភាសោ បវេតិ កម្មុនា តេន ទិស្សតេ សញ្ញតេ

ធម្ម តំ អបស្សន្តិ ពីហុរំ ការំ អហំ កាសំ ។

ពីហុរំ បវេតិ កម្មុនា តេន ទិស្សតេ សញ្ញតេ

ធម្ម តំ អបស្សន្តិ ពីហុរំ ការំ អហំ កាសំ ។

(១៩) [illegible]

អបរេន អកិសិត្វា សមាគមស្មិំ បិយមេវ ។

(១៩) [illegible]

[illegible] ។

[illegible] ទុតិយំ ។

---

# មហាសុកជាតកំ

(២០) [illegible]

[illegible]

[illegible]

---

• [illegible] ។



[illegible] ។

(១៨) [illegible] ។

(១៩) [illegible] ។

[illegible] ទី ១ ។

---

# មហាសុកជាតក

(២០) [illegible]

អាចិក្ខ ញាតិព្យសនំ ធិជានំ ។

(៦១) ធិជោ ធិជានំ បវរោសិ បក្ខិ ច
ចក្កវាក សរណំ តំ ឧបេមិ
ឧបា ឥមេ(១) មានិកំ បញ្ចុយន្តិ
លុទ្ទា ចណ្ឌាលា ករំ តេ សុខាយ ។

(៦២) មិត្តំ សហាយញ្ច ករោន្តិ បណ្ឌិតា
កាលេ អកាលេ សុខមេសមានា(២)
ករោមិ តេ សេនក ឯតមត្ថំ
អរិយោ ហិ អរិយស្ស ករោតិ កិច្ចំ ។

(៦៣) យំ ហោតិ កិច្ចំ អនុកម្បកេន
អរិយស្ស អរិយេន កតំ តយីទំ(៣)
អត្តានុរក្ខី ភវ មា អទយ្ហិ
លច្ឆាម បុត្តេ តយិ ជីវមានេ ។

(៦៤) តវេវ រក្ខាវរណំ ករោន្តោ
សរីរភេទាបិ ន សន្តសាមិ

១ ម. ឧ. ឥមេ ។ ២ ម. សុខមេសមានា ។ ៣ ម. [illegible]



ពួកព្រានបក្សី នូវសេចក្តីវិនាសរបស់ពួកញាតិ ជាញាតិ (នៃយើងដល់សត្វបក្សី) ។

(៦១) (ក្ងុកពោលថា កែវក្រាបទូលស្តេចឥន្ទ្រ) បពិត្រស្តេចឥន្ទ្រ ព្រះអង្គជា ទិជជាតិ ជាបក្សីប្រសើរ ជាងពួកទិជជាតិ ខ្ញុំសូមយកព្រះអង្គជាទីពឹង ដ្បិត ពួកព្រានទាំងនេះ រកនាំ ណាស់ ប្រាថ្នានឹងស៊ីកូនខ្ញុំ ១ របស់ខ្ញុំ សូមព្រះអង្គ (មេត្តាប្រោសប្រណី) ឲ្យខ្ញុំបានសេចក្តីសុខ ។

(៦២) (ស្តេចឥន្ទ្រពោលថា) បណ្ឌិតធ្វើនូវមិត្រនិងសំឡាញ់ ទាំងក្នុងកាលគួរ ទាំងកាលមិនគួរ កាលស្វែងរកនូវសេចក្តីសុខ ម្នាលក្ងុក យើងនឹងធ្វើនូវប្រយោជន៍នុ៎ះដល់អ្នក ព្រោះ អរិយជនតែងធ្វើនូវកិច្ចដល់អរិយជន (ដូចគ្នា) ។

(៦៣) (ក្ងុក...) កិច្ចណាដែលអរិយជនជាអ្នកអនុគ្រោះ គប្បីធ្វើ ដល់អរិយជន កិច្ចនោះព្រះអង្គបានធ្វើហើយ សូមទ្រង់រក្សា នូវព្រះអង្គចុះ សូមទ្រង់ កុំទៅក្រែងយាក្ស ពួកយើង ព្រះអង្គរស់នៅ យើងនឹងនឹងបាននូវកូនទាំងឡាយ (ទៀត) ។

(៦៤) (ស្តេចឥន្ទ្រ ...) យើងនឹងធ្វើនូវការរក្សានិងការពារ ការពារអ្នក ក្រៅតែបែកធ្លាយនូវសរីរៈ ក៏មិនតក់ស្លុតដែរ

ការេន្តិ ហេតេ សខិលំ សមាគេ

តាលំ ចជន្តា សមរេស(១) ឋានា ។

(២៤) សុវណ្ណការំ កញ្ចនកាសំ អណ្ណាជាយំ វិតានុមោ

អត្ថាយ កុរោក បុត្ត អត្តានំ អបាគតេ ។

(២៥) ធុតាចិ ហេតេ ចលិតា សតស្សតា

និត្តាធុកម្មាយ ចតិដ្ឋហន្តិ

ធុត្តា មមន្តា(២) គហិតា តកោស្មិ

អត្ថំ ចរេថ មម ភាតរោ(៣) ។

(២៦) ចរេន ចារេន ច អត្តតា ច

មិត្តំ សហាយញ្ច ករេម្ពំ បណ្ឌិតោ

ការេមិ តេ សេនក មិគទន្តំ

អរិយោ ហិ អរិយស្ស ការេតិ កិច្ចំ ។

(២៧) អបេក្ខស្សុ ត្វំ តាត តុវំ និសីទ

បុត្តា បិតុ ចាតិ អត្ថចរិយំ

អហំ ចរិស្សាមិ តវេ អត្ថំ

សេនស្ស បុត្ត ចរិត្តាយមានោ ។

---

១ ម. ឧស្សន្នេ សង្គហេសេ ។ ម. ឧស្សន្នេ សមាគេសេ ។ ២ មន្តា ជាតិ អត្ថរក្ខាល់ ចំស្រុទ្ធ ។ ៣ ម. ភាតរោ ។



ព្រោះសំឡាញ់ទាំងឡាយនោះ តែងតែរាប់អានឲ្យធ្វើ(កិច្ចការ)

ដល់សំឡាញ់ផងគ្នា នេះជាធម៌របស់សប្បុរសទាំងឡាយ ។

(២៤) (អាត្មាសុខខាត់) ស្តេចអាគរទេសជាសត្វស្វាគេតែកកើតកើ ធុន

ធ្វើនូវការកើតដែលគេធ្វើ ដោយកម្លាំងព្រួស ដើម្បីប្រយោជន៍(នឹង

ការ)ដល់កូនទាំងឡាយ ដែលឋិតនៅកណ្ដាលអន្តរាយ ។

(២៥) (វិទូត...) បុគ្គលគួរចងអ្នកដោក (សេស ឬប្រេស) ក៏ដោយ

ក៏ជីការដោយកម្លាំងរបស់ខ្លួនក៏ដោយ ហើយត្រូវប៉ាត់ទាំងខ្លួនធុន

ដោយលោកសន្តិសុខក្រោមរបស់ពួកមិត្ត ពួកទាំងឡាយរបស់

ខ្ញុំ មាននេសន្តិក្តៅក្រោយ ខ្ញុំមក (យកអ្នក) ជាតរ(ទាំងពីរ)

បាក្រសន្ធក្រោចទៅក្នុងទឹក ចូរអ្នកប្រព្រឹត្តប្រយោជន៍ដល់ខ្ញុំ ។

(២៦) (អាណ្ណក...) បណ្ឌិតទាំងឡាយ តែងចងមិត្រនឹងសំឡាញ់

ដោយព្រៀងផង ដោយស្រៀងផង ដោយខ្លួនផង ម្នាល

វិទូត យើងនឹងធ្វើប្រយោជន៍នេះដល់អ្នកធុន ព្រោះអរិយជន

តែងធ្វើកិច្ចដល់អរិយជនដូចគ្នា ។

(២៧) (កូនអាណ្ណក...) បាក្រសន្ធក អ្នកចូរជាបុគ្គលមាននេសេច-

ក្តីព្រួយកិច្ច អង្គុយស្ងៀមចុះ កូនតែងប្រព្រឹត្តប្រយោជន៍

ដល់បុក ខ្ញុំនឹងជួយការពារនូវកូនវិទូត ហើយប្រព្រឹត្តនូវ

ប្រយោជន៍ដល់ខ្លួនលោក ។

(២៩) អទ្ធា ហិ តាត សតមេស ធម្មោ

ធុវត្ថា ចិត្ត ចរេ អធម្មចរិយំ

អបេយ្យ មំ ធិស្វាន បវុឌ្ឍកាយំ

សេចស្ស ធុត្តាចិ ន ភោជយេយ្យុំ ។

(៣០) បស្ស មនុស្សា មិគកិសេដ្ឋ

កយដ្ឋិកា សេដ្ឋមុបច្ចជន្តិ

ធុត្តា មមដ្ឋា កកិមាកតោស្មិ

ត្វំ បោសិ កជា ករ មេ សុតាយ ។

(៣១) ការេមិ តេ សេដ្ឋតា បិតមត្ថុំ

អាយាមិ តេ ជំ ជិសរិ វតាយ

តាចិ ហិ វញ្ញូ បហុ សម្បជាតោ

ន កំយមេ អត្តជធស្ស ត្ដិយា ។



(២៩) (អទ្ធាក . . .) ព្រាហ្មណ៍ នេះជាធម៌របស់សប្បុរសទាំង

ឡាយ កូនត្រូវតែប្រព្រឹត្តប្រយោជន៍ ដើម្បីវុឌ្ឍ ពិតមែន

ហើយ តែកូនក្រុមដមទេ មិនគប្បីទៀតទៀតនៅក្នុងឆរបស់ខ្ញុំ

ព្រោះឃើញខ្លួនពេញវ័យមានកាយធំ ។

(៣០) (ខ្ញុំ...) បពិត្រព្រះអង្គប្រសើរ ដោយសេចក្ដីព្យាយាម

កម្ពុជ ម៉ែក កូនសម្លាប់ពួកមនុស្ស ត្រូវទៅប្រស័ព្ទ

ហើយ កំបាំងខ្លួនទៅពីចោរលើប្រសើរ កូនទាំងឡាយ

របស់ខ្ញុំ បានសេចក្ដីក្ដៅក្រហាយ (ព្រោះហេតុនោះ) ខ្ញុំមក

(យកព្រះអង្គ) ជាគតិ ព្រះអង្គជាស្ដេចរបស់យើង សូមព្រះ

អង្គមេត្តា (ប្រោសប្រណី) ខ្ញុំឲ្យបានសេចក្ដីសុខ ។

(៣១) (ស៊ិព:...) ព្រាហ្មណ៍ខ្ញុំណា ឃើញធ្វើខ្លួនប្រយោជន៍

ខ្ញុំផ្ដល់អ្នកមក យើងនឹងទៅសម្លាប់ពួកសត្រូវរបស់អ្នក

ឲ្យអ្នកព្រួយ ជាអ្នកបានដល់សម្លាប់ខ្លួនត្រូវបាន ដឹង

ច្បាស់ (ខ្ញុំកើតឡើងដល់មិត្ត) មិនគប្បីប្រើប្រែ

ក្លួនដែលទុកដូចជាខ្លួន ដូចស្ដេចកើត ។

(៣៦) មិត្តំ កយិរាថ សុហទយញ្ច

អយិរញ្ច កយិរាថ សុខាគមាយ

និវត្ថកោចោវ សរេភិហន្ត្វា

មោទាម បុត្តេហិ សមគ្គិភូតា ។

(៣៧) សកាចិត្តស្ស[១] ការេន សហាយស្សាបលាយិនោ

កុជន្តមុបកុជន្តិ លោមហំសា[២] ហទយង្គមំ ។

(៣៨) មិត្តំ សហាយំ អធិគម្ម បណ្ឌិតោ

សោ ភុញ្ជតិ បុត្តំ បសុំ ធនំ ច

អហញ្ច បុត្តា ច បតី ច មយ្ហំ

មិត្តានុកម្បាយ សមគ្គិភូតា ។

ភជេតា សុរេតា ច អត្តោ

សម្បន្នសខិស្ស ភវន្តិ ហេតេ

សោ មិត្តវា យសវា ឧគ្គតត្តោ

អស្មិញ្ច លោកេ មោទតិ កាមកាមី ។

---

១ ឧ. សកំ ម. មិត្តស្ស ។ ២ ឧ. ម. លោមសា ។



(៣៦) (ក្ងោកញីនិយាយនឹងក្ងោកឈ្មោល) បុគ្គលគួរធ្វើ (នូវបុគ្គលណាមួយ) ឲ្យជាមិត្រផង ឲ្យជាសំឡាញ់ផង គួរធ្វើ (នូវបុគ្គលណាមួយ) ឲ្យជាម្ចាស់ផង ដើម្បីបាននូវសេចក្តីសុខ យើងទាំងឡាយ (គាប់ពាក់បង់នូវក្ងោកសម្រាប់បាន ដោយកំឡាំងនៃមិត្ត) ហើយនឹងបាននូវមិត្រនោះ រីករាយជាមួយនឹងកូនទាំងឡាយ ដូចជាបុគ្គលដែលមានអាវក្រោះពាក់ហើយ ការពារកំនូវកូនសត្វទាំងឡាយបានផុតព្រួញ ។

(៣៧) កូនខ្លួនទាំងឡាយ (ហាក្យញៀសមុទនឹងពិការ) ស្ទើរត្រូវចក្ក ហើយស្រែកហៅ (ចំ) ដែលកំពុងស្រែកយំ ដោយសារសេចក្តីក្លាហានរបស់សីហៈជាមិត្ររបស់ខ្លួន ជាសំឡាញ់ ជាសត្វមិនមាន ។

(៣៨) បណ្ឌិតនោះបើបានសំឡាញ់ នូវសត្វចិញ្ចឹម ឬកំឡាំងក្រឡ ព្រោះតែស្រីៗមិត្រសំឡាញ់ ខ្ញុំ កូនកូនខ្ញុំ ប្ដីរបស់ខ្ញុំ បាន មូលមិត្ត ដោយសេចក្តីអនុគ្រោះរបស់មិត្រ ។ បុគ្គល មាន ផង មានមិត្រជាក្លៀវក្លាផង (ជាមិត្រក្លាហើយ) គាប ត្រូវឬ យោជន៍បាន ឲ្យសំឡាញ់ទាំងឡាយនុ៎ះ កើតមាន ដល់បុគ្គល ដែលបរិបូណ៌ដោយសំឡាញ់ បព្វជិត អ្នកប្រាជ្ញនោះ បុគ្គលអ្នកមានមិត្រ មានយស មាន សេចក្តីចំរើនរុងរឿង រមែងរីករាយក្នុងលោកនេះ ។

(៣៥) ការំ សហាយានំ មិត្តានំ ពលវន្តានំ សេនក

បស្ស មិត្តានុកម្បាយ សមគ្គម្ហា សញាតកោ

ស្យេន ពលវន្តេន យោ មិត្តំ កុរុតេ ទិជោ

ឋិរសោ សុខិតោ ហោតិ យថាហំ ត្វញ្ច សេនកាតិ ។

មហាឧក្កុសជាតកំ តតិយំ ។

---

## ឧទ្ទាលកជាតកំ

(៣៦) ខរាជិនា ជដិលា បង្កទន្តា

ទុម្មក្ខរូបា[១] យេ មន្តំ ជប្បន្តិ

កច្ចិ នុ តេ មានុសកេ បយោគេ

ឥទំ វិទូ បរិមុត្តា អបាយា ។

(៣៧) បាបានិ កម្មានិ ករេយ្យ រាជ

ពហុស្សុតោ ចេ ន ចរេយ្យ ធម្មំ

សហស្សវេទោបិ ន តំ បដិច្ច

ទុក្ខា បមុញ្ចេ ចរណំ អបត្វា ។

១ ម. ទុម្មុខរូបា ។



(៣៥) បពិត្រខ្ទឹងឈ្មោល បុគ្គលសូម្បីក្រខ្សត់ ក៏គួរធ្វើនូវមិត្តធម៌ អ្នកចូរមើលចុះ យើងទាំងឡាយបានព្រមព្រៀងគ្នាជាមួយនឹងញាតិទាំងឡាយ ដោយសេចក្តីអនុគ្រោះរបស់មិត្រ ។ បពិត្រខ្ទឹងឈ្មោល បក្សីណាធ្វើនូវមិត្រជាមួយនឹងបុគ្គលក្លៀវក្លា ជាមួយនឹងបុគ្គលមានកំឡាំង បក្សីនោះរមែងបានសេចក្តីសុខយ៉ាងនេះ ដូចខ្ញុំនឹងអ្នក ។

ចប់ មហាឧក្កុសជាតក ទី ៣ ។

---

## ឧទ្ទាលកជាតក

(៣៦) (ព្រះរាជាទ្រង់ត្រាស់ថា) ពួកជដិលណាដណ្តប់ស្បែកខ្លាឃ្មុំទាំងក្រចក មានធ្មេញប្រឡាក់ដោយមន្ទិល មានភក្កមិនបន្តក់ មានរូបកាក្រក់ កំពុងរាយនូវមន្ត ជដិលទាំងនោះ បានដឹងនូវការប្រព្រឹត្តនូវតបៈ នឹងការសូត្ររាយនូវមន្តនេះ គង់សេចក្តីព្យាយាមជារបស់មនុស្ស នឹងបានរួចចាកអបាយដែរឬ ។

(៣៧) (បុរោហិតក្រាបទូលថា) បពិត្រមហារាជ បើបុគ្គលជាពហុស្សូត មិនប្រព្រឹត្តធម៌ ធ្វើតែអំពើលាមកទាំងឡាយ បុគ្គលនោះសូម្បីចេះនូវវេទមួយពាន់ ហើយអាស្រ័យនូវភាពជាពហុស្សូតនោះ តែមិនទាន់បានសម្រេចនូវចរណៈ (សមាបត្តិប្រាំបី) ទេ ក៏មិនគប្បីរួចចាកទុក្ខឡើយ ។

(៣៨) សហស្សក្ខោបិ ច តំ បជិត្វ

ធុត្វា បបុត្តេ ចរណំ អបត្វា

ឧញ្ញាមំ វេទា អជលា ករន្តិ

សសំយមំ ចរណញ្ញេវ សច្ចំ ។

(៣៩) ឃរោវ វេទា អជលា ករន្តិ

សសំយមំ ចរណញ្ញេវ សច្ចំ

កិត្តិញ្ច បប្បោតិ អធិច្ច វេទេ

សន្តិំ បុណាតិ ចរណេន ទន្តោ ។

(៤០) ភត្តា មាតា បិតា ពន្ធុ យេន ជាតោ ស្វយេវសោ

ទន្តាលតោ អហំ ភោតោ សោត្ថិយកុលវំសតោ ។

(៤១) កថំ ភោ ព្រាហ្មណោ ហោតិ កថំ ភវតិ កេវលី

កាថញ្ច បរិនិព្វាណំ ធម្មដ្ឋោ កិត្តិ វុច្ចតិ ។



(៣៨) (ម្នាល[illegible]) បុគ្គលសូម្បីរៀននូវវេទមួយពាន់ ហើយអាស្រ័យនូវភាពជាពហុស្សូតនោះ តែមិនទាន់បាន សម្រេចនូវចរណៈ (សមាបត្តិប្រាំបី) ទេ ក៏មិនគប្បីរួចចាកទុក្ខ ឡើយ ខ្ញុំសំគាល់ថាវេទទាំងឡាយជាសភាពឥតផល មានតែ ចរណៈដែលប្រកបដោយការសង្រួម ទើបជាការពិតប្រាកដ ។

(៣៩) (ប៉ុកហ៊ិត...) ខ្ញុំមិនមែនពោលថា វេទទាំងឡាយ ជា សភាពឥតផលទេ តែចរណៈដែលប្រកបដោយការសង្រួម ជារបស់ពិតមែន ឯបុគ្គលរៀននូវវេទទាំងឡាយ ព្រោះតែ បាននូវកិត្តិសព្ទ បុគ្គលអ្នកទូន្មានដោយចរណៈហើយ ទើប បានដល់នូវការស្ងប់រម្ងាប់ (និព្វាន) ។

(៤០) (ម្នាល[illegible]...) មាតាបិតានឹងនៅពង្ស ត្រូវតែគួរចិញ្ចឹម តាក្រោក ក៏ពីបុគ្គលណា បុគ្គលនោះឯង នៅជាបុគ្គលនោះដែល តាត្រា ឈ្មោះម្នាលកៈ ជាអ្នកនៅក្នុងត្រកូលនៃសាក្តិយាតាត្រូវចំរើន ។

(៤១) (ប៉ុកហ៊ិត...) ម្នាលអ្នកដ៏ចំរើន បុគ្គលឈ្មោះថា ព្រាហ្មណ៍ តើដោយប្រការដូចម្តេច បុគ្គលមានគុណគម៌បរិបូណ៌ តើដោយ ប្រការដូចម្តេច មួយទៀត ការរលត់កិលេសតើដោយប្រការដូចម្តេច បុគ្គលដែលគេហៅថាអ្នកតាំងនៅក្នុងធម៌ តើដោយប្រការដូចម្តេច ។

(២២) ចិរំ ការ៉ា អគ្គិមាធាយ ព្រាហ្មណោ

អាហោសិត្តំ យេធំ ទស្សេតិ យសុំ

បរិវត្តកេ ព្រាហ្មណោ ហោតិ ខេមី

ធម្មេ ឋិតំ តេន អមាបយីសុ ។

(២៣) ន សុទ្ធិ សេចនេន អត្ថិ នប៉ិ កេវលី ព្រាហ្មណោ

ន ចេវ ខន្តិ សោរច្ចំ នប៉ិ សោ បរិនិព្វុតោ ។

(២៤) កាថំ កោ ព្រាហ្មណោ ហោតិ កាថំ ករតិ កេវលី

កាថញ្ច បរិនិព្វានំ ធម្មដ្ឋោ តិដ្ឋិ វុច្ចតិ ។

(២៥) អក្ខេត្តវត្ថុ អមមោ និរាសោ

និល្លោភបាបោ ករណោកខីណោ

បរិវត្តកេ ព្រាហ្មណោ ហោតិ ខេមី

ធម្មេ ឋិតំ តេន អមាបយីសុ ។



(២២)(ទុក្ខលក:...) បុគ្គលកាន់យកខ្លាក្លើងហើយ ធ្វើខ្លួនការប់រមែងឱ្យមានបញ្ញា ឈ្មោះជាព្រាហ្មណ៍ ព្រាហ្មណ៍កាលស្រោចទឹក(អភិសេក) បូជា (ខ្លួយញ្ញ) ហើយលើកខ្លួនសរសើរយញ្ញ ព្រាហ្មណ៍ធ្វើយ៉ាងនេះ ឈ្មោះជាអ្នកមានសេចក្ដីក្សេម (ផុតពីទុក្ខភ័យ) ហៅ(ព្រាហ្មណ៍នោះ)ជាអ្នកស្ថិតនៅក្នុងធម៌ដោយហេតុនោះ ។

(២៣) (បុរោហិត...) សេចក្ដីបរិសុទ្ធិក្ដីមិនមានដោយការស្រោចទឹកទេ បុគ្គលដែលឈ្មោះជា ព្រាហ្មណ៍ អ្នកបរិបូណ៌ដោយគុណធម៌ ខន្តិ សោរច្ចៈ នឹងបុគ្គលអ្នកលះទុក្ខបាននោះ មិនមាន (ដោយការស្រោចទឹកជាដើមទេ) ។

(២៤) (ទុក្ខលក...) នែអ្នកដ៏ចំរើន បុគ្គលដែលឈ្មោះជាព្រាហ្មណ៍កើតដោយប្រការដូចម្ដេច បុគ្គលដែលជាអ្នកមានគុណធម៌ដ៏បរិបូណ៌កើតដោយប្រការដូចម្ដេច ម្យ៉ាងទៀត ការលះកិលេសកើតដោយប្រការដូចម្ដេច បុគ្គលដែលគេហៅថាជាអ្នកឋិតនៅក្នុងធម៌កើតដូចម្ដេច ។

(២៥) (បុរោហិត...) បុគ្គលមិនមានស្រែចំការ មិនមានផៅពង្ស មិនមានសេចក្ដីប្រកាន់ មិនមានសេចក្ដីប្រាថ្នា មិនមានសេចក្ដីលោភដ៏លាមក អស់សេចក្ដីជាប់ជំពាក់ក្នុងភព ព្រាហ្មណ៍ធ្វើយ៉ាងនេះ ទើបឈ្មោះជាអ្នកដល់នូវសេចក្ដីក្សេម (ផុតពីទុក្ខភ័យ) ហៅ (ព្រាហ្មណ៍នោះ) ជាអ្នកឋិតនៅក្នុងធម៌ដោយហេតុនោះ ។

(៤៦)ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ចណ្ឌាលបុក្កុសា
សព្វេ សោរតា ទន្តា សព្វេ បរិនិព្វុតា
សព្វេសំ សីតិភូតានំ អត្ថិ សេយ្យោ[១]វ បាបិយោ ។

(៤៧)ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ចណ្ឌាលបុក្កុសា
សព្វេ សោរតា ទន្តា សព្វេ បរិនិព្វុតា
សព្វេសំ សីតិភូតានំ នត្ថិ សេយ្យោវ បាបិយោ ។

(៤៨)ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ចណ្ឌាលបុក្កុសា
សព្វេ សោរតា ទន្តា សព្វេ បរិនិព្វុតា ។
សព្វេសំ សីតិភូតានំ នត្ថិ សេយ្យោវ បាបិយោ
[២]បសត្ថំ ករោសិ ព្រហ្មញ្ញំ សោត្ថិយកុលវំសតំ ។

---

១ ម. សេយ្យោ ។ ២ ម. បត្ថំ ។



(៤៦) (ទេវិលក...) ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកចណ្ឌាលនឹងជនអ្នកកើតសម្រាម ពួកជនទាំងអស់ ឈ្មោះថាជាអ្នកស្លូតបូត ជាអ្នកទូន្មានឥន្ទ្រិយបានហើយ ពួកជនទាំងអស់ ឈ្មោះថា មានទុក្ខរលត់ហើយ គុណដ៏ប្រសើរនឹងទោសដ៏លាមក មានដល់ជនទាំងអស់ ដែលជាអ្នកមានសេចក្តីត្រជាក់ត្រជំ (ដែរឬ) ។

(៤៧) (បុរោហិត...) ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកជនចណ្ឌាលនឹងជនអ្នកកើតសម្រាម ពួកជនទាំងអស់ដែលជាអ្នកស្លូតបូត មានឥន្ទ្រិយទូន្មានបានហើយ ពួកជនទាំងអស់ ឈ្មោះថាមានទុក្ខរលត់ហើយ គុណដ៏ប្រសើរ នឹងទោសដ៏លាមកមិនមានដល់ពួកជនទាំងអស់ ដែលជាអ្នកមានសេចក្តីត្រជាក់ត្រជំឡើយ ។

(៤៨) (ទេវិលក...) ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកជនចណ្ឌាលនឹងជនអ្នកកើតសម្រាម ពួកជនទាំងអស់ដែលជាអ្នកស្លូតបូត មានឥន្ទ្រិយទូន្មានបានហើយ ពួកជនទាំងអស់ ឈ្មោះថាមានទុក្ខរលត់ហើយ គុណដ៏ប្រសើរ នឹងទោសដ៏លាមក មិនមានដល់ជនទាំងអស់ ដែលមានសេចក្តីត្រជាក់ត្រជំឡើយ (កាលបើយ៉ាងនេះ) អ្នកប្រព្រឹត្តនូវការពារនៃខ្លួនជាព្រាហ្មណ៍ គួរឱ្យគេសរសើរ ហើយញុំាងនូវត្រកូលនៃសោត្ថិយគោត្រ (ឲ្យវិនាស) ។

(៦៩) ឆាយារុក្ខេហិ វក្ខេហិ    វិហារំ ករោ ជានិតិ
ន តេសំ ជាយតេ វត្ថុំ    សោ ភាគោ អនុបច្ឆិន្ន
និវេសេ មនុស្សេសុ    យទា សុជ្ឈន្តិ មាណវា
ន តេសំ ជាតិំ បុច្ឆន្តិ[១]    ធម្មមញ្ញាយ សុព្វតា ។

ខុទ្ទាលកជាតកំ បឋមំ ។

---

## ភិសជាតកំ

(៨០) អស្សំ គវំ រជតំ ជាតរូបំ
ភរិយញ្ច សោ ឥធ លភតំ មនាបំ
បុត្តេហិ ទារេហិ សមង្គិ ហោតុ
ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៨១) មាលញ្ច សោ កាសិកចន្ទនញ្ច[២]
ធារេតុ បុត្តស្ស ពហូ ភវន្តុ
កាមេសុ តិព្វំ កុរុតំ អបេក្ខំ
ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

---

១ ម. ជាតិ ពុច្ឆន្តិ ។ ម. ជាតិសុជ្ឈន្តិ ។ ២ ម. កាសិយំ ចន្ទនំ ច ។



(៦៩) (ចុះពេជ្រ..) វិហារដែលគេប្រគេនដោយសំពត់ទាំងឡាយ មាន
ពំណិព្រហ្មចារ្យនីៗ ស្រមោលរបស់សំពត់ទាំងនោះ មិនផ្សេងគ្នា
ឡើយ (មានសម្បុរតែមួយបែប) ការជ្រលក់នោះ ក៏មិនផ្សេងគ្នា
ដែរ (ដាំងណាមិញ) សម្បើមនុស្សទាំងឡាយ ក៏ដាំងនោះដែរ
ពួកមាណពបរិសុទ្ធ (ដោយអរិយមគ្គ) ក្នុងកាលណា ពួកជនមាន
វត្តល្អ បានដឹងនូវនិព្វានធម៌ ក៏មិនសាកសួរនូវជាតិរបស់មាណព
ទាំងនោះ (ក្នុងកាលនោះ) ឡើយ ។

ចប់ ខុទ្ទាលកជាតក ទី ៤ ។

---

## ភិសជាតក

(៨០) (មហាសត្វនោះពោលសច្ចវាទ) ម្នាលព្រាហ្មណ៍ បុគ្គលណាលួច
ក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបាននូវសេះ
ផង គោផង ប្រាក់ផង មាសផង ប្រពន្ធជាទីគាប់ចិត្តក្នុងលោកនេះ
ផង ចូរនៅព្រមព្រៀងគ្នា ដោយកូនទាំងប្រពន្ធទាំងឡាយចុះ ។

(៨១) (ភាតាទី២សច្ចវាទ) ម្នាលព្រាហ្មណ៍ បុគ្គលណាលួចក្រអៅ
ឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរទ្រទ្រង់នូវផ្កាកម្រង
ផង នូវសំពត់ដែលគេនាំមកអំពីដែនកាសីនិងខ្លឹមចន្ទន៍ផង ចូរឲ្យ
បុគ្គលនោះមានកូនច្រើនផង ចូរឲ្យ(បុគ្គលនោះ) ធ្វើនូវសេចក្តី
អាឡោះអាល័យដ៏ក្រៀវក្លា ក្នុងកាមទាំងឡាយផង ។

(៤២) បហុតធញ្ញោ កសិមា យសស្សី
បុត្តេ គិហី ធនិមា សព្វកាមេ
វយំ អបស្សំ ឃរមាវសាតុ
ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៤៣) សោ ខត្តិយោ ហោតុ បសយ្ហការី
រាជាធិរាជា ពលវា យសស្សី
ស ចាតុរន្តំ មហិមាវសាតុ
ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៤៤) សោ ព្រាហ្មណោ ហោតុ អវីតរាគោ
មុហុត្តនក្ខត្តបថេសុ យុត្តោ
បូជេតុ នំ រដ្ឋបតី យសស្សី
ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៤៥) អជ្ឈាយកំ សព្វសមន្តវេទំ[1]
តបស្សិនំ មញ្ញតុ សព្វលោកោ
បូជេន្តុ[2] នំ ជានបទា សមេច្ច
ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

● ១. សព្វសាមន្តវេទំ ។ ២ ម. [illegible] បូជេន្តុ ។

១៨

សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក

(៤២) (តាបសទី ៣ សួរថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូករបស់លោក (បុគ្គលនោះ) ចូរមានស្រូវច្រើន មានកសិកម្ម មានយស (បាន) នូវកូនទាំងឡាយ ជាគ្រហស្ថ មានទ្រព្យ ចូរ(បាន) នូវកាមគ្រប់យ៉ាង ចូរកុំឲ្យឃើញនូវវ័យ (របស់ខ្លួន) នៅគ្រប់គ្រងផ្ទះចុះ ។

(៤៣) (តាបសទី ៤ សួរថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរបានជាក្សត្រ អ្នកធ្វើនូវការរឹបជាន់ ជារាជាធិរាជ មានពល មានយស ចូរបានគ្រប់គ្រងនូវផែនដី ដែលមានសមុទ្រទាំង ៤ ជាទីបំផុតចុះ ។

(៤៤) (តាបសទី ៥ សួរថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរជាព្រាហ្មណ៍មិនប្រាសចាករាគៈ ចូរប្រកបក្នុងគន្លងក្បួនយាមខណៈនក្ខត្តឫក្ស បុគ្គលជាម្ចាស់នៃដែន (ស្តេច) ដែលមានយស ចូរបូជាព្រាហ្មណ៍នោះចុះ ។

(៤៥) (តាបសទី ៦ សួរថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក លោកទាំងអស់ ចូរសំគាល់ (នូវបុគ្គលនោះ) ថាជាអ្នកស្វាធ្យាយនូវវេទ ព្រមទាំងមន្តគ្រប់យ៉ាង ថាជាអ្នកមានតបៈ ពួកអ្នកជនបទ ចូរឃើញហើយបូជានូវបុគ្គលនោះចុះ ។

(៤៦) ចតុស្សទំ គាមវរំ សមិទ្ធំ
ទិន្នញ្ហិ សោ ភុញ្ជតុ វាសវេន
អវីតរាគោ មរណំ ឧបេតុ
ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៤៧) សោ គាមណី ហោតុ សហាយមជ្ឈេ
នច្ចេហិ គីតេហិ បមោទមានោ
មា រាជតោ ព្យសនមលត្ថ កិញ្ចិ
ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៤៨) យំ ឯករាជា បថវី វិជិត្វា
ឥត្ថីសហស្សាន ឋបេតុ អគ្គំ
សីមន្តិនីនំ បវរា ភវាតុ
ភិសានិ តេ ព្រាហ្មណ យា អហាសិ ។

(៤៩) ឥសីនំ(១) ហិ សា សព្វសមាគតានំ
ភុញ្ជេយ្យ សាទុំ អវិកម្បមានា
ចរាតុ លាភេន វិកត្ថមានា
ភិសានិ តេ ព្រាហ្មណ យា អហាសិ ។

១ ម. ឥសីនំ ។





(៤៦) (តាបសជាសំឡាញ់ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកដំណឹងឡាយរបស់លោក បុគ្គលនោះ ចូរបរិភោគនូវស្រុកសួយដ៏ស្តុកស្តម្ភ ដែលព្រះឥន្ទ្រ(១)ប្រទានឲ្យហើយ ហាក់ដូចស្ដេចកាមរាគៈ ប្រុគេទៀត ចូរដល់នូវមរណៈ ទាំងមិនទាន់បានប្រាសចាកកាមរាគៈចុះ ។

(៤៧) (តាបសជាទំប្រុសស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកដំណឹងឡាយរបស់លោក បុគ្គលនោះចូរបានជាចៅស្រុក ចូររីករាយដោយការរាំ នឹងច្រៀងក្នុងកណ្ដាលនៃសំឡាញ់ កុំឲ្យបាននូវសេចក្ដីវិនាសតិចតួចអំពីស្ដេចឡើយ ។

(៤៨) (នាងកញ្ញាទៅស្បថថា) បពិត្រព្រាហ្មណ៍ ស្រីណាលួចក្រអៅឈូកដំណឹងឡាយរបស់លោក សូមឲ្យស្ដេចឯករាជដែលទ្រង់ឈ្នះនូវផែនដីហើយតាំងតាំង(ស្រីនោះ)ឲ្យប្រសើរលើសជាងស្រីទាំងមួយពាន់ សូមឲ្យ(ស្រីនោះ) បានជាស្រីប្រសើរលើសជាងស្រីទាំងឡាយចុះ ។

(៤៩) (នាងទាសីស្បថថា) បពិត្រព្រាហ្មណ៍ ទាសីណាលួចក្រអៅឈូកដំណឹងឡាយរបស់លោក ក៏បណ្ដាទាសីទាំងឡាយ ទាសីនោះចូរកុំញាប់ញ័រ (ក្នុងកណ្ដាល) នៃពួកតាបសទាំងឡាយដែលប្រជុំគ្នាទាំងអស់ ចូរបរិភោគនូវភោជនឆ្ងាញ់ (ទាសីនោះ) ចូរប្រព្រឹត្តនិយាយអួតដោយលាភ ត្រាច់ទៅក្នុងលោកចុះ ។

១- វត្ថុលោកិកនិ មនុស្ស ១ ស្រូវ ១ សេះ ១ ទឹក ១ ។ គន្ធិកា ។

(៦០) អាវាសិកោ ហោតុ មហាវិហារេ

នវកម្មិកោ ហោតុ កជង្គលាយំ

អាលោកសន្ធឹ ទិវសា[១] ករោតុ

ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៦១) សោ ពជ្ឈតុ បាសសតេហិ ឆព្ភិ

រម្មា វនា និយ្យតុ រាជធានឹ

តុត្តេហិ សោ ហញ្ញតុ បាចនេហិ

ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៦២) អលក្កមាលី តិបុកណ្ណវិទ្ធា

លដ្ឋិហតោ សប្បមុខំ ឧបេតុ

សកច្ច ពទ្ធោ[២] វិសិខំ ចរាតុ

ភិសានិ តេ ព្រាហ្មណ យោ អហាសិ ។

(៦៣) យោ វេ អនដ្ឋំ នដ្ឋន្តិ ចាហ

កាមេវ សោ លភតុ ភុញ្ជតុ ច

អគារមជ្ឈេ មរណំ ឧបេតុ

យោ វា ភោន្តោ សង្កតិ កញ្ចិទេវ ។

---

១ ឱ. អាលោកសន្ធិំ ទិវសំ ។ ២ ម. សកច្ចុ ពន្ធោ ។ ម. សកច្ចពន្ធោ ។



(៦០) (ទេវតាស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក (បុគ្គលនោះ) ចូរបានជាចៅអាវាសក្នុងមហាវិហារចុះ ចូរធ្វើនូវនវកម្ម ក្នុងនគរឈ្មោះកជង្គលៈចុះ ចូរធ្វើនូវពន្លឺបង្អួចឲ្យហើយតែមួយថ្ងៃចុះ ។

(៦១) (ម៉ីរស្បថថា) បពិត្រព្រាហ្មណ៍ ម៉ីរណាលួចក្រអៅឈូកទាំងឡាយរបស់លោក ម៉ីរនោះ ចូរជាប់ដោយអន្ទាក់ច្រើនគ្រឿងក្រៃលែងជាង៦ (គឺលើសទាំង៦ គឺនឹងចង្កើរ) ចូរឲ្យគេនាំអំពីព្រៃ ជាទីរីករាយទៅកាន់រាជធានីចុះ ម៉ីរនោះចូរឲ្យគេវាយដោយកន្ត្រើទាំងឡាយ ដែលមានដងវែងមានបន្លាពីរចុះ ។

(៦២) (ស្វាស្បថថា) បពិត្រព្រាហ្មណ៍ ស្វាណាលួចក្រអៅឈូកទាំងឡាយរបស់លោក (ស្វានោះ) ចូរមានស្រែខ្សែក ហើយគេចោះត្រចៀកបំពាក់សំណចុះ ឲ្យហ្មពស់ក្បាលដោយរំពាត់ ហើយចូរទៅរកមាត់ពស់ចុះ ឲ្យគេចងយ៉ាំងមាំ ហើយដើរទៅកាន់ច្រកល្ហកចុះ ។

(៦៣) (ព្រះមហាសត្វស្បថថា) នែអ្នកដ៏ចម្រើនទាំងឡាយ បុគ្គលណា ពោលនូវវត្ថុដែលមិនបាត់ថាបាត់ ម្យ៉ាងទៀត បុគ្គលណារង្កៀសចំពោះបុគ្គល (ចំពោះអ្នកទាំងឡាយ) បុគ្គលនោះ ចូរបាន នឹងចូរបរិភោគនូវកាមទាំងឡាយចុះ ចូរស្លាប់ក្នុងកណ្ដាលនៃផ្ទះចុះ ។

(៦៦) យេនេស ភេទា វិចរន្តិ លោកេ,
ឥដ្ឋញ្ច កន្តញ្ច ពហូនមេតំ
បិយំ មនុញ្ញំ ឥធ ជីវលោកេ
កស្មា ឥសយោ នប្បសំសន្តិ កាមេ ។

(៦៧) កាមេសុ វេ ហញ្ញរេ ពជ្ឈរេ ច
កាមេសុ ទុក្ខញ្ច ភយញ្ច ជាតំ
កាមេសុ ភូតាធិបតី បមត្តា
បាបានិ កម្មានិ ករោន្តិ មោហា ។
តេ បាបធម្មា បសវេត្វ បាបំ
កាយស្ស ភេទា និរយំ វជន្តិ
អាទីនវំ កាមគុណេសុ ទិស្វា
តស្មា ឥសយោ នប្បសំសន្តិ កាមេ ។

(៦៨) វីមំសមានោ ឥសិនោ ភិសានិ
តីរេ គហេត្វាន ថលេ និធេសិំ
សុទ្ធា អបាបា ឥសយោ វសន្តិ
ឯតានិ តេ ព្រហ្មចារី ភិសានិ ។



(៦៦) (សក្កទេវរាជពោលថា) (សត្វទាំងឡាយ) រមែងវង្វេងព្រោះតែកាមទាំងកិលេសកាមណា ហើយត្រាច់ទៅក្នុងលោក តែកាមទាំងកិលេសកាមនុ៎ះ ជាទីត្រេកអរផង ជាទីពេញចិត្តផង ជាទីស្រឡាញ់ផង ជាទីគាប់ចិត្តរបស់ទេវតានិងមនុស្សច្រើនគ្នាក្នុងជីវលោកនេះ ចុះហេតុអ្វីក៏ពួកឥសីមិនសរសើរនូវកាមទាំងឡាយ ។

(៦៧) (មហាសត្វពោលថា) ជនទាំងឡាយ ត្រូវគេវាយ ត្រូវគេចង ព្រោះតែកាមទាំងឡាយ សេចក្តីទុក្ខផង ភ័យផង តែងកើតឡើងក៏ព្រោះតែកាមទាំងឡាយ បពិត្រព្រះភូតាធិបតី សត្វទាំងឡាយស្រវឹង ព្រោះកាមទាំងឡាយ ធ្វើនូវអំពើទាំងឡាយដ៏លាមក ព្រោះវង្វេង ។ ជនមានធម៌ដ៏លាមកទាំងឡាយនោះ ទទួលនូវបាប លុះបែកធ្លាយនៃកាយ រមែងទៅកើតក្នុងនរក ព្រោះហេតុនោះ បានជាពួកឥសីមិនសរសើរនូវកាមទាំងឡាយ ព្រោះឃើញទោស ក្នុងកាមគុណទាំងឡាយ ។

(៦៨) (សក្ក...) ខ្ញុំល្បងមើលទេ ខ្ញុំយកក្រអៅឈូកទាំងឡាយរបស់ឥសីឡើងទៅកប់ទុកលើគោក (ទេវរាជនេះ ខ្ញុំដឹងហើយថា) ឥសីទាំងឡាយ ជាអ្នកបរិសុទ្ធ មិនមានបាប បពិត្រលោកជាព្រហ្មចារី នុ៎ះក្រអៅឈូកទាំងឡាយរបស់លោក ។

(៦៧) ន តេ នដា នោ បន កីឡនេយ្យា
ន ពន្ធវា នោ បន តេ សហាយា
កិស្មឹ បវត្ថ(១) សហស្សនេត្ត
ឥសីនំ ត្វំ កីឡសិ ទេវរាជ ។

(៦៨) អាចរិយោ មេសិ បិតា ច មយ្ហំ
ឯសា បតិដ្ឋា ខលិតស្ស ព្រហ្មេ
ឯកាបរាធំ ខម ភូរិបញ្ញ
ន បណ្ឌិតា កោធពលា ភវន្តិ ។

(៦៩) សុវាសិតំ ឥសិនំ ឯករត្តំ
យំ វាសវំ ភូតបតិទ្ទសាម
សព្វេវ ភោន្តោ សុមនា ភវន្តុ
យំ ព្រាហ្មណោ បច្ចុទាបាទិ ភិសានិ ។

(៧០) អហញ្ច សារីបុត្តោ ច មោគ្គល្លានោ ច កស្សបោ
អនុរុទ្ធោ បុណ្ណានន្ទោ តទាសុំ សត្ត ភាតរោ ។

១ ម. បរត្ថ ។ ឧ. បវត្ថ ។



(៦៧) (មហាសត្វ...) ម្នាលទេវរាជ ជាសហស្សនេត្ត (ពួកយើង) មិនមែនជាអ្នករបាំរបស់អ្នកទេ ទាំងមិនមែនជាបុគ្គលគួរអ្នកលេងទេ មិនមែនជាផៅពង្ស ទាំងមិនមែនជាសំឡាញ់របស់អ្នកទេ ហេតុអ្វីក៏អ្នក (ធ្វើ) នូវសេចក្តីមើលងាយចំពោះបុគ្គលដទៃ ហើយលេងជាមួយនឹងពួកឥសី ។

(៦៨) (សក្ក...) បពិត្រតាបសដ៏ប្រសើរ លោកម្ចាស់ជាអាចារ្យរបស់ខ្ញុំផង ជាបិតារបស់ខ្ញុំផង ម្លប់ព្រះបាទរបស់លោកម្ចាស់នេះសូមជាទីពឹង (របស់ខ្ញុំ) ដែលមានសេចក្តីភ្លាំងភ្លាត់ហើយ បពិត្រតាបស មានប្រាជ្ញាដូចជាផែនដី សូមលោកម្ចាស់អត់នូវកំហុសម្តង បណ្ឌិតទាំងឡាយ មិនមានសេចក្តីក្រោធជាកំឡាំងទេ ។

(៦៩) (មហាសត្វ...) កាលដែលពួកឥសី(នៅក្នុងព្រៃ) សូម្បីតែមួយយប់ក៏ឈ្មោះថាបាននៅល្អហើយ ព្រោះថាយើងទាំងឡាយបានជួបនឹងព្រះកោសិយៈជាម្ចាស់នៃទេវតា ពួកអ្នកដ៏ចំរើនទាំងអស់គ្នា ចូរមានចិត្តរៀបល្អចុះ ដ្បិតព្រាហ្មណ៍ (ជាអាចារ្យរបស់អ្នកទាំងឡាយ) បានខ្ចីក្រអៅឈូកវិញហើយ ។

(៧០) (អភិសម្ពុទ្ធគាថា) បងប្អូនប្រាំពីរនាក់ក្នុងកាលនោះ គឺ តថាគត១ សារីបុត្ត១ មោគ្គល្លាន១ កស្សប១ អនុរុទ្ធ១ បុណ្ណ១ អានន្ទ១ ។

ភគិនី ឧប្បលវណ្ណា   ទាសី ខុជ្ជុត្តរា តទា
ចិត្តោ គហបតិ ទាសោ   យក្ខោ សាតាគិរោ តទា ។
បាលិលេយ្យោ តទា នាគោ   មធុទោ សេដ្ឋវានរោ
កាឡុទាយី តទា សក្កោ   ឯវំ ធារេថ ជាតកន្តិ ។

ភិសជាតកំ បញ្ចមំ ។

## សុរុចិជាតកំ

(៧១) មហេសី រុចិនោ ភរិយា   អានីតា បឋមំ អហំ
ទស វស្សសហស្សានិ   យំ មំ សុរុចិ អានយិ[១] ។
សាហំ ព្រាហ្មណ រាជានំ   វេទេហំ មិថិលគ្គហំ
នាភិជានាមិ កាយេន   វាចាយ ឧទ ចេតសា
សុរុចិំ អតិមញ្ញិត្ថ   អាវិ វា យទិ វា រហោ ។
ឯតេន សច្ចវជ្ជេន   បុត្តោ ឧប្បជ្ជតំ ឥសេ
មុសា មេ ភណមានាយ   មុទ្ធា ផលតុ សត្តធា ។
(៧២) ភត្តុ មមាតា សស្សុ បិយា   មាតា បិតា ច សស្សុរោ[២]

១ ឱ. ម. សុរុចិមានយិ ។ ២ ឱ. ភត្តុ មមាតស្សុ បិតា មាតា បាបិ សុរុចិរោ ។ ម. ភត្តុ មម សស្សុ មាតា បិតា បាបិ ច សស្សុរោ ។



ក្នុងកាលនោះ ប្អូនស្រីគឺនាងឧប្បលវណ្ណា ទាសីគឺនាងខុជ្ជុត្តរា ក្នុងកាលនោះ ខ្ញុំប្រុសគឺ គហបតីឈ្មោះចិត្តៈ ទេវតា គឺសាតាគិរយក្ខ ។ ក្នុងកាលនោះ ដំរីប្រសើរ គឺដំរីឈ្មោះបាលិលេយ្យ ស្វាដ៏ប្រសើរ គឺមធុទៈ ក្នុងកាលនោះ ទេវិន្ទ ឈ្មោះសក្កៈ គឺកាឡុទាយី អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

ចប់ ភិសជាតក ទី ៥ ។

## សុរុចិជាតក

(៧១) (នាងសុមេធាទេវី ពោលថា) ខ្ញុំជាមហេសីភរិយារបស់ព្រះបាទសុរុចិ ដែលព្រះអង្គទ្រង់នាំមកមុនដំបូង ព្រះបាទសុរុចិនាំខ្ញុំមកអស់មួយម៉ឺនឆ្នាំហើយ ។ បពិត្រព្រាហ្មណ៍ ខ្ញុំនោះមិនដែលដឹងថា ខ្ញុំបានមើលងាយព្រះរាជាសុរុចិជាធំក្នុងដែនវិទេហៈ ព្រះអង្គគ្រប់គ្រងនូវក្រុងមិថិលា ដោយកាយ ដោយវាចា ឬដោយចិត្ត ក្នុងទីកំបាំង ក្នុងទីចំពោះមុខឡើយ ។ បពិត្រឥសី សូមឲ្យបុត្តកើត (ក្នុងផ្ទៃរបស់ខ្ញុំ) ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហកសូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ ។

(៧២) ព្រះភស្តាផង ព្រះមាតាក្មេកផង ព្រះបិតាក្មេកផង ព្រះមាតាបង្កើតនឹងបិតាបង្កើតផង ជាទីគាប់ចិត្ត ជាទីស្រឡាញ់ (របស់ខ្ញុំ)

តេ មំ ព្រហ្មេ វិជានាហិ យាវ អដ្ឋស្ស ជីវិតំ ។
សាហំ អតិចារិនី កាមសា ធម្មចារិនី
សក្កច្ចំ តេ ឧបដ្ឋាសិំ រត្តិន្ទិវមតន្ទិតា ។
ឯតេន សច្ចវជ្ជេន បុត្តោ ឧប្បជ្ជតំ តវ
មុសា មេ ភណមានាយ មុទ្ធា ផលតុ សត្តធា ។
(៩៣) សោឡសិត្ថីសហស្សានិ សហភរិយានិ ព្រាហ្មណ
តាសុ ឥស្សា វា កោធោ វា នាហុ មយ្ហំ កុទាចនំ ។
ហិតេន តាសំ នន្ទាមិ ន ច មេ កាចិ អប្បិយា
អត្តានំវានុកម្បាមិ សទា សព្វា សបត្តិយោ ។
ឯតេន សច្ចវជ្ជេន បុត្តោ ឧប្បជ្ជតំ តវ
មុសា មេ ភណមានាយ មុទ្ធា ផលតុ សត្តធា ។
(៩៤) ទាសេ កម្មករេ បោសេ យេ ចញ្ញេ អនុជីវិនោ
បោសេមិ សហធម្មេន សទា បមុទិតិន្ទ្រិយា ។





បពិត្រព្រហ្ម ព្រះបិតាក្មេកនឹងព្រះមាតាក្មេកទាំងពីរនោះ រស់នៅ ដរាបណា កិច្ចនាខ្ញុំ ដរាបនោះ ។ ខ្ញុំនោះជាស្រីប្រកបដោយសេចក្តី មិនត្រេកអរនឹងការមិនបៀតបៀន ជាអ្នកប្រព្រឹត្តធម៌ ដោយពិតប្រាកដ មិនខ្ជិលច្រអូស បានបំរើព្រះមាតាក្មេកនឹងព្រះបិតាក្មេកនោះដោយសេចក្តីគោរពទាំងយប់ទាំងថ្ងៃ ។ បពិត្រឥសី សូមឲ្យបុត្រកើត ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ ។

(៩៣) បពិត្រព្រាហ្មណ៍ ខ្ញុំមិនមានសេចក្តីប្រច័ណ្ឌ ឬសេចក្តីក្រោធចំពោះពួកស្ត្រីទាំងមួយម៉ឺនប្រាំមួយពាន់ ដែលជាភរិយាជាមួយគ្នាក្នុងកាលណាមួយឡើយ ។ ខ្ញុំត្រេកអរ ចំពោះស្ត្រីទាំងនោះ ដោយប្រយោជន៍ ស្រីណាមួយ មិនជាទីស្រឡាញ់របស់ខ្ញុំដែលមានឡើយ ខ្ញុំអនុគ្រោះពួកស្ត្រីរួមប្តីទាំងអស់ សព្វ ៗ កាលដូចជាខ្លួនឯង ។ បពិត្រឥសី សូមឲ្យបុត្រកើត ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ ។

(៩៤) ខ្ញុំមានឥន្ទ្រិយស្រស់ស្រាយសព្វៗកាល បានចិញ្ចឹមនូវទាសៈទាំងឡាយផង កម្មករទាំងឡាយផង បុគ្គលដែលត្រូវចិញ្ចឹមទាំងឡាយផង ពួកជនដទៃដែលរស់នៅអាស្រ័យសារផង តាមសមគួរដល់ហេតុ

ឯតេន សច្ចវជ្ជេន ពុត្តោ ឧប្បជ្ជតំ តវេ
មុសា មេ ភណមានាយ មុទ្ធា ផលតុ សត្តធា ។
(៧៥) សមណេ ព្រាហ្មណេ ចាបិ អញ្ញេ ចាបិ វណិព្វកេ
តប្បេមិ អន្នបានេន សទា បយតបាណិនី ។
ឯតេន សច្ចវជ្ជេន ពុត្តោ ឧប្បជ្ជតំ តវេ
មុសា មេ ភណមានាយ មុទ្ធា ផលតុ សត្តធា ។
(៧៦) ចាតុទ្ទសី បញ្ចទសី យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាហិតំ
ឧបោសថំ ឧបវសាមិ[១] សទា សីលេសុ សំវុតា ។
ឯតេន សច្ចវជ្ជេន ពុត្តោ ឧប្បជ្ជតំ តវេ
មុសា មេ ភណមានាយ មុទ្ធា ផលតុ សត្តធា ។
(៧៧) សព្វេ តេ ធម្មគុណា រាជបុត្តិ យសស្សិនិ
សំវិជ្ជន្តិ តយិ ភទ្ទេ យេ ត្វំ កិត្តេសិ អត្តនិ ។

១ ម. ឧបវសិំ ។



បពិត្រទេវី សូមឲ្យបុត្រកើត ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ ។

(៧៥) ខ្ញុំមានចិត្តរីករាយហើយ បានផ្គត់ផ្គង់នូវពួកសមណៈផង នូវពួកព្រាហ្មណ៍ផង នូវពួកវណិព្វកៈដទៃផង ដោយបាយនិងទឹកសព្វកាល ។ បពិត្រទេវី សូមឲ្យបុត្រកើត ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ ។

(៧៦) ខ្ញុំជាស្ត្រីសង្រួមក្នុងសីលទាំងឡាយសព្វកាល បានរក្សានូវឧបោសថ ប្រកបដោយអង្គទាំង ៨ អស់ថ្ងៃទី ១៤ ផង អស់ថ្ងៃទី ១៥ ផង អស់ថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ។ បពិត្រទេវី សូមឲ្យបុត្រកើតដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ ។

(៧៧) (សក្កទេវរាជពោលថា) ម្នាលនាងរាជបុត្រី មានយសដ៏ចំរើន នាងបានថ្លែងនូវធម្មគុណទាំងឡាយណា (ដែលមាន) ក្នុងខ្លួន ធម្មគុណទាំងនោះទាំងអស់ មានបរិបូណ៌ ចំពោះនាងដែរហើយ ។

ខត្តិយោ ជាតិសម្បន្នោ អភិជាតោ យសស្សិមា
ធម្មរាជា វេទេហានំ បុត្តោ ឧប្បជ្ជតេ តវ ។
(៧៨) ទុម្មី[១] រជោជល្លធរោ អឃេ វេហាយសណ្ឋិតោ
មនុញ្ញំ ភាសសេ វាចំ យំ មយ្ហំ ហទយង្គមំ ។
ទេវតា នុសិ សគ្គម្ហា ឥសិ វាសិ មហិទ្ធិកោ
កោ វាសិ ត្វំ អនុប្បត្តោ អត្តានំ មេ បវេទយ ។

(៧៩) យំ ទេវសង្ឃា វន្ទន្តិ សុធម្មាយ សមាគតា
សោហំ សក្កោ សហស្សក្ខោ អាគតោស្មិ តវន្តិកេ ។
ឥត្ថិយោ ជីវលោកស្មិំ យា ហោន្តិ សមចារិនី
មេធាវិនី សីលវតី សស្សុទេវា បតិព្វតា ។
តាទិសាយ សុមេធាយ សុចិកម្មាយ នារិយា
ទេវា ទស្សនមាយន្តិ មានុសិយា អមានុសា ។
ត្វញ្ច ភទ្ទេ សុចិណ្ណេន បុព្វេ សុចរិតេន ច
ឥធ រាជកុលេ ជាតា សព្វកាមសមិទ្ធិនី ។

១ ក្រុម្ភី ឥតិបាឋោ ទិស្សតិ ។



ព្រះរាជបុត្រជាក្សត្រប្រកបព្រមដោយជាតិ កើតបរិសុទ្ធអំពីចំណែក ទាំងពីរ មានយស ជាស្តេចប្រកបដោយធម៌ របស់ជនទាំងឡាយ អ្នកនៅក្នុងដែនវិទេហៈ នឹងកើតដល់នាង ។

(៧៨) (នាងសុមេធាទេវី...) អ្នកមានក្លៀកក្រហា ទ្រទ្រង់ធូលីលំអង ឋិតនៅលើអាកាសវេហាស ពោលពាក្យជាទីពេញចិត្ត ដែលជាក់ជាប់ចូលទៅក្នុងហឫទ័យរបស់ខ្ញុំ ។ ចុះអ្នកជាទេវតា ទើបនឹងមកអំពីឋានសួគ៌ ឬជាឥសីអ្នកមានឫទ្ធិច្រើន ម្យ៉ាងទៀត អ្នកជាអ្វី បានមកដល់ (ក្នុងទីនេះ) ចូរអ្នកប្រកាសខ្លួនឲ្យជាក់ដល់ខ្ញុំ ។

(៧៩) (សក្កទេវរាជ...) ពួកទេវតាប្រជុំគ្នាក្នុងរោងឈ្មោះសុធម្មាហើយ ថ្វាយបង្គំនូវខ្ញុំណា ខ្ញុំនោះឈ្មោះសក្កៈ ជាអ្នកឃើញនូវហេតុមួយពាន់(ដោយមួយរំពេច)បានមកក្នុងសំណាក់នាង ។ ស្ត្រីទាំងឡាយណា ក្នុងជីវលោក ដែលជាអ្នកប្រព្រឹត្តស្មើ មានប្រាជ្ញា មានសីល ទុកម្តាយក្មេកដូចជាទេវតា មានវត្តចំពោះប្តី ។ ទេវតាទាំងឡាយមិនមែនជាមនុស្ស មកជួបនឹងនាងនារី ជាមនុស្សដែលមានបញ្ញាល្អ មានការងារស្អាត ប្រាកដស្មើដោយស្ត្រីទាំងនោះ ។ ម្នាលនាងដ៏ចំរើន នាងបានមកកើតក្នុងរាជត្រកូលនេះ ជាស្ត្រីសម្រេចនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដោយសារអំពើសុចរិត ដែលនាងបានសាងសន្សំមកក្នុងកាលមុន ។

អយញ្ច តេ រាជបុត្តិ   ឧភយញ្ច កាជក្កហោ
ជេភលាភព្វបត្តិ ច   តាក្កិ ច វិជ ជីវិតេ ។
កិរំ សុមេធេ សុចិម្ហី   ធម្មមត្តធិ ចាលយ
បសាហាំ តិធិរំ យាមិ   បិយំ មេ ករ ធស្សថ្តិ ។

សូចិជាតកំ ឆដ្ឋំ ។

---

## បញ្ចុបោសថិកជាតកំ

(៤០) អប្បោស្សុក្កោ ទានិ តុវំ កបោត
វិហង្គម ន តវ ភោជនត្ថោ
ខុទំ បិបាសំ អធិវាសយន្តោ
កស្មា ភវំ ឧបោសថិកោ[១] កបោត ។

(៤១) អហំ បុរេ គិទ្ធិគតោ[២] កបោតិយា
អស្មឹ បទេសស្មឹ ឧភោ រមាម
អថគ្គហី សាកុណិកោ កបោតឹ
អកាមកោ តាយ វិនា អហោសឹ ។

---

១ អគ្គិបរិចារិកោ អគ្គិកាយំ ទិស្សតិ ។ ២ សទ្ធិ គតិ អគ្គិកាយំ ទិស្សតិ ។



ម្នាលនាងរាជបុត្រី ទេវឯងជាភរិយាកាន់យកនូវជ័យនៃនាង គួរ
លោកទាំងពីរ គឺភរិយាគឺគូនៃលោកទ [illegible] ឈ្មោះគូជីវិតនេះ
១ ។ ម្នាលនាងសុមេធា សូមឲ្យនាងមានសេចក្ដីសុខរស់កាលយូរ
នាងចូររក្សានូវធម៌គូនឹងខ្លួនចុះ យើងនឹងទៅកាន់ឋាននៃត្រកូលវិញ
ការចុះចូលមិត្តនឹងនាង [illegible] ស្រឡាញ់ពេញចិត្តរបស់យើង ។

ចប់ សូចិជាតក ទី ៦ ។

---

## បញ្ចុបោសថិកជាតក

(៤០) (តាបសពោលថា) ម្នាលព្រាប ឥឡូវនេះ អ្នកមានសេចក្ដីខ្វល់ខ្វាយតិច ម្នាលបក្សី អ្នកមិនមានសេចក្ដីត្រូវការដោយចំណីសោះ ម្នាលព្រាប អ្នកទ្រាំអត់ទ្រាំនូវសេចក្ដីឃ្លាននឹងស្រេក ជាសត្វរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

(៤១) (ព្រាបពោលថា) កាលមុន ខ្ញុំមានចិត្តជាប់នឹងមេព្រាប យើងខ្ញុំទាំងពីរនាក់ត្រេកអរក្នុងទីនេះ (ក្នុងការ) ក្នុងប្រទេសនោះ ស្រាប់តែសត្វខ្លែង មកចាប់យកមេព្រាបទៅ ខ្ញុំក៏អស់សេចក្ដីត្រេកអរ ព្រោះព្រាត់ប្រាសចាកមេព្រាបនោះ ។

ជាតាភាក វិប្បយោគេន តស្សា
មនោមយំ វេទន វេទយាមិ
តស្មា អហំ ឧបោសថំ បាលយាមិ
រាគោ មមំ មា បុនរាគមាសិ ។

(៨២) អនុជ្ជុគាមិ ឧរគ ទុជិវ្ហ
ទាឋាវុធោ ឃោរវិសោសិ សប្ប
ខុទ្ទំ បិបាសំ អធិភុយ្យ ទ្ធោ
កស្មា ករំ ពោសថំ កោ នុ ទីឃ ។

(៨៣) ឧសភោ អហុ ពលវា គាមិកស្ស
ចលក្កកូ[១] វណ្ណពលូបបន្នោ
សោ មំ អក្កមិ តំ កុបិតោ អទំសឹ
ទុក្ខាភិតុន្នោ មរណំ ឧបាគា ។
តតោ ជនា និក្ខមិត្វាន គាមា
កន្ទិត្វា រោទិត្វា អបក្កមិំសុ
តស្មា អហំ ឧបោសថំ បាលយាមិ
កោធោ មមំ មា បុនរាគមាសិ ។

---

១ ចលក្កកូ ហោតិ អដ្ឋកថាយំ ទិស្សតិ ។ យុគបានំ សេលាយ-ស្សេវំ បរិវត្តំ អតិ អភិធានប្បទីបិកាយំ ទិស្សតិ ។





ខ្ញុំនឹងឃ្លាតនៅឆាត់កូនចិត្ត ព្រោះព្រាត់ប្រាសចាកមេព្រាបនោះ ហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យរាគៈគ្របសង្កត់ខ្ញុំបានទៀតឡើយ ។

(៨២) (តាបស...) ម្នាលពស់ ជាសត្វដែលជាតិល្ហូនទៅមិនត្រង់ មានអណ្តាតពីរ អ្នកមានចង្កូមជាអាវុធ មានពិសដ៏ក្លៀវក្លា ម្នាលសត្វមានខ្លួនវែង អ្នកអត់ទ្រាំនូវសេចក្តីឃ្លាននឹងសេចក្តីស្រេកហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

(៨៣) (ពស់...) គោឈ្មោលមេហ្វូងរបស់អ្នកស្រុក ជាគោមានកំលាំង មានបូកវិលយោរ បរិបូណ៌ដោយសម្បុរនឹងកំលាំង គោនោះដើរជាន់ខ្ញុំ ខ្ញុំខឹង បានចឹកវា ។ គោនោះត្រូវសេចក្តីទុក្ខគ្របសង្កត់ហើយក៏ស្លាប់ទៅ ។ លំដាប់នោះ ពួកជនចេញអំពីស្រុក កន្ទក់កន្ទេញ យំទួញ ហើយដើរចៀសចេញទៅ ព្រោះហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យសេចក្តីក្រោធគ្របសង្កត់ខ្ញុំបានទៀតឡើយ ។

(៨៥) មតាន មំសានិ ពហូ សុសានេ

មនុញ្ញរូបំ តវ ភោជនេតំ

ទុដ្ឋំ ចីតាសំ អតិកសយន្តោ

កស្មា ករោតាសទិកោ សិគាល ។

(៨៦) ឧរស្ស កាដ្ឋិ មហតោ តជស្ស

កុណបេ រតោ ហត្ថិមំសេសុ គិទ្ធោ

ឧណ្ហោ ច ភតោ តិច្ចិណា ច រស្មិយោ

តេ សោភសយិ តស្ស ការសមត្ថំ ។

ការសោ ក បណ្ណោ ច អហំ កឆន្តេ

ឧ មេ អហុ និក្ខមតាយ មន្តោ

មហា ច មេ យោ សហសា ឧរស្សំ

សោ ទេមយិ តស្ស ការសមត្ថំ ។

តតោ អហំ និក្ខមិសំ កឆន្តេ

ឧព្ភោ យថា កហុម្មា ឧម្មត្តោ

តស្មា អហំ តោសជ តាលយាមិ

លោកោ មមំ ឆា ចុឆកតតាសិ ។



(៨៥) (ពះស...) ក្នុងព្រៃស្មសាន មានសាច់របស់សត្វស្លាប់ដ៏ច្រើន សាច់ទាំងនុះជាភោជនជាទីគាប់ចិត្តរបស់អ្នក ម្នាលបបក អ្នកទំរង់ទ្រាំនូវតំណាងនឹងស្រេក ហើយកក្កូនទៅ ទៅឲ្យសម ហើព្រោះហេតុអ្វី ។

(៨៦) (បបក...) ខ្ញុំជាសត្វត្រេកអរក្នុងសាកសព ញាំមក្នុងសាច់ដំរីទាំងឡាយ បានចូលទៅក្នុងពោះនៃដំរីធំ ឲ្យលំដំក្តៅផង ស្ងួតនៃកំពង់ព្រះអាទិត្យដ៏ក្លៀវក្លាផង របស់ទាំងនោះញ៉ាំងទ្វារកោយាព័ដីនោះឲ្យស្អុតត្រៀម ។ បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំស្គមស្លៀក (ក្នុងពោះនៃដំរីនោះ) ខ្ញុំរកផ្លូវចេញមកវិញមិនរួច ស្រាប់តែភ្លៀងធំបង្អុរចុះមក (ក្នុងវេលានោះ) ភ្លៀងនោះធ្វើទ្វារកោយាព័នៃដំរីនោះឲ្យទទឹកសើម ។ បពិត្រលោកម្ចាស់ដ៏ចំរើន លំដាប់នោះ ទើបខ្ញុំចេញមកដូចជាព្រះចន្ទ ដែលរួចអំពីមាត់នៃរាហូ ព្រោះហេតុនោះ បានជាខ្ញុំ ខ្លាចញ័រ ទៅឲ្យសម កុំឲ្យលោកៈគ្រប់សត្វគត់ខ្ញុំបានទៀតឡើយ ។

(៨៦) វម្មិកថូបស្មិំ កិបិល្លិកានិ
និប្បោថយន្តោ តុវំ បុរេ ចរាសិ
ខុទ្ទំ បិបាសំ អធិវាសយន្តោ
កស្មា ភវំ បោសថិកោ នុ អជ្ជ ។

(៨៧) សកំ និកេតំ អតិហីឡយានោ
អត្រិច្ឆតាយ មលគំ(១) អគច្ឆឹ
តតោ ជនា និក្ខមិត្វាន គាមា
កោទណ្ឌកេន បរិបោថយឹសុ មំ ។
សោ ភិន្នសីសោ រុហិរមក្ខិតង្គោ
បច្ចាគមាសឹ សកំ និកេតំ
តស្មា អហំ បោសថំ បាលយាមិ
អត្រិច្ឆតា មា បុនរាគមាសិ ។

(៨៨) យំ នោ អបុច្ឆិត្ថ តុវំ ភទន្តេ
សព្វេវ ព្យាករិម្ហា យថាបជានំ
មយម្បិ បុច្ឆាម តុវំ ភទន្តេ
កស្មា ភវំ បោសថិកោ នុ ព្រហ្មេ ។

---

១ ឱ. អត្រិច្ឆតា មល្លយាតំ ។





(៨៦) (កបស...) កាលពីដើម អ្នកធ្លាប់ស៊ីនូវកណ្ដៀរទាំងឡាយ លើកំពូលដំបូក ម្នាលតាបស អ្នកទំនត់ទ្រាំនូវសេចក្ដីឃ្លាននឹងស្រេកហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

(៨៧) (ភាយំ...) ខ្ញុំមើលងាយនូវលំនៅរបស់ខ្លួន បានចូលទៅកាន់ស្រុកនៃមនុស្សដទៃ ព្រោះតែសេចក្ដីប្រាថ្នាលើសលប់ គ្រានោះ ពួកជនចេញមកពីស្រុក ហើយក៏វាយខ្ញុំជាយ៉ាប់ៗ ខ្ញុំនោះបែកក្បាលប្រឡាក់ឈាមអស់ទាំងខ្លួន ហើយត្រឡប់មកកាន់លំនៅរបស់ខ្លួនវិញ ព្រោះហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យសេចក្ដីប្រាថ្នាលើសលប់ គ្របសង្កត់បានទៀតឡើយ ។

(៨៨) (សត្វទាំងនេះ...) បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់បានសាកសួរនូវសេចក្ដីណាចំពោះយើងទាំងឡាយ យើងទាំងអស់គ្នាក៏បានឆ្លើយនូវសេចក្ដីនោះ តាមចំនេះដែលខ្លួនបានដឹងរួចហើយ បពិត្រលោកម្ចាស់ដ៏ចំរើន ពួកយើងសូមសួរលោកម្ចាស់វិញ បពិត្រព្រាហ្មណ៍ លោកម្ចាស់បានរក្សានូវឧបោសថ តើព្រោះហេតុអ្វី ។

(៨៩) អនុបលិត្តោ មម អស្សមម្ហិ
បច្ចេកពុទ្ធោ មុហុត្តំ និសីទិ
សោ មំ អវេទិ គតិមាគតិញ្ច
នាមញ្ច គោត្តំ ចរណញ្ច សព្វំ ។
ឯវម្បហំ វន្ទិ ន តស្ស បាទេ
ន ចាបិហំ មានគតេន បុច្ឆិំ
តស្មា អហំ បោសថំ បាលយាមិ
មានោ មមំ មា បុនរាគមាសីតិ ។

បញ្ចុបោសថិកជាតកំ សត្តមំ ។

## មហាមោរជាតកំ

(៩០) សចេ ហិ ត្យាហំ ធនហេតុ គាហិតោ
មា មំ អវធិ ជីវគាហំ គហេត្វា
រញ្ញោ ច មំ សម្ម ឧបន្តិ នេហិ
មញ្ញេ ធនំ លច្ឆសិនប្បកំ ។
(៩១) ន មេ អយំ តុយ្ហ វធាយ អជ្ជ
សមាហិតោ ចាបធុរេ កលាបោ
បាសញ្ច ត្យាហំ អធិបាតយិស្សំ
យថាសុខំ គច្ឆតុ មោររាជា ។



(៨៩) (តាបស...) ព្រះបច្ចេកពុទ្ធ មិនប្រឡាក់ (ដោយកិលេស) គង់ក្នុងអាស្រមរបស់យើងមួយរំពេច ព្រះអង្គបានញុំាងយើងឲ្យដឹងនូវទី ដែលត្រូវទៅនិងទីដែលត្រូវមកផង នូវនាមផង នូវគោត្រផង នូវសេចក្តីប្រព្រឹត្តទាំងអស់ផង ។ បើទុកជាយ៉ាងនេះ ក៏យើងនៅតែមិនថ្វាយបង្គំព្រះបាទា នៃព្រះបច្ចេកពុទ្ធនោះ ម្យ៉ាងទៀត យើងមិនបានសាកសួរ ព្រោះលុះក្នុងអំណាច ហេតុនោះ បានជាយើងរក្សាឧបោសថ កុំឲ្យមានះគ្របសង្កត់យើងបានទៀតឡើយ ។

ចប់ បញ្ចុបោសថិកជាតក ទី ៧ ។

## មហាមោរជាតក

(៩០) (ស្តេចក្ងោកពោធិសត្វពោលថា) ម្នាលសំឡាញ់ ប្រសិនបើអ្នកចាប់ខ្ញុំ ព្រោះហេតុនៃទ្រព្យ អ្នកកុំសម្លាប់ខ្ញុំឡើយ សូមចាប់ខ្ញុំទាំងរស់ ហើយនាំខ្ញុំទៅកាន់សំណាក់ព្រះរាជាចុះ អ្នកទំនងជានឹងបាននូវទ្រព្យដ៏ច្រើន ។

(៩១) (ព្រានព្រៃពោលថា) ធ្នូប្រសើរនិងព្រួញនេះ ខ្ញុំមិនមែនយកប្រើប្រៀបដើម្បីនឹងបាញ់អ្នកក្នុងថ្ងៃនេះទេ ខ្ញុំនឹងបាញ់ផ្តាច់អន្ទាក់របស់អ្នកចេញ (ដោយគិតថា) ស្តេចក្ងោកចូរទៅតាមសប្បាយចុះ ។

(៤២) យំ សត្ត វស្សានិ មមានុគច្ឆិ
រត្តិន្ទិវំ ខុប្បិបាសំ សហន្តោ
អជ្ជ តស្ស មំ បាសវសូបនីតំ
បមុត្តយេ ឥច្ឆសិ ពន្ធនស្មា ។
បាណាតិបាតា វិរតោ នុសជ្ជ
អភយន្នុ តេ សព្វភូតេសុ ទិន្នំ
យំ មំ តុវំ បាសវសូបនីតំ
បមុត្តយេ ឥច្ឆសិ ពន្ធនស្មា ។

(៤៣) បាណាតិបាតា វិរតស្ស ព្រូហិ
អភយញ្ច យោ សព្វភូតេសុ ទេតិ
បុច្ឆាមិ តំ មោររាជេតមត្ថំ
ឥតោ[១] ចុតោ កិំ លភតេ សុខំ សោ ។

(៤៤) បាណាតិបាតា វិរតស្ស ព្រូមិ
អភយញ្ច យោ សព្វភូតេសុ ទេតិ
ទិដ្ឋេវ ធម្មេ លភតេ បសំសំ
សគ្គញ្ច សោ យាតិ សរីរភេទា ។

១ ឱ, ម. ឥតោ ។



(៤២) (ស្តេចក្ងោក...) អ្នកទំអត់ទ្រាំនូវសេចក្តីស្រេកឃ្លាន តាំងយប់តាំងថ្ងៃ ដើរចាប់តាមខ្ញុំអស់ប្រាំពីរឆ្នាំហើយ កាលបើយ៉ាងនេះ ព្រោះហេតុអ្វីក៏អ្នកចង់ដោះខ្ញុំ ដែលកំពុងជាប់អន្ទាក់ឲ្យរួចអំពីអន្ទាក់វិញ ។ អ្នកទើបនឹងវៀរចាកបាណាតិបាតក្នុងថ្ងៃនេះឬ ឬក៏អ្នកឲ្យអភ័យដល់សត្វទាំងពួង បានជាអ្នកចង់ដោះខ្ញុំ ដែលកំពុងជាប់អន្ទាក់ឲ្យរួចចាកអន្ទាក់វិញ ។

(៤៣) (កូនព្រានព្រៃ...) ម្នាលស្តេចក្ងោក អ្នកចូរប្រាប់អំពីបុគ្គលដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យដល់សត្វទាំងពួងផង ខ្ញុំសួរអ្នកនូវសេចក្តីនុ៎ះ បុគ្គលនោះច្យុតអំពីលោកនេះទៅ នឹងបាននូវសេចក្តីសុខដូចម្តេចខ្លះ ។

(៤៤) (ស្តេចក្ងោក...) ខ្ញុំនឹងប្រាប់អំពីបុគ្គល ដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យ ដល់សត្វទាំងពួង បុគ្គលនោះរមែងបាននូវសេចក្តីសរសើរ ក្នុងបច្ចុប្បន្នផង លុះបែកធ្លាយសរីរៈទៅ នឹងបានទៅកើតនៅឋានសួគ៌ផង ។

(៩៥) ន សន្តិ ទេវា ឥតិ អាហុ ឯកេ
ឥធេវ ជីវោ វិភវំ ឧបេតិ
តថា ផលំ សុកតទុក្កដានំ
ទត្តុបញ្ញត្តញ្ច វទន្តិ ទានំ
តេសំ វចោ អរហតំ សទ្ទហានោ
តស្មា អហំ សកុណេ ឃាតយាមិ ។

(៩៦) ចន្ទោ ច សុរិយោ ច ឧភោ សុទស្សនា
គច្ឆន្តិ ឱភាសយមន្តលិក្ខេ
ឥមស្ស លោកស្ស បរស្ស វា តេ
កថន្នុ តេ អាហុ មនុស្សលោកេ ។

(៩៧) ចន្ទោ ច សុរិយោ ច ឧភោ សុទស្សនា
គច្ឆន្តិ ឱភាសយមន្តលិក្ខេ
បរស្ស លោកស្ស ន តេ ឥមស្ស
ទេវាតិ តេ អាហុ មនុស្សលោកេ ។



(៩៥) (កូនព្រាន...) សមណព្រាហ្មណ៍ពួកខ្លះបានពោលថា ទេវតាទាំងឡាយ មិនមានទេ ជីវៈគឺសត្វលោកនេះ រមែងដល់នូវសេចក្ដីដាច់សូន្យ ផលនៃអំពើដែលសត្វធ្វើល្អ ធ្វើអាក្រក់ រមែងដល់នូវសេចក្ដីដាច់សូន្យដូចគ្នា ទាំងពោលថាទានជាគុណជាតដែលមនុស្សល្ងង់បញ្ញត្តហើយ ខ្ញុំជឿពាក្យ របស់សមណព្រាហ្មណ៍ ជាព្រះអរហន្តទាំងនោះ ហេតុនោះ បានជាខ្ញុំសម្លាប់សត្វស្លាបទាំងឡាយ ។

(៩៦) (ស្ដេចក្រុង...) ព្រះចន្ទនឹងព្រះអាទិត្យទាំងពីរ ជារបស់ឃើញហើយ ភ្លឺរុងរឿង ទៅក្នុងអាកាស ព្រះចន្ទនឹងព្រះអាទិត្យទាំងនោះ (ជារបស់) លោកនេះឬលោកដទៃ (ពួកជន) គឺមនុស្សលោកហៅព្រះចន្ទនឹងព្រះអាទិត្យទាំងនោះថាជាអ្វី ។

(៩៧) (កូនព្រាន...) ព្រះចន្ទនឹងព្រះអាទិត្យទាំងពីរ ជារបស់ឃើញហើយ ភ្លឺរុងរឿង ទៅក្នុងអាកាស ព្រះចន្ទនឹងព្រះអាទិត្យទាំងនោះ (ជារបស់) លោកដទៃ មិនមែនរបស់លោកនេះទេ ពួកជន គឺមនុស្សលោក ហៅព្រះចន្ទនឹងព្រះអាទិត្យទាំងនោះថាជាទេវតា ។

(៩៨) ឃរដ្ឋា តេ ធីហតា ហីនកា
អហេតុកា យេ ច វទន្តិ កម្មំ
តថា ផលំ សុកតទុក្កតានំ
ទត្តុប្បញ្ញត្តំ យេ ច វទន្តិ ទានំ ។

(៩៩) អទ្ធា ហិ សច្ចំ វចនំ តវេតំ
កថញ្ហិ ទានំ អផលំ ភវេយ្យ
តថា ផលំ សុកតទុក្កតានំ
ទត្តុប្បញ្ញត្តា កថំ ភវេយ្យុំ ។
កថង្ករោ កិន្តិករោ កិមាចរំ
កិំ សេវមានោ កេន តបោគុណេន
អក្ខាហិ មេ(១) មោរភាជមគ្គំ
យថា អហំ នោ និរយំ បតេយ្យំ ។

(១០០) យេ កេចិ អត្ថិ សមណា បថព្យា
កាសាយវត្ថា អនគារិយំ ចរន្តិ
បាតោវ បិណ្ឌាយ ចរន្តិ កាលេ
វិកាលចរិយា វិរតា ហិ សន្តោ ។

---

១ ម. អក្ខាហិ និ ពនំ ។



(៩៨) (ស្តេចកោក...) សមណព្រាហ្មណ៍ណាមិនពោលការកម្ម មិនពោលការផលនៃកម្ម ដែលសត្វធ្វើល្អ ធ្វើអាក្រក់ មួយទៀត សមណព្រាហ្មណ៍ណា ពោលថា ទានជាគុណជាតដែលមនុស្សសន្មតហើយ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកហីនក៏ ជាអ្នកអាហាក្កក៏ ត្រូវតែវិញ្ញូជនតិះដៀល ក្នុងលោកនេះ មិនខាន ។

(៩៩) (កូនព្រានព្រៃ...) ពាក្យរបស់អ្នកនុ៎ះទៀងពិត ព្រោះទានជាគុណជាតឥតផលដូចម្តេចកើត ផលនៃអំពើដែលសត្វធ្វើល្អធ្វើអាក្រក់ក៏ដូចគ្នា ម្យ៉ាងទៀត (ទាន) ជាគុណជាតដែលមនុស្សសន្មតហើយ ដូចម្តេចកើត ។ ខ្ញុំធ្វើអំពើដូចម្តេច ធ្វើដោយហេតុដូចម្តេច ប្រព្រឹត្តដូចម្តេច សេពនូវអ្វី ដោយគុណនៃតបៈដូចម្តេច មិនគប្បីធ្លាក់ទៅក្នុងនរកយ៉ាងណា ម្នាលស្តេចកោក អ្នកសូមប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ដោយធ្លាយយ៉ាងនោះ ។

(១០០) (ស្តេចកោក...) ពួកសមណៈណាមួយនៅលើផែនដី ជាអ្នកស្លៀកសំពត់កាសាវៈ ប្រព្រឹត្តក្នុងភេទនៃបុគ្គលគ្មានផ្ទះ ត្រាច់ទៅបិណ្ឌបាតអំពីព្រឹក ក្នុងកាលគួរ វៀរចាកកិរិយាត្រាច់ទៅក្នុងកាលខុស ជាអ្នកស្ងប់រម្ងាប់ ។

តេ ច កាលេ ឧបសន្តចិត្តា

បុញ្ញានិ យំ តេ មនសោ បិយំ សិយា

តេ តំ បវក្ខន្តិ យថាបជានំ

ធម្មស្ស លោកស្ស បរស្ស ចក្ខុំ ។

(១០៣) ឥតិរ ជិណ្ណំ ឥរោ ទុកណំ

បណ្ឌុបលាសំ ហរិតោ ទុមោ

និស្សព្យហីនោ មម លុទ្ធកោ

ជហាមហំ លុទ្ធកកាមវជ្ជំ ។

(១០៤) យោ តាហំ មេ សកុណា អត្ថិ តត្ថា

សកាមំ ឧក្កាមំ មិលនេត្តំ

តេសំ អហំ ជីវិតមទ្ធ ចត្តំ

មោក្ខញ្ច តេ អច្ចសាតំ ចិតេកំ ។

---

១ ឱ. [illegible]



អ្នកចូលទៅកាន់សមណៈទាំងនោះ តាមការល្មម ក្នុងទីនោះ ហើយ ចូរសាកសួរចុះ ព្រោះដល់ណា ដែលជាទីពេញចិត្ត របស់អ្នក លោកនឹងប្រាប់នូវប្រយោជន៍នោះ ជាប្រយោជន៍ ក្នុងលោកនេះ និងក្នុងលោកខាងមុខ (ដល់អ្នក) តាមទំនង នៃការយល់ឃើញ (របស់លោក) ។

(១០៣) (ក្នុងគ្រានៅក្រុងខ្ញុំគ្រាស់ជាព្រានបក្សីកក្កុងរហើយក៏សំដែង
ជា) [illegible]
[illegible]
[illegible]
ទៀត (ជាព្រានពាល) នូវស៊ីកលៀន ។

(១០៤) (បក្សីកក្កុងរទ្ធិសក្កុណាយោជា) ពួកបក្សីណាច្រើនរយ ដែល ខ្ញុំបានចងទុកក្នុងលំនៅ (របស់ខ្លួន) ខ្ញុំក៏ឱ្យនូវជីវិតដល់សត្វទាំងឡាយនោះ ក្នុងថ្ងៃនេះ ខ្ញុំបានដោះលែងហើយ សត្វទាំងនោះ ចូរទៅកាន់ លំនៅរបស់ខ្លួនចុះ ។

(១០៣) លុទ្ទោចរី បាសហត្ថោ អរញ្ញេ
ពាធេតុ មោរាធិបតី យសស្សី
ពន្ធិត្វា មោរាធិបតី យសស្សំ
ទុក្ខា បមុញ្ចុ យថាហំ បមុត្តោតិ ។

មហាមោរជាតកំ អដ្ឋមំ ។

## តច្ឆសូករជាតកំ

(១០៤) យមេសមានា វិចរិម្ហា បព្វតានិ វនានិ ច
អន្វេសំ វិបុលេ ញាតី តេមេ អជ្ឈគមា មយំ ។
ពហុញ្ចិទំ មូលផលំ ភក្ខោ ចាយំ អនប្បកោ
រម្មា ចិមា គិរីនទិយោ ផាសុវាសោ ភវិស្សតិ ។
ឥធេវាហំ វសិស្សាមិ សហ សព្វេហិ ញាតិភិ
អប្បោស្សុក្កោ និរាសង្កី អសោកោ អកុតោភយោ ។



(១០៣) (អភិសម្ពុទ្ធគាថា) ព្រានព្រៃមានអន្ទាក់ក្នុងដៃ ត្រាច់ទៅក្នុងព្រៃ ដើម្បីចាប់ចងស្តេចក្ងោក ដែលមានយស លុះចាប់ចងស្តេចក្ងោក ដែលមានយសបានហើយ ក៏បានរួចចាកសេចក្តីទុក្ខ ដូចអាត្មាអញដែលបានរួច (ចាកទុក្ខដោយសារមគ្គញ្ញាណ) ដូច្នោះដែរ ។

ចប់ មហាមោរជាតក ទី៨ ។

## តច្ឆសូករជាតក

(១០៤) (ស្រូកឈ្មោះតច្ឆកៈពោលថា) យើងកាលស្វែងរកពួកញាតិណា ដើរទៅកាន់ភ្នំនិងព្រៃទាំងឡាយ យើងក៏ស្វែងរកពួកញាតិដ៏ច្រើន ឯពួកញាតិទាំងនោះយើងបានជួបហើយ ។ មើមឈើនិងផ្លែឈើនេះដ៏ច្រើនផង ភក្ខាហារនេះច្រើនផង ភ្នំនិងស្ទឹងទាំងនេះជាទីរីករាយផង ជាលំនៅដ៏សប្បាយ ។ យើងនឹងមិនមានសេចក្តីខ្វល់ខ្វាយ មិនមានសេចក្តីរង្កៀស មិនមានសេចក្តីសោក មិនមានភ័យអំពីទីណា នឹងនៅក្នុងទីនេះឯង ជាមួយនឹងពួកញាតិទាំងអស់ ។

[១០៥] អញ្ញំ លេណំ បរិយេស សត្តុ នោ ឥធ វិជ្ជតិ

សោ តត្ថ សូករេ ហន្តិ ឥធាគន្ត្វា វរំ វរំ ។

[១០៦] កោ នុម្ហាកំ ឥធ សត្តុ កោ ញាតី សុសមាគតេ

ទុប្បធំសេ បធំសេតិ តំ មេ អក្ខាហិ បុច្ឆិតោ ។

[១០៧] ឧទ្ធគ្គរាជី មិគរាជា ពលី ទាឋាវុធោ មិគោ

សោ តត្ថ សូករេ ហន្តិ ឥធាគន្ត្វា វរំ វរំ ។

[១០៨] ន នោ ទាឋា (១) ន វិជ្ជន្តិ ពលំ កាយេ សមោហិតំ

សព្វេ សមគ្គា ហុត្វាន វសំ កាហាម ឯកកំ ។

[១០៩] ហទយង្គមំ កណ្ណសុខំ វាចំ ភាសសិ តច្ឆក

យោបិ យុទ្ធេ បលាយេថ (២) តម្បិ បច្ឆា ហនាមសេ ។

---

១ នោ ទាឋា វិជ្ជន្តិ អដ្ឋកថាយំ ទិស្សតិ ។ ២ បលាយេថាតិ សយេតិ



(១០៥) (កូនជ្រូកឯទៀតពោលថា) ម្នាលតច្ឆកៈ អ្នកចូរស្វែងរកទីជ្រក ដទៃទៀតទៅចុះ (ព្រោះ) គឺទីនេះមានសត្រូវចំពោះពួកយើង សត្រូវនោះ តែងមកក្នុងទីនេះ ហើយសម្លាប់ជ្រូកទាំងឡាយ (សំដៅតែជ្រូកណា) ដែលធាត់ៗ ។

(១០៦) (តច្ឆកៈ...) សត្វណា ជាសត្រូវនឹងពួកយើងក្នុងទីនេះ សត្វណាកំចាត់បង់នូវញាតិ កំពុងនៅជួបជុំគ្នា ដែលសត្រូវកំចាត់បង់ បានដោយក្រ អ្នក ខ្ញុំសួរហើយ ចូរប្រាប់នូវហេតុនោះ ។

(១០៧) (កូនជ្រូក...) ម្រឹគ (មួយ) ជាស្តេចនៃម្រឹគ មានក្រឡានៃសរីរៈ ខាងលើ មានកំលាំងកាយ មានចង្កូមជាអាវុធ ម្នាលតច្ឆកៈ ម្រឹគនោះ មកក្នុងទីនេះ ហើយសម្លាប់ជ្រូកទាំងឡាយ ដែលធាត់ៗ ។

(១០៨) (តច្ឆកៈ...) ខ្នាយទាំងឡាយរបស់ពួកយើង មិនមែនជាមិនមានទេ កំលាំងក៏ប្រជុំចុះក្នុងកាយ បើពួកយើងទាំងអស់ជាអ្នកព្រមព្រៀងគ្នា នឹងធ្វើខ្លាតែម្នាក់ឯងនោះ ឲ្យលុះអំណាចបាន ។

(១០៩) (កូនជ្រូក...) ម្នាលតច្ឆកៈ អ្នកពោលនូវពាក្យជាទីគាប់ចិត្ត គាប់ត្រចៀកណាស់ ដូច្នេះ ប្រសិនបើជ្រូកណា រត់ចោលពួកក្នុងចំបាំង យើងនឹងសម្លាប់ជ្រូកនោះ ក្នុងកាលជាខាងក្រោយ ។

(១១០) បាណាតិបាតា វិរតោ នុ អជ្ជ
អភយំ នុ តេ សព្វភូតេសុ ទិន្នំ
ជាហំ នុ តេ មិគកិរិយ ន សន្តិ
យោ សព្វបត្តោ កបណោវ ឈាយសិ ។

(១១១) ន មេ ជាហំ ន វិជ្ជន្តិ ពលំ កាយេ សមោហិតំ
ញាតី ច និស្សាយ សមត្តំ ឯកកោ
តស្មា ច ឈាយាមិ វនម្ហិ ឯកកោ ។
ធម្មស្សុតំ យន្តិ ទិសាទិសំ[១] បុរេ
ភយដ្ឋិតា លេណគវេសិនោ បុថូ
តេនាធិ សន្តន្ន វសន្តិ ឯកតោ
យត្ថដ្ឋិតា ទុប្បសហជ្ជ តេ មយា ។
បរិណាយកសម្បន្នា សហិតា ឯកវាទិនោ
តេ មំ សមគ្គា ហឹសេយ្យុំ តស្មា នេសំ ន បត្ថយេ ។

---

១ ម. ធ. ទិសោទិសំ ។





(១១០) (ក្ងួតស្ទិល...) ម្នាលអ្នកមានព្យាយាមជាទីពួកម្រឹគ ក្នុងថ្ងៃនេះ អ្នកវៀរចាកបាណាតិបាតឬ ឬក៏អ្នកឲ្យអភ័យដល់ពួកសត្វទាំងអស់ ឬមួយអ្នកមិនមានចង្កូម បានជាអ្នកទៅក្នុងទីស្ងាត់(ជ្រូក) ហើយសញ្ជប់សញ្ជឹង ដូចជាសត្វកំព្រា ។

(១១១) (ខ្លា...) ខ្ញុំមិនមែនជាមិនមានចង្កូមទេ កំឡាំងក៏ប្រជុំល្អក្នុងកាយ ខ្ញុំម្នាក់ឯង បានឃើញពួកញាតិរបស់ជ្រូកព្រមព្រៀងគ្នា ក្នុងទីតែមួយ ហេតុនោះ បានជាសញ្ជប់សញ្ជឹងក្នុងព្រៃ ។

បានឮថា ក្នុងកាលមុន ជ្រូកទាំងឡាយនេះ តែងទៅកាន់ទិសតូចធំ ព្រោះភ័យគ្រប់សណ្ឋានហើយ ក៏ស្វែងរកទីជ្រកកោនម្នាក់ៗគ្នា ឥឡូវនេះ ជ្រូកទាំងនោះរឹតនៅក្នុងទីណា ដែលខ្ញុំគ្រប់សណ្ឋានបានដោយលំបាក ជ្រូកទាំងនោះក៏មកនៅប្រជុំជាមួយគ្នា (ក្នុងទីនោះ) ។

ជ្រូកទាំងឡាយនោះ ជាបរិណាយកដោយនាយក ប្រកបព្រមព្រៀង មូលមាត់គ្នា ព្រមព្រៀងគ្នា គប្បីបៀតបៀនខ្ញុំ ព្រោះហេតុនោះ ខ្ញុំមិនប្រាថ្នាជ្រូកទាំងនោះៗ ។

(១១៦) យំ ហោតិ ឥស្ដោ អសុរេ ជិហាតិ

យំ ហោតិ សោភោ ហត្ថិ តំ នេ បសយ្ហ

យំ ហោតិ ព្យគ្ឃា មិគសដ្ឋបន្តោ

វេ វេ ហន្ដិ ពលញ្ហិ តាតំសិ ។

(១១៧) ន ហោតិ ឥស្ដោ ន សោភោ ធម៌ ព្យគ្ឃា មិគាធិបោ

សមន្ដេ សហិតេ ញាតី ព្យគ្ឃា ន ក្រុរតេ វសេ ។

(១១៨) កុក្កុលកា សកុណិកា សង្ឃិនោ គណចារិនោ

សម្មោទមានា ឯកជ្ឈំ ឧប្បតន្ដិ ឌយន្ដិ ច ។

តេសញ្ច ឌិយមានានំ ឯកេត្ថ អបសក្កតិ

តញ្ច សេនោ និកាសេតិ វេយ្យគ្ឃិយេវ សា គតិ ។

(១១៩) ឧស្សាហិតោ ជដិលេន លុទ្ទេនាមិសចក្ខុនា

ទាឋី ទាឋីសុ បក្ខន្ទិ បញ្ញមានោ យថា បុរេ ។



(១១៦) (កូដជដិល...) ព្រះតេជន្តៀតមួយអន្ទ ឈ្មោះខ្ទីរក្ដ

អស្សុរៈ ខ្ទឹននៃមួយ ស្ដ្រីបាតយកខ្ទៀតបក្សីបាន

ភ្លាមមួយ ដូចប្រុះនិងប្រើគតិសម្លាប់ខ្លួនប្រើនដែលតាក់ៗ

បាន ដ្បិតជាតំលាំង (នៃខ្លានោះ) ប្រាកដថ្លៃពោះ ។

(១១៧) (ខ្លា ..) មិនជាព្រះតេជន្ទ មិនជាខ្ទឹន មិនជាខ្លា ជាស្ដេចនៃ

ម្រឹគទេ ភូមិនធ្វើ (ខ្ទៀតជ្រូក) ដែលមានញាតិព្រមព្រៀងគ្នា

ប្រើនប្រៀបខ្លួនទុក ឲ្យលុះក្នុងអំណាចបានឡើយ ។

(១១៨) (កូដជដិល..) ពួកបក្សីតូចៗ ឈ្មោះកុក្កុលិកា មានហ្វូងហើរទៅ

ជាមួយគ្នា រីករាយគ្នា ហើរទៅកាន់ឈើ ក៏ជាមួយគ្នា បានចំណី

ហើយ ហើរទៅ (តាមអាកាស) ក៏ជាមួយគ្នា ។ កាលបក្សី

ទាំងនោះ កំពុងមូលមិត្រគ្នា បណ្ដាបក្សីទាំងនោះ តែមានបក្សី

មួយហើរឃ្លាតពីគេម្នាក់ឯង ខ្លែងចាប់យកខ្លួនបក្សីដែលហើរឃ្លាត

ពីគេនោះបាន នោះជាគតិរបស់ខ្លា ។

(១១៩) (អភិសម្ពុទ្ធគាថា) (ខ្លានោះ) ត្រូវជដិលកាក្រក់ ដែលមានភ្នែក

សំឡឹងតែតាមិសបញ្ចុះហើយ តាំងខ្លួនមានចង្កូម ស្ទុះជាមុខ

ដូច ក៏ស្ទុះទៅកាន់ជ្រូក ដែលមានចង្កូមដែរ ។

(១១៦) សាធុ សម្ពហុលា ញាតី អបិ រុក្ខា អរញ្ញជា

សូករេហិ សមគ្គេហិ ព្យគ្ឃោ ឯកាយនេ ហតោ ។

(១១៧) ព្រាហ្មណញ្ចេវ ព្យគ្ឃញ្ច ឧភោ ហន្ត្វាន សូករា

អានន្ទិនោ បមោទិតា មហានាទមនាទិសុំ ។

(១១៨) តេ សុទំ ឧទុម្ពរមូលស្មឹ សូករា សុសមាគតា

តច្ឆកំ អភិសិញ្ចឹសុ ត្វំ នោ រាជាសិ ឥស្សរោតិ ។

តច្ឆសូករជាតកំ ទសមំ ។

---

## មហាវាណិជជាតកំ

(១១៩) វាណិជា សមិតឹ[១] កត្វា នានារដ្ឋតោ អាគតា

ធនាហារា បក្កមឹសុ ឯកំ កត្វាន គាមណឹ ។

តេ តំ កន្តារមាគម្ម អប្បភក្ខំ អនោទកំ

មហានិគ្រោធមទ្ទក្ខុំ សីតច្ឆាយំ មនោរមំ ។

តេ ច តត្ថ និសីទិត្វា តស្ស រុក្ខស្ស ឆាយយា[២]

វាណិជា សមចិន្តេសុំ ពាលា មោហេន បារុតា

អល្លាយតេ អយំ រុក្ខោ អបិ វារីវ សន្ទតិ

---

១ ម. សមិតឹ ។ ២ ម. ឆាយាយ ។



(១១៦) (ព្រោះថា...) គួរឲ្យសរសើរ ពួកញាតិច្រើនរូប សូម្បីតែ ឈើដែលដុះក្នុងព្រៃ (ក៏គួរឲ្យសរសើរ) ព្រោះ (ខ្លាគ់ឯង) ត្រូវពួកជ្រូក ព្រមគ្នា សម្លាប់បានក្នុងផ្លូវតែមួយ ។

(១១៧) (អភិសម្ពុទ្ធគាថា) ជ្រូកទាំងឡាយបានសម្លាប់ខ្លាព្រាហ្មណ៍និងខ្លា ទាំងពីរនាក់បានហើយក៏ត្រេកអរពេកពេក ស្រែកឡូឡាសម្រែកដ៏ខ្លាំងៗ

(១១៨) ជ្រូកទាំងឡាយនោះ ប្រជុំគ្នាទៀបគល់ដើមល្វា អភិសេកជ្រូកឈ្មោះតច្ឆកៈថា សូមព្រះអង្គជាស្តេចជាឥស្សរៈរបស់ពួកយើង ។

ចប់ តច្ឆសូករជាតក ទី ១០ ។

---

## មហាវាណិជជាតក

(១១៩) (ព្រះសាស្តាទ្រង់ត្រាស់ថា) ពាណិជទាំងឡាយ ជាអ្នកស្វែងរកទ្រព្យមកអំពីដែនផ្សេងៗ ធ្វើនូវការប្រជុំ (ក្នុងក្រុងពារាណសី) ធ្វើបុគ្គលម្នាក់ ឲ្យជាធំ ហើយចៀសចេញទៅ ។ ពាណិជទាំងឡាយនោះ មកដល់ផ្លូវឆ្ងាយដាច់ស្រយាលនោះ ជាផ្លូវមិនមានស្បៀងអាហារមិនមានទឹក បានឃើញដើមជ្រៃធំ មានម្លប់ត្រជាក់ជាទីរីករាយនៃចិត្ត ។ ឯពាណិជទាំងនោះ ជាបុគ្គលល្ងង់ត្រូវមោហៈបិទបាំង ក៏អង្គុយក្រោមម្លប់ឈើនោះ ក្នុងទីនោះ ហើយប្រឹក្សាគ្នាថា យើងឃើញ ឈើនេះហាក់ដូចជាសើម ដោយទឹក ហាក់ដូចជាមានទឹកហូរទៅ

ឥង្ឃស្ស បុរិមំ សាខំ   មយំ ឆិន្ទាម វាណិជា ។
សា ច ឆិន្នាវ បគ្ឃរិ   អច្ឆំ វារិ អនាវិលំ
តេ តត្ថ ន្ហាត្វា បិវិត្វា   យាវតិច្ឆិំសុ វាណិជា
ទុតិយំ សមចិន្តេសុំ   ពាលា មោហេន បារុតា
ឥង្ឃស្ស ទក្ខិណំ សាខំ   មយំ ឆិន្ទាម វាណិជា ។
សា ច ឆិន្នាវ បគ្ឃរិ   សាលិមំសោទនំ ពហុំ
អប្បោទវណ្ណេ កុម្មាសេ   សិង្គិំវិទលសូបិយោ(១)
តេ តត្ថ ភុត្វា ខាទិត្វា   យាវតិច្ឆិំសុ វាណិជា ។
តតិយំ សមចិន្តេសុំ   ពាលា មោហេន បារុតា
ឥង្ឃស្ស បច្ឆិមំ សាខំ   មយំ ឆិន្ទាម វាណិជា ។
សា ច ឆិន្នាវ បគ្ឃរិ   នារិយោ សមលង្កតា
វិចិត្តវត្ថាភរណា   អាមុត្តមណិកុណ្ឌលា ។
អបិសុ វាណិជា ឯកា   នារិយោ បញ្ចវីសតិ
សមន្តា បរិវារិំសុ   តស្ស រុក្ខស្ស ឆាយយា
តេ តាហិ បរិចារេត្វា   យាវតិច្ឆិំសុ វាណិជា ។

---

១. ម. សិង្គិវេរំ លហុចិយោ ។



បើដូច្នោះ យើងជាពួកឈ្មួញនឹងកាប់នូវមែកឈើខាងកើត ។ លោកឯមែកនោះគ្រាន់តែត្រូវពួកឈ្មួញកាប់ដាច់ភ្លាម ក៏ស្រក់ទឹកចេញ ឯទឹកក៏ថ្លាមិនល្អក់ ពាណិជទាំងនោះបានងូតផឹកក្នុងទឹកនោះដរាបដល់អស់ចំណង់ ។ ពួកឈ្មួញពាល ត្រូវមោហៈបិទបាំង ប្រឹក្សានូវហេតុទី ២ ថា បើដូច្នោះ ពួកយើងជាពួកឈ្មួញ នឹងកាត់នូវមែកឈើខាងត្បូងនោះទៀត ។ លោកឯមែកឈើនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ហូរចេញនូវបាយនៃស្រូវសាលី ដំណាប់ជាមួយសាច់ដ៏ច្រើន នូវនំកុម្មាស ហាក់ដូចជាបាយលាយមានទឹកតិច នូវសម្លខ្ញី នឹងសម្លសណ្ដែកបាយ ពាណិជទាំងនោះ បានបរិភោគទំពាស៊ីក្នុងទីនោះដរាបដល់អស់ចំណង់ ។ ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង ក៏ប្រឹក្សានូវហេតុទី៣ថា បើដូច្នោះ យើងជាពួកឈ្មួញនឹងកាត់មែកឈើខាងលិចនោះទៀត ។ លោកឯមែកនោះគ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ចេញនូវពួកនាងនារី មានខ្លួនតាក់តែងហើយ មានសំពត់នឹងគ្រឿងអលង្ការៈដ៏វិចិត្រ ពាក់កែវមណីនឹងកុណ្ឌល ។ គួរសរសើរផង ពាណិជទាំងឡាយមាននាងនារីម្នាក់ៗ ចំណែកនាងនារី ២៥ នាក់ ចោមរោម (នូវពួកឈ្មួញទាំង) ក្រោមម្លប់ឈើនោះដោយជុំវិញ ពាណិជទាំងនោះ ត្រូវនាងនារីទាំងនោះ ចោមរោមហើយ ដរាបអស់ចំណង់ ។

ចតុត្ថំ សមចិន្តេសុំ ពាលា មោហេន បារុតា
និគ្រោធស្ស ឧត្តរំ សាខំ មយំ ឆិន្ទាម វាណិជា ។
សា ច ឆិន្នាវ បគ្ឃរិ មុត្តា វេឡុរិយា ពហូ
រជតំ ជាតរូបញ្ច កុត្តិយោ បដិយានិ ច
កាសិកានិ[1] ច វត្ថានិ ឧទ្ទិយានិ ច កម្ពលា
តេ តត្ថ ភារេ ពន្ធិត្វា យាវតិច្ឆិំសុ វាណិជា ។
បញ្ចមំ សមចិន្តេសុំ ពាលា មោហេន បារុតា
និគ្រោធស្ស មូលំ ឆិន្ទាម អបិ ភិយ្យោ លភាមសេ ។
អថុដ្ឋហិ សត្ថវាហោ យាចមានោ កតញ្ជលិ
និគ្រោធោ កឹ អបរជ្ឈតិ វាណិជា ភទ្ទមត្ថុ តេ ។
វារិទា បុរិមា សាខា អន្នបានញ្ច ទក្ខិណា
នារិទា បច្ឆិមា សាខា សព្វកាមេ ច ឧត្តរា
និគ្រោធោ កឹ អបរជ្ឈតិ វាណិជា ភទ្ទមត្ថុ តេ ។

---
១ ម. កាសិយានិ ។



ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង ក៏ប្រឹក្សាគ្នាជាគំរប់ ទី ៤ ថា បើដូច្នោះ យើងជាពួកឈ្មួញ នឹងកាត់នូវមែកឈើខាងជើងនោះទៀត ។ សាខាមែកនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ហូរចេញនូវកែវមុក្តានិងកែវពៃទូរ្យដ៏ច្រើនផង នូវប្រាក់ផង នូវមាសផង នូវកម្រាលសម្រាប់ក្រាលលើខ្នងដំរីជាដើមផង នូវកម្រាលរោមសត្វជាដើមផង នូវសំពត់ដែលគេធ្វើក្នុងដែនកាសីផង នូវសំពត់កម្ពលឈ្មោះឧទ្ទិយានៈផង ពាណិជទាំងនោះ ក៏វេចយកនូវភារៈ ដរាបដល់អស់ចំណង់ក្នុងទីនោះ ។ ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង ក៏ប្រឹក្សាគ្នាជាគំរប់ទី ៥ ថា បើដូច្នោះ ពួកយើងនឹងកាត់គល់ឈើនោះ មុខជានឹងបានច្រើនជាងនេះទៅទៀត គ្រានោះឈ្មួញជាធំ ក្រោកឡើងផ្គងអញ្ជលីអង្វរថា ដើមជ្រៃ ប្រទូស្តពួកអ្នកដូចម្តេច ម្នាលពាណិជទាំងឡាយ សេចក្តីចំរើនចូរមានដល់អ្នកចុះ ។ មែកខាងកើត បានឲ្យទឹកផ្លូវផង មែកខាងត្បូង បានឲ្យបាយនិងទឹកផង មែកខាងលិច បានឲ្យនាងនារីទាំងឡាយផង មែកខាងជើង បានឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងផង ដើមជ្រៃប្រទូស្តពួកអ្នកដូចម្តេច ម្នាលពាណិជទាំងឡាយ សេចក្តីចំរើនចូរមានដល់អ្នកចុះ ។

យស្ស រុក្ខស្ស ឆាយាយ និសីទេយ្យ សយេយ្យ វា
ន តស្ស សាខំ ភញ្ជេយ្យ មិត្តទុព្ភោ ហិ បាបកោ ។
តេ ច តស្ស អនាទិត្វា ឯកស្ស វចនំ ពហូ
និសិតាហិ កុឋារីហិ មូលតោ នំ ឧបក្កមុំ ។
(១៦០) តតោ នាគា និក្ខមឹសុ សន្នទ្ធា បណ្ណវីសតិ
ធនុគ្គហានំ តិសតា ឆសហស្សា ច វម្មិនោ ។
(១៦១) ឯតេ ហនថ ពន្ធថ មា វោ មុញ្ចិត្ថ ជីវិតំ
ឋបេត្វា សត្ថវាហំ សព្វេ ភស្មំ ករោថ នេ ។
(១៦២) តស្មា ហិ បណ្ឌិតោ បោសោ សម្បស្សំ អត្ថមត្តនោ
លោភស្ស ន វសំ គច្ឆេ ហនេយ្យ រិសកំ[1] មនំ
ឯវមាទីនវំ ញត្វា តណ្ហា ទុក្ខស្ស សម្ភវំ
វីតតណ្ហោ អនាទានោ សតោ ភិក្ខុ បរិព្វជេ ។

មហាវាណិជជាតកំ ទសមំ ។

[1] ម. ឆ. ហនេយ្យារិសកំ ។



បុគ្គលអង្គុយឬដេក ក្រោមម្លប់នៃឈើណា មិនគួរកាច់បំបាក់មែកឈើនោះឡើយ ព្រោះថាបុគ្គលអ្នកប្រទូស្តមិត្រ ជាមនុស្សអាក្រក់ ។ ឯឈ្មួញទាំងនោះ ច្រើនគ្នា មិនអើពើនូវពាក្យនៃឈ្មួញ ជាធំម្នាក់ ឯនោះ ក៏ចូលទៅដើម្បីនឹងកាត់នូវដើមជ្រៃនោះត្រង់គល់ ដោយពូថៅទាំងឡាយ ដែលខ្លួនសំលៀងហើយ ។

(១៦០) (អភិសម្ពុទ្ធគាថា) លំដាប់នោះ នាគទាំងឡាយ ២៥ សៀតគ្រឿងក្រោះហើយផង ពួកនាគកាន់ធ្នូ៣០០ផង ពួកពាហានកាន់ខែលប្រាំមួយពាន់ផង ក៏ចេញមក ។

(១៦១) (នាគរាជ...) អ្នកទាំងឡាយចូរសម្លាប់ ចូរចងនូវពាណិជទាំងនុ៎ះ អ្នកទាំងឡាយកុំលែងនូវជីវិតឡើយ អ្នកទាំងឡាយ ចូរធ្វើនូវពួកពាណិជទាំងអស់នោះឲ្យទៅជាផេះ ទុកតែពាណិជជាធំម្នាក់ប៉ុណ្ណោះ ។

(១៦២) (អភិសម្ពុទ្ធគាថា) ព្រោះហេតុនោះ បណ្ឌិតបុរស កាលបើបានឃើញច្បាស់ នូវប្រយោជន៍របស់ខ្លួន មិនគប្បីលុះអំណាចនៃលោភៈឡើយ គួរតែកំចាត់បង់នូវចិត្ត ដែលប្រកបដោយលោភៈជាគ្រឿងផ្ទុយនោះ ភិក្ខុបើបានដឹងនូវទោស (គឺលោភៈ) យ៉ាងនេះ ដឹងនូវការកើតឡើងនៃទុក្ខ ព្រោះតណ្ហា យ៉ាងនេះហើយ គប្បីប្រព្រឹត្តជាអ្នកមានតណ្ហាទៅប្រាសហើយ មិនមានសេចក្តីប្រកាន់មាំ មានស្មារតី ។

ចប់ មហាវាណិជជាតក ទី ១០ ។

# សាធិនរាជជាតកំ

(១៦៣) អព្ភុតោ វត លោកស្មឹ ឧប្បជ្ជិ លោមហំសនោ
ទិព្វោ រថោ បាតុរហុ វេទេហស្ស យសស្សិនោ ។
(១៦៤) ទេវបុត្តោ មហិទ្ធិកោ មាតលិ ទេវសារថិ
និមន្តយិត្ថ រាជានំ វេទេហំ មិថិលគ្គហំ
ឯហិមំ រថមារុយ្ហ រាជសេដ្ឋ ទិសម្បតិ
ទេវា ទស្សនកាមា តេ តាវតឹសា សឥន្ទកា
សរមានា ហិ តេ ទេវា សុធម្មាយំ សមច្ឆរេ ។
តតោ ច រាជា សាធិនោ វេទេហោ មិថិលគ្គហោ
សហស្សយុត្តំ អភិរុយ្ហ អគា ទេវាន សន្តិកេ
(សហស្សយុត្តំ ហយវាហឹ ទិព្វយានមធិដ្ឋិតោ
យាយមានោ មហារាជា អទ្ទសា ទេវសភំ ឥទំ)
តំ ទេវា បដិនន្ទឹសុ ទិស្វា រាជានមាគតំ
ស្វាគតន្តេ មហារាជ អថោ តេ អទុរាគតំ
និសីទ ទានិ រាជីសិ ទេវរាជស្ស សន្តិកេ ។





# សាធិនរាជជាតក

(១៦៣) (ពួកអ្នកនគរពោលថា ស្តេចរបស់យើង) ចំឡែកណាស់តើ គួរឲ្យព្រឺរោម កើតឡើង ក្នុងលោក រថជាទិព្វបានកើតប្រាកដ ដល់ស្តេចវិទេហៈ ព្រះអង្គមានយស ។

(១៦៤) (អភិសម្ពុទ្ធគាថា) ទេវបុត្រឈ្មោះមាតលី ជាទេវសារថី មានឫទ្ធិច្រើន បានអញ្ជើញព្រះបាទវិទេហៈ ព្រះអង្គគ្រប់គ្រងក្រុងមិថិលាថា បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គយាងឡើងកាន់រថនេះ ទេវតាតាវត្តិង្សព្រមទាំងព្រះឥន្ទ្រ ចង់ឃើញព្រះអង្គ ព្រោះទេវតាទាំងឡាយរលឹកព្រះអង្គ នៅរង់ចាំក្នុងរោងឈ្មោះសុធម្មា ។ លំដាប់នោះឯង ព្រះបាទវិទេហៈ ព្រះនាមសាធិន ព្រះអង្គគ្រប់គ្រងក្រុងមិថិលា ទ្រង់យាងឡើងកាន់រថ ទឹមដោយសេះច្រើន ហើយបានយាងទៅក្នុងសំណាក់នៃទេវតាទាំងឡាយ (ព្រះរាជាជាធំ ទ្រង់ប្រថាប់លើទិព្វយានឈ្មោះហយវាហី ដែលទឹមដោយសេះច្រើន កំពុងយាងទៅក៏បានទតឃើញទេវសភានេះ) ពួកទេវតាបានឃើញព្រះរាជានោះមកដល់ហើយ ក៏ត្រេកអរ ស្មោះចំពោះថា បពិត្រមហារាជ ព្រះអង្គយាងមកស្រួលហើយមិនមែនយាងមកដោយមិនស្រួលទេ បពិត្រព្រះរាជាអ្នកស្វែងរកគុណដ៏ប្រសើរ ឥឡូវនេះសូមព្រះអង្គទ្រង់គង់ក្នុងសំណាក់នៃទេវរាជចុះ ។

សាលក្ខាមិ ឥជិចម្ពុត្ត វេទេហំ មិថិលគ្គហំ
និមន្តយិត្ថ កាមេហិ អាសនេន ច ភិសេកេ
អនុភោសិ ឥធុប្បត្តោ ទេវានំ វសវត្តិនំ
វស ទេវេសុ រាជិសិ សព្វកាមសមិទ្ធិសុ
តាវត្តឹសេសុ ទេវេសុ ភុញ្ជ កាមេ អមានុសេ ។

(១៤៨) អហំ បុរេ សគ្គគតោ រមាមិ
នច្ចេហិ គីតេហិ ច វាទិតេហិ
សោទានិ អជ្ជ ន រមាមិ សគ្គេ
អាយុន្នុ ខីណំ មរណន្នុ សន្តិកេ
ឧទាហុ មុឡ្ហោស្មិ ជនិន្ទសេដ្ឋ ។

(១៤៩) ន តាយុ ខីណំ មរណញ្ច ទូរេ(១)
ន ចាបិ មុឡ្ហោ នរវីរសេដ្ឋ
តុយ្ហញ្ច បុញ្ញានិ បរិត្តកានិ
យេសំ វិបាកំ ឥធ វេទយិត្ថោ

១ ម. ន តាយុ ខីណំ មរណន្តុ ទូរេ ។ ឱ. នតាយុ ខីណំ មរណញ្ច ទូរេ ។



និព្រះនាងក៏ទទួលពាក្យតាមដំណោះព្រះបាទទៀតថា: ព្រះអង្គគ្រប់គ្រងក្រុងមិថិលា ព្រះនាងបានអញ្ជើញដោយកាមទាំងឡាយផង ដោយអាសនៈផងក៏ជា ច្រើនណាស់ហើយ ព្រះអង្គបានដល់កាមសុខ របស់ទេវតាទាំងឡាយ ដែលញ៉ាំងគេឲ្យប្រព្រឹត្តទៅតាមខ្លួន បពិត្រព្រះរាជាអ្នកស្ដែងកុសលដ៏ប្រសើរ សូមព្រះអង្គគង់នៅក្នុងពួកទេវតា ដែលសម្រេចនូវកាមគ្រប់យ៉ាងបាន សូមព្រះអង្គសោយនូវកាមទាំងឡាយ ដែលមិនមែនជារបស់មនុស្សក្នុងពួកទេវតាជាន់តាវត្តឹង្សចុះ ។

(១៤៨) (ព្រះបាទសាធិនរាជ...) កាលពីដើម ខ្ញុំមកនៅក្នុងឋានសួគ៌ រីករាយដោយរបាំចម្រៀងនិងប្រគំទាំងឡាយ ឥឡូវនេះក្នុងថ្ងៃនេះ ខ្ញុំមិនត្រេកអរក្នុងឋានសួគ៌ទេ បពិត្រព្រះជនិន្ទដ៏ប្រសើរ អាយុ (របស់ខ្ញុំ) នឹងអស់ឬ ឬសេចក្ដីស្លាប់ (បិតនៅ) ក្នុងទីជិត ឬក៏ខ្ញុំជាមនុស្សវង្វេង ។

(១៤៩) (សក្ក...) បពិត្រព្រះអង្គដ៏ប្រសើរ មានព្យាយាមជាទីផុត អាយុរបស់ព្រះអង្គមិនទាន់អស់ទេ ចំណែកសេចក្ដីស្លាប់របស់ព្រះអង្គ (ក៏បិតនៅ) ក្នុងទីឆ្ងាយ មួយវិញទៀត ព្រះអង្គ មិនមែនជាមនុស្សវង្វេងទេ តែថា ព្រះអង្គ សោយនូវផលនៃបុណ្យណា ក្នុងទេវលោកនេះ បុណ្យរបស់ព្រះអង្គនោះ ក៏ច

សេ ទេវានុការេន  កតំ សេដ្ឋំ និសេវតិ

តាវត្តិំសេសុ ទេវេសុ  បញ្ចកាមេ អមានុសេ ។

(១៦៧) យថា យាចិតកំ យានំ  យថា យាចិតកំ ធនំ

ឯវំ សម្បទមេវេតំ  យំ បរតោ ទានបច្ចយា

ន ចាហមេតមិច្ឆាមិ  យំ បរតោ ទានបច្ចយា

សយំ កតានិ បុញ្ញានិ  តំ មេ អាវេណិយំ ធនំ

សោហំ គន្ត្វា មនុស្សេសុ  កាហាមិ កុសលំ ពហុំ

ទានេន សមចរិយាយ  សំយមេន ទមេន ច

យំ កត្វា សុខិតោ ហោតិ  ន ច បច្ឆានុតប្បតិ ។

(១៦៨) ឥមានិ តានិ ខេត្តានិ  ឥទំ និក្ខំ សុកុណ្ឌលំ

ឥមា តា ហរិតានុតា  ឥមា នជ្ជោ សវន្តិយោ

ឥមា តា បោក្ខរណិយោ  រម្មា ចក្កវាកកូជិតា



បពិត្រព្រះករុណាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គគង់នៅជាមួយ ទេវតាទាំងពួង សូមព្រះអង្គសោយកាមគុណទាំងឡាយ មិនមែន ជារបស់មនុស្ស គឺទេវលោកជាន់តាវត្តិង្ស ។

(១៦៧) (ព្រះរាជា ..) យានដែលខ្ចីគេ និងទ្រព្យដែលខ្ចីគេ មានឧបមា យ៉ាងណាមិញ ទ្រព្យណាដែលគេបាន ព្រោះបុគ្គលដទៃឲ្យជា បច្ច័យ ទ្រព្យនុះឯង ក៏មានឧបមេយ្យយ៉ាងនោះដែរ ទ្រព្យណាដែល គេបាន ព្រោះបុគ្គលដទៃឲ្យជាបច្ច័យ ខ្ញុំមិនចង់បានទ្រព្យនុះឡើយ បុណ្យទាំងឡាយដែលខ្ញុំបានធ្វើហើយដោយខ្លួនឯង បុណ្យនោះទុក ជាទ្រព្យរបស់ខ្ញុំជាប់តាមខ្លួន ខ្ញុំនោះនឹងទៅធ្វើកុសលឲ្យច្រើនក្នុង មនុស្ស ដោយឲ្យទានផង កិរិយាប្រព្រឹត្តធម៌ស្មើផង កិរិយាសង្រួម ដោយសីលផង កិរិយាទូន្មានខ្លួនដោយឥន្ទ្រិយផង ព្រោះថា បុគ្គលធ្វើ កុសលហើយ រមែងដល់នូវសេចក្តីសុខ ទាំងមិនក្តៅក្រហាយ រឿយៗ គឺកាលជាខាងក្រោយ ។

(១៦៨) (សាធិនរាជ ពោលនឹងស្តេចនារទៈថា) ស្រែទាំងឡាយនេះផង ទឹកប្រកបដោយកុណ្ឌល[១]ដ៏ល្អនេះផង ដែនដីដ៏ខៀវស្រស់ ដោយ ស្មៅតិណខៀវនេះផង ស្ទឹងទាំងឡាយដែលកំពុងហូរនេះផង ស្រះ បោក្ខរណីទាំងឡាយ ជាទីរីករាយ មានសត្វចាក្រពាកយំហើយ

១ ទឹកមានកំពែងសម្រាប់ចុកទំលាយទឹកឲ្យហូរស្រួល ។ អដ្ឋកថា ។

មន្ទាលកេហិ សញ្ឆន្នា បទុមុប្បលកេហិ ច
យស្សាមាន មមាយិំសុ កឹ នុ តេ ទិសតំ គតា ។

តានិ ច ខេត្តានិ សោ ភូមិភាគោ
តេយេវ អារាមវនុបចារា
តមេវ មយ្ហំ ជនតំ អបស្សតោ
សុញ្ញា វ មេ នារទ ខាយតេ ទិសា ។

(១៦៤) ទិដ្ឋា មយា វិមានានិ ឱភាសេន្តា ចតុទ្ទិសា
សម្មុខា ទេវរាជស្ស តិទសានញ្ច សម្មុខា ។
វុត្ថំ មេ ភវនំ ទិព្វំ ភុត្តា កាមា អមានុសា
តាវតឹសេសុ ទេវេសុ សព្វកាមសមិទ្ធិសុ ។
សោហំ ឯតាទិសំ ហិត្វា បុញ្ញាយម្ហិ ឥធាគតោ
ធម្មមេវ ចរិស្សាមិ នាហំ រជ្ជេន អត្ថិកោ ។
អទណ្ឌាវចរំ មគ្គំ សម្មាសម្ពុទ្ធទេសិតំ
តំ មគ្គំ បដិបជ្ជិស្សំ យេន គច្ឆន្តិ សុព្វតា ។

សាធិនរាជជាតកំ ឯកាទសមំ ។

---





ដែលដេរដាសដោយបត្តិលណា ដោយផ្កាឈូក និងផ្កាឧប្បលនេះផង ពួកជនណា ប្រកាន់នូវទីទាំងឡាយនេះថាជារបស់អញ ជនទាំងនោះ ទៅកាន់ទិសណាហ្ន៎ ។

អធិប្បាយ: ស្រែទាំងឡាយ នៅជាស្រែទាំងនោះដដែល ភូមិភាគ នៅជាភូមិភាគនោះដដែល ទុមហារៈនៃសួនច្បារទាំងឡាយ ក៏នៅជាទុមហារៈនោះដដែល តែជាកាលយើងមិនឃើញនូវជនទាំងនោះ ទិសប្រាកដដល់យើង ហាក់ដូចជាសូន្យឈឹង

(១៦៤)(ព្រះរាជា...)វិមានទាំងឡាយ ញុំងទិសទាំង៤ ឲ្យភ្លឺចាំងក្នុងទីចំពោះមុខទេវរាជផង ចំពោះមុខពួកទេវតាជាន់ត្រៃត្រិង្សផង យើងបានឃើញហើយ ។ ភពជាទិព្វយើងបាននៅហើយ កាមទាំងឡាយមិនមែនជារបស់មនុស្ស យើងបានបរិភោគហើយក្នុងពួកទេវតាជាន់តាវត្តិង្ស សម្រេចនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងបាន ។ យើងនោះបានលះបង់សម្បត្តិទិព្វប្រាកដដូច្នោះ ហើយមកក្នុងទីនេះ ដើម្បីធ្វើបុណ្យ យើងនឹងប្រព្រឹត្តធម៌តែម្យ៉ាង យើងមិនមានសេចក្តីត្រូវការដោយរាជសម្បត្តិទេ ។ ព្រះពុទ្ធទាំងឡាយដែលមានវត្តល្អ ស្ដេចយាងទៅតាមផ្លូវណា យើងនឹងដើរទៅតាមផ្លូវនោះ ដែលព្រះសម្មា-សម្ពុទ្ធសំដែងហើយ ជាផ្លូវដែលបុគ្គលមិនមានអាជ្ញាត្រាច់ទៅ ។

ចប់ សាធិនរាជជាតក ទី ១១ ។

# ទសព្រាហ្មណជាតកំ

(១៣០) រាជា អវោច វិធុរំ ធម្មកាមោ យុធិដ្ឋិលោ
ព្រាហ្មណេ វិធុរ បរិយេស សីលវន្តេ ពហុស្សុតេ
វិរតេ មេថុនា ធម្មា យេ មេ ភុញ្ជេយ្យុ ភោជនំ
ទក្ខិណំ សម្ម ទស្សាម យត្ថ ទិន្នំ មហប្ផលំ ។

(១៣១) ទុល្លភា ព្រាហ្មណា ទេវ សីលវន្តោ ពហុស្សុតា
វិរតា មេថុនា ធម្មា យេ តេ ភុញ្ជេយ្យុ ភោជនំ ។
ទស ខលុ មហារាជ យា តា ព្រាហ្មណជាតិយោ
តេសំ វិភង្គំ វិចយំ វិត្ថារេន សុណោហិ មេ ។
បសិព្វកេ គហេត្វាន បុណ្ណេ មូលស្ស សំវុតេ
ឱសធិកាយោ គន្ថេន្តិ ន្ហាបយន្តិ ជបន្តិ ច ។



# ទសព្រាហ្មណជាតក

(១៣០) (ព្រះសាស្តាទ្រង់ត្រាស់ថា) ព្រះរាជា ជាយុធិដ្ឋិលគោត្រ ព្រះអង្គប្រាថ្នានូវធម៌ ទ្រង់ត្រាស់នឹងអាមាត្យឈ្មោះវិធុរៈថា ម្នាលវិធុរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ទក្ខិណាទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន ម្នាលសំឡាញ់ យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៣១) (អាមាត្យឈ្មោះវិធុរៈ ក្រាបទូលថា) បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម នឹងបរិភោគនូវភោជនរបស់ព្រះអង្គ រកបានដោយក្រ ។ បពិត្រមហារាជ ពួកជាតិព្រាហ្មណ៍ទាំងឡាយណាមាន ១០ យ៉ាង សូមព្រះអង្គ ទ្រង់ព្រះសណ្តាប់ នូវការបែកចែក នឹងការពិនិត្យពិច័យ នូវព្រាហ្មណ៍ទាំងនោះ តាមប្រាជ្ញារបស់ទូលព្រះបង្គំ ដោយពិស្តារចុះ ។ ព្រាហ្មណ៍ទាំងឡាយ កាន់ការុងទាំងឡាយ ដែលពេញដោយឫសឈើ បិទមាត់ជិត ហើយតែងក្រងថ្នាំទាំងឡាយផង ផ្ងូតទឹកឲ្យគេផង សែកនូវ(ក្បួនវិជ្ជា)ផង ។

តិកិច្ឆកសមា រាជ តេបិ វុច្ចន្តិ ព្រាហ្មណា
អញ្ញាតេ តេ មហារាជ តាទិសេ និបចាយសេ ។

(១៣៦) អបេតា តេ ច ព្រាហ្មញ្ញា[១] (ឥតិ រាជា កោរព្យោ)
ន តេ វុច្ចន្តិ ព្រាហ្មណា

អញ្ញេ វិធុរ បរិយេស សីលវន្តេ ពហុស្សុតេ
វិរតេ មេថុនា ធម្មា យេ មេ ភុញ្ជេយ្យុ ភោជនំ
ទក្ខិណំ សម្បទស្សាម យត្ថ ទិន្នំ មហប្ផលំ ។

(១៣៧) កិង្កិណិកាយោ គហេត្វាន ឃោសេន្តិ បុរតោបិ តេ
បេសនានិបិ គច្ឆន្តិ រថចរិយាសុ សិក្ខរេ ។
បរិហារិកសមា រាជ តេបិ វុច្ចន្តិ ព្រាហ្មណា
អញ្ញាតេ តេ មហារាជ តាទិសេ និបចាយសេ ។

១ ឱ. ព្រាហ្មញ្ញា ។



បពិត្រព្រះរាជា ឯព្រាហ្មណ៍ទាំងឡាយនោះ ស្មើដោយពេទ្យ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ទូលព្រះបង្គំជាខ្ញុំ បានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍ប្រាកដដូច្នោះឬ ។

(១៣៦) (ព្រះរាជាត្រាស់ថា...) ពួកព្រាហ្មណ៍ទាំងនោះ ច្រាសចាកភាពជាព្រាហ្មណ៍ ពួកព្រាហ្មណ៍ទាំងនោះ គេមិនហៅថា ព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទាន ដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៣៧) (វិធុរៈ...) ព្រាហ្មណ៍ទាំងឡាយនោះ កាន់ឃ្មោះទាំងឡាយ ហើយឃោសនាពីខាងមុខ (នៃស្តេចនិងអាចារ្យ) ក៏មាន ទៅកាន់ទីសម្រាប់បម្រើគេក៏មាន សិក្សាការសិល្បរថក៏មាន ។ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ស្មើដោយជនអ្នកបំរើ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

(១៣៤) អបេតា តេ ច ព្រាហ្មញ្ញា (ឥតិ ភគវា ឯតទវោច)

ន តេ វុច្ចន្តិ ព្រាហ្មណា

អញ្ញេ វិជ្ជេ បរិយេស សីលវន្តេ ពហុស្សុតេ
វិរតេ មេថុនា ធម្មា យេ តេ ភុញ្ជេយ្យ ភោជនំ
ទក្ខិណំ សម្មទស្សាម យត្ថ ទិន្នំ មហប្ផលំ ។

(១៣៥) កមណ្ឌលុំ គហេត្វាន វង្កទណ្ឌញ្ច ព្រាហ្មណា
បច្ចុបេស្សន្តិ រាជានោ គាមេសុ និគមេសុ ច
នាទិន្នេ វុដ្ឋហេស្សាម គាមម្ហិ និគមម្ហិ វា
និគ្គាហកសមា ហេតេ តេបិ វុច្ចន្តិ ព្រាហ្មណា
អក្ខាតា តេ មហារាជ តាទិសេ និបតាមសេ ។

(១៣៦) អបេតា តេ ច ព្រាហ្មញ្ញា (ឥតិ ភគវា ឯតទវោច)

ន តេ វុច្ចន្តិ ព្រាហ្មណា



(១៣៤) (ព្រះរាជាត្រាស់...) ព្រាហ្មណ៍ទាំងឡាយនោះប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៣៥) (វិធុរៈ...) ព្រាហ្មណ៍ទាំងឡាយ កាន់ឃ្នោកដាក់ទឹកផង ដំបងក្ងកផង ចូលទៅអែបអប នឹងស្តេចទាំងឡាយ ក្នុងស្រុកក្តីនិគម (ដោយគិតថា) កាលបើគេមិនឲ្យ (វត្ថុអ្វីមួយ) ក្នុងស្រុក ឬនិគម យើងនឹងមិនក្រោកឡើយ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយបុគ្គលអ្នកយកពន្ធ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងនេះ) ខ្ញុំព្រះអង្គបានក្រាបបង្គំទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ ។

(១៣៦) (ព្រះរាជាត្រាស់...) ព្រាហ្មណ៍ទាំងឡាយនោះប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ

អញ្ញេ វិធុរ បរិយេស សីលវន្តេ ពហុស្សុតេ

វិរតេ មេថុនា ធម្មា យេ មេ ភុញ្ជេយ្យុ ភោជនំ

ទក្ខិណំ សម្មទស្សាម យត្ថ ទិន្នំ មហប្ផលំ ។

(១៣៧) ទីឃកេសនខលោមា បង្កទន្តា រជស្សិរា

ឱកិណ្ណា រជរេណូហិ យាចកា វិចរន្តិ តេ

ខាណុឃាតសមា រាជ តេបិ វុច្ចន្តិ ព្រាហ្មណា

អក្ខាតា តេ មហារាជ តាទិសេ និមន្តយាមសេ ។

(១៣៨) អបេតា តេ ច ព្រហ្មញ្ញា (ឥតិ រាជា កោរព្យោ)

ន តេ វុច្ចន្តិ ព្រាហ្មណា

អញ្ញេ វិធុរ បរិយេស សីលវន្តេ ពហុស្សុតេ

វិរតេ មេថុនា ធម្មា យេ មេ ភុញ្ជេយ្យុ ភោជនំ



ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណា-ទាន (ចំពោះបុគ្គលនោះ) ។

(១៣៧) (វិធុរៈ...) ព្រាហ្មណ៍ទាំងឡាយនោះ មានរោមក្លៀកនិងក្រចកដុះវែង មានធ្មេញប្រកបដោយមន្ទិល មានធូលីលើក្បាល រោយរាយដោយធូលីនិងលំអងដី ត្រាច់ទៅសូម (ទ្រព្យផ្សេងៗ) បពិត្រព្រះករុណា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយជនអ្នកជីកគល់ដង្កត់ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍ដែលប្រសើរជាងទៀត ។

(១៣៨) (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគ ភោជនរបស់យើង

ទក្ខិណំ សម្ម ទស្សាម យត្ថ ទិន្នំ មហប្ផលំ ។

[១៣៩] ហរីតកំ អាមលកំ អម្ពំ ជម្ពុំ វិភីតកំ

លពុជំ ទន្តបោណានិ បេលុវា ពទរានិ ច

រាជាយតនំ ឧច្ឆុពុដំ ធូមនេត្តំ មធុអញ្ជនំ

ឧច្ចាវចានិ បណិយានិ(១) វិក្កិណន្តិ ជនាធិប

វណិជកសមា រាជ តេបិ វុច្ចន្តិ ព្រាហ្មណា

អក្ខាតា តេ មហារាជ តាទិសេ និបតាមសេ ។

[១៤០] អបេតា តេ ច ព្រហ្មញ្ញា (ឥតិ រាជា កោរព្យោ)

ន តេ វុច្ចន្តិ ព្រាហ្មណា

អញ្ញេ វិធុរ បរិយេស សីលវន្តេ ពហុស្សុតេ

វិរតេ មេថុនា ធម្មា យេ មេ ភុញ្ជេយ្យុ ភោជនំ

ទក្ខិណំ សម្ម ទស្សាម យត្ថ ទិន្នំ មហប្ផលំ ។

១ ម. បណីតានិ ។



ម្នាលសំឡាញ់ ទក្ខិណាទាន ដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៣៩) (វិធុរៈ...) បពិត្រព្រះបាទអធិបតី (ព្រាហ្មណ៍ចាំទីឡាយ) ជួញសម៉ផង កន្ទួតព្រៃផង ស្វាយផង ព្រីងផង សម៉ាក់ភេកផង ខ្នុរសម្ពុផង ឈើស្ទន់ផង ព្នៅផង ពុទ្រាផង ឈើកែសផង ទឹកអំពៅនិងស្ករអំពៅផង ទៀនផង ទឹកឃ្មុំនិងថ្នាំបន្តក់ភ្នែកផង ជួញលក្ខណៈមានតម្លៃថោកថ្លៃច្រើនផង បពិត្រព្រះរាជា ព្រាហ្មណ៍ចាំទីឡាយនោះ ប្រាកដស្មើដោយពាណិជ លោកហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ចាំទីឡាយនោះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះ ។

(១៤០) (ព្រះរាជាកោរព្យៈ) ព្រាហ្មណ៍ចាំទីឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ ពួកព្រាហ្មណ៍ចាំទីឡាយនោះ គេមិនហៅថា ព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ចាំទីឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទាន ដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៦១) កសិវណិជ្ជំ ការេន្តិ    បោសយន្តិ អជេឡកេ

កុមារិយោ បវេច្ឆន្តិ    វិវាហន្តិ វហន្តិ ច

សមា អម្ពដ្ឋវេស្សេហិ    តេបិ វុច្ចន្តិ ព្រាហ្មណា

អក្ខាតា តេ មហារាជ    តាទិសេ និមន្តយាមសេ ។

(១៦២) អបេតា តេ ច ព្រាហ្មញ្ញា (ឥតិ រាជា កោរព្យោ)

ន តេ វុច្ចន្តិ ព្រាហ្មណា

អញ្ញេ វិធុរ បរិយេស    សីលវន្តេ ពហុស្សុតេ

វិរតេ មេថុនា ធម្មា    យេ មេ ភុញ្ជេយ្យុ ភោជនំ

ទក្ខិណំ សម្បទស្សាម    យត្ថ ទិន្នំ មហប្ផលំ ។

(១៦៣) និក្ខិត្តភិក្ខំ ភុញ្ជន្តិ    គាមេស្វេកេ បុរោហិតា

ពហូ តេ បរិបុច្ឆន្តិ    អណ្ឌច្ឆេទា និលញ្ឆកា

បសូបិ តត្ថ ហញ្ញន្តិ    មហឹសា សូករា អជា



(១៦១) (វិធុរៈ...) (ព្រាហ្មណ៍ទាំងឡាយ) តែងធ្វើនូវកសិកម្មនិងពាណិជ្ជ-កម្មផង ចិញ្ចឹមពពែនិងចៀមផង ទំនុកបម្រុងកូនក្រមុំផង រៀបចំអាពាហ៍ពិពាហ៍ផង ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយកុដុម្ពិកៈនិងវេស្សៈ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលថ្វាយព្រះអង្គហើយ យើងនឹងនិមន្តហៅពួកព្រាហ្មណ៍បែបនេះបានឬ ។

(១៦២) (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្មដែលគប្បីបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៦៣) (វិធុរៈ...) មានព្រាហ្មណ៍ពួកខ្លះ ជាបុរោហិត (បរិភោគនូវភិក្ខាដែលគេតម្កល់ទុកឲ្យខ្លួន) ពួកជនច្រើនគ្នា តែងសាកសួរព្រាហ្មណ៍នោះ ព្រាហ្មណ៍ទាំងនោះជាអ្នកក្រៀវគោ (គោជាមេ) ផង ជាគ្រូសាក់ផង សម្លាប់សត្វចិញ្ចឹមគឺក្របីជ្រូកនិងពពែផង ក្នុងស្រុកនោះ

គោឃាតកសមា រាជ តេបិ វុច្ចន្តិ ព្រាហ្មណា

អក្ខាតា តេ មហារាជ តាទិសេ និបតាមសេ ។

(១៦៦) អបេតា តេ ច ព្រាហ្មញ្ញា (ឥតិ ភណតិ កោរព្យោ)

ន តេ វុច្ចន្តិ ព្រាហ្មណា

អញ្ញេ វិទូ បរិយេស សីលវន្តេ ពហុស្សុតេ

វិរតេ មេថុនា ធម្មា យេ មេ ភុញ្ជេយ្យុំ ភោជនំ

ទក្ខិណំ សម្ម ទស្សាម យត្ថ ទិន្នំ មហប្ផលំ

(១៦៧) អសិចម្មំ គហេត្វាន ខគ្គំ បគ្គយ្ហ ព្រាហ្មណា

វេស្សបថេសុ តិដ្ឋន្តិ សត្ថំ អព្ពាហយន្តិ តេ

សមា គោបនិសាទេហិ តេបិ វុច្ចន្តិ ព្រាហ្មណា

អក្ខាតា តេ មហារាជ តាទិសេ និបតាមសេ ។



បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ព្រោះថាស្មើដោយបុគ្គលអ្នកសម្លាប់គោ នោះហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនោះ) ខ្ញុំព្រះអង្គបានក្រាបទូល ចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍ដទៃផ្សេងទៀត ។

(១៦៦) (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ព្រោះឃ្លាតចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃទៀត ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទាន ដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៦៧) (វិធុរៈ...) ព្រាហ្មណ៍ទាំងឡាយកាន់ដាវនិងខែល កាន់ព្រួញ ឈរនៅតាមផ្លូវធំ ជាទីទៅនៃពួកឈ្មួញ ចាំការពារឈ្មួញឲ្យផុត (អំពីពួកចោរ) ព្រាហ្មណ៍ទាំងឡាយនោះ ព្រោះថាស្មើដោយពួកអ្នកគង្វាលគោនិងពួកអ្នកនេសាទ នោះហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនោះ) ខ្ញុំព្រះអង្គក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍ដទៃផ្សេងទៀត ។

(១៤៦) អបេតា តេ ច ព្រាហ្មញ្ញា (ន់ក កថា ធ សោករតេ្យ)

ន តេ វុទ្ធិ ព្រាហ្មណា ।

អញ្ញេ វិជ្ជា ចរិយេស សីលវន្តា ពហុស្សុតា

វិនេ មេធុនា ធម្មា យេ តេ កុញ្ជយ្យុ គោធនំ

ឧក្កំណំ សត្ត ឧស្សន្ត យត្ថ ធិន្និ មនាប្ចលំ ។

(១៤៧) អញ្ញេ កុជំកំ ភត្តា ក្ខជាធិ តាយន្តិ តេ

សសវិត្យេ តាមេន្តិ អកោតា ឧបូតន្ចំ

តេ លុទ្ធកាសមា ភជ តេបំ វុទ្ធិ ព្រាហ្មណា

អត្ថា តា តេ ឧហាកជ តាធំសេ ធិបតានសេ ។

(១៤៨) អបេតា តេ ច ព្រាហ្មញ្ញា (ន់ក កថា ធ សោករតេ្យ)

ន តេ វុទ្ធិ ព្រាហ្មណា

អញ្ញេ វិជ្ជា ចរិយេស សីលវន្តា ពហុស្សុតា

វិនេ មេធុនា ធម្មា យេ តេ កុញ្ជយ្យុ គោធនំ



(១៤៦) (ព្រាហ្មណ៍ការក្ស...) ព្រាហ្មណ៍ចាស់ៗទាំងនោះ ប្រាសចាក ការជាព្រាហ្មណ៍ តែព្រាហ្មណ៍ចាស់ៗទាំងនោះ គេមិនហៅថា ព្រាហ្មណ៍ទេ ម្នាលវិទូរ៖ អ្នកចូរស្ទើរព្រាហ្មណ៍ចាស់ៗទាំងនោះវិញ ដែលជាអ្នកមានសីល ជាពហុស្សូត រៀនចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទាន ដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៤៧) (វិទូរ...) ព្រាហ្មណ៍ចាស់ៗទាំងនោះ (ធ្វើខ្លួនកោងក្រ ធ្វើ អន្ទាក់ក្តែចាស់ៗ យៀតយៀននូវខ្សែយក់ទ្រព្យច្រើន នូវខ្សែ ច្រើនជាណ្តើកផង បរិត្រៀរកថា ព្រាហ្មណ៍ចាស់ៗទាំងនោះប្រាកដ ស្មើដោយព្រានព្រៃ ព្រាហ្មណ៍ចាស់ទាំងនោះ គេហៅថា ព្រាហ្មណ៍ដែរ បរិត្រមហាកជ (ព្រាហ្មណ៍ចាស់នោះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះ ព្រះអង្គហើយ យើងនឹងចូលទៅស្ទើរព្រាហ្មណ៍បែបនេះ ។

(១៤៨) (ព្រាហ្មណ៍ការក្ស . . .) ព្រាហ្មណ៍ចាស់ៗទាំងនោះ ប្រាស ចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ចាស់ៗទាំងនោះ គេមិន ហៅថា ព្រាហ្មណ៍ទេ ម្នាលវិទូរ៖ អ្នកចូរស្ទើរពួក ព្រាហ្មណ៍ចាស់ៗ ជាទៅវិញ ដែលជាអ្នកមានសីល ជា ពហុស្សូត រៀនចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង

ឧក្កិណ្ណំ សព្វ ឧស្សាប យត្ត ធំដុំ មហាពលំ ។

(១៦៩) អញ្ញេ ឧបស្សេ ការាមាហំ ហេដ្ឋា មញ្ចេ បសក្កិតា

កដាហោ ទុព្វាំ ក្លាយន្តិ សោវយាកេ ទុបដ្ឋិកេ

មលបដ្ឋសហេ កដ តេបំ វុទ្ធិ ព្រាហ្មណា

អក្ខាតា តេ ឋហាកដ តាធិសេ ធិបាតមសេ ។

(១៧០) អបេតា តេ ឥ ព្រាហ្មញ្ញា ផេតិ កដា ឥ (តោទតេស្សា)

ឧ តេ វុទ្ធិ ព្រាហ្មណា

អញ្ញ វិទ្ធុ ចក់យស សីលវន្តេ ពហុស្សុតេ

វិរតេ មេថុនា ធម្មា យោ មេ កុតេក្ខយស្ស កោជនំ

ឧក្កិណ្ណំ សព្វ ឧស្សាប យត្ត ធិទ្ធិ មហាពលំ ។



ម្នាលសំឡាញ់ ទក្ខិណាទានដែលយើងឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

(១៦៩) (វិទ្ធុ...) ព្រាហ្មណ៍ទាំងឡាយដទៃទៀត មិនបានត្រេកអរ ក៏ដេកទាំងក្រោមគ្រែ កាលគេលោមយានព្រាហ្មណ៍ហើយ ស្តេចទាំងឡាយក៏ស្រេកទឹកព្រមទាំងសើទៀត បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ព្រាហ្មណ៍ស្មើដោយដំណើរចុះអំពីល្អ គេហៅថា ព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនោះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងដូចជាសេកនូវព្រាហ្មណ៍ព្រាហ្មណ៍ផ្ទុយទៅ ។

(១៧០) (ព្រះរាជាពោលថា...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកការជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយ ដទៃទៀតដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ) ។

---

* [illegible] ។

(១៨១) អត្ថិ ខោ ព្រាហ្មណា លោកេ សីលវន្តោ ពហុស្សុតា
វិរតា មេថុនា ធម្មា យេ តេ ភុញ្ជេយ្យុ ភោជនំ។
ឯកញ្ច ភត្តំ ភុញ្ជន្តិ ន ច មជ្ជំ បិវន្តិ តេ
អក្ខាតា តេ មហារាជ តាទិសេ និមន្តយាមសេ។

(១៨២) ឯតេ ខោ ព្រាហ្មណា វិធុរ សីលវន្តោ ពហុស្សុតា
ឯតេ វិធុរ បរិយេស ខិប្បញ្ច នេ និមន្តយាហិ។

ទសព្រាហ្មណជាតកំ ទុតិយំ ។

## ភិក្ខាបរម្បរជាតកំ

(១៨៣) សុខុមាលរូបំ ទិស្វា រដ្ឋា វិវនមាគតំ
កូដាគារវរូបេតំ មហាសយនមុបោចិតំ[១]
តស្ស តេ បេមកេនាហំ អទាសិំ វឌ្ឍមោទនំ
សាលីនំ វិចិតំ ភត្តំ សុចិមំសូបសេចនំ

១ មហាសយនមុបាសិតន្តិបិ ។



(១៨១) (វិធុរ..) បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម គួរនឹងបរិភោគភោជនរបស់ព្រះអង្គ មានដែរ ។ ព្រាហ្មណ៍ទាំងនោះ បរិភោគនូវភត្តតែម្តង ទាំងមិនផឹកនូវទឹកស្រវឹង បពិត្រមហារាជ (ពួកព្រាហ្មណ៍នេះ) ខ្ញុំព្រះអង្គបានក្រាបទូលព្រះអង្គហើយ យើងនឹងចូលទៅនិមន្តពួកព្រាហ្មណ៍ប្រាកដដូច្នោះ ។

(១៨២) (ព្រះរាជា...) ម្នាលវិធុរៈ ពួកព្រាហ្មណ៍ទាំងនេះ ជាអ្នកមានសីល ជាពហុស្សូតពិតមែន ម្នាលវិធុរៈ អ្នកចូរស្វែងរកពួកព្រាហ្មណ៍ទាំងនុ៎ះ ចូរនិមន្តព្រាហ្មណ៍ទាំងនោះមកឆាប់ៗ ។

ចប់ ទសព្រាហ្មណជាតក ទី២ ។

## ភិក្ខាបរម្បរជាតក

(១៨៣) (កុដុម្ពិកៈទូលថា) ខ្ញុំព្រះអង្គបានឃើញព្រះអង្គ មានព្រះរូបទន់ភ្លន់ ចេញចាកដែនមកកាន់ព្រៃស្ងាត់ ប្រកបដោយផ្ទះកំពូលដ៏ប្រសើរ មានសយនៈដ៏ធំ ដែលគេក្រាលបំរុងទុក ទើបថ្វាយព្រះយាស្ងោយ ដ៏ឧត្តម ជាភត្តនៃស្រូវសាលី ដ៏វិចិត្រ លាយដោយសាច់ដ៏ស្អាត ចំពោះព្រះអង្គនោះ ដោយសេចក្តីស្រឡាញ់

កឹ ត្វំ ភត្តំ បដិគ្គយ្ហ ព្រាហ្មណស្ស អទាបយិ

អត្តានំ អនសិត្វាន កោយំ ធម្មោ នុ តេ ភវំ

(១៨៤)អាចរិយោ ព្រាហ្មណោ មយ្ហំ កិច្ចាកិច្ចេសុ ព្យាវដោ

គរុ ច អាមន្តនីយោ ច ទាតុមរហាមិ ភោជនំ ។

(១៨៥)ព្រាហ្មណំ ជាតិ បុច្ឆាមិ គោតមំ រាជបូជិតំ

រាជា តេ ភត្តំ បាទាសិ សុចិំ មំសូបសេចនំ

កឹ ត្វំ ភត្តំ បដិគ្គយ្ហ ឥសិស្ស ភោជនំ អទា

អចេត្តញ្ញាសិ ធនស្ស កោយំ ធម្មោ នុ តេ ភវំ

(១៨៦)ភរាមិ បុត្តទារេ ច ឃរេសុ គធិតោ អហំ

ភុញ្ជេ មានុសកេ កាមេ អនុសាសាមិ រាជិនោ

អារញ្ញិកស្ស ឥសិនោ ចិររត្តំ តបស្សិនោ

វុឌ្ឍស្ស ភាវិតត្តស្ស ទាតុមរហាមិ ភោជនំ ។



ព្រះអង្គទទួលព្រះក្រយាស្ងោយនោះហើយ តែមិនសោយដោយព្រះ
អង្គឯង ត្រឡប់ជាប្រទានដល់ព្រាហ្មណ៍វិញ សូមក្រាបថ្វាយបង្គំ
ចំពោះព្រះអង្គ តើការណ៍នេះជាសភាពដូចម្តេច ។

(១៨៤) (ព្រះរាជាត្រាស់ថា) ព្រាហ្មណ៍(នេះ) ជាអាចារ្យរបស់យើង
ជាអ្នកខ្វល់ខ្វាយ ក្នុងកិច្ចគួរនិងកិច្ចមិនគួរផង ជាបុគ្គលគួរគោរពផង
គួរឲ្យយើងនិយាយរកផង (ព្រោះហេតុនោះ) យើងគួរឲ្យភោជន ។

(១៨៥) (កុម្ភីរ...) សួរថា ខ្ញុំសូមសួរព្រាហ្មណ៍ ជាគោតមគោត្ត
ដែលព្រះរាជាបូជា ព្រះរាជាបានប្រទានភត្ត ដែលលាយដោយ
សាច់ដ៏ស្អាតដល់អ្នក អ្នកបានទទួលភត្តនោះហើយ ក៏បានប្រោះអោយ
ភោជនដល់ឥសីវិញ អ្នកប្រព្រឹត្តជាវិធីថា ខ្ញុំមិនមែនជាទទួលនៃ
ចាន ខ្ញុំសូមថ្វាយបង្គំចំពោះអ្នក តើការណ៍នេះជាសភាពដូចម្តេច ។

(១៨៦) (ព្រាហ្មណ៍តបថា) ខ្ញុំតែងចិញ្ចឹមកូននិងប្រពន្ធផង ជំពាក់
ចិត្តក្នុងផ្ទះទាំងឡាយផង ប្រៀនប្រដៅព្រះរាជា សូមព្រះអង្គ
សោយកាមគុណទាំងឡាយ ជារបស់នៃមនុស្សផង ព្រោះហេតុនោះ
បានជាខ្ញុំគួរប្រោះភោជនដល់ឥសីវិញ ដែលនៅក្នុងព្រៃ មាន
តបៈអស់កាលវែង ចំរើនដោយគុណ មានចិត្តចំរើនហើយ ។

[១៥៧] ឥសិញ្ចជាតំ កុដ្ឋាប់ ករិសិ ជមមិសន្តំ
បទុម្មុត្តរូបមលោកេ ចក្ខុមំ វជស្សិរី
ឋលោ សុគ្ធាវិហរសិ ចារិកំ សិ ជីវិតំ
កិញ្ចុ កេន ឥយា សេវ្យា យស្ស ទិំ កោជធំ អតោ ។

[១៥៨] ទណាមាលុកោសត្ថំ តិណាលិតក្កណធំ ច
ធុំ សាមាកតិកិ សំហារិយំ បហារិយំ
សាកំ កិសំ ធទុំ មិសំ គន្ធនលកានំ ច
ធានំ អាហាន្ត[១] កុច្ឆាមំ អគ្គិ ទេសោ បវិត្តោ
បបេត្វា អបប្ផស្ស អមមស្ស សកិញ្ចនោ
អលាលាស្ស សាធាលោ ជាតុមហាម៉ កោជធំ ។

[១៥៩] កិញ្ចុញ្ចឋានំ ចុដ្ឋាម៉ កុណ្ឌិមាសីព សន្តំ
ឥតិ តេ កគ្គិ ធាតសំ សុក្ខិសូបសេចធំ
កំ ទុំ កត្តំ បដិគ្គហ្ម កុណ្ឌិ កុញ្ចសំ ឋិកកោ
ជាញ្ញំ កាញ្ជិ ចិមាទ្ទសំ កោយំ ធម្មៈ ជបត្តុតោ ។

១ ម. អាហុ ។ ឆ អាហរិត្វា ។





(១៥៧) (កុដ្ឋិក:...) សព្វិតេន ខ្ញុំសូមសួរអ្នក ដែលសូមកើតមក ហើយបរិស បានកោមកៀកនឹងក្រុងត្រវ់វែង បានបញ្ញាប្រាកប ហើយមន្ទិល បានខ្ជះខ្ជាយក្តុល លោកនៅក្នុងព្រៃឆ្ងាក់ឯង មិនស្ដាយជីវិត លោកបានប្រាកបកាដជួលកិច្ចណា គឺគ្រឿង ប្រាសាទជាដីលោក ហើយគុណផ្ទូរម្ចូល ។

(១៥៨) (តាបសតបវ៉) គាត្ថាមឹកដំឡូងឈ្មោះកោលុកសម្ពះ និងកាលកន្ទះ តាំងឡាយផង ដំឡូងឈ្មោះតិលាល៉ និងតក្កល:តាំងឡាយផង ព្រួន ស្រស់ដីនីស្ពៅ (យកមក) ថែមទុក (ហំរការ) ផង នាំយកគ្រឿង អន្លក់និងក្រៅសារ៉េក ទឹកឃ្មុំ សាច់ ពក្រាតីដែកត្តួល់ព្រៃ មកប៉ះការ ផង រោះជាកំណាត់របស់គាត្ថា គាត្ថាបុគ្គលដ៏សុ មានសេចក្តី ខ្វល់ខ្វាយ មានសេចក្តីប្រកាន់នៅឡើយ ត្រូវប្រាកនរកាដនដល់កិច្ច ដែលជាអ្នកមិនដ៏សុ មិនមានកណ្ដា មិនមានសេចក្តីប្រកាន់ ។

(១៥៩) (កុដ្ឋិក:...) សព្វិតេន ខ្ញុំសូមសួរកិច្ចដែលអង្គុយសៀមមានក្តុល ផ្ទូតរោទាំងនេះ (ផង) បានប្រាកនកង្គដែលលាយអោយសាច់ដីស្គាន ដល់លោក លោកខ្ជលក្តរគារហើយ គឺហាំការសៀមម្នាក់ ឯង មិនបានអញ្ជើញបុគ្គលដទៃណាមួយ (ឡូហំរការផង) ទៀយ ខ្ញុំសូមប្រាយបន្ទិចការលោក តើការណ៍នេះជាសកាក់ជួរម្ចូល ។

[១៦១] ន បចាមិ ន បាចេមិ  ន ឆិន្ទាមិ ន ឆេទយេ

តំ មំ អកិញ្ចនំ ញត្វា  សព្វបាបេហិ អារតំ

វាមេន ភិក្ខមាទាយ  ទក្ខិណេន កមណ្ឌលុំ

ឥសិ មេ ភត្តំ អទាសិ  សុធិំ សប្បិបសេចនំ ។

ឋិតោ ហិ ធាតុបត្តម្ហិ  សមណោ សបរិគ្គហោ

បត្តិកាមហំ មញ្ញេ  យោ ទាតារំ និមន្តយេ ។

[១៦២] អត្ថាយ វត មេ អជ្ជ  ឥធាគច្ឆិ រថេសភោ

យោហំ អជ្ជ បជានាមិ  យត្ថ ទិន្នំ មហប្ផលំ ។

រជ្ជេសុ គិទ្ធា រាជានោ  កិច្ចាកិច្ចេសុ ព្រាហ្មណា

ឥសី មូលផលេ គិទ្ធា  វិប្បមុត្តា ច ភិក្ខវោ ។

ភិក្ខាបរម្បរជាតកំ តេរសមំ ។

---



[១៦១] (ព្រាហ្មណ៍ពោល ។) អាត្មាមិនដាំស្លខ្លួនឯង មិនប្រើឲ្យគេដាំស្ល មិនកាត់ខ្លួនឯង មិនប្រើគេឲ្យកាត់ ហេតុនោះ កុដុម្ពិកជាអធិបតីនៃដីជ្រាប អាត្មាថាជាអ្នកមិនមានសេចក្តីកង្វល់ ជាអ្នកប្រាសចាកបាបគ្រប់ចំពូក ទើបកាន់បាត្រដោយដៃឆ្វេង កាន់សព្វាភរណ៍ដោយដៃស្តាំ ហើយប្រគេនភត្តដែលលាយដោយសាច់ស្ពានោះដល់អាត្មា ។ អាត្មាគិតថា ជនទាំងឡាយ (មានស្តេចជាដើម) នុ៎ះ ជាអ្នកប្រកាន់ជារបស់អញ មានសេចក្តីតូចនៃហាង ត្រូវនិមន្ត (ដល់បុគ្គលប្រាកដស្មើដោយអាត្មា) បុគ្គលណា អញ្ជើញនូវអ្នកឲ្យទាន (មកបរិភោគ) អាត្មាសំគាល់ (នូវបុគ្គលនោះ) ថាជាអ្នកប្រតិបត្តិខុសចំពោះ ។

[១៦២] (កុដុម្ពិកៈ ។) ឥសីនៅថ្ងៃនេះ ព្រះករុណាព្រះអង្គប្រសើរលើរថ បានយាងមកកន្លែងនេះ ដើម្បីប្រយោជន៍ដល់ខ្ញុំមែនហើយ ព្រោះខ្ញុំបានដឹងច្បាស់ក្នុងថ្ងៃនេះថា ទានដែលគេឲ្យហើយ ចំពោះបុគ្គលណា ជាទានមានផលច្រើន ។ ស្តេចទាំងឡាយ ជាប់ចំពាក់ក្នុងផែនដី ពួកព្រាហ្មណ៍ ជាប់ចំពាក់ក្នុងកិច្ចតូចធំ ពួកឥសី ជាប់ចំពាក់ក្នុងមើមឈើ និងផ្លែឈើ ឯពួកភិក្ខុទើបរួចស្រឡះចាកកិលេស ។

ចប់ ភិក្ខាបរម្បរជាតក ទី១៣ ។

បកិណ្ណកនិបាតសង្ខេប ឧទ្ទានំ

## តស្សុទ្ទានំ

សុរំ កណ្ឌរមុត្តា ទកផិតសោ

កិសជាត មហេសិ កាលោកាកេ

អដ្ឋ ហោរ សកដ្ឋក កណាិដគោ

វេឡុ កដ សព្រាហ្មណា កិច្ចុបរំ ។

បកិណ្ណកនិបាតំ និដ្ឋិតំ ។

---

បកិណ្ណកនិបាត ឧទ្ទាន

## ឧទ្ទាននៃបកិណ្ណកនិបាតនោះគឺ

និយាយអំពីសេក ១ កិន្នរ ១ គប់ភ្លើង ១ ផងិលផណ្ដប់

ស្បែកខ្លាឃ្មុំចាំផ្គ្រាបក ១ ក្រសៅឈ្មួក ១ ឥន្ទមហាសិ ១

ព្រាបដីប្រសើរ ១ ក្ងោក ១ ជ្រូកឈ្មោះតុណ្ឌកៈ ១ ពាណិជ ១

សាតិនកជ ១ ព្រាហ្មណ៍ ១ ចក្ខុនិងត្រចៀក ១ ។

ចប់ បកិណ្ណកនិបាត ។

## វីសតិនិបាតជាតកំ

### មាតង្គជាតកំ

(១៦២) កុតោ នុ អាគច្ឆសិ ទុម្មវាសី
ឱតល្លកោ បំសុបិសាចកោវ
សង្ការចោឡំ បដិមុញ្ច កណ្ឋេ
កោ រេ តុវំ ហោសិ អទក្ខិណេយ្យោ ។

(១៦៣) អន្នំ តវេទំ បកតំ យសស្សិ[១]
តំ ខជ្ជរេ ភុញ្ជរេ បិយ្យរេ ច
ជានាសិ មំ ត្វំ បរទត្តូបជីវឹ
ឧត្តិដ្ឋបិណ្ឌំ លភតំ សបាកោ ។

(១៦៤) អន្នំ មមយិទំ បកតំ ព្រាហ្មណានំ
អត្ថត្ថាយ សទ្ធហតោ មមយិទំ
អបេហិ ឯត្តោ កិមិធដ្ឋិតោសិ
ន មាទិសា តុយ្ហំ ទទន្តិ ជម្ម ។

---
១ ម. យសស្សី ។



## វីសតិនិបាតជាតក

### មាតង្គជាតក

(១៦២) (មណ្ឌព្យកុមារសួរថា) អ្នកមកអំពីទីណា បានជាមាន
ប្រដាប់ស្លៀកដណ្តប់សៅហ្មង ល្មោក ដូចជាបិសាចលើគំនរដី
ពាក់ឆ្នូតកំណាត់សំពត់ ដែលគេបោះចោលលើគំនរសម្រាមព្យួរក
ខ្លួនអ្នកជាបុគ្គលផ្លូសផ្លាស មិនមែនជាទក្ខិណេយ្យបុគ្គលទេ ។

(១៦៣) (មាតង្គមហាសត្វឆ្លើយថា) គ្រឿងបរិភោគនេះបរិបូណ៌ដោយ
យស អ្នកបានតាក់តែងហើយ ពួកជនតែងទំពាស៊ី បរិភោគ
នឹងផឹកគ្រឿងបរិភោគនោះ អ្នកស្គាល់ហើយនូវយើងថាជាអ្នក
ចិញ្ចឹមជីវិតដោយអាហារដែលគេឲ្យ សូមឲ្យមនុស្សចណ្ឌាល
បាននូវដុំបាយដែលបុគ្គលគប្បីទៅឈរជិត ។

(១៦៤) (មណ្ឌព្យកុមារ...) គ្រឿងបរិភោគនេះ ខ្ញុំបានតាក់តែង
បម្រើពួកព្រាហ្មណ៍ នេះជាគ្រឿងរបស់ខ្ញុំដែលខ្ញុំជឿចំពោះ
សេចក្តីចំរើនរបស់ខ្លួន អ្នកចូរចៀសចេញអំពីទីនេះ អ្នកមក
ឋិតនៅ ក្នុងទីនេះធ្វើអ្វី ម្នាលបុគ្គលកំណាច បុគ្គល
ទាំងឡាយប្រហែលយើង មិនឲ្យគ្រឿងបរិភោគដល់អ្នកទេ ។

(១២៥) ថលេ ច និន្នេ វបន្តិ ពីជំ
អនូបខេត្តេ ផលមាសីសមានា
ឯតាយ សទ្ធាយ ទទាហិ ទានំ
អប្បេវ អារាធយេ ទក្ខិណេយ្យេ ។

(១២៦) ខេត្តានិ មយ្ហំ វិទិតានិ លោកេ
យេសាហំ ពីជានិ បតិដ្ឋបេមិ
យេ ព្រាហ្មណា ជាតិមន្តូបបន្នា
តានីធ ខេត្តានិ សុបេសលានិ ។

(១២៧) ជាតិមទោ ច អតិមានិតា ច
លោភោ ច ទោសោ ច មទោ ច មោហោ
ឯតេ អគុណា យេសុ ច សន្តិ សព្វេ
តានីធ ខេត្តានិ អបេសលានិ ។
ជាតិមទោ ច អតិមានិតា ច
លោភោ ច ទោសោ ច មទោ ច មោហោ
ឯតេ អគុណា យេសុ ន សន្តិ សព្វេ
តានីធ ខេត្តានិ សុបេសលានិ ។



(១២៥) (ព្រះមហាសត្វ...) ពួកអ្នកប្រាថ្នាផលស្រូវ តែងព្រោះព្រួស ក្នុងទីទួលឬទីទំនាប និងទីវាលមិនមែនជាស្រែ អ្នកចូរឲ្យទានដោយសទ្ធាបែបនេះចុះ សូមអ្នកញ៉ាំងទក្ខិណេយ្យបុគ្គលឲ្យត្រេកអរផង ។

(១២៦) (មណ្ឌព្យកុមារ...) យើងព្រោះព្រួសទាំងឡាយក្នុងស្រែណា ស្រែទាំងនោះក្នុងលោក យើងស្គាល់ច្បាស់ ពួកព្រាហ្មណ៍ណា ជាអ្នកប្រកបដោយជាតិនិងមន្ត ពួកព្រាហ្មណ៍ទាំងនោះ មានសីលជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះ ។

(១២៧) (មហាសត្វ...) សេចក្តីស្រវឹងព្រោះជាតិ ១ ភាពជាបុគ្គលមើលងាយអ្នក ១ លោភៈ ១ ទោសៈ ១ សេចក្តីស្រវឹង ១ មោហៈ ១ ទោសទាំងអស់នេះ មានទៅក្នុងបុគ្គលណា បុគ្គលក្នុងនោះ មិនមែនជាអ្នកមានសីលជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះឡើយ ។ សេចក្តីស្រវឹងព្រោះជាតិ ១ ភាពជាបុគ្គលមើលងាយអ្នក ១ លោភៈ ១ ទោសៈ ១ សេចក្តីស្រវឹង ១ មោហៈ ១ ទោសទាំងអស់នេះ មិនមានក្នុងបុគ្គលណា បុគ្គលក្នុងនោះ ទើបឈ្មោះថាមានសីលជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះ ។

(១៦៨) កុត្ថ គតា ឧបជោតិយោ ច
ឧបជ្ឈាយោ អថ វា គណ្ឌកុច្ឆិ
ឥមស្ស ទណ្ឌញ្ច វធញ្ច ទត្វា
គលេ គហេត្វា ខលយាថ[១] ជម្មំ ។

(១៦៩) គិរឹ នខេន ខណសិ អយោ ទន្តេហិ ខាទសិ
ជាតវេទំ បទហសិ យោ ឥសឹ បរិភាសសិ ។

(១៧០) ឥទំ វត្វាន មាតង្គោ ឥសិ សច្ចបរក្កមោ
អន្តលិក្ខស្មឹ បក្កាមិ ព្រាហ្មណានំ ឧទិក្ខតំ ។

(១៧១) អាវេឋិតំ បិដ្ឋិតោ ឧត្តមង្គំ
ពាហុំ បសារេតិ អកម្មនេយ្យំ
សេតានិ អក្ខីនិ យថា មតស្ស
កោ មេ ឥមំ បុត្តមកាសិ ឯវំ ។

(១៧២) ឥធាគមា សមណោ ទុម្មវាសី
ឱតល្លកោ បំសុបិសាចកោវ
សង្ការចោឡំ បដិមុញ្ច កណ្ឋេ
សោ តេ ឥមំ បុត្តមកាសិ ឯវំ ។

១– ម. ខលយាថ ។





(១៦៨) (មណ្ឌព្យកុមារ...) (ឆ្មាំទ្វារពាក់) ឈ្មោះឧបជោតិយៈ១ ឈ្មោះឧបជ្ឈាយៈ១ ឈ្មោះគណ្ឌកុច្ឆិ១ ទៅក្នុងទីណា អ្នកទាំងឡាយចូរឲ្យសម្លាប់នូវមនុស្សលាមកនេះ ហើយចាប់ច្របិតក ចូរនាំចេញទៅ ។

(១៦៩) (មហាសត្វ...) អ្នកណាជេរប្រទេចនូវឥសី អ្នកនោះឈ្មោះថាជីកភ្នំដោយក្រចក ឈ្មោះថាខាំទំពាដែកដោយធ្មេញ ឈ្មោះថាក្សាយោមលេបភ្លើង ។

(១៧០) (អភិសម្ពុទ្ធគាថា) ឥសីឈ្មោះមាតង្គៈ ជាអ្នកមានសេចក្តីព្យាយាមទៀងត្រង់ លុះពោលពាក្យនេះហើយក៏ចេញទៅក្នុងអាកាស ចំពោះមុខពួកព្រាហ្មណ៍កំពុងក្រឡេកមើល ។

(១៧១) (នាងទិដ្ឋមង្គលិកាពោលថា) ក្បាល (របស់កូនអញ) ល្មួលទៅខាងក្រោយ ដើមដៃណាតចេញទៅមិនគួរដល់ការងារ ភ្នែកទាំងឡាយសដូចជាបុគ្គលស្លាប់ អ្នកណាធ្វើកូនអញនេះ ឲ្យទៅជាយ៉ាងនេះ ។

(១៧២) (ពួកមាណពពោលថា) មានសមណៈ (មួយរូប) មកក្នុងទីនេះ មានប្រដាប់ស្លៀកពាក់អាក្រក់ ណាមក ដូចជាបិសាចពាលី កាចម៉ី ពាក់នៅកនូវកំណាត់សំពត់ ដែលគេបោះចោលលើគំនរសម្រាម ព្រឹក សមណៈនោះបានធ្វើកូនរបស់នាងនេះ ឲ្យយ៉ាងនេះ ។

(១៧៣) កតមំ ទិសំ អគមា ភូរិបញ្ញោ
អក្ខាថ មេ ព្រាហ្មណា ឯតមត្ថំ
គន្ត្វាន តំ បដិករេមុ អច្ចយំ
អប្បេវ នំ បុត្ត លភេមុ ជីវិតំ ។

(១៧៤) វេហាយសំ អគមា ភូរិបញ្ញោ
បថទ្ធុនោ បណ្ណរសេវ ចន្ទោ
អបិចាបិ សោ បុរិមំ ទិសំ អគច្ឆិ
សច្ចប្បដិញ្ញោ ឥសិ សាធុរូបោ ។

(១៧៥) អាវេឡិតំ បិដ្ឋិតោ ឧត្តមង្គំ
ពាហុំ បសារេតិ អកម្មនេយ្យំ
សេតានិ អក្ខីនិ យថា មតស្ស
កោ មេ ឥមំ បុត្តមកាសិ ឯវំ ។

(១៧៦) យក្ខា ហវេ សន្តិ មហានុភាវា
អន្វាគតា ឥសយោ សាធុរូបា
តេ ទុដ្ឋចិត្តំ កុបិតំ វិទិត្វា
យក្ខា ហិ តេ បុត្តមកាសុ ឯវំ ។





(១៧៣) (នាងទិដ្ឋមង្គលិកា .) សមណៈមានប្រាជ្ញាក្រាស់ ដូចផែនដីនោះ ទៅកាន់ទិសដូចម្តេច ម្នាលព្រាហ្មណ៍ទាំងឡាយ អ្នកទាំងឡាយចូរប្រាប់ សេចក្តីនុ៎ះដល់ខ្ញុំ យើងនឹងទៅ សូមខមាទោសចំពោះសមណៈនោះ ធ្វើម្តេចហ្ន៎ យើងនឹង បានកូននោះ មានជីវិតរស់នៅ ។

(១៧៤) (ពួកព្រាហ្មណ៍...) សមណៈមានប្រាជ្ញាក្រាស់ដូចផែនដី បានទៅកាន់អាកាស ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ដើរទៅតាម ផ្លូវអាកាស មួយទៀត សមណៈនោះជាឥសី មានការ ប្តេជ្ញាពិតទៀងទាត់ មានសភាពដ៏ល្អ បានទៅកាន់ទិសខាង កើតហើយ ។

(១៧៥) (នាងទិដ្ឋមង្គលិកា...) ក្បាល (របស់កូនខ្ញុំ) ត្រូវបែរទៅខាង ក្រោយ ដើមដៃលាតចេញទៅ មិនគួរដល់ការងារ ភ្នែកទាំង ឡាយសដូចភ្នែកបុគ្គលស្លាប់ អ្នកណាហ្ន៎ ធ្វើកូនខ្ញុំនេះ ឲ្យ ទៅជាយ៉ាងនេះ ។

(១៧៦) (ព្រះមហាសត្វ...) ពួកយក្សមានអានុភាពច្រើន (មក ដោយពិត) ពួកឥសីមានសភាពដ៏ល្អ មកហើយ (ក្នុងទី នេះ) ពួកយក្សដឹងថា (កូនរបស់នាង) មានចិត្តប្រទូស្ត ក្រោធ ខឹង ហើយបានធ្វើនូវកូននាង ឲ្យយ៉ាងនេះ ។

(១៧៧) យស្សា ច តេ បុត្តកាមស្ស រតិ
ហុញ្ញោវមេ ហ កុមារោ ព្រហ្មចារី
តុវំ មេ តាវ សរណំ ភវាសិ
អជ្ជាគតា បុត្តសោកេន ភិក្ខុ ។

(១៧៨) តទេវ ហិ ឯតរហិ ច មយ្ហំ
មនោបទោសោ ន មមត្ថិ កោចិ
បុត្តេ ច តេ វេធមានេ ជនេត្តិ
អត្ថិ ច ជានាតិ អជិន្ទ វេទេ ។

(១៧៩) អទ្ធា ហវេ ភិក្ខុ មុហុត្តកេន
សម្មុយ្ហតេវ បុរិសស្ស សញ្ញា
ឯកាបរាធំ ខម ភូរិបញ្ញ
ន បណ្ឌិតា កោធពលា ភវន្តិ ។

(១៨០) ឥធេវ មយ្ហំ ខត្តិយបិណ្ឌិ
ឥទំ មណ្ឌព្យោ កុញ្ចិត អព្យាបញ្ញោ
យស្សា ច តេ បុត្តំ ច វិហេឋយាមិ
បុត្តោ ច តេ ហោហិតិ សោ អរោគោ ។



(១៧៧) (នាងចិញ្ចមាណវិកា...) បើព្រះអង្គបានធ្វើកូនរបស់ខ្ញុំ ឲ្យ យ៉ាំងនេះហើយ សូមលោកជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ កុំទ័ង ចំពោះខ្ញុំ នាងខ្ញុំជាស្រីសូមផល់ ឪពុករបស់លោកជាទីពឹង បពិត្រភិក្ខុ ខ្ញុំមកដោយសេចក្តីសោកចំពោះកូន ។

(១៧៨) (ព្រះមហាសត្វ..) កាលនោះក៏ដោយ ឥឡូវនេះក៏ដោយ យើងមិនមានការប្រទូស្តចិត្តចំពោះ ដល់កូនរបស់នាង ជាអ្នកស្រីឯង ដោយសេចក្តីស្រើបក៏ទេ វៀរលែងហើយ មិនស្គាល់សេចក្តីពិតនេះ ។

(១៧៩) (នាងចិញ្ចមាណវិកា...) បពិត្រភិក្ខុ សញ្ញារបស់បុរសវៃមិន ត្រូវក៏ដោយមួយរ៉ែកចាប្រាកដ បរ៉ែនោះលោកតាម ប្រាកដក្រាស់ខ្លួនដែនដី សូមលោកអត់ឱនទោសកំហុសខ្លួន ខ្ញុំ អ្នកប្រាជ្ញទាំងឡាយ ពឹងមិនមានកោធជាកំឡាំង ។

(១៨០) (ព្រះមហាសត្វ...) ជួរវៀមព្ធាព្យកុមារ ដែលជាបុគ្គល មានប្រាជ្ញាតិច ជាបុត្តរបស់នាង ហើយកាន់ខ្មៅម្ដាយ ដែល ឃើញលះហើយចូលមកនេះ ចំណែកនាងច្លួយកូនដ៏វិសេស វៀរលៀនឲ្យកូនរបស់នាង ចាំងកូនរបស់នាងនោះ នឹង ទៅជាបុគ្គលមិនមានទោស ។

(១៨១) មន្ទាក្ស តាលោសិ បរិត្តបញ្ញោ

យោ ទុក្ខមេត្តា ឧបពោរិតោសិ

មហាគ្គសាវេសុ ចតាសិ តាធំ

កិលិដ្ឋកាមេសុ អសញ្ញតេសុ ។

ជដា ច កេសា អជិនា ចវត្ថា

ជល្លូបតាមំ ខុទ្ទំ បរិត្តំ

ចជំ ឥធំ បស្សេជ ទុម្មេធំ

ន ជដាជិនំ តាយតេ អប្បបញ្ញំ ។

យេសំ ភវោ ចោគោ ចោគោ អវិជ្ជា ច វិកប្បិតា

ទីឃាសកំ អហាន្តោ តេសុ សិទ្ធិ មហាបុល្លិ ។

(១៨២) ឧបបាទ្ធ មធំ មេជ្ឈោ មាតត្តសិ្ស យសស្សិន

សព្វាវិសជ្ជោ ខុទ្ធិញ្ញោ មេជ្ឈាញ្ញំ តតា អហុតិ ។







(១៧១) (តាន៍ទំរួបន្តិលិកា...) ខ្លាលមន្ទាក្យ: អ្នកជាបុគ្គលតាល

មានប្រាជ្ញាស្តួចស្តើង អ្នកជាបុគ្គលមិនស្គាល់ ខុសត្រូវ

តាំងឡាយ អ្នកឡូតាមចំពោះតែកូនចៅ ដែលមានទឹកចិត្ត

កិលេសដ៏ច្រើន មានដំណើរទៅតាម ជាអ្នកមិនសង្រួម ។

(ពួកជនទូទៅ) ប្តីសក់ សៀកស្បែកខ្លាឃ្មុំ មានមុខស្រូប

ស្រពោន (ដោយពុកមាត់ពុកចង្កា) ដូចអណ្តើកមិនតាំង អ្នក

តាំងឡាយ ពួកមិនពួកសត្វដែលមានសភាពគគ្រាក់នៃខ្ពុរ

ដ្បិតពួកសក់នឹងស្បែកខ្លាឃ្មុំ ការពារបុគ្គល ដែលមាន

ប្រាជ្ញាតិច មិនបានទេ ។ ពួកបុគ្គលណា លោភៈ

ទោសៈ នឹងអវិជ្ជា ពួកបុគ្គលនោះឈ្មោះថា ជាអ្នកដែលគួរណា-

ស្រួល ទានដែលបុគ្គលធ្វើចំពោះពួកបុគ្គលតាំងនោះ ទើប

ជាទានមានផលច្រើន ។

(១៧២) (អភិសម្ពុទ្ធតាថា) ស្តេចតក៏ដែលមេឃ: បៀតបៀនខ្លួនបិត្តរបស់

មាតុគ្គាមបស ជាអ្នកមានយស ស្តេចតក៏ដែលមេឃ: ក្រោមតាំង

ព័សិទ្ធិគឺជាប់ស្អូង ដែលឈ្មោះមេឃ:គឺទៅជាព្រៃកន្តែកលោការ ។

## ចិត្តសម្ភូតជាតកំ

[១៨៣] សព្វំ នរានំ សផលំ សុចិណ្ណំ
ន កម្មុនា កិញ្ចន មោឃមត្ថិ
បស្សាមិ សម្ភូតំ មហានុភាវំ
សកម្មុនា បុញ្ញផលូបបន្នំ ។
សព្វំ នរានំ សផលំ សុចិណ្ណំ
ន កម្មុនា កិញ្ចន មោឃមត្ថិ
កច្ចិន្នុ ចិត្តស្សបិ ឯវមេវ
ឥទ្ធោ មនោ តស្ស យថាបិ មយ្ហំ ។
[១៨៤] សព្វំ នរានំ សផលំ សុចិណ្ណំ
ន កម្មុនា កិញ្ចន មោឃមត្ថិ
ចិត្តំបិ ជានាហិ តថេវ ទេវ
ឥទ្ធោ មនោ តស្ស យថាបិ តុយ្ហំ ។
[១៨៥] ភវំ នុ ចិត្តោ សុតមញ្ញតោ តេ
ឧទាហុ តេ កោចិ នំ ឯតទក្ខា
គាថា សុគីតា ន មមត្ថិ កង្ខា
ទទាមិ តេ គាមវរំ សតញ្ច ។





## ចិត្តសម្ភូតជាតក

(១៨៣) (ព្រះរាជាត្រាស់ថា) សេចក្ដីទាំងពួងដោយការធ្វើទាំងអស់ ដែលនរជនតាំងទុកល្អហើយដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ ខ្ញុំឃើញសម្ភូតបណ្ឌិត មានអានុភាពច្រើន ជាអ្នកបរិបូណ៌ដោយផលនៃបុណ្យដោយការធ្វើរបស់ខ្លួន ។ សេចក្ដីទាំងពួងដោយការធ្វើទាំងអស់ ដែលនរជនតាំងទុកល្អហើយដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ ចិត្តរបស់បណ្ឌិតឈ្មោះចិត្តៈនោះសម្រេច ដូចចិត្តតាត្មាអញដែរឬហ្ន៎ ។

(១៨៤) (តាបសក្រាបទូលថា) សេចក្ដីទាំងពួងដោយការធ្វើទាំងអស់ ដែលនរជនតាំងទុកល្អហើយ ដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ជ្រាប នូវបណ្ឌិតឈ្មោះចិត្តៈនោះ មានចិត្តសម្រេច ដូចព្រះរាជហឫទ័យព្រះអង្គដែរ ។

(១៨៥) (ព្រះរាជា...) (សំដីនេះ) អ្នកបានឮមក (អំពីសំណាក់) បណ្ឌិតឈ្មោះចិត្តៈដ៏ចំរើនឬ ឬជនណាមួយប្រាប់សេចក្ដីនុះដល់អ្នក គាថា (នេះ) អ្នកច្រៀងពីរោះហើយ ខ្ញុំមិនមានសេចក្ដីសង្ស័យទេ ខ្ញុំឲ្យស្រុកសួយមួយរយ ដល់អ្នក ។

(១៨៦) ន ចាហំ ជនេន្ត សុតមញ្ញាតោ ទេ
ឥសិំ ច ទេ បិតមត្តិ អសំសិ
តណ្ហាណ ប្រញ្ញា បជិតាយេ តាជំ
អមិ ធុរេភិ អត្តមនោ ធនេយ្យំ ។

(១៨៧) យោជេន្តុ មេ[១] រាជរថេ សុការេ ចិត្តសិព្វនេ
កដ្ឋំ នាគានំ តន្តុជ តិវេយ្យំ បដិមុញ្ចថ ។
អាហាញ្ញារេ កេវិមុជិត្តសត្ថា[២]
សីហាមិ យានាមិ ច យោជយន្តុ
អជ្ជរោហំ អស្សរថំ គទំសុំ
យញ្ញេ ឧត្តំសុរមិសី ចំសិត្តិ ។

(១៨៨) សុលទុណោកោ តែ ទេ អារោហសិ
គជា សុកិតា បរិសាយ មជ្ជេ
សោបំ ឥសី សីលវត្តបទ្ធិ
ធិស្វា បតិកោ សុមនោហមស្មិ ។

(១៨៩) អាសនំ ធុរកំ ថជ្ជំ បដិក្កណ្ហាតុ ហោ ភវំ
អគ្គេ ភវន្តំ បុច្ឆាម អគ្គំ ករោតុ ហោ ភវំ ។

១ ម. យោជេន្តុ ឋ ។ ម. យោជេន្តុ ឋ ។ ២ ម. អាហញ្ញុំ
ចារិនុទិតសោរម្ភ ។ ម. អាហញ្ញំ ចារិនុទិតសោរម្ភ ។



(១៨៦) (ពាក...) ខ្ញុំព្រះអង្គ មិនបានឮ (អំពីសំណាក់) បណ្ឌិត ឈ្មោះចិត្តៈទេ តែឥសី (មួយរូប) បានប្រាប់នូវសេចក្តីនេះ ដល់ខ្ញុំព្រះអង្គថា អ្នកចូរទៅប្រៀបតាមគន្លងព្រះរាជា ក្រែង លោកស្គាល់សព្វព្រះរាជហឫទ័យ នឹងប្រោសប្រទាន នូវរបស់ដ៏ប្រសើរដល់អ្នក ។

(១៨៧) (ព្រះរាជា...) អ្នកទាំងឡាយចូរទឹមរថទាំងឡាយ ដែល ធ្វើយ៉ាងល្អ ប្រៀបប្រដាប់ដ៏ពិចិត្រ ចូរចងនូវវាំងផ្ទង់ ពាក់នូវ ប្រៀបប្រដាប់កនៃដំរីទាំងឡាយ ។ អ្នកទាំងឡាយ ចូរយកស្គរ នឹងសំភោរផ្លុំនូវស័ង្ខផង ចូរទឹមនូវយានទាំងឡាយដ៏លឿនៗផង ថ្ងៃនេះឯង អញនឹងទៅមើលឥសី ដែលអង្គុយក្នុងស្រមោល អញនឹងទៅកាន់ស្រែមានោះ ។

(១៨៨) ខ្ញុំ តាតអញ បានលាភល្អណាស់ហើយ គាត់ដែលបាន អញប្រៀបធៀបហើយ កណ្តាលបរិស័ទ ក្នុងអញបាន ឃើញ នូវឥសី ដ៏បរិបូណ៌ដោយសីលនិងវត្ត ហើយក៏ ត្រេកអរីកាយ ។

(១៨៩) សូមលោកទទួលនូវ ទូរលន្តាសនៈ ទឹក និងប្រេងលាបជើង របស់យើងខ្ញុំ បពិត្រលោកម្ចាស់ខ្ញុំ សូមលោកទទួលនូវកម្មមាន តម្លៃ សូមលោកទទួលនូវគ្រឿងតម្លៃរបស់យើងខ្ញុំ ។

(១៩០) វញ្ចេ តេ អាសេជិ កាកេន្ទ
ចាតុរោហិ បរិបាវយស្ស
កាកេហិ អាកាសមនុក្កមាយ
មុរោបមំ វស្សាយំ កាកេម ។

(១៩១) តិស្សា ចលិ ឧទ្ធរិតស្ស ពក
អហោ សុចិណ្ណស្ស មហាវិបាកំ
អត្តានមេវ បដិសំយមិស្ស
ន ចក្ខុយេ មុត្តបសុំ នចំ ភ ។

ធរោទិមា វស្សធសា មហាទិ ឥធ ធីរោតិ
អបរម្ភញ្ញោ តំ ទុដំ ឆមេ្យ ពិម្ពោ សុសរូហិ
មក្ខ កា ចទ្ធិ កា ទិម្ភ កា រតំ កា ធមេសិតា
តំ មេ ក្មុច្ឆហិ តារេហិ ភជ ហុក្ខាស្មិ កថ្ឋតា ។
សោហំ អរិ បសាតាមិ មក្កុ មេ ចបុមជ្ជតិ
អន្តោកោធាធិបច្ចស្ស កា រតិ កា ធមេសិតា ។



(១៩០) ក្អួចជនក្នុងត្រូវទ្វីបនៅ ស្ញុតទីកកាយផល់លោកផង ស្មេ
លោកមន្ទ្រក្អកតាប៉ែរើផង ស្មេលោកត្រូវខ្ញុំការ ដើម្បី
អនុគ្រោះ យើងទាំងពីរផងនេះ ចាំមើលកង ។

(១៩១) (ពិតបណ្ឌិតពោលថា) បពិត្រព្រះរាជា ភ្នាក់ការបានឃើញ
ខ្លួនលាវិនខ្ចាក នឹងផលដីព្រោះសិកបស់មម៉ា ដែលបុន
សត្វ ដោយប្រាំក ភ្នាក់ការពីផលព្រមនូវខ្លួនតែម្យ៉ាង
ភ្នាក់ការមិនប្រាថ្នាខ្លួន ឬសត្វចិញ្ចឹម ឬក្រៀវ ។

១០ ឆ្នាំ ១០ ម៉ឺនេះ ជាជីវិតរបស់ពួកសត្វក្នុងលោកនេះ ជីវិតនោះ
មិនដល់កំណត់នោះនៅឡើយ ក៏ស្លឹមស្រពោននៅ ដូចជាដើម
បបុសដែលគេកាត់ហើយ ។ ការយើជីវិតនោះ (ស្រពោននៅ
យ៉ាងនេះ) តើកកយ ដូចម្ដេចកើត លេងសើច ដូចម្ដេចកើត
ត្រេកអរដូចម្ដេចកើត ស្វែងរកទ្រព្យដូចម្ដេចកើត បពិត្រព្រះរាជា
ភ្នាក់ការមានប្រយោជន៍ ដោយក្លួននឹងប្រាកដ ដូចម្ដេចកើត
ភ្នាក់ការ ជាបុគ្គលដុតពាក់ចំណងហើយ ។ ភ្នាក់ការនោះ
នឹងឡាច់យ៉ាងនេះ បច្ចុកជម្ងឺនមើលដឹយ ចំពោះភ្នាក់ការនេះ
ការយើភ្នាក់ការត្រូវបាន ត្រេកសត្រូវ (យ៉ាងនេះ) តើ
ត្រេកអរដូចម្ដេចកើត ស្វែងរកទ្រព្យ ដូចម្ដេចកើត ។

ជាតិ នរានំ អធមា ជនិន្ទ
ចណ្ឌាលយោនិ ទ្វិបទកនិដ្ឋា[1]
សកេហិ កម្មេហិ សុទុក្កតេហិ
ចណ្ឌាលិគព្ភេ អវសិម្ហ ឧភោ ។
ចណ្ឌាលាហុវម្ហាវន្តីសុ មិគា នេរញ្ជរំ បតិ
ឧក្កុសា នម្មទាតីរេ ត្យជ្ជ ព្រាហ្មណខត្តិយា ។
(១៩២) ឧបនិយ្យតិ ជីវិតមប្បមាយុំ
ជរូបនីតស្ស ន សន្តិ តាណា
ករោហិ បញ្ចាល មមេត វាក្យំ
មា កាសិ កម្មានិ និរយូបបត្តិយា ។
ឧបនិយ្យតិ ជីវិតមប្បមាយុំ
ជរូបនីតស្ស ន សន្តិ តាណា
ករោហិ បញ្ចាល មមេត វាក្យំ
មា កាសិ កម្មានិ ទុក្ខប្ផលានិ ។

១ ម. ទ្វិបទាធមា ។





បពិត្រព្រះអង្គជាធំជាងជន ជាតិរបស់ពួកសត្វ ជាទម្លាប់នឹងជាតពាល កំណើតមនុស្សចណ្ឌាលលាមក ជាងពួកសត្វគ្រប់ពួកសត្វជើងពីរ យើងទាំងពីរនាក់ កើតក្នុងមនុស្សចណ្ឌាល ក្នុងកាលមុន ព្រោះតែអំពើរបស់ខ្លួន ដែលអាក្រក់ក្រៃលែង ។ យើងទាំងពីរនាក់កើតជាមនុស្សចណ្ឌាល ក្នុងដែនអវន្តី ហើយទៅមកកើតជាម្រឹគប្រហាក់ស្ទឹងនេរញ្ជរា ទៅកើតជាសត្វអក្កោះ[1] ទៀតនៅស្ទឹងនម្មទា ក្នុងថ្ងៃនេះ យើងជាព្រាហ្មណ៍នឹងក្សត្រិយ៍ ។

(១៩២) ជីវិតនិងអាយុ មានប្រមាណតិច ត្រូវជរានាំចូលទៅ (កាន់សេចក្ដីស្លាប់) កាលបើសត្វត្រូវជរានាំចូលទៅ (កាន់សេចក្ដីស្លាប់ហើយ) ទីពឹងក៏គ្មានទេ បពិត្រព្រះបាទបញ្ចាលៈ សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើទាំងឡាយ ដែលមាននរកជាទីកើតឡើយ ។ ជីវិតនិងអាយុ មានប្រមាណតិច ត្រូវជរានាំទៅ (កាន់សេចក្ដីស្លាប់) កាលបើសត្វត្រូវជរានាំទៅ (កាន់សេចក្ដីស្លាប់ហើយ) ទីពឹងក៏គ្មានទេ បពិត្រព្រះបាទបញ្ចាលៈ សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើ នូវអំពើទាំងឡាយ ដែលមានផលជាទុក្ខឡើយ ។

១ អាចារ្យខ្លះថា សត្វអន្ទង់ខ្មៅ ។

ឧបនិយ្យតិ ជីវិតមប្បមាយុំ
ជរូបនីតស្ស ន សន្តិ តាណា
ករោហិ បញ្ចាល មមេត វាក្យំ
មាកាសិ កម្មានិ ទុក្ខុទ្រយានិ ។
ឧបនិយ្យតិ ជីវិតមប្បមាយុំ
វណ្ណំ ជរា ហន្តិ នរស្ស ជិយ្យតោ
ករោហិ បញ្ចាល មមេត វាក្យំ
មាកាសិ កម្មំ និរយូបបត្តិយា ។

(១៨៣) អទ្ធា ហិ សច្ចំ វចនំ តវេតំ
យថា ឥសី ភាសសិ ឯវមេតំ
កាមា ច មេ សន្តិ អនប្បរូបា
តេ ទុច្ចជា មាទិសកេន ភិក្ខុ ។
នាគោ យថា បង្កមជ្ឈេ ព្យសន្នោ
បស្សំ ថលំ នាភិសម្ភោតិ គន្តុំ
ឯវម្បហំ កាមបង្កេ ព្យសន្នោ
ន ភិក្ខុនោ មគ្គមនុព្វជាមិ ។



ជីវិតតិចណាស់ មានប្រមាណតិច ត្រូវគេនាំទៅ (កាន់សេចក្តីស្លាប់) កាលបើសត្វត្រូវគេនាំទៅ (កាន់សេចក្តីស្លាប់ហើយ) ទីពឹងពំនាក់គ្មានទេ បពិត្រព្រះបាទបញ្ចាលៈ សូមព្រះអង្គធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើជាទីក្លាយដែលជាប្រធាននៃទុក្ខ គឺកិលេសឡើយ ។ ជីវិតតិចណាស់ មានប្រមាណតិច ត្រូវគេនាំទៅ (កាន់សេចក្តីស្លាប់) ជរាតែងកំចាត់បង់នូវសម្បុររបស់សត្វ ដែលកំពុងគ្រាំគ្រា បពិត្រព្រះបាទបញ្ចាលៈ សូមព្រះអង្គធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើដើម្បីកើតក្នុងនរកឡើយ ។

(១៨៣) (ព្រះរាជា...) ពាក្យ(របស់លោក)នុះ ពេញជាពិតមែនហើយ បពិត្រឥសី លោកពោលយ៉ាងណា សេចក្តីនុះយ៉ាងនោះ បពិត្រភិក្ខុ តែកាមទាំងឡាយរបស់ខ្ញុំ មានសភាពមិនតិចទេ កាមទាំងនោះ បុគ្គលប្រៀបដូចខ្ញុំ លះបង់បានដោយក្រ ។ ដំរីជាប់នៅក្នុងកណ្តាលភក់ មិនអាចដើរទៅកាន់ទីគោកដោយខ្លួនឯងយ៉ាងណា ខ្ញុំក៏ជាបុគ្គលជាប់នៅក្នុងភក់ គឺកាម មិនអាចបួសតាមផ្លូវ(ចរណៈ)របស់លោកជាភិក្ខុយ៉ាងនោះដែរ

យថាបិ មាតា ច បិតា ច បុត្តំ
អនុសាសរេ កាម្មិ សុចី ការយេ្យ
បរិច្ច នំ តំ អនុសាស ការេ
យថា ចិរំ ឋេត្វ សុចី ការេយ្យុំ ។
(១៩៦) សោ ទេ ទុរំ ទស្សហាសេ ឋមិន្ទ
កាមេ ឥមេ មានុសកេ បហាតុំ
ធម្មំ ចរេ បដ្ឋមយស្ស ភាជ
អលម្ពកាមេ ច ទេ មាហុ រដ្ឋេ ។
ធុតា វិវាតុ ឥសិ ហេ បរេស្សា
និមន្តកា សមណព្រាហ្មណានំ
តេ អនុហាបេន្ត ទុបជ្ជហស្ស
កំគ្គុន សេហាសមបច្ចយេន ច ។
អន្នេន ហានេន បសន្នចិត្តា
សន្តប្បយ សមណព្រាហ្មណេ ច
ធត្វា ច ភុត្វា ច យថានុភាវំ
អនិន្ទិតោ សគ្គមុបេហិ ឋានំ ។



មាតាបិតា ប្រៀនប្រដៅបុត្ត (ហៅយ១ចុយយ៉ាង) ទៅ្យល្អ បុត្ត គឺធម្មតារសេចក្តីសុខ យ៉ាងណា បពិត្រលោកដ៏ចំរើន សូមលោកប្រៀនប្រដៅខ្ញុំតាមសមគួរ សូមឲ្យខ្ញុំបានលោកានុគោហើយ បានសេចក្តីសុខជាអង្វែង ក៏យ៉ាងនោះដែរ ។

(១៩៦) (ចិត្តបណ្ឌិត...) បពិត្រព្រះអង្គជាធំជាងជន ពេញព្រះអង្គមិនគាប់ចិត្តនូវកាមគុណទាំងឡាយ ជារបស់មនុស្សនេះជាដើម បពិត្រព្រះរាជា សូមព្រះអង្គគង់ចុះកាន់ការប្រព្រឹត្តធម៌ ឯការតែងវែលមិនប្រព្រឹត្តធម៌ ក៏សូមកុំឲ្យមានក្នុងដែនរបស់ព្រះអង្គឡើយ ។ សូមឲ្យគ្នាទាំងឡាយ (របស់ព្រះអង្គ) ជាអ្នកនិមន្តនូវពួកព្រាហ្មណ៍ ចេញទៅកាន់ទិសទាំង ៦ (ទិសមុខមិនរើសមុខ) សូមឲ្យព្រះអង្គទំនុកបម្រុងនូវសមណព្រាហ្មណ៍ទាំងនោះ ដោយបាយ ទឹក សំពត់ទីសេនាសនៈបច្ច័យ ។ សូមព្រះអង្គមានព្រះទ័យជ្រះថ្លាហើយញ៉ាំងសមណព្រាហ្មណ៍ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក លុះព្រះអង្គឲ្យទានទាំងប្រើប្រាស់ (ខ្លួន) តាមសមគួរដល់កម្លាំងហើយ ជាអ្នកមានគេមិនតិះដៀល ហើយសូមឲ្យទៅកើតក្នុងឋានសួគ៌ ។

សចេ ច តំ ភជ មតោ សហេយ្យ
ធារីតលោហិ បរិភយេន្តុំ
ឥមមេវ តាជី មនសិការោហិ
ភាសេហិ ចេតំ បរិសាយ មជ្ឈេ ។
អក្កោសកាសសយោ ជន្តុ វណ្ណា ធីរោ ហាយិតោ
បរិភាវេណ្ណា សុភណេហិ ស្វាជ្ជ ភជាតំ វុត្តីតំ ។

ចិត្តសម្ភូតជាតកំ ទុតិយំ ។

---

# សិវិជាតកំ

(១៩៨) ទូរេ អបស្សំ ថេរោវ ចក្ខុំ យាចិតុមាគតោ
ឯកនេត្តា ភវិស្សាម ចក្ខុំ មេ ទេហិ យាចិតោ ។

(១៩៩) កេនានុសិដ្ឋោ ឥធមាគតោសិ
វណិព្វក ចក្ខុបថានិ យាចិតុំ
សុទុទ្ទទំ យាចសិ ឧត្តមង្គំ
យមាហុ នេត្តំ បុរិសេន ទុច្ចជំ ។





បពិត្រព្រះរាជា បើសិនព្រះអង្គស្រេចនឹងលះបង់សត្វព្រះអង្គដែលមាន
ក្នុងការីពាមាកមហារី សូមព្រះអង្គធ្វើនូវ ក្នុងព្រះទ័យ
ចំពោះសភាវៈនេះ ម្យ៉ាងទៀត សូមព្រះអង្គ (ទ្រង់ត្រាស់)
ប្រោសនូវហេតុនេះតាមវាចានេះ ក្នុងកណ្តាលបរិស័ទផង
សព្វគុណដែលក្នុងទីពល ឡើងដោយតាមការក្នុងនៃ ជាសត្វប្រព្រឹត្តប្រយោជន៍
ដោយគុណសម្បត្តិ សត្វនោះនោះទៅជាព្រះរាជា ក្នុងថ្ងៃនេះ ។

ចប់ ចិត្តសម្ភូតជាតក ទី ២ ។

---

# សិវិជាតក

(១៩៨) (ព្រះឥន្ទ្រក្លែងភេទជាព្រាហ្មណ៍ចាស់ក្រាបទូលថា) ខ្ញុំព្រះអង្គជាបុគ្គលចាស់ជរា មើលមិនឃើញឆ្ងាយ មកដើម្បីសុំនូវព្រះនេត្រ ខ្ញុំព្រះអង្គជាអ្នកមានភ្នែកម្ខាង កាលបើខ្ញុំសុំហើយ សូមព្រះអង្គប្រទាននូវព្រះនេត្រដល់ខ្ញុំព្រះអង្គ ។

(១៩៩) (ព្រះបាទសិវិរាជត្រាស់សួរថា) នែស្មូម អ្នកណាប្រាប់អ្នក ទើបអ្នកមកក្នុងទីនេះ ហើយសុំនូវភ្នែកទាំងឡាយ ផលទាំងឡាយរបស់ភ្នែកណា ជារបស់ដែលបុរសលះបង់បានដោយក្រ អ្នកសុំនូវភ្នែក ជាអវយវៈដ៏ខ្ពង់ខ្ពស់នោះ ដែលគេលះបង់បានដោយក្រៃក្រៃលែង ។

[១៨៧] យថាបិ ទេវេសុ សុផុល្លិតំ
មយកិតំ តំ អាហុ មនុស្សលោកេ
តេជានុសិទ្ធោ ជលរកកាសិ
វណ្ឌិតោ ចង្កមមានំ យាចិតុំ ។
វណ្ឌិតោ មយ្ហ ទលេ អនុត្តរំ
ឧណាហំ ទេ ចង្កមមានំ យាចិតោ
ឧណាហំ ទេ ចង្កមមំ អនុត្តរំ
យថាបិ ខេត្តំ បុរិសេន ឧត្តំ ។
យេន អត្ថេន អាគញ្ឆិ យមត្ថមភិបត្ថយំ
តេ តេ វិជ្ជត្ថុ សព្វញ្ញូ លភ ចង្កមំ ព្រាហ្មណ ។
បរិកម្មំ យាចមានស្ស ទុកយាចំ ឧណាមហំ
ស ចង្កមា កដ្ឋ ជនស្ស បេក្ខតោ
យថិច្ឆសេ តំ គណេ សមិជ្ឈតុ ។
[១៨៨] មា ហោ ចេវ អភា ចក្ខុំ មា ហោ សាវេ បរក្កមំ
ឧបំ ទេហិ មហាកឋ ឧត្តា ទេវ្យិយា ពហុ ។





(១៨៧) (ព្រះថេរ...) ផ្កាទេវតាងឈើកោលលំអិតទេវតាវិសេសណា
ជាសុផល្លិតក្តីទេវលោក ផ្កាដងឈើកោលលំអិតទេវតាវិសេស
នោះជាមយ: ក្នុងមនុស្សលោក ខ្ញុំទទួលសូម ដែលទេវតា
វិសេសនោះប្រគល់ ហើយមកក្នុងទីនេះព្រោះសុំព្រះនេត្រតាំង
ឡាយ ។ ខ្ញុំទទួលសូម ការសូមជាកិច្ចរបស់ខ្ញុំ កាលបើ
ខ្ញុំសូមព្រះនេត្រតាំងឡាយ សូមព្រះអង្គប្រទាន ផ្កាដងឈើ
កោលខ្ញុំក្នុងណា ជាជាតរបស់ដែលប្រសើរ លះចុះមកយក
សូមព្រះអង្គប្រទាននូវព្រះនេត្រដ៏ប្រសើរនោះដល់ខ្ញុំព្រះអង្គ ។
(ព្រះចក្ខុទសីភដ...) ខ្ញុំមកមកដោយប្រយោជន៍ណា ប្រាថ្នានូវ
ប្រយោជន៍ណា សេចក្តីត្រិះរិះនូវប្រយោជន៍នោះ សូមឲ្យសម្រេច
ដល់អ្នកចុះ ម្នាលព្រាហ្មណ៍ អ្នកចូរបាន នូវភ្នែកតាំងឡាយ ។
កាលបើ អ្នកសូមភ្នែកមួយ យើងនឹងឲ្យភ្នែកទាំងពីរ កាលជនទាំងពួង
មើល សូមអ្នកនោះជាបុគ្គលមានភ្នែកទៅចុះ អ្នកប្រាថ្នានូវរបស់
ណា របស់នោះចូរសម្រេចដល់អ្នក ។
(១៨៨) (ក្នុងជនកោលជា) បពិត្រព្រះសម្មតិទេព សូមទ្រង់កុំ
ប្រទាននូវព្រះនេត្រ សូមទ្រង់កុំលះបង់ នូវក្នុងយើងទាំង
អស់គ្នាឡើយ បពិត្រមហារាជ សូមទ្រង់ប្រទាន នូវព្រះ
រាជទ្រព្យ គឺកែវមុក្តា និងកែវពិទូរ្យដ៏ច្រើនវិញចុះ ។

យុត្តំ ទេវ រថំ ទេហិ　អាជានិយេ អលង្កតេ

ញាតេ ទេហិ មហារាជ　ហេមកប្បនិវាសសេ ។

យថា តំ សីហយោ សព្វេ　សម្មោទ្ទា សាជា សតោ

សមន្តា បរិការេយ្យុំ　នរំ ទេហិ រថេសភ ។

(១៤៤) យោ វេ ទស្សន្តិ វត្វាន　អទានេ កុរុតេ មនោ

ភិយ្យោ សោ បតិតំ ទាសំ　គិតយំ បដិស្សុតំ ។

យោ វេ ទស្សន្តិ វត្វាន　អទានេ កុរុតេ មនោ

បាបា បាបតរោ ហោតិ　សម្បត្តោ យមសាធនំ ។

យញ្ហិ កយិរា តញ្ហិ វទេ　យំ ន កយិរា ន តំ វទេ

អករោន្តំ ភាសមានំ　បរិជានន្តិ បណ្ឌិតា ។



ហាក្រែកព្រះសម្មតិទេព សូមទ្រង់ប្រទាននូវរថ ដែលទឹមដោយសេះអាជានេយ្យ ដែលប្រដាប់ហើយ បពិត្រមហារាជ សូមព្រះអង្គប្រទាននូវរថពាក់ផ្កាយ ព្រោះដោយគ្រឿងប្រដាប់ក្បាល និងបណ្ដាញមាសផងចុះ ។ សត្វទាំងឡាយទាំងពួង ព្រមទាំងកំដរ ហោមរោមព្រះអង្គដោយជុំវិញ ត្រង់ការ ដោយប្រការណា បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ សូមព្រះអង្គប្រទានដោយប្រការនោះចុះ ។

(១៤៤) (ព្រះរាជា...) បុគ្គលណាពោលថាគ្នានឹងឲ្យ ហើយធ្វើនូវចិត្តគំនិតកាលមិនឲ្យវិញ បុគ្គលនោះ ឈ្មោះថាយកអន្ទាក់ដែលធ្លាក់លើផែនដីមកពាក់ក្នុងក ។ បុគ្គលណាពោលថាគ្នានឹងឲ្យ ហើយធ្វើនូវចិត្តគំនិតកាលមិនឲ្យវិញ បុគ្គលនោះ ឈ្មោះថាជាបុគ្គលលាមកក្រៃលែងជាងបុគ្គលលាមក ហើយដល់នូវឋានជាទីសម្រេចរបស់ព្រះយមរាជ ។ បុគ្គលគប្បីធ្វើនូវរបស់ណា គប្បីនិយាយនូវរបស់នោះ មិនគប្បីធ្វើនូវរបស់ណា មិនគប្បីនិយាយនូវរបស់នោះ ព្រោះបណ្ឌិតទាំងឡាយតែងកំណត់ដឹងនូវបុគ្គលដែលមិនធ្វើ តែនិយាយ ។

[២០០] អាយុំ នុ វណ្ណំ នុ សុខំ ពលំ នុ
កឹ បត្ថយានោ នុ ជនិន្ទ ទេសិ
កថញ្ហិ រាជា សិវីនំ អនុត្តរោ
ចក្ខូនិ ទជ្ជា បរលោកហេតុ ។

[២០១] ន វាហមេតំ យសសា ទទាមិ
ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ
សតញ្ច ធម្មោ ចរិតោ បុរាណោ
ឥច្ចេវ ទានេ រមតេ មនោ មម ។

[២០២] ន មេ ទេស្សា ឧភោ ចក្ខុ អត្តានំ មេ ន ទេស្សិយំ
សព្វញ្ញុតំ បិយំ មយ្ហំ តស្មា ចក្ខុំ អទាសហំ ។

[២០៣] សខា ច មិត្តោ ច មមាសិ សីវិក
សុសិក្ខិតោ សាធុ ករោហិ មេ វចោ
ឧទ្ធរិត្វា ចក្ខូនិ មមំ ជិគីសតោ
ហត្ថេសុ ឋបេហិ វនិព្វកស្ស ។



[២០០] (ក្មួកជាងកាតក្យ...) បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គប្រាថ្នានូវរបស់អ្វី គឺអាយុ ឬពណ៌សម្បុរ ឬសេចក្តីសុខ ឬកំលាំង ទើបព្រះអង្គប្រទាន (ព្រះនេត្រ) ព្រះរាជាដ៏ប្រសើរជាធំជាងអ្នកនៅក្នុងដែនសិវិទាំងឡាយ មិនសមបើប្រទានព្រះនេត្រទាំងឡាយ ព្រោះហេតុនៃប្រយោជន៍ក្នុងបរលោក ។

[២០១] (ព្រះរាជា...) អាត្មាអញមិនមែនឲ្យចក្ខុទាន ព្រោះយសទេ មិនមែនប្រាថ្នាកូន មិនមែនប្រាថ្នាទ្រព្យ មិនមែនប្រាថ្នានូវដែនទេ ធម៌ដ៏ប្រពៃណីនៃសប្បុរសទាំងឡាយជាអ្នកបុរាណ ដែលពួកសប្បុរសធ្លាប់ប្រព្រឹត្តមកហើយ ចិត្តរបស់អាត្មាអញតែងត្រេកអរក្នុងការឲ្យ ដោយប្រការដូច្នេះឯង ។

[២០២] (អភិសម្ពុទ្ធគាថា) ភ្នែកទាំងពីរ មិនជាទីស្អប់ របស់តថាគតទេ តថាគតមិនមែនស្អប់ខ្លួនរបស់តថាគតទេ សព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ តថាគតបានឲ្យនូវភ្នែក ។

[២០៣] (ព្រះរាជា..) ម្នាលនាយពេទ្យឈ្មោះសីវិកៈ អ្នកជាសំឡាញ់ ជាមិត្ររបស់យើង អ្នកបានរៀនវិជ្ជាពេទ្យស័ក្តិល្អហើយ ចូរធ្វើតាមសំដីរបស់យើងដោយប្រពៃចុះ កាលយើងកំពុងប្រាថ្នា អ្នកចូរឆ្កៀលនូវភ្នែកទាំងឡាយ (របស់យើង) ហើយដាក់លើដៃរបស់ស្មូមចុះ ។

(៦០៤) ទោណំភោ សិវិកវេជ្ជ សិវិរាជា វចនំ ករ
រញ្ញោ ចក្ខុំ ឧទ្ធរិត្វា ព្រាហ្មណស្សុបនាមយំ
សចក្ខុ ព្រាហ្មណោ អាសិ អន្ធោ រាជា ឧបាវិសិ ។

(៦០៥) តតោ សោ កតិបាហស្ស ឧបរូឡ្ហេសុ ចក្ខុសុ
សុភំ អាមន្តយី រាជា សិវីនំ រដ្ឋវឌ្ឍនោ ។
យោ នេហិ សារថិ យានំ យុត្តញ្ច បដិវេទយ
ឧយ្យានភូមឹ គច្ឆាម ពោក្ខរញ្ញោ វនានិ ច ។
សោ ច ពោក្ខរណីតីរេ បល្លង្កេន ឧបាវិសិ
តស្ស សក្កោ បាតុរហុ ទេវរាជា សុជម្បតិ ។

(៦០៦) សក្កោហមស្មិ ទេវិន្ទោ អាគតោស្មិ តវន្តិកេ
វរំ វរស្សុ រាជិសិ យំ កិញ្ចិ មនសិច្ឆសិ ។

(៦០៧) បហូតំ មេ ធនំ សក្ក ពលំ កោសោ ចនប្បកោ
អន្ធស្ស មេ សតោ ទានិ មរណញ្ញេវ រុច្ចតិ ។





(៦០៤) (អភិសម្ពុទ្ធគាថា) ពេទ្យឈ្មោះសិវកៈ លុះត្រាស់ទ្រង់ព្រះនាម
សិវិ ហៅថា (យាំងនេះហើយ) ក៏ធ្វើតាមព្រះបន្ទូល ហើយឆ្កៀលខ្វេះ
ព្រះនេត្រទាំងពីររបស់ព្រះរាជា ដាក់នៅឲ្យព្រាហ្មណ៍ ចំណែក
ព្រាហ្មណ៍ក៏នៅជាបុគ្គលមានភ្នែក ព្រះរាជាក៏នៅជាបុគ្គលខ្វាក់ ។

(៦០៥) (អភិសម្ពុទ្ធគាថា) តាំងពីនោះមក ប្រមាណពីរបីថ្ងៃ លុះដល់ព្រះ
នេត្រទាំងពីរស៊ុះឡើង ព្រះរាជាជាម្ចាស់ញ៉ាំងដែនសិវិរាស្ត្រឲ្យចំរើនដល់ពួក
ជនអ្នកសិវិ ទ្រង់ត្រាស់បង្គាប់នាយសារថីថា នែនាយសារថី អ្នក
ចូរទឹមយាន លុះទឹមហើយចូរក្រាបទូលយើង យើងនឹងទៅកាន់ទីឧទ្យាន
ដែលមានស្រះបោក្ខរណីនិងព្រៃព្រឹក្សា ។ ព្រះបាទសិវិនោះ ទ្រង់
គង់ចុះទៅលើគ្រែបល្ល័ង្ក ក្បែរច្រាំងស្រះបោក្ខរណី ទេវរាជ
ឈ្មោះសក្កៈ ជាសុជម្បតិ ក៏មកដល់ចំពោះព្រះអង្គ ។

(៦០៦) (ព្រះឥន្ទ...) ខ្ញុំជាទេវរាជឈ្មោះសក្កៈ ជាធំជាងទេវតា មក
កាន់សំណាក់ព្រះអង្គ បពិត្រព្រះរាជឥសី ព្រះអង្គប្រាថ្នាចង់បានវត្ថុណាមួយ
ចំពោះតែណាមួយ សូមព្រះអង្គទទួលយកពរនោះ ។

(៦០៧) (ព្រះបាទសិវិ...) បពិត្រសក្កៈ ទ្រព្យនិងកំលាំងរបស់ខ្ញុំមានច្រើន
ហើយ ទាំងឃ្លាំងរបស់ខ្ញុំ មិនមែនមានតិចទេ កាលបើខ្ញុំនៅតែខ្វាក់
ដូច្នេះ ខ្ញុំពេញចិត្តចំពោះសេចក្ដីស្លាប់តែម្យ៉ាង ។

(៦០៨) យានិ សច្ចានិ ទិបទិន្ទ តានិ ភាសស្សុ ខត្តិយ
សច្ចំ តេ ភណមានស្ស បុន ចក្ខុ ភវិស្សតិ ។

(៦០៩) យេ មំ យាចិតុមាយន្តិ នានាគោត្តា វនិព្វកា
យោបិ មំ យាចតេ តត្ថ សោបិ មេ មនសោ បិយោ
ឯតេន សច្ចវជ្ជេន ចក្ខុ មេ ឧបបជ្ជថ ។

(៦១០) យំ មំ សោ យាចិតុំ អាគា ទេហិ ចក្ខុន្តិ ព្រាហ្មណោ
តស្ស ចក្ខូនិ បាទាសិំ ព្រាហ្មណស្ស វនិព្វតោ
ភិយ្យោ មំ អាវិសិ បីតិ សោមនស្សញ្ចនប្បកំ
ឯតេន សច្ចវជ្ជេន ទុតិយំ មេ ឧបបជ្ជថ ។

(៦១១) ធម្មេន(១) ភាសិតា គាថា សិវីនំ រដ្ឋវឌ្ឍន
ឯតានិ តវ នេត្តានិ ទិព្វានិ បដិទិស្សរេ(២) ។
តិរោកុឌ្ឌំ តិរោសេលំ សមតិគ្គយ្ហ បព្វតំ
សមន្តា យោជនសតំ ទស្សនំ អនុភោន្តុ តេ ។

---

១ ម. ធម្ម ។ ២ ម. បតិទិស្សរេ ។



(៦០៨) (ព្រះឥន្ទ...) បពិត្រក្សត្រិយ៍ជាធំជាងពួកជនមានជើងពីរ សូមព្រះអង្គពោល នូវពាក្យទាំងឡាយដែលជាសច្ចៈចុះ កាលបើព្រះអង្គពោលនូវពាក្យសច្ចៈ ព្រះនេត្រនឹងមានឡើងវិញ ។

(៦០៩) (ព្រះបាទសិវិ...) ពួកស្មូមណា មានគោត្រផ្សេងៗគ្នា មកដើម្បីសូមចំពោះយើង បណ្ដាស្មូមទាំងនោះ ស្មូមណាសូមយើង ស្មូមនោះជាទីស្រឡាញ់ នៃចិត្តរបស់យើង សូមឲ្យភ្នែកកើតមានដល់យើង ដោយការពោលនូវពាក្យសច្ចៈនេះ ។

(៦១០) ព្រាហ្មណ៍នោះមកដើម្បីសូម នូវភ្នែកណានឹងយើងថា សូមព្រះអង្គប្រទាននូវភ្នែក យើងក៏បានឲ្យនូវភ្នែកទាំងឡាយនោះ ដល់ព្រាហ្មណ៍ដែលសូមនោះហើយ ។ បីតិនិងសោមនស្សដ៏ច្រើន ក៏កើតឡើងដល់យើង ដោយហេតុនោះ សូមឲ្យភ្នែកជាគំរប់ពីរ កើតមានដល់យើង ដោយពោលពាក្យសច្ចៈនេះ ។

(៦១១) (ព្រះឥន្ទ...) បពិត្រក្សត្រិយ៍ អ្នកញុំាងដែនរបស់អ្នកដែនសិវិ ឲ្យចំរើន គាថាដែលព្រះអង្គពោលតាមធម៌ សូមឲ្យព្រះនេត្រទាំងពីរ របស់ព្រះអង្គនេះ ប្រាកដជាទិព្វ ។ ព្រះនេត្រទាំងពីរ របស់ព្រះអង្គនោះ សូមឲ្យបាននូវការឃើញហួសឆ្ងាយ ទៅខាងក្រៅ ជញ្ជាំង ខាងក្រៅភ្នំ អស់ទីចំនួនមួយរយយោជន៍ ដោយជុំវិញ ។

(៦១៦) កោនីធ វិត្តំ ន ទទេយ្យ យាចិតោ
អបិ វិសិដ្ឋំ សុបិយម្បិ អត្តនោ
តិង្ឃ សព្វេ សិវយោ សមាគតា
ទិព្វានិ នេត្តានិ មមជ្ជ បស្សថ ។
តិរោកុឌ្ឌំ តិរោសេលំ សមតិគ្គយ្ហ បព្វតំ
សមន្តា យោជនសតំ ទស្សនំ អនុភោន្តិ មេ ។
ន ចាគមត្តា បរមត្ថិ (កិញ្ចិ) មច្ចានំ ឥធ ជីវិតេ
ទត្វាន មានុសំ ចក្ខុំ លទ្ធំ (មេ) ចក្ខុំ អមានុសំ ។
ឯតម្បិ ទិស្វា សិវយោ ទេថ ទានានិ ភុញ្ជថ
ទត្វា ច ភុត្វា ច យថានុភាវំ
អនិន្ទិតា សគ្គមុបេថ ឋានំ ។

សិវិជាតកំ តតិយំ ។

---

## សិរិមន្ទជាតកំ

(៦១៧) បញ្ញាយុបេតំ សិរិយា វិហីនំ
យសស្សិំ វាបិ អបេតបញ្ញំ
បុច្ឆាមិ សេនក ឯតមត្ថំ



(៦១៦) (ព្រះបាទសិវិ...) អ្នកណាមួយក្នុងលោកនេះ ដែលគេសូម ហើយមិនឲ្យនូវទ្រព្យដ៏ពេញចិត្ត ឬទ្រព្យដ៏វិសេស ជាទីស្រឡាញ់ ដ៏ក្រៃលែងរបស់ខ្លួន នែអ្នកដែនសិវិទាំងអស់ដែលមកប្រជុំគ្នា ចូរអ្នកទាំងឡាយមើល នូវភ្នែកទាំងពីររបស់អញ ដែលជាទិព្វ ក្នុងថ្ងៃនេះចុះ ។ ចក្ខុទាំងពីររបស់យើង កើតឡើងនៅការឃើញនូវរូបឆ្ងាយ ទៅកាន់ក្រៅជញ្ជាំង ក្រៅថ្ម ក្រៅភ្នំ អស់ទីចំនួនមួយរយយោជន៍ដោយជុំវិញ ។ (វត្ថុណាមួយ) ក្នុងជីវិត របស់សត្វទាំងឡាយនេះ កើតមិនប្រសើរជាងការបរិច្ចាគទេ (ខ្លួនយើង) បានឲ្យនូវចក្ខុជារបស់មនុស្សហើយបាននូវចក្ខុទិព្វ ដែលមិនមែនជារបស់មនុស្ស ។ ម្នាលអ្នកដែនសិវិទាំងឡាយ អ្នកទាំងឡាយបានឃើញហេតុនេះហើយ ចូរឲ្យទាន ចូរបរិភោគ លុះឲ្យហើយ បរិភោគហើយ តាមសមគួរដល់អានុភាព សូមឲ្យជាអ្នកមិនមានអ្នកណាតិះដៀលបាន ហើយចូរទៅកាន់ឋានសួគ៌ចុះ ។

ចប់ សិវិជាតក ទី ៣ ។

---

## សិរិមន្ទជាតក

(៦១៧) (ព្រះរាជាវិទេហៈត្រាស់សួរថា) នែសេនកៈ យើងសួរនូវសេចក្តីនេះ នឹងអ្នក បុគ្គលប្រកបដោយប្រាជ្ញា ប្រាសចាកសិរីសម្បត្តិ ១ បុគ្គលមានយស ប្រាសចាកប្រាជ្ញា ១

កមេត្ថ សេយ្យោ កុសលា វទន្តិ ។

(២១៦) ធីរា ច ពាលា ច ហវេ ជនិន្ទ

សិប្បូបបន្នា ច អសិប្បិនោ ច

សុជាតិមន្តោបិ អជាតិមស្ស

យសស្សិនោ បេសការា ភវន្តិ

ឯតម្បិ ទិស្វាន អហំ វទាមិ

បញ្ញោ និហីនោ សិរិមាវ សេយ្យោ ។

(២១៧) តុវម្បិ បុច្ឆាមិ អនោមបញ្ញ

មហោសធ កេវលធម្មទស្សិ

ពាលំ យសស្សឹ បណ្ឌិតំ អប្បភោគំ

កមេត្ថ សេយ្យោ កុសលា វទន្តិ ។

(២១៨) បាបានិ កម្មានិ ករោន្តិ ពាលា

ឥធមេវ សេយ្យោ ឥតិ មញ្ញមានា

ឥធលោកទស្សី បរលោកំ អទស្សី

ឧភយត្ថ ពាលោ កលិមគ្គហេសិ

ឯតម្បិ ទិស្វាន អហំ វទាមិ

បញ្ញោវ សេយ្យោ ន យសស្សិ ពាលោ ។



អ្នកប្រាជ្ញទាំងឡាយពោលថា បណ្ដាបុគ្គលទាំងពីរនោះ បុគ្គលណា ប្រសើរជាង ។

(២១៦) (ពាក្យសេនកៈ ...) បពិត្រព្រះអង្គជាធំជាងជន ពួកអ្នកប្រាជ្ញ ពួកជនពាល ពួកជនអ្នកបរិបូណ៌ដោយសិល្បៈ និងពួកជនមិនមានសិល្បៈ សូម្បីជាអ្នកមានជាតិខ្ពស់ តែងតែជាអ្នកធ្វើនូវការបំរើជនអ្នកមានយស ដែលមិនមានជាតិ ខ្ញុំព្រះអង្គបានឃើញហេតុនេះ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

(២១៧) (ព្រះរាជា...) ម្នាលមហោសធ អ្នកមានប្រាជ្ញាមិនថោកថយ ជាអ្នកឃើញនូវហេតុដោយសព្វគ្រប់ យើងសួរអ្នក អំពីបុគ្គលពាលមានយស បណ្ឌិតគ្មានភោគៈ តើអ្នកប្រាជ្ញទាំងឡាយពោលថា បណ្ដាបុគ្គលទាំងពីរនោះ បុគ្គលណាប្រសើរជាង ។

(២១៨) (មហោសធបណ្ឌិត...) ពួកជនពាល តែងធ្វើនូវអំពើអាក្រក់ទាំងឡាយ ហើយសំគាល់ថា អំពើនេះឯង ជាអំពើប្រសើរ ជាអ្នកឃើញត្រឹមតែលោកនេះ មិនឃើញនូវលោកខាងមុខទេ បុគ្គលពាលតែងកាន់យកនូវទោសក្នុងលោកទាំងពីរ ខ្ញុំព្រះអង្គបានឃើញហេតុនេះ សូមទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ ។

(៦០៧) ន សិប្បមេតំ វិទធាតិ ភោគំ
ន ពន្ធវា ន សរីរវណ្ណោ
បស្សេឡមូគំ សុខមេធមានំ
សិរីហិ នំ ភជតេ គោរវិន្ទំ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោ និហីនោ សិរិមាវ សេយ្យោ ។

(៦០៨) លទ្ធា សុខំ មជ្ជតិ អប្បបញ្ញោ
ទុក្ខេន ផុដ្ឋោបិ បមោហមេតិ
អាគន្តុនា សុខទុក្ខេន ផុដ្ឋោ
បវេធតិ វារិចរោវ ឃម្មេ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោវ សេយ្យោ ន យសស្សិ ពាលោ ។

(៦០៩) ទុមំ យថា សាទុផលំ អរញ្ញេ
សមន្តតោ សមភិសរន្តិ បក្ខី



(៦០៧) (ពាក្យសេនកៈ...) សិល្បៈនេះ រមែងមិនផ្តល់នូវភោគសម្បត្តិទេ បុគ្គលមានផៅពង្ស ក៏មិនផ្តល់នូវបុគ្គលបាននូវភោគសម្បត្តិដែរ ចំណែកបុគ្គលអ្នកមាននូវសម្បុរនៃសរីរៈ (មានរូបរាងល្អ) ក៏មិនផ្តល់នូវបុគ្គលបាននូវភោគសម្បត្តិដែរ សូមទ្រង់ទតបុរសអ្នកដែលនិយាយមិនកើតគឺគោរវិន្ទសេដ្ឋី ជាមនុស្សហៀរទឹកមាត់ ដល់នូវសេចក្តីសុខ ជាអ្នកសោយសុខព្រោះសិរី ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

(៦០៨) (មហោសថ ) បុគ្គលអប្បប្រាជ្ញ បានសេចក្តីសុខហើយ រមែងស្រវឹង លុះត្រូវសេចក្តីទុក្ខប៉ះពាល់វិញ ក៏ដល់នូវសេចក្តីវង្វេង បុគ្គលអប្បប្រាជ្ញ ត្រូវសេចក្តីសុខនិងទុក្ខមកថ្មីៗប៉ះពាល់ហើយ ក៏រមែងញាប់ញ័រ ដូចជាវារិចរ (សត្វត្រាច់ទៅក្នុងទឹក) ដែលញាប់ញ័រក្នុងកាលក្តៅ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ ។

(៦០៩) (ពាក្យសេនកៈ . . . ) ពួកសត្វបក្សី តែងហើរសំដៅទៅពោមរោមដើមឈើ ដែលមានផ្លែផ្អែមក្នុងព្រៃ យ៉ាងណា

ឯឡមូ គំ សធនំ សគោត្តំ
ពហុជ្ជនោ ភជតិ អត្ថហេតុ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោ និហីនោ សិរិមាវ សេយ្យោ ។

(៦៦០) ន សាធុ ពលវា ពាលោ សាហសំ វិន្ទតេ ធនំ
កន្ទន្តមេតំ ទុម្មេធំ កឌ្ឍន្តិ និរយំ ភុសំ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោវ សេយ្យោ ន យសស្សិ ពាលោ ។

(៦៦១) យា កាចិ នជ្ជោ គង្គមភិស្សវន្តិ
សព្វា វ តា នាមគោត្តំ ជហន្តិ
គង្គា សមុទ្ទំ បដិបជ្ជមានា
ន ខាយតេ ឥទ្ធិបរោ(១) ហិ លោកោ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោ និហីនោ សិរិមាវ សេយ្យោ ។

១. ម. ឥទ្ធិបញ្ញោ ហិលោក ។





ជនជាច្រើនតែងគប់រកនូវបុគ្គលស្ញុកស្ញូក ហើយប្រកបដោយទ្រព្យ និងគោត្រ ព្រោះហេតុតែប្រយោជន៍ ក៏យ៉ាងនោះដែរ ខ្ញុំព្រះអង្គ បានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

(៦៦០) (មហោសធ...) បុគ្គលពាលមានកំឡាំង រមែងបានទ្រព្យ (ព្រោះដណ្ដើម) នូវកម្មដ៏ក្តៅក្រហាយ មិនល្អទេ ពួកនិរយបាលតែង ទាញក្រឡាក់នូវបុគ្គលពាល ឥតប្រាជ្ញា ដែលកន្ទក់កន្ទេញនោះ យកទៅកាន់នរក ដ៏ក្តៅក្រហាយ ខ្ញុំព្រះអង្គបានឃើញហេតុនេះ ហើយ ទើបទូលថា បុគ្គលអ្នកមានប្រាជ្ញាហ្នឹងឯង ជា បុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ ។

(៦៦១) (អាចារ្យសេនកៈ...) ទឹកស្ទឹងទាំងឡាយណាមួយ រមែងហូរ ចាក់ទៅកាន់ទន្លេគង្គា ទឹកស្ទឹងទាំងអស់នោះ រមែងលះបង់នូវ នាមនិងគោត្រ ទឹកទន្លេគង្គាកាលហូរដល់សមុទ្រ (រមែង បានឈ្មោះថាមហាសមុទ្រយ៉ាងណា) បុគ្គលដែលមានប្រាជ្ញា ជាគ្រឿងសម្រេច ក៏មិនប្រាកដក្នុងលោកយ៉ាងនោះដែរ ខ្ញុំព្រះ អង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

(៦៦៦) យះគេហេត្វា ឧទធិ[១] បហាន្តិ

ឧបយន្តិ នជ្ជោ សព្វកាលំ អសង្ខ្យំ

សោ សាគរោ និច្ចមុឡារវេគោ

វេលំ ន អច្ចេតិ មហាសមុទ្ទោ

ឯវម្បិ ពាលស្ស បជប្បិតានិ

បញ្ញំ ន អច្ចេតិ សិរី កទាចិ

ឯតម្បិ ទិស្វាន អហំ វទាមិ

បញ្ញោវ សេយ្យោ ន យសស្សិ ពាលោ ។

(៦៦៧) អសញ្ញតោ ចេបិ បរេសមត្ថំ

ភណាតិ សណ្ឋានគតោ យសស្សី

តស្សេវ តំ រូហតិ ញាតិមជ្ឈេ

សិរី ហិ នំ ការយតេ ន បញ្ញា

ឯតម្បិ ទិស្វាន អហំ វទាមិ

បញ្ញោ និហីនោ សិរិមាវ សេយ្យោ ។

១. មសុទ្ធិ ។



(៦៦៦)(មហោសធ..) ៖ ណាកសេនកៈ បានពោលថាមហាសមុទ្រណា

ជាធំសមុទ្រធំ ទឹកស្ទឹងទាំងឡាយតែងហូរទៅក្នុងសមុទ្រនោះ

រាប់មិនបាន អស់កាលទាំងពួង សមុទ្រនោះ មានសមុទ្ររឹ

លើសលប់ជានិច្ចក៏មែន តែថា ទឹកមហាសមុទ្រក៏មិនគប្បីនឹងឲ្យ

ច្រាំងបានទេ ការប្រឹក្សារបស់មនុស្សពាល ក៏យ៉ាងនោះដែរ

ទាំងពីកាលណាមក បុគ្គលអ្នកមានសិរីរមែងមិនគប្បីនឹងឲ្យបុគ្គល

មានប្រាជ្ញាបានឡើយ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ

ទើបទូលថា បុគ្គលមានប្រាជ្ញាប៉ុណ្ណឹងឯង ជាបុគ្គលប្រសើរ ឯ

បុគ្គលពាលមានយស មិនប្រសើរ ។

(៦៦៧)(អសញ្ញតោ...) បុគ្គលមានយសបើនៅក្នុងទីនិច្ច័យ ទើ

ទុកជាមិនប្រៀនទុក ក៏អាចប្រាប់ផ្លូវសេចក្តី ចំពោះគ្នាផងដែរ

បាន សំដីរបស់បុគ្គលមានយសនោះឯង រមែងល្អណាស់

ក្នុងកណ្តាលនៃពួកញាតិ អ្នកដទៃមិនអាចញ៉ាំងបុគ្គលដែលមាន

ប្រាជ្ញា តែសាបសូន្យបាត់សិរី ឲ្យធ្វើការ (ទេ) បានទេ ខ្ញុំព្រះ

អង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា

ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

[៦៦៦] បរស្ស ក អង្គតោ កិំ ហេតុ

កាណោ មុសា កាសតិ អបរបញ្ញោ

សោ និន្ទិតោ ហោតិ សកាយ ឆព្ទេ

បច្ឆាបិ សោ ទុគ្គតិគាមិ ហោតិ

ឯតម្បិ និស្សាយ អហំ វទាមិ

បញ្ញោវ សេយ្យោ ន យសស្សិ កាណោ ។

[៦៦៧] អគ្គម្បិ ចេ កាសតិ ភូរិបញ្ញោ

អនាធិយោ អព្យថតោ ឆលិញ្ញោ

ន តស្ស តំ រូហតិ ញាតិមជ្ឈេ

សិរី ច បញ្ញាណវតោ ន ហោតិ

ឯតម្បិ និស្សាយ អហំ វទាមិ

បញ្ញោ និហីនោ សិរិមាវ សេយ្យោ ។

[៦៦៨] បរស្ស ក អង្គតោ កិំ ហេតុ

ន កាសតិ អលិកំ ភូរិបញ្ញោ

សោ បូជិតោ ហោតិ សកាយ ឆព្ទេ

បច្ឆាបិ សោ សុគតិគាមិ ហោតិ



(៦៦៦) (មហោសថ...) បុគ្គលកាលសឹក្បក្រាញ់ រមែងនិយាយកុហក ព្រោះហេតុនៃអ្នកដទៃផ្ទុយឯងក៏ បុគ្គលកាលនោះ ត្រូវគេតិះដៀលក្នុងកណ្ដាលទីប្រជុំ ក្នុងកាលខាងក្រោយ បុគ្គលកាលនោះ រមែងទៅកាន់ទុគ្គតិ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលដែលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលកាលមានយស មិនប្រសើរ ។

(៦៦៧) (កាព្យរសេនកៈ...) បុគ្គលមានប្រាជ្ញក្រាស់ផ្ទុយដែនដី មិនមានទីលំនៅ មិនមានទ្រព្យធន ជាបុគ្គលក្រីក្រ ទើបកេជា ពោលនូវសេចក្ដី (ណាមួយ) ពាក្យសំដីរបស់បុគ្គលដែលមានប្រាជ្ញនោះ ក៏មិនល្អលាស់ក្នុងកណ្ដាលនៃពួកញាតិ ទាំងសិរីរបស់បុគ្គលមានប្រាជ្ញក៏មិនមាន ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញ ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

(៦៦៨) (មហោសថ ..) បុគ្គលអ្នកមានប្រាជ្ញក្រាស់ផ្ទុយដែនដី រមែងមិននិយាយពាក្យលេះលោះ ព្រោះហេតុនៃបុគ្គលដទៃផ្ទុយឯងដែរ បុគ្គលអ្នកមានប្រាជ្ញនោះ មានគេបូជាក្នុងកណ្ដាលទីប្រជុំ លុះកាលខាងក្រោយ អ្នកមានប្រាជ្ញនោះ រមែងទៅកាន់សុគតិ

ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញាវ សេយ្យោ ន យសស្សិ ពាលោ ។

(៦៦៣) ហត្ថិគវស្សា មណិកុណ្ឌលា ច
នារិយោ ច ឥទ្ធកុលេសុ ជាតា
សព្វា តា ឧបភោគា ភវន្តិ
ឥទ្ធស្ស បោសស្ស អនិទ្ធិមន្តោ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោ និហីនោ សិរិមាវ សេយ្យោ ។

(៦៦៤) អសំវិហិតកម្មន្តំ ពាលំ ទុម្មន្តិមន្តិនំ[1]
សិរី ជហាតិ ទុម្មេធំ ជិណ្ណំវ ឧរគោ តចំ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញាវ សេយ្យោ ន យសស្សិ ពាលោ ។

(៦៦៥) បញ្ច បណ្ឌិតា មយំ ភទ្ទន្តេ
សព្វេ បញ្ជលិកា ឧបដ្ឋិតា តំ
ត្វំ នោ អភិភុយ្យ ឥស្សរោសិ
សក្កោវ ភូតបតិ ទេវរាជា

[1] ម. ទុម្មេធិនំ ។



ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ ។

(៦៦៣) (សេនកៈ...) ដំរី គោ សេះ កែវមណី កុណ្ឌលទាំងនារី ដែលកើតមានក្នុងត្រកូលដ៏ស្តុកស្តម្ភ ដំរី គោ សេះ ជាដើមទាំងអស់នោះ ជារបស់មិនមានឫទ្ធិ ទើបជាគ្រឿងឧបភោគ (ប្រើប្រាស់) របស់បុរសជាឥស្សរៈ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

(៦៦៤) (មហោសថ...) សិរីតែងលះបង់បុគ្គលពាល ដែលមិនចេះចាត់ចែងនូវការងារ ជាអ្នកមានគំនិតអាក្រក់ ឥតប្រាជ្ញា ដូចពស់ដែលលះបង់នូវសំណកចាស់ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ ។

(៦៦៥) (សេនកៈ..) បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គទាំង ៥ នាក់សុទ្ធសឹងជាបណ្ឌិត ប្រណម្យដៃចំពោះព្រះអង្គទាំងអស់គ្នា ព្រះអង្គជាធំលើសលប់ពួកខ្ញុំព្រះអង្គ ដូចជាទេវរាជៈឈ្មោះសក្កៈជាម្ចាស់នៃទេវតា

ឯតម្បិ ទិស្វាន អហំ វទាមិ

បញ្ញោ និហីនោ សិរិមាវ សេយ្យោ ។

(៤៣០) ទាសោវ បញ្ញស្ស យសស្សិ ពាលោ

អត្ថេសុ ជាតេសុ តថាវិធេសុ

យំ បណ្ឌិតោ និបុណំ សំវិធេតិ

សម្មោហមាបជ្ជតិ តត្ថ ពាលោ

ឯតម្បិ ទិស្វាន អហំ វទាមិ

បញ្ញោវ សេយ្យោ ន យសស្សិ ពាលោ ។

(៤៣១) អទ្ធា ហិ បញ្ញាវ សតំ បសត្ថា

កន្តា សិរី ភោគរតា មនុស្សា

ញាណញ្ច ពុទ្ធានមតុល្យរូបំ

បញ្ញំ ន អច្ចេតិ សិរី កទាចិ ។



ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

(៤៣០) (មហាសេន...) បុគ្គលពាលដែលមានយស ទុកដូចជាទាសៈ របស់បុគ្គលអ្នកមានប្រាជ្ញា កាលបើហេតុទាំងឡាយប្រាកដដូច្នោះកើតហើយ អ្នកប្រាជ្ញកាត់តែងដោយប្រាជ្ញាដ៏ល្អិតណា បុគ្គលពាលតែងដល់នូវការវង្វេងក្នុងប្រាជ្ញាដ៏ល្អិតនោះ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ ។

(៤៣១) តាមពិត ពួកសប្បុរស តែងសរសើរប្រាជ្ញាតែម្យ៉ាង ពួកមនុស្សតែងត្រេកអរចំពោះភោគៈ សិរីគ្រាន់តែជាទីត្រេកអររបស់(ពួកមនុស្សពាល) មួយទៀត ញាណនៃអ្នកប្រាជ្ញទាំងឡាយមិនមានអ្វីប្រៀបផ្ទឹមបានទេ តាំងពីកាលណាមក បុគ្គលអ្នកមានសិរី ក៏មិនដែលកន្លងនូវបុគ្គលមានប្រាជ្ញាបានឡើយ ។

(២៣២) យន្នំ អបុច្ឆិម្ហ អកិត្តយី នោ
មហោសធ កេវលធម្មទស្សី
គវំ សហស្សំ ឧសភញ្ច នាគំ
អាជញ្ញយុត្តេ ច រថេ ទស ឥមេ
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ
ទទាមិ តេ គាមវរានិ សោឡសាតិ ។

សិរិមន្ទជាតកំ បញ្ចមំ ។

## រោហន្តមិគជាតកំ

(២៣៣) ឯតេ យូថា បតិយន្តិ ភីតា មរណស្ស ចិត្តកា
គច្ឆ តុវម្បិ មា កង្ខិ ជីវិស្សន្តិ តយា សហ ។
(២៣៤) នាហំ រោហណ គច្ឆាមិ ហទយំ មេ អវ(១)កស្សតិ
ន តំ អហំ ជហិស្សាមិ ឥធ ហេស្សាមិ ជីវិតំ ។
តេ ហិ នូន មរិស្សន្តិ អន្ធា អបរិណាយកា
គច្ឆ តុវម្បិ មា កង្ខិ ជីវិស្សន្តិ តយា សហ ។

១ ម. អវកន្តតិ ។



(២៣២) (ព្រះបាទវិទេហរាជ...) ម្នាលមហោសធៈ ជាអ្នកឃើញធម៌សព្វគ្រប់ យើងបានសួរនូវប្រស្នាណា អ្នកបានដោះស្រាយនូវប្រស្នានោះដល់យើង យើងត្រេកអរដោយការដោះស្រាយនូវប្រស្នា (របស់អ្នក) យើងសូមឲ្យគ្រឿងទាំងនេះ គឺគោមួយពាន់ គោឧសភ (ជាដើម) ផង ដំរីផង រថដែលទឹមដោយសេះអាជានេយ្យ ១០ ផង ស្រុកល្អ ១៦ ផង ដល់អ្នក ។

ចប់ សិរិមន្ទជាតក ទី ៥ ។

## រោហន្តមិគជាតក

(២៣៣) (រោហណៈម្រឹគពោលថា) ម្នាលចិត្តកៈ ហ្វូងម្រឹគទាំងនេះ ភ័យខ្លាចសេចក្តីស្លាប់ ទើបរត់ចេញទៅ សូមអ្នកទៅចុះ កុំសង្ស័យឡើយ ហ្វូងម្រឹគទាំងឡាយនឹងរស់នៅជាមួយនឹងអ្នក ។

(២៣៤) (ចិត្តកៈម្រឹគជាប្អូនពោលថា) បពិត្ររោហណៈ ខ្ញុំមិនទៅទេ ហឫទ័យរបស់ខ្ញុំនៅតែសេចក្តីសោកគ្របសង្កត់ ខ្ញុំមិនលះបង់អ្នកបានទេ ខ្ញុំនឹងស៊ូលះបង់ជីវិតក្នុងទីនេះ ។

(រោហណ...) មាតាបិតាទាំងនោះ ជាសត្វខ្វាក់ មិនមានអ្នកដឹកនាំទេ នឹងស្លាប់មិនខាន អ្នកចូរទៅចុះ កុំសង្ស័យឡើយ មាតាបិតានឹងរស់នៅជាមួយនឹងអ្នក ។

តាហំ កេហាន គច្ឆាមិ  ហានយំ មេ អវកាសតិ

ន តំ ពទ្ធំ ជហិស្សាមិ  ឥធ ហោស្សាមិ ជីវិតំ ។

(២៣៥) តស្ស កីរ ជលាបេស្ស  ក្រោធ កញ្ញាស្មិំ អាយសេ

តស្ស ឥទ្ធិ មា កាមិ  ជីវិស្សន្តិ តយោ សហា ។

(២៣៦) តាហំ កេហាន គច្ឆាមិ  ហានយំ មេ អវកាសតិ

ន តំ អហំ ជហិស្សាមិ  ឥធ ហោស្សាមិ ជីវិតំ ។

តេ ហិ ទ្វេ ឧរិស្សន្តិ  អញ្ញា អបរិណាយកា

តស្ស ឥទ្ធិ មា កាមិ  ជីវិស្សន្តិ តយោ សហា ។

តាហំ កេហាន គច្ឆាមិ  ហានយំ មេ អវកាសតិ

ន តំ ពទ្ធំ ជហិស្សាមិ  ឥធ ហោស្សាមិ ជីវិតំ ។

(២៣៧) អយំ សោ លុទ្ទកោ ឯតិ  លុទ្ទរូបោ សហាវុធោ

យោ មេ វធិស្សតិ អជ្ជ  មាលុតា សត្តិយា ឥមំ ។



(ចិន្តកៈ...) បពិត្រលោកមាន: ខ្ញុំមិនទៅទេ ហេតុអ្វីយរបស់ខ្ញុំនៅ សេចក្ដីសោកតាញកន្ត្រាក់ ខ្ញុំមិនលះបង់អ្នកបងដែលជាប់អន្ទាក់ទេ ខ្ញុំនឹងស៊ូលះបង់ជីវិតក្នុងទីនេះ ។

[៦៣៥] (កេទាន:ប្រើនកោលថា) ម្ចាស់នាងជាអ្នកភិតភ័យ នាងចូរទៅចុះ ចូរទៅចុះ ខ្ញុំនេះយើងជាប់ក្នុងអន្ទាក់ភាពនឹងនៃអក ចូរនាងទៅចុះ កុំសង្ស័យឡើយ មាតាបិតានឹងរស់នៅជាមួយនាង ។

[៦៣៦] (សុតតាប្រើនកោលថា) បពិត្រលោកមាន: ខ្ញុំមិនទៅទេ ហេតុអ្វីយរបស់ខ្ញុំ គ្រាសេចក្ដីសោកតាញកន្ត្រាក់ ខ្ញុំមិនលះបង់ពោលអ្នកបងទេ ខ្ញុំនឹងស៊ូលះបង់ជីវិតក្នុងទីនេះឯង ។

(កេទាន:...) មាតាបិតាទាំងនោះ ជាសត្វខ្វាក់ មិនមានអ្នកដឹកនាំ មុខជានឹងស្លាប់មិនខាន នាងចូរទៅចុះ កុំសង្ស័យឡើយ មាតាបិតានឹងរស់នៅជាមួយនឹងនាង ។

(សុតតាប្រើន...) បពិត្រលោកមាន: ខ្ញុំមិនទៅទេ ហេតុអ្វីយរបស់ខ្ញុំ គ្រាសេចក្ដីសោកតាញកន្ត្រាក់ ខ្ញុំមិនលះបង់អ្នកបងដែលជាប់អន្ទាក់ទេ ខ្ញុំនឹងស៊ូលះបង់ជីវិតក្នុងទីនេះឯង ។

[៦៣៧] (កេទាន:ប្រើន...) ព្រានណានឹងសំឡាប់យើង គឺនៅថ្ងៃនេះដោយព្រួញ ឬដោយលំពែង ព្រានមានរូបដ៏សាហាវ មានកាំភ្លើងជាប់ជាមួយ កំពុងដើរមក ។

(២៥៨) សា មុហុត្តំ បលាយិត្វា  ភយដ្ដា ភយតជ្ជិតា
សុទុក្ករំ អការា ភីរុ  មរណាយូបនិវត្តថ ។

(២៥៩) កិន្នុ តេមេ មិគា ហោន្តិ  មុត្តា គន្ទំ ឧទាសរេ
ន មំ ចជិតុមិច្ឆន្តិ  ជីវិតស្សាបិ ការណា ។

(២៦០) ញាតកា ហោន្តិ មេ លុទ្ទ  សោទរិយា បិតាមាតុកា
ន មំ ចជិតុមិច្ឆន្តិ  ជីវិតស្សាបិ ការណា ។

(២៦១) តេ ហិ មូឡ នរិស្សន្តិ  អគ្គា អបរិណាយកា
បត្តម្ហំ ជីវិតំ ទេហិ  កាតរំ មុញ្ច លុទ្ទក ។

(២៦២) សោ តេ អហំ បមោចេស្សាមិ  មាតាបេតិករំ មិគំ
នន្ទន្តុ មាតាបិតរោ  មុត្តំ ទិស្វា មហាមិគំ ។

(២៦៣) ឯវំ លុទ្ទក នន្ទស្សុ  សហ សព្វេហិ ញាតិភិ
យថាហមជ្ជ នន្ទាមិ  មុត្តំ ទិស្វា មហាមិគំ ។



(២៥៨) (អភិសម្ពុទ្ធគាថា) សុភមាតាម្រឹគនោះជាសត្វភិតភ័យ ស្លុតខ្លាំង ក៏បម្រះបោលចេញអំពីភ័យហើយ តែនៅ អស់ពេលមួយស្របក់ ត្រឡប់មកវិញព្រោះសេចក្តីស្នេហាវិញ ឈ្មោះថាបានធ្វើនូវអំពើដ៏កម្រក្រៃពេក ។

(២៥៩) (ព្រានសួរថា) ម្រឹគទាំងនេះ ត្រូវជាអ្វីនឹងឯង រួចចាកអន្ទាក់ហើយ ចូលមកកាន់អ្នកវិញ ម្រឹគទាំងនោះសូម្បីមានហេតុដល់ជីវិត ក៏មិនព្រមបោះបង់អ្នក ។

(២៦០) (រោហនៈម្រឹគ...) ម្នាលព្រាន ម្រឹគទាំងនេះ ជាបងប្អូនរបស់ខ្ញុំ កើតក្នុងផ្ទៃជាមួយគ្នា មានមាតាតែមួយ សូម្បីមានហេតុដល់ជីវិត ក៏មិនព្រមបោះបង់ចោលខ្ញុំ ។

(២៦១) (ចិត្តៈម្រឹគ...) ម្នាលព្រាន មាតាបិតាទាំងនោះ ជាសត្វខ្វាក់ មិនមានអ្នកដឹកនាំ នឹងស្លាប់មិនខាន សូមអ្នកឲ្យនូវជីវិតដល់ម្រឹគទាំង ៣ សូមអ្នកលែងរោហនៈម្រឹគជាបងខ្ញុំចេញ ។

(២៦២) (ព្រាន...) ខ្ញុំនឹងលែងនូវម្រឹគ ដែលជាអ្នកចិញ្ចឹមនូវមាតាបិតា ឲ្យដល់អ្នកទាំងឡាយ មាតាបិតាគួររីករាយ ព្រោះឃើញនូវម្រឹគដ៏ប្រសើរដែលរួចហើយចុះ ។

(២៦៣) (ចិត្តៈម្រឹគ...) ម្នាលព្រាន ថ្ងៃនេះខ្ញុំត្រេកអរ ព្រោះបានឃើញនូវម្រឹគដ៏ប្រសើរដែលរួចហើយ យ៉ាងណា សូមអ្នកត្រេកអរជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនោះដែរ ។

(៦៦៦) កាមំ តុំ ជនោ ភ្ហោ ការសំ ទុចរិតស្មិ ជីវិត

កាមំ បុត្ត អមោចេសិ ក្រុដាសន្ត លុទ្ធកោ ។

(៦៦៧) ភណំ កណ្ណសុខំ គិរំ ហទយង្គំ ហទយស្សិតំ

សុភាសិតាហិ ភាសាហិ ធិត្តាកោ មំ អមោចយិ ។

ភណំ កណ្ណសុខំ គិរំ ហទយង្គំ ហទយស្សិតំ

សុភាសិតាហិ ភាសាហិ សុកតា មំ អមោចយិ ។

សុត្វា កណ្ណសុខំ គិរំ ហទយង្គំ ហទយស្សិតំ

សុភាសិតានិ សុត្វាន លុទ្ទកោ មំ អមោចយិ ។

(៦៦៨) ឯវំ អានន្ទិតោ ហោតុ សហ ទារេហិ លុទ្ទកោ

យថា ហមជ្ជ នន្ទាមិ ទិស្វា គេហមាគតំ ។

(៦៦៩) ននុ ត្វំ អវច លុទ្ទ ចម្មកញ្ញាណំ អាហរំ

អថ កេន នុ វណ្ណេន ចម្មកញ្ញាណំ នាហរិ ។

---

១. ម. ចាយព័ស្សុំ ។



(៦៦៦) (ភរិយាព្រានសួរថា) កាលបើម្រឹគចូលទៅដល់ (កាន់សេចក្តី ស្លាប់)ហើយ តើអ្នកបានដោះដោយហេតុអ្វី នែកូន ព្រានបាន ដោះអ្នកចេញចាកអន្ទាក់ដោយ តើដោយហេតុដូចម្តេច ។

(៦៦៧) (ពោធិសត្វ...) ពិត្តៈព្រឹកនិយាយពាក្យ ជាសុខដល់ត្រចៀក ជាពាក្យចូលទៅកាន់ហឫទ័យ ស្រស់ស្រាយក្នុងហឫទ័យ បានដោះខ្ញុំ (ចាកអន្ទាក់) ដោយពាក្យជាសុភាសិត ។ សុកតាព្រឹកនិយាយ ពាក្យជាសុខដល់ត្រចៀក ជាពាក្យចូលទៅកាន់ហឫទ័យ ស្រស់ស្រាយ ក្នុងហឫទ័យ បានដោះខ្ញុំ (ចាកអន្ទាក់) ដោយពាក្យជាសុភាសិត ។ ព្រាននោះបានស្តាប់ពាក្យ ជាសុខដល់ត្រចៀក ជាពាក្យចូលទៅ កាន់ហឫទ័យ ស្រស់ស្រាយក្នុងហឫទ័យហើយ ក៏បានដោះខ្ញុំ (ចាក អន្ទាក់) ព្រោះស្តាប់ពាក្យជាសុភាសិត ។

(៦៦៨) (ព្រឹកអាឯពោធិសត្វពោលថា) ខ្ញុំសូម ឲ្យត្រេកអរ ព្រោះបាន ឃើញព្រះពោធិសត្វដែលមកដល់ យ៉ាងណា សូមឲ្យព្រានត្រេកអរ ដោយកូននឹងប្រពន្ធទាំងឡាយ យ៉ាងនោះដែរ ។

(៦៦៩) (ព្រានភរិយាប្រាប់ស្វាមី) ម្នាលព្រាន អ្នកបាននិយាយថា ខ្ញុំនឹងនាំស្បែក ឬស្បែកម្រឹគមក មិនតែប៉ុណ្ណោះ ដោយហេតុដូចម្តេច ទើប អ្នកមិននាំយកស្បែក ឬស្បែកម្រឹគមក ។

(៦៥៨) ហារយន្តុ ហត្ថី ក្ខេ តាសព្វា សោ មិគោ
អភិរុយ្ហ តំ មិគកំ ឥត្ថា បុត្តា ទុហាសយេ។
ឥស្សរេ អហុ សំវេគោ អត្ថោ លោមហំសនោ
ឥមញ្ចាហំ ទិដ្ឋំ បាតុ អជ្ជ ហំសោម្ហិ ជីវិតំ។

(៦៥៩) កីទិសោ តេ មិគោ លុទ្ទ កីទិសោ ឧត្តមោ មិគោ
កាបិលោ កាទិសោ កណ្ហោ កេ បសំសសិ។

(៦៦០) ទិព្វាគសិង្គា សុចិភិលា ជាតរូបមយា
ហោ លោហិតកា អស្សំ អញ្ជនគ្គា មនោរមា។

(៦៦១) បទិសា តេ មិគា ភេរ បទិសា ឧត្តមា មិគា
នានាបេក្ខក ភេរ ឧ តេ សោ អភិហារយិ[១]។

(៦៦២) ឥទ្ធិ មិគ្គសតំ លុទ្ទ ជ្វលញ្ច មណិកុណ្ឌលំ
បក្ខស្សញ្ច បល្លង្កំ ឧម្មាកុម្មសំវិធិតំ។

• ១. ឱ. អភិហារយំ ។ ម. អភិហារយិ ។



(៦៥៨) (ព្រាម...) ម្រឹគនោះចូលមកជាប់អន្ទាក់បង់ ជាប់នៅកន្លែងនាក់
រាជរឹងហើយ ដែលម្រឹគនៅទីដែលខ្លួន (បានគូទ) ក៏ចូលមកការស្គាល់
ម្រឹគនោះ ។ សេចក្ដីតក់ស្លុត ការព្រឺព្រួចរោម ដែលមិនធ្លាប់
កើតក៏កើតមានដល់ខ្ញុំព្រះអង្គនោះ ជាលើកខ្ញុំព្រះអង្គ ទីដែលធ្លាប់ម្រឹគ
នេះនៅ ខ្ញុំព្រះអង្គនឹងលះបង់នូវជីវិត ក្នុងថ្ងៃនេះឯង ។

(៦៥៩) (ព្រាហ្មណ៍...) ម្នាលព្រាន ពួកម្រឹគទាំងនោះមានសម្បុរដូចម្ដេច
ពួកម្រឹគមានធម៌ដូចម្ដេច មានវណ្ណៈដូចម្ដេច មានសីលដូចម្ដេច ទើប
អ្នកសរសើរពួកម្រឹគទាំងនោះ ។

(៦៦០) (ព្រាន...) ពួកម្រឹគទាំងនោះ មានស្នែងស មានកេសកន្ទុយ
ស្អាត មានស្បែកលាយដូចមាស មានជើងក្រហម មានភ្នែកជិត
បារីដូចជាគេបន្តក់ នូវជាទីត្រេកអរនៃចិត្ត ។

(៦៦១) បពិត្រព្រះសម្មតិទេព ពួកម្រឹគទាំងនោះ មានសភាពដូច្នេះ ពួក
ម្រឹគមានធម៌ដូច្នេះ បពិត្រព្រះសម្មតិទេព ពួកម្រឹគទាំងនោះ ជាសត្វ
ចិញ្ចឹមមាតាបិតា ខ្ញុំព្រះអង្គមិនហ៊ានតាំងយកម្រឹគទាំងនោះមកទេ ។

(៦៦២) (ព្រះរាជា..) នែព្រាន យើងនឹងឲ្យ នូវគ្រឿងអលង្ការ
ម្រឹគសត នូវកែវមណី នឹងកុណ្ឌល និងក្រាលក្រាលជង នូវបល្ល័ង្ក
ដូចជ្រុង ជីវិតវៀង ដូចជាផ្កាត្រកៀតជង (ដល់អ្នក) ។

ទ្វេ ច សាទិសិយោ ភរិយា ឧសភញ្ច គវំ សតំ
ធម្មេន រជ្ជំ ការេស្សំ ពហុការោ មេសិ លុទ្ទក ។
កសិវណិជ្ជា ឥណទានំ ឧញ្ឆាចរិយា ច លុទ្ទក
ឯតេន ទារំ ពោសេហិ មា បាបំ អករី បុនាតិ ។

រោហន្តមិគជាតកំ ចតុត្ថំ ។

## ហំសជាតកំ

(៦៥៣) ឯតេ ហំសា បក្កមន្តិ វក្កង្គា ភយមេរិតា
ហរិត្តច ហេមវណ្ណ កាមំ សុមុខ បក្កម
ឱហាយ មំ ញាតិគណា ឯកំ បាសវសំ គតំ
អនបេក្ខមានា គច្ឆន្តិ កឹ ឯកោ អវហីយសិ ។
បតេវ បតតំ សេដ្ឋ នត្ថិ ពទ្ធេ សហាយតា[១]
មា អនីឃាយ ហាបេសិ កាមំ សុមុខ បក្កម ។

១ ម. សហាយតាតិ ទិស្សតិ ។



ម្នាលព្រាន អ្នកមានឧបការៈច្រើនដល់យើង យើង (នឹងឲ្យ) នូវភរិយាពីរនាក់ ដែលមានរូបទ្រង់ទ្រាយស្មើគ្នា នូវគោមួយរយ មានទាំងគោឧសភផង យើងនឹងសោយរាជ្យតាមធម៌ ។ ម្នាលព្រាន អ្នកចូរចិញ្ចឹមកូនប្រពន្ធដោយការងារទាំងនេះ គឺកសិកម្ម ពាណិជ្ជកម្ម ឥណទានកម្ម (ការឲ្យខ្ចី) និងការស្វែងរកចំណី (ជាសម្មាអាជីវៈ) អ្នកកុំធ្វើបាបម្តងទៀតឡើយ ។

ចប់ រោហន្តមិគជាតក ទី ៤ ។

## ហំសជាតក

(៦៥៣) (ស្តេចហង្សព្រះពោធិសត្វពោលថា) ពួកហង្ស មានកន្ទុយកោងនេះ ត្រូវភ័យគ្របសង្កត់ហើយ ក៏ហើរទៅ ម្នាលសុមុខៈ មានសម្បុរដូចមាស អ្នកចូរជៀសខ្លួនទៅចុះ ។ ពួកញាតិលះបង់ខ្ញុំតែម្នាក់ឯង ដែលលុះអំណាចអន្ទាក់ ជនទាំងនោះឥតអាល័យ ហើរទៅហើយ ចុះអ្នកនៅតែម្នាក់ឯងដូចម្តេចបាន ។ ការដែលហើរចេញទៅ របស់ពួកសត្វស្លាប ជាការប្រសើរ ការប្រព្រឹត្តទៅជាមួយអ្នកដែលជាប់ចំណង ជាការប្រសើរ មិនមែនទេ អ្នកកុំធ្វើសេចក្តីព្យាយាមឲ្យសាបសូន្យ ដោយសេចក្តីត្រូវឡើយ ម្នាលសុមុខៈ អ្នកចូរជៀសខ្លួនចេញទៅតាមប្រាថ្នាចុះ ។

(២៥៤) នាហំ ទុក្ខបរេតោបិ ធតរដ្ឋ តុវំ ជហេ

ជីវិតំ មរណំ វា មេ តយា សទ្ធិំ ភវិស្សតិ ។

(២៥៥) ឯតទរិយស្ស កល្យាណំ យំ ត្វំ សុមុខ ភាសសិ

តញ្ច វីមំសមានាហំ បតតេ តំ អវស្សជឹ ។

(២៥៦) អបទេន បទំ យាតិ អន្តលិក្ខចរោ ទិជោ

អារា បាសំ ន ពុជ្ឈិ ត្វំ ហំសានំ បវរុត្តម ។

(២៥៧) យទា បរាភវោ ហោតិ បោសោ ជីវិតសង្ខយេ

អថ ជាលញ្ច បាសញ្ច អាសជ្ជាបិ ន ពុជ្ឈតិ ។

(២៥៨) ឯតេ ហំសា បក្កមន្តិ វក្កង្គា ភយមេរិតា

ហរិត្តច ហេមវណ្ណ ត្វញ្ញេវ អវហីយសិ ។

ឯតេ ភុត្វា ច បិត្វា ច បក្កមន្តិ វិហង្គមា

អនបេក្ខមានា វក្កង្គា ត្វញ្ញេវេកោ ឧបាសសិ ។



(២៥៤) (សុមុខៈហង្សពោលថា) បពិត្រស្ដេចហង្សឈ្មោះធតរដ្ឋ ព្រះអង្គត្រូវសេចក្ដីទុក្ខគ្របសង្កត់ហើយ ខ្ញុំព្រះអង្គមិនលះបង់នូវព្រះអង្គទេ ការរស់ឬការស្លាប់របស់ខ្ញុំព្រះអង្គ នឹងមាននៅជាមួយព្រះអង្គ ។

(២៥៥) (ស្ដេចហង្ស...) ម្នាលសុមុខៈ អ្នកពោលនូវពាក្យណា ពាក្យនុ៎ះជាពាក្យល្អរបស់អ្នកឯង ចំណែកខាងខ្ញុំ ល្បងមើលអ្នក ក្នុងការហើរចេញទៅ ទើបពោលពាក្យ (យ៉ាងនេះ) នឹងអ្នក ។

(២៥៦) (កូនព្រានព្រៃពោលថា) សត្វបក្សីជាសត្វគ្រាច់ទៅក្នុងអាកាស រមែងទៅកាន់ផ្លូវតាមអាកាសដែលមិនមែនជាផ្លូវ ម្នាលអ្នកដ៏ប្រសើរ ជាធំពួកបក្សីហង្ស (ស្ដេច) អ្នកមិនដឹងនូវអន្ទាក់អំពីចម្ងាយ ។

(២៥៧) (ស្ដេចហង្ស...) សេចក្ដីវិនាសមានមក ក្នុងកាលណា សត្វកាលបើជីវិតត្រូវអស់ហើយ ទោះបីប្រទះនូវសំណាញ់ ឬអន្ទាក់ រមែងមិនដឹង ក្នុងកាលនោះ ។

(២៥៨) (ព្រានពោលនឹងសុមុខៈហង្សថា) ពួកបក្សីហង្សមានកក្តក់ទាំងនេះ លុះត្រូវភ័យគ្របសង្កត់ហើយ ក៏ហើររត់ទៅ ម្នាលអ្នកមានស្បែកដ៏ទៀង មានវណ្ណៈដូចមាស អ្នកម្នាក់ឯងសល់នៅ ។ ពួកបក្សីទាំងនេះ ជាសត្វទៅតាមអាកាស ឥតមានអាល័យ ជាសត្វមានកក្តក់ លុះស៊ីហើយផឹកហើយ ក៏ហើរចេញទៅ អ្នកតែម្នាក់ឯងចូលមកវិញ ។

កឹ នុ តាយំ ទិជា ហោតិ  មុត្តា ពទ្ធំ ឧបាសសិ

ឱហាយ សកុណា យន្តិ  កឹ ឯកោ អវហិយ្យសិ ។

(៦៥៩) រាជា មេ សោ ទិជាមិត្តោ  សខា បាណសមោ ច មេ

នេវ នំ វិជហិស្សាមិ  យាវ កាលស្ស បរិយាយំ ។

(៦៦០) យោ ច ត្វំ សខិនោ ហេតុ  បាណំ ចជិតុមិច្ឆសិ

សោ តេ សហាយំ មុញ្ចាមិ  ហោតុ រាជា តវានុគោ ។

(៦៦១) ឯវំ លុទ្ទក នន្ទស្សុ  សហ សព្វេហិ ញាតិភិ

យថាហមជ្ជ នន្ទាមិ  មុត្តំ ទិស្វា ទិជាធិបំ ។

(៦៦២) កច្ចិ នុ ភោតោ កុសលំ  កច្ចិ ភោតោ អនាមយំ

កច្ចិ រដ្ឋមិទំ ផីតំ  ធម្មេន អនុសាសសិ ។

(៦៦៣) កុសលញ្ចេវ មេ ហំស  អថោ ហំស អនាមយំ

អថោ រដ្ឋមិទំ ផីតំ  ធម្មេន អនុសាសហំ



បក្សី នេះត្រូវជាអ្វីនឹងអ្នក ទើបអ្នកនៅចាំ (ពាក់អន្ទាក់) ចូលមក
គេបក្សីដែលជាប់ហើយ ពួកបក្សីទាំងឡាយហើរចោល អស់ទៅហើយ
ហេតុអ្វីបាន អ្នកសល់នៅតែម្នាក់ឯង ។

(៦៥៩) (សុមុខៈហង្ស...) បក្សីនេះជាស្ដេចរបស់យើងផង ជាមិត្ត
របស់យើងផង ជាសំឡាញ់ស្មើដោយជីវិតរបស់យើងផង ខ្ញុំយើង
នឹងមិនលះបង់នូវបក្សីនោះ ដរាបអស់កាលនៃជីវិត ។

(៦៦០) (ព្រាន..) អ្នកណាប្រាថ្នាលះបង់ជីវិត ព្រោះហេតុសំឡាញ់
យើងនឹងលែងនូវសំឡាញ់របស់អ្នកនោះ ក្ដីការលះបង់នេះ
សូមឱ្យស្ដេចរបស់អ្នកទៅជាមួយនឹងអ្នកចុះ ។

(៦៦១) (សុមុខៈហង្ស...) ម្នាលព្រាន ក្ដីដូចនេះ យើងត្រេកអរព្រោះ
បានឃើញនូវស្ដេចបក្សីរួចចាកចំណង យ៉ាងណា អ្នកចូរត្រេកអរ
ជាមួយនឹងញាតិទាំងអស់ យ៉ាងនោះដែរ ។

(៦៦២) (ស្ដេចហង្ស...) ព្រះអង្គមានសេចក្ដីសុខស្រួលទេឬ ព្រះអង្គ
មិនមានជម្ងឺផ្កាត់ទេឬ ព្រះអង្គនៅតែប្រៀនប្រដៅ នូវអ្នកដែនដ៏ធំ
ទូលាយនេះ តាមធម៌ទេឬ ។

(៦៦៣) (ព្រះរាជាតបថា) ម្នាលហង្ស យើងមានសេចក្ដីសុខស្រួលទេ
ម្នាលហង្ស យើងមិនមានជម្ងឺផ្កាត់ទេ ខ្ញុំយើងក៏បានប្រៀន
ប្រដៅ នូវអ្នកដែនដ៏ធំទូលាយនេះ តាមធម៌ ។

(៦៦៤) កច្ចិ ភោតោ អមច្ចេសុ ទោសោ កោចិ ន វិជ្ជតិ

កច្ចិ អារា អមិត្តា តេ ឆាយា ទក្ខិណតោរិវ ។

(៦៦៥) អថោបិ មេ អមច្ចេសុ ទោសោ កោចិ ន វិជ្ជតិ

អថោ អារា អមិត្តា មេ ឆាយា ទក្ខិណតោរិវ ។

(៦៦៦) កច្ចិ តេ សាទិសី ភរិយា អស្សវា បិយភាណិនី

បុត្តរូបយសូបេតា តវ ឆន្ទវសានុគា ។

(៦៦៧) អថោបិ មេ សាទិសី ភរិយា អស្សវា បិយភាណិនី

បុត្តរូបយសូបេតា មម ឆន្ទវសានុគា ។

(៦៦៨) កច្ចិ តេ ពហវោ បុត្តា សុជាតា រដ្ឋវឌ្ឍន

បញ្ញាជវេន សម្បន្នា សម្មោទន្តិ តតោ តតោ ។

(៦៦៩) សន្តិ មេ ពហវោ តេ បុត្តា ចតុរដ្ឋ មយា សុតា



(៦៦៤) (ស្ដេចថា...) ក្នុងអាមាត្យរបស់ព្រាហ្មណ៍ មិនមានកំហុសណាមួយទេឬ ពួកសត្រូវនៃព្រាហ្មណ៍ក្នុងទីឆ្ងាយ ដូចជាស្រមោល (ដែលមិនមាន) ក្នុងទិសខាងត្បូងដែរឬ ។

(៦៦៥) (ព្រាហ្មណ៍...) ក្នុងអាមាត្យរបស់យើង មិនមានកំហុសណាមួយទេ ទាំងសត្រូវរបស់យើងក្នុងទីឆ្ងាយ ក៏ដូចស្រមោល (ដែលមិនមាន) ក្នុងទិសខាងត្បូង ដូច្នោះ ។

(៦៦៦) (ស្ដេចថា...) ភរិយារបស់ព្រាហ្មណ៍មានចិត្តស្មើគ្នា ជាស្រីស្ដាប់បង្គាប់ព្រាហ្មណ៍ ស្រដីនូវពាក្យជាទីស្រឡាញ់ បរិបូណ៌ដោយបុត្តនឹងរូបនឹងយសបរិវារ ល្មមតាមអំណាចសេចក្ដីប្រាថ្នារបស់ព្រាហ្មណ៍ដែរឬ ។

(៦៦៧) (ព្រាហ្មណ៍...) ភរិយារបស់យើងមានចិត្តស្មើគ្នា ជាស្រីស្ដាប់បង្គាប់យើង ស្រដីពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្តនឹងរូបនឹងយសបរិវារ ល្មមតាមអំណាចសេចក្ដីប្រាថ្នារបស់យើងទេ ។

(៦៦៨) (ស្ដេចថា...) ចុះព្រាហ្មណ៍អ្នកញុំាងដែនឲ្យចំរើន ព្រាហ្មណ៍មានព្រះរាជបុត្រច្រើន កើតឡើងដោយល្អ បរិបូណ៌ដោយសន្ទុះនៃប្រាជ្ញា ត្រេកអរក្នុងទីនោះៗ ដែរឬ ។

(៦៦៩) (ព្រាហ្មណ៍...) ម្នាលស្ដេចអ្នកញុំាងដែនឲ្យចំរើន យើងមានកូនមួយរយមួយនាក់ ដែលអ្នកផងឮសូរសាយថា យើងជាអ្នក (មានកូនច្រើន)

តេសំ ត្វំ កាតុមរហសិ   តាសុជ្ជុទ្ធិ តេ វទា ។

(៤៧០) ឧបបន្នោ ចេ ហោតិ   ជាតិយា វិនយេន ច

អថ បច្ឆា គុណេ យោតិ   គារេ្វ អាភស្ស សីលតិ ។

តស្ស សីហីរបញ្ញស្ស   អាភេ ជាយតេ មហា

វត្តមេក្ខាវ វស្សាទិ   ថុលាធំ មនុស្សត្តិ ។

អសារេ សារយោគញ្ញូ   មតី នត្វេវ វិន្ទតិ

សារកាវ គិរព្ភស្ស   អត្ថកយោវ សីលតិ ។

ហីនជច្ចោបិ ចេ ហោតិ   ឧដ្ឋាតា ធិតិមា នរោ

អាចារសីលសម្បន្នោ   និសេ អគ្គីវ ភាសតិ ។

ឯតំ វេ ឧបមំ កត្វា   បុត្តេ វិជ្ជាសុ វាចយ

សំវិរុឡ្ហេថ មេធាវី   ខេត្តេ ពីជំវ វុដ្ឋិយា ។

ហំសជាតកំ ឆដ្ឋំ ។

---



កូនចៅទាំងនោះ ដែលមិនទាន់ដឹងសំដីរបស់អ្នកនោះ សូមអ្នកប្រាប់ នូវសំដី ដែលត្រូវធ្វើដល់កូនចៅទាំងនោះចុះ ។

(៤៧០) (សេដ្ឋីតបថា...) បុគ្គលកើតក្នុងត្រកូលណា ដោយជាតិនិងវិន័យ តែបើក្នុងកាលជាខាងក្រោយ គឺកាលដែលខ្លួនចាស់ ធ្វើនូវសេចក្ដីព្យាយាមក្នុងកិច្ចការ ដែលនាំឲ្យចុះក្នុងសេចក្ដីអន្តរាយ ។ កាលបុគ្គលចាស់នោះ មានប្រាជ្ញាក្រៃលែង ពោលគឺកើតឡើងជាច្រើនយ៉ាង បុគ្គលចាស់នោះ ដែលឃើញគុណនៃព្រឹទ្ធចាស់ ដូចបុគ្គលនឹងរកគ្រឿងស្លៀកពាក់ ។ បុគ្គលចាស់ដឹងនូវសេចក្ដីព្យាយាមក្នុងលទ្ធិមិនមានខ្លឹមជាលទ្ធិមានខ្លឹម ដែលមិនបានសួរប្រាជ្ញ តែដឹងថាចុះក្នុងសេចក្ដីអន្តរាយមិនបាន ដូចជាសត្វសេកៈ ល័ងចុះក្នុងត្រង់តែតិច ។ ជនកើតក្នុងជាមានជាតិថោកថយ តែជាអ្នកមានការប្រឹងប្រែង មានប្រាជ្ញា ជាប្ដូរហើយជាតារសើប ដែលរុងរឿងដូចជាភ្លើង ក្នុងរាត្រី ។ សូមព្រះអង្គធ្វើសេចក្ដីនេះឯង ឲ្យជាគ្រឿងប្រៀបធៀប ហើយញ៉ាំងកូនប្រុសផង ឲ្យប្រតិស្ឋានក្នុងវិជ្ជាទាំងឡាយ ព្រោះអ្នកប្រាជ្ញតែងលូតលាស់ល្អ ដូចពូជដែលលូតលាស់ក្នុងស្រែ ក្នុងកាលដែលមានភ្លៀង ។

ចប់ ហំសជាតក ទី ៦ ។

# សត្តិគុម្ពជាតកំ

[៤៧១] មិគលុទ្ធោ មហារាជា បញ្ចាលានំ រថេសភោ

និក្ខន្តោ សហ សេនាយ ឱគណោ វនចារកោ ។

តត្ថទ្ទស អរញ្ញស្មិំ តក្ករានំ កុដឹ កតំ

តម្ហា[១] កុដិយា និក្ខម្ម សុវោ លុទ្ទានិ ភាសតិ ។

សម្បន្នវាហនោ បោសោ យុវា សម្មដ្ឋកុណ្ឌលោ

សោភតិ លោហិតុណ្ហីសោ ទិវា សុរិយោវ ភាសតិ ។

មជ្ឈន្តិកេ សម្បត្តេ សុត្តោ រាជា សសារថិ

ហន្ទស្សាភរណំ សព្វំ គណ្ហាម សាហសា មយំ ។

និសីថេ[២] រហោទានិ សុត្តោ រាជា សសារថិ

អាទាយ វត្ថំ មណិកុណ្ឌលញ្ច

ហន្ត្វាន សាខាហិ អវត្ថរាម ។

[៤៧២] កិន្នុ ឧម្មត្តរូបោវ សត្តិគុម្ព បភាសសិ

ទុរាសទា ហិ រាជានោ អគ្គិ បជ្ជលិតោ យថា ។

១ ម. តស្សា ។ ២ ម. និសីថេបិ ។ ឱ. និសីថេ ។



# សត្តិគុម្ពជាតក

[៤៧១] (ព្រះមានព្រះភាគត្រាស់ថា) មហារាជជាធំជាងព្រានម្រឹគ ជាបុគ្គលប្រសើរលើស របស់អ្នកដែនបញ្ចាល បានយាងចេញជាមួយនឹងសេនា សាបសូន្យពាក់កណ្តាល ស្តេចចូលមកកាន់ព្រៃ ។ បានឃើញផ្ទះ របស់ពួកចោរ ដែលគេធ្វើក្នុងព្រៃនោះ សត្វសេកហើរចេញអំពីផ្ទះនោះហើយ និយាយនូវសំដី ដ៏អាក្រក់ថា ព្រះរាជាជាបុរសកំលោះ មានយានជំនិះបរិបូណ៌ មានកុណ្ឌលដ៏ល្អ មានព្រះឧណ្ហីសៈ (ក្បាំង) ដ៏ក្រហមប្រាល ល្អរុងរឿងដូចព្រះអាទិត្យក្នុងវេលាថ្ងៃ ។ ឥឡូវនេះ ព្រះរាជាព្រមទាំងនាយសារថីដេកលក់ក្នុងវេលាថ្ងៃត្រង់ ហើយដូច្នោះ យើងនឹងយកគ្រឿងប្រដាប់ទាំងពួង របស់ព្រះរាជានោះដោយរហ័ស ។ ឥឡូវនេះ ស្តេចព្រមទាំងនាយសារថីដេកលក់ក្នុងទីស្ងាត់ ដូចនៅកណ្តាលអធ្រាត្រ

យើងនឹងយកសំពត់ កែវមណី និងកុណ្ឌល

ហើយសម្លាប់ រួចគ្របដោយមែកឈើ ។

[៤៧២] (បោរិកាសុត្តាហោរពោលថា) ម្នាលសត្តិគុម្ពៈ ឯងនិយាយដូចជាមនុស្សឆ្កួត ព្រោះថា ព្រះរាជាទាំងឡាយ យាងមកអំពីចម្ងាយ ប្រៀបដូចជាភ្លើងកំពុងឆេះ ។

(៦៧៣)អជ្ជ ហិ ត្វំ បតិកោ លុទ្ធោ  មហន្តោ ថុល្លាចិ កន្ទសិ

មាតរំ មន្តា ទត្តាយ  ការំ ន ត្វំ វិជិតុព្រសេ ។

(៦៧៤)មន្តេហិ សព្ព ការមាហោ រថំ យោជេត្វា សារថិ

សក្កុណោ ទេ ន វត្តុំ អត្ថំ កច្ចាន អស្សុមិ ។

(៦៧៥)យុត្តោ រថោ មហារាជ  យុត្តោ ច ពលវាហនោ

អធិតិដ្ឋ មហារាជ  អត្ថំ កច្ចាន អស្សុមិ ។

(៦៧៦)កោធុមេរ កតា សមេ្ត  យេ អស្សំ បរិចារកា

ឋិស កត្វាន បញ្ចាលោ  សុត្តោ តេសំ អនស្សុតា ។

កោធសង្ខារាធិ កណ្ហាជ  សត្តិយោ  តោមរានិ ច

ឋិស កត្វាន បញ្ចាលោ  មា តេ ធុត្តេ ជីវិតំ ។

(៦៧៧)អជាបកេ បនិធម្មិក  សុកេ លោហិតកុល្លិកោ

ស្វាគតេ មហារាជ  អតោ តេ អនុកត្តំ

ឥស្សរោសិ អនុប្បត្តោ  យំ វេទត្តិ បវេទយ ។

---

១ ម. ន ។





(៦៧៣) (សត្តុភស្តៈ ពោលថា) ម្នាលបតិកោលុទ្ធៈ អ្នកឯងដែលជាបុគ្គលស្រើប ទើបរំភើញញយើងយ៉ាងនេះ អ្នកសួរប៉ុណ្ណោះ (ពោរកម្ម) ព្រោះមាតារបស់ខ្ញុំតក្រោកមុខ ។

(៦៧៤) (ព្រះរាជាត្រាស់ថា) នែនាយសារថីសំឡាញ់ ចូរអ្នកលើករលាំង ព្រោកឡើង ចូរទឹមរថទៅ យើងមិនអាចញុំចិត្តនឹងលក្សណ៍ យើងនឹង ទៅកាន់អាស្រមវិញ ។

(៦៧៥) (នាយសារថីទូលថា) បពិត្រមហារាជ ទូលព្រះបង្គំបានទឹមរថ ទឹមពាហនៈដ៏មានកំឡាំងហើយ បពិត្រមហារាជ សូមព្រះអង្គឡើង គង់ចុះ យើងនឹងទៅកាន់អាស្រមវិញ ។

(៦៧៦) (សត្តុភស្ត. ) ពួករាជរាជកុលអាស្រម ទៅកន្លែងណាអស់ទៅហើយ ស្តេចកន្លែងបញ្ចាលរាជនៅជុំ ដំណើរមិនឃើញរបស់ពួកជារ ពាំងនោះហើយ ។ ពួកចាំងឡាយទៅបន្ទុះ ជា៖ នឹងលំពែង ស្តេច កដើងបញ្ចាលនៅកុំពីគេទៅ ពួកចាំងឡាយកុំប្រើដីកីតេស្បើយ ។

(៦៧៧) (កត់សម្ពទ្ធតាថា) ក្នុងកាលនោះ សត្វសេកដ៏ដទៃទៀត មានចំពុះសឹក្រហម បានទទួលការតាក់ថា បពិត្រមហារាជ ព្រះអង្គស្តេច មកស្រួលហើយ មួយទៀត ដំណើរមករបស់ព្រះអង្គមិនខាស់ទេ ព្រះអង្គជាធំបានមកដល់ហើយ សូមទ្រង់មានព្រះបន្ទូលប្រាប់នូវ ព្រះរាជបំណង ដែលមានក្នុងដំណើរយាងមកនេះចុះ ។

តិណ្ឌុកានិ បិយាលានិ មធុកេ កាសុមារិយោ

ផលានិ ខុទ្ទកប្បានិ ភុញ្ជ រាជ វរំ វរំ ។

ឥទម្បិ បានីយំ សីតំ អាភតំ គិរិគព្ភរា

តតោ បិវ មហារាជ សចេ ត្វំ អភិកង្ខសិ ។

អរញ្ញំ ឧញ្ឆាយ គតា យេ អស្មំ បរិចារកា

សយំ ឧដ្ឋាយ គណ្ហវ្ហោ ហត្ថា មេ នត្ថិ ទាតវេ ។

(៦៧៨) ភទ្ទកោ វតាយំ បក្ខី ទិជោ បរមធម្មិកោ

អថេសោ ឥតរោ បក្ខី សុវោ លុទ្ទានិ ភាសតិ ។

ឯតំ ហនថ ពន្ធថ មា វោ មុញ្ចិត្ថ ជីវិតំ

ឥច្ចេវំ វិលបន្តស្ស (១) សោត្ថិំ បត្តោស្មិ អស្សមំ ។

(៦៧៩) ភាតរោស្មា មហារាជ សោទរិយា ឯកមាតុកា

ឯករុក្ខស្មិំ (២) សំវឌ្ឍា នានាខេត្តគតា ឧភោ ។

សត្តិគុម្ពោ ច ចោរានំ អហញ្ច ឥសីនំ ឥធ

អសតំ សោ សតំ អហំ តេន ធម្មេន នោ វិនា ។

១- [illegible] ។ ២ [illegible] ។



បពិត្រព្រះរាជា សូមព្រះអង្គសោយផ្លែព្រីង ផ្លែទន្លាប់ ផ្លែចារ ផ្លែព្រះ ហម្ពង្គ ផ្លែស្រគំនិងផ្លែមៀនល្មមតូចៗ ដ៏ប្រសើរប្រសើរចុះ ។ បពិត្រមហារាជ ទឹកនេះសោតត្រជាក់ ដែលខ្ញុំនាំមកអំពីជ្រោះភ្នំ សូមព្រះអង្គសោយ (ទឹក) អំពីជ្រោះនោះចុះ បើព្រះអង្គប្រាថ្នា ។ ពួកជនដែលជាអ្នកបម្រើខ្ញុំព្រះអង្គ ទៅកាន់ព្រៃដើម្បីស្វែងរក (ភោជន) ហើយ សូមព្រះអង្គក្រោកឡើង យកដោយព្រះអង្គឯងចុះ ខ្ញុំព្រះអង្គមិនមានដៃប្រគេនទេ ។

(៦៧៨) (ព្រោះថា...) សត្វបក្សីទិជាតិនេះ ល្អ ព្រោះថាជាសត្វមានធម៌ក្រៃលែង ចំណែកសត្វបក្សីសេកក្រៅពីនេះ និយាយពាក្យអាក្រក់ថា អ្នកទាំងឡាយចូរសម្លាប់ ចូរចងនូវបុរសនេះ អ្នកទាំងឡាយកុំលែងជីវិតឡើយ កាលសេកនោះកំពុងនិយាយយ៉ាងនេះ យើងក៏បានរួចមកដល់អាស្រមនេះដោយសួស្ដី ។

(៦៧៩) (សេកច្ឆេក: .. ) បពិត្រមហារាជ យើងខ្ញុំទាំងពីរជាបងប្អូនបង្កើត មានមាតាតែមួយនឹងគ្នា កើតឡើងនៅលើដើមឈើតែមួយ តែទៅកាន់ទីផ្សេងគ្នា ។ សត្តិគុម្ពៈទៅកាន់សំណាក់នៃពួកចោរ ចំណែកខ្ញុំព្រះអង្គមកកាន់សំណាក់នៃពួកឥសីនេះ សត្តិគុម្ពៈ (ចូលទៅកាន់សំណាក់) នៃពួកអសប្បុរស ខ្ញុំព្រះអង្គ (ចូលមកកាន់សំណាក់) នៃពួកសប្បុរស (ហេតុនោះ) សត្តិគុម្ពៈនឹងខ្ញុំមិនស្មើគ្នាដោយធម៌នោះទេ (១) ។

១ [illegible] ។

[៤៨០] យត្ថ វេគោ ច ភេត្វា ច    និក្ខមតិ វេទនាតិ ច
អាឡោឡោ សហាសាកាក    តាធិ សោតត្ថ សិក្ខាតិ ។
ឥធ សច្ចញ្ច ធម្មោ ច    អហឹសា សំយមោ ទមោ
តាសត្ថកាតាយដំ    អត្ថំ វន្តាសិ្ម ការកា ។

[៤៨១] យំ យំ ហិ ករ គច្ឆតិ    សត្ថុ ក យថិ ក អសំ
សីលវន្តំ វិសីលំ ក    វសំ អាសេស្ស កន្តតិ ។
យាតិសំ កុរុតេ មិត្តំ    យាតិសញ្ចូបសេវតិ
សោបិ តាតិសកោ ហោតិ    សហវាសោ ហិ តាតិសោ ។
សេវមានោ សេវមានំ    សម្ផុដ្ឋោ សម្ផុសំ បរំ
សរោ ទុដ្ឋោ កលាបំវ    អលិត្តមុបលិម្បតិ ។
ឧបលេបភយា ធីរោ    នេវ បាបសខា សិយា
បូតិមច្ឆំ កុសគ្គេន    យោ នរោ ឧបនយ្ហតិ
កុសាបិ បូតិ វាយន្តិ    ឯវំ ពាលូបសេវនា ។



[៤៨០] ការសង្វាត់ក្ដី ឧស្សាហ៍ក្ដី ការបង្ខំក្ដី បញ្ញាតក្ដី ការចូលក្ដី ការកំហែងក្ដី មាននៅក្នុងសំណាក់បុគ្គលណា សត្វទាំងឡាយ រមែងសិក្សាតាមកិច្ចការ ក្នុងសំណាក់បុគ្គលនោះ ។ សេចក្ដីពិតក្ដី សុចរិតក្ដី ការមិនបៀតបៀនក្ដី ការសង្រួមសីលក្ដី ការទូន្មានខ្លួនក្ដី មាននៅក្នុងទីនេះ ហេតុនោះ ខ្ញុំព្រះករុណាបានខ្ជាក់ចោលនូវគ្រឿងស្អុយ ប្រៀបដូចជា ក្អួតចោលនូវទឹកដោះ ។

[៤៨១] បពិត្រព្រះរាជា តិរច្ឆាន ឬបុគ្គលគប់រកបុគ្គលណា ទោះជាសប្បុរស ឬអសប្បុរស មានសីល ឬទុស្សីល រមែងលុះអំណាចបុគ្គលនោះឯង ។ បុគ្គលធ្វើនូវបុគ្គលបែបណា ឲ្យជាមិត្រ ចូលទៅគប់រកនូវបុគ្គលបែបណា បុគ្គលនោះក៏មានសភាពបែបនោះ ឯការនៅរួមគ្នាក៏ដូច្នោះ ។ កូនសរស្រោបថ្នាំ ឆ្លងកាត់ផ្លូវលើសគ្រួសកាតាព្រួញដែលកូនសរស្រោបគឺរហ័យ រមែងប្រឡាក់កូនសរស្រែដែលមិនប្រឡាក់ (ដោយថ្នាំពិស) ដូចគ្នា ដែលត្រូវលាប់ដោយថ្នាំពិសនោះ ប្រឡាក់ដំបងស ។ ព្រោះភ័យអំពីការប្រឡាក់ អ្នកប្រាជ្ញមិនគប្បីមានបាបជាសំឡាញ់ ជនណាខ្ចប់ត្រីស្អុយ ដោយចុងស្បូវភ្លាំង ស្បូវភ្លាំងក៏មានក្លិនស្អុយផ្សាយចេញ ការគប់រកនូវបុគ្គលពាល (របស់ជនទាំងឡាយ) ក៏យ៉ាងនោះដែរ ។

តគរញ្ច បលាសេន យោ នរោ ឧបនយ្ហតិ
បត្តាបិ សុរភី វាយន្តិ ឯវំ ធីរូបសេវនា
តស្មា បលាសបុដស្សេវ ញត្វា សម្បាកមត្តនោ
អសន្តេ នោបសេវេយ្យ សន្តេ សេវេយ្យ បណ្ឌិតោ
អសន្តោ និរយំ នេន្តិ សន្តោ បាបេន្តិ សុគ្គតិន្តិ ។

សត្តិគុម្ពជាតកំ តតិយំ ។

## ភល្លាតិយជាតកំ

[៦៨៦] ភល្លាតិយោ នាម អហោសិ រាជា
រដ្ឋំ[១] បហាយ មិគវំ អចារិ
សោ អគ្គមាសិ គិរិវរំ គន្ធមាទនំ
សុបុប្ផិតំ កិំបុរិសានុចិណ្ណំ ។
សាឡូរសង្ឃញ្ច និសេធយិត្វា
ធនុកលាបញ្ច សោ និក្ខិបិត្វា
ឧបាគមិ វចនំ វត្តុកាមោ
យត្ថដ្ឋិតា កិំបុរិសា អហេសុំ ។
ហិមច្ចយេ ហេមវតាយ តីរេ
កិមិធដ្ឋិតា មន្តយវ្ហោ អភិណ្ហំ

១ ម. រដ្ឋេ ។



ជនណា ខ្ចប់នូវឫសក្រស្នា ដោយស្លឹកឈើ សូម្បីស្លឹកឈើ ក៏មានក្លិនក្រអូបផ្សាយចេញ ការសេពគប់នូវអ្នកប្រាជ្ញ (របស់ជនទាំងនោះ) ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ បុគ្គលជាអ្នកប្រាជ្ញ ដឹងច្បាស់នូវបញ្ញាចាស់ទុំរបស់ខ្លួន ដូចជាកញ្ចប់ស្លឹកឈើ មិនគួរសេពគប់នូវអសប្បុរស គួរសេពគប់នឹងពួកសប្បុរស (ព្រោះ) ពួកអសប្បុរស តែងនាំទៅនរក ពួកសប្បុរសតែងនាំសត្វទៅសុគតិ ។

ចប់ សត្តិគុម្ពជាតក ទី ៣ ។

## ភល្លាតិយជាតក

(៦៨៦) (ព្រះមហាសត្វត្រាស់ថា) ព្រះរាជាព្រះនាមភល្លាតិយៈ បានលះបង់នូវដែន ហើយស្ដេចចេញទៅកាន់ទីសម្លាប់ម្រឹគ ព្រះអង្គបានយាងទៅដល់ភ្នំ ដ៏ប្រសើរឈ្មោះគន្ធមាទន៍ ជាទីមានផ្កាស្គុះស្គាយ ដ៏ដែលសេពដោយពួកកិន្នរ ។ ព្រះអង្គប្រាថ្នាដើម្បីពោលពាក្យ (នឹងពួកកិន្នរ) ទើបហាមឃាត់ហ្វូងឆ្កែ ហើយដាក់ធ្នូនិងកំពង់ព្រួញ រួចយាងទៅត្រង់កន្លែងដែលពួកកិន្នរឋិតនៅ ។ (ព្រះរាជាត្រាស់ថា) កាលរដូវរងាកន្លងទៅហើយ ម្ដងឡើយ អ្នកទាំងឡាយ ឋិតនៅក្នុងទីនេះ ប្រឹក្សាគ្នារឿយៗ ប្រហែលស្ទឹងហេមវតី

ពុច្ឆាមិ វោ មានុសទេហវណ្ណា

កថំ វោ ជានន្តិ មនុស្សលោកេ ។

(៦៨៣) មាលាគិរឹ(១) បណ្ឌរកំ ចិត្តកូដំ

សីតោទកា(២) អនុវិចរាម ឯត្ថ

មិគា មនុស្សរិវ និភាសវណ្ណា

ជានន្តិ នោ កិម្បុរិសាតិ លុទ្ទ ។

(៦៨៤) សុកិច្ឆរូបំ បរិទេវយវ្ហោ

អាលិង្គិតោ ចាសិ បិយោ បិយាយ

ពុច្ឆាមិ វោ មានុសទេហវណ្ណា

កិមិទំ កេន រោទថ អប្បតីតា ។

សុកិច្ឆរូបំ បរិទេវយវ្ហោ

អាលិង្គិតោ ចាសិ បិយោ បិយាយ

ពុច្ឆាមិ វោ មានុសទេហវណ្ណា

កិមិទំ កេន វិលបថ អប្បតីតា ។

សុកិច្ឆរូបំ បរិទេវយវ្ហោ

អាលិង្គិតោ ចាសិ បិយោ បិយាយ

---

១ ឱ. មល្លគិរឹ ។ ឱ. មល្លគិរឹ ។ ២ ឱ. សីតោទិយា ។





យើងសូមសួរពួកអ្នក ដែលមានពន្លឺកាយនឹងសម្បុរដូចជាមនុស្ស គេស្គាល់អ្នកទាំងឡាយបាន ក្នុងមនុស្សលោក ដោយប្រការដូចម្តេច ។

(៦៨៣) (កិន្នរីទូលថា) ម្នាលព្រាន ពួកយើង តែងត្រាច់ទៅកាន់ ភ្នំឈ្មោះមាលាគិរី ភ្នំឈ្មោះបណ្ឌរកៈ ភ្នំត្រកូដ និងស្ទឹងមានទឹកដ៏ត្រជាក់ ពួកយើងជាម្រឹគមានសំនៀងប្រាកដដូចជាពួកមនុស្ស គេស្គាល់ពួកយើងថាជាកិន្នរ ។

(៦៨៤) (ព្រានថា...) អ្នកទាំងពីរ មានសភាពដូចជាទុក្ខក្រៃលែង ខ្ញុំយល់ អ្នកឯងជាទីស្រឡាញ់ ត្រូវនាងដ៏ជាទីស្រឡាញ់ ឱបរឹតហើយ យើងសូមសួរនូវពួកអ្នក ដែលមានពន្លឺកាយនឹងសម្បុរដូចមនុស្ស អ្នកទាំងឡាយ កាន់សេចក្តីដូចម្តេច ទើបខំយំក្នុងព្រៃនេះ អ្នកទាំងពីរ មានសភាពដូចជាទុក្ខក្រៃលែង ខ្ញុំយល់ អ្នកឯងជាទីស្រឡាញ់ ត្រូវនាងដ៏ជាទីស្រឡាញ់ ឱបរឹតហើយ យើងសូមសួរ នូវពួកអ្នក ដែលមានពន្លឺកាយនឹងសម្បុរដូចជាមនុស្ស អ្នកទាំងឡាយ កាន់សេចក្តីដូចម្តេច ទើបយំរៀបរាប់ក្នុងព្រៃនេះ ។ អ្នកទាំងពីរ មានសភាពដូចជាទុក្ខក្រៃលែង ខ្ញុំយល់ អ្នកឯងជាទីស្រឡាញ់ ត្រូវនាងដ៏ជាទីស្រឡាញ់ ឱបរឹតហើយ

បុច្ឆាមិ ភេ មានុសទេហវណ្ណេ
កិំ បិន ពិល សោចថ អប្បតីតា ។

(៦៨៥) យមេករត្តឹ[1] វិប្បវសិម្ហ[2] លុទ្ទ
អកាមកា អញ្ញមញ្ញំ សរន្តា
តមេករត្តឹ អនុតប្បមានា
សោចាម សា រត្តិ បុន ន ហេស្សតិ ។

(៦៨៦) យមេករត្តឹ អនុតប្បថេតំ
ធនំវ នដ្ឋំ បិតរញ្ច បេតំ
បុច្ឆាមិ ភេ មានុសទេហវណ្ណេ
កថំ វិនាភាវមកប្បយិត្ថ ។

(៦៨៧) យមិមំ នទឹ បស្សសិ សីឃសោតំ
នានាទុមច្ឆទនំ សេលកូលំ
តំ មេ បិយោ ឧត្តរិ វស្សកាលេ
មមញ្ច មញ្ញំ អនុពន្ធតីតិ ។
អហញ្ច អង្កោលកមោចិនាមិ
អតិមុត្តកំ សត្តលិយោធិកញ្ច
បិយោ ច មេ ហេហិតិ មាលភារី

១ ម. យមេករត្តឹ ។ ២ ម. វសិម្ហ ។



យើងសូមសួរនូវអ្នក ដែលមានរាងកាយនិងសម្បុរ ដូចមនុស្ស អ្នកកាត់អន់ចិត្តដូចម្ដេច ទើបសោកស្ដាយក្រៃពេក ។

(៦៨៥) (កិន្នរី...) ម្នាលព្រាន យើងទាំងពីរនាក់ ជាអ្នកព្រាត់ប្រាស់គ្នា អស់មួយរាត្រី រលឹកគ្នាទៅវិញទៅមក មិនដាច់អាល័យ ក្ដៅក្រហាយនឹងរាត្រីមួយនោះ ទើបយំសោក ព្រោះរាត្រីនោះ នឹងមិនមានទៀត ។

(៦៨៦) (ព្រះរាជា...) អ្នកទាំងពីរ ក្ដៅក្រហាយនឹងរាត្រីមួយណា ដូចបុគ្គលក្ដៅក្រហាយចំពោះទ្រព្យដែលបាត់ និងមាតាបិតា ដែលទៅកាន់បរលោក យើងសូមសួរ នូវអ្នក ដែលមានរាងកាយនិងសម្បុរដូចមនុស្ស ចំពោះរាត្រី (នោះ) តើអ្នកទាំងពីរសម្រេចនូវការនៅព្រាត់គ្នាដូចម្ដេច ។

(៦៨៧) (កិន្នរី...) អ្នកឃើញនូវស្ទឹងណា ដែលមានខ្សែទឹកហូរលឿន ជាស្ទឹងបិទបាំងដោយដើមឈើផ្សេងៗ មានមាត់ច្រាំងថ្មហើយ ដោយខ្ញុំ កិន្នរ (ជាប្ដី) ជាទីស្រឡាញ់របស់ខ្ញុំ បានដើរឆ្លង នូវស្ទឹងនោះ ក្នុងរដូវភ្លៀង ដោយគិតថា កិន្នរីមកតាម ក្រោយខាងខ្ញុំដែរ ។ ចំណែកខាងខ្ញុំ ក៏កំពុងតែបេះផ្កា ព្រួស ផ្កាចន្ទា ផ្កាម្លិះ និងផ្កាយូថិកា ដោយចំណង់ថា កិន្នរ (ជាប្ដី)ជាទីស្រឡាញ់របស់អាត្មាអញនឹងបានទ្រទ្រង់កម្រងផ្កា

អហញ្ច នំ មាលិនិ អជ្ឈុបេស្សំ ។
អហញ្ចិទំ កុរវកំ ឱចិនាមិ
ឧទ្ទាលកា បាតលិ សិន្ទុវារិតា
បិយោ ច មេ ហេហិតិ មាលភារី
អហញ្ច នំ មាលិនិ អជ្ឈុបេស្សំ ។
អហញ្ច សាលស្ស សុបុប្ផិតស្ស
ឱចេយ្យ បុប្ផានិ ករោមិ មាលំ
បិយោ ច មេ ហេហិតិ មាលភារី
អហញ្ច នំ មាលិនិ អជ្ឈុបេស្សំ ។
អហញ្ច សាលស្ស សុបុប្ផិតស្ស
ឱចេយ្យ បុប្ផានិ ករោមិ ការំ
ឥទញ្ច នោ ហេហិតិ សន្ថរត្ថំ
យត្ថជ្ជិមំ វិហរិស្សាម រត្តិំ ។
អហញ្ច ខោ អគ្គលុំ ចន្ទនញ្ច
សិលាយ បិសាមិ បមត្តរូបា
បិយោ ច មេ ហេហិតិ រោសិតង្គោ
អហញ្ច នំ រោសិតា អជ្ឈុបេស្សំ ។





ចាំងការគ្នាអញជាអ្នកប្រហាច់ក្រមុំក្ដៅ នឹងបានចូលទៅកាន់ឋាន (ជាប្ដី) នោះ (ក្នុងលោក) ។ មួយទៀត ខ្ញុំបាក់ក្ដាក្រកៈ ចាំងក្ដាកជប្រើក្បនឹងក្ដាប្រទៀនក៏ខ្ញុំបោះ ដោយចំណាំថា កិន្នរ (ជាប្ដី) ជាទីស្រឡាញ់របស់គ្នាអញ នឹងជាអ្នកប្រហាច់ក្រមុំក្ដៅ ចាំងការគ្នាអញក៏ជាអ្នកប្រហាច់ក្រមុំក្ដៅ នឹងចូលទៅកាន់ឋានជាប្ដីនោះ (ក្នុងលោក) ។ មួយទៀត ខ្ញុំបានបោះខ្ទាំក្ដាសាលព្រឹក្ស ដែលរីកស្គុះស្គាយ ធ្វើជាគ្រឿងប្រហាច់ ដោយចំណាំថា ថ្ងៃនេះយើងនឹងទៅក្នុងទីណាអស់ក្រមួយ គ្រឿងប្រហាច់នេះ នឹងបានជាក្រោលរបស់យើងក្នុងទីនោះ ។ មួយទៀត ខ្ញុំបានលសាកជាអ្នកធ្វើរប្រពាស ក្លិនខ្ញុំមក្រញា នឹងខ្ញុំមានខ្លួនលើផ្ទ ដោយចំណាំថា កិន្នរជាប្ដីជាទីស្រឡាញ់របស់គ្នាអញ នឹងបានលាបខ្លួនព្រហ្ម ចាំងខ្លួនអញក៏បានលាបស្រឡាប ហើយនឹងចូលទៅកាន់ឋានជាប្ដីនោះក្នុងលោក ។

អថាគមា សលិលំ សីឃសោតំ
នុទំ សាលេ សលលេ កណ្ណិការេ
អាប្លុថេ តេន ទុហត្ថរោច
សាយំ នទី អាសិ មយា សុទុត្តរា ។
ឥតោសុ តីរេសុ មយំ ឥធា ឋិតា
សម្បស្សន្តា ឧភយោ អញ្ញមញ្ញំ
សកិំ ព្រេក្ខាម សកិំ ហសាម
ការិដ្ឋង ពោ អកមា សត្តរី សា ។
តាតោ ច ពោ ឥត្តរេ សុរិយុគ្គតិ
តរិត្វាន ចងំ ឥត្តរិយាច លុទ្ទ
អាលិង្គិយា អញ្ញមញ្ញំ មយំ ឥកោ
សកិំ ព្រេក្ខាម សកិំ ហសាម ។
តិហុលតឹ សត្ត សតានិ លុទ្ទ
យមិធ មយំ វិប្បវសិត្ថ បុព្វេ
តីស្សេកិមំ ជីវិតំ ក្ខមិតាល
កោតិង ភត្តាយ វិកា កិសេយ្យ ។
(២៨៨) អាយុញ្ច វោ កីវតកោ នុ សម្ម
សចេបិ ជានាថ វទេថ អាយុំ



លំដាប់នោះ ទឹកស្ទឹងមានខ្សែលឿនរហ័ស ហូរនាំយកផ្កាសាល-ព្រឹក្ស ផ្កាស្រល់និងផ្កាកណ្ណិការ (ដែលខ្ញុំបានទុក ក្នុងទីទៀបមាត់ច្រាំង) មានទឹកដ៏ពេញដោយខ្សែរលក ទាំងស្ទឹងនោះ ខ្ញុំក៏ឆ្លងផុតនោះដោយលំបាកក្រៃលែង ។ ព្រោះនោះ យើងទាំងពីរនាក់ក៏ឈរក្បែរឆ្នេរស្ទឹងម្នាក់ម្ខាង មើលឃើញគ្នាទៅវិញទៅមក ម្តងយំ ម្តងសើច រាត្រីនោះរបស់យើងក៏កន្លងទៅដោយក្រ ។ ម្នាលព្រាហ្មណ៍ កាលបើព្រះអាទិត្យរះឡើងក្នុងវេលាព្រឹក យើងទាំងពីរនាក់ក៏ឆ្លងស្ទឹងទទេ(ស្ទឹងមិនមានទឹក)ហើយឱបគ្នាទៅវិញទៅមក ម្តងយំ ម្តងសើច ។ ម្នាលព្រាហ្មណ៍ កាលមុន យើងបានព្រាត់ប្រាសគ្នាអស់មួយរាត្រី កន្លងមកចំនួន៧០០ឆ្នាំហើយ (៦៩៩ឆ្នាំ) ម្នាលកូនចាល សីវៈ (របស់អ្នក) នេះ ត្រឹមតែមួយឆ្នាំ អ្នកណាហ្ន៎ ក្នុងលោកនេះ នៅរស់ព្រាត់គ្នាតិចតួចយ៉ាងជាទីស្រឡាញ់អាចុន ។

(២៨៨) (ព្រះរាជា...) នែសំឡាញ់ ចុះអាយុរបស់អ្នកទាំងឡាយចំនួនប៉ុន្មាន បើអ្នកដឹង ចូរអ្នកប្រាប់អាយុ (ដល់យើង)

អនុស្សរន្តា សាមិកា ហ
អក្កោដ មេ តំ អវិកម្បមានា ។

(៦៨៩) អាយុញ្ច នោ វស្សសហស្ស សម្ម
ន ចន្តរា តាបកោ អត្ថិ ហោតិ
អប្បំ ទុក្ខំ សុខមេវ ភិយ្យោ
អវីតរាគា វិជហាម ជីវិតំ ។

(៦៩០) ឯតញ្ច សុត្វាន អមានុសានំ
ភល្លាតិយោ ឥត្តរំ ជីវិតន្តិ
និវត្តថ ន មិគវំ អចរិ
អទាសិ ទានានិ អភុញ្ជិ ភោគេ ។

(៦៩១) ឯតញ្ច សុត្វាន អមានុសានំ
សម្មោទថ មា កលហំ អកត្ថ
មា វោ តបី អត្តកម្មាបរាធោ
យថាបិ តេ កិម្បុរិសេករត្តិំ ។



ព្រោះបើអ្នកទាំង២ (បើអ្នកណាមួយក្តី) ចាំមកពីភ្នំគន្ធ
មាទន៍ក្តី សូម្បីអ្នកកុំឲ្យភ្លេចប្រយ័ត្នសេចក្តីនោះ ផងហើយ ។

(៦៨៩) (កិន្នរី...) ម្នាលព្រាន អាយុរបស់យើងមួយពាន់ឆ្នាំ ទើប
មិនមានរោគដ៏អាក្រក់ ក្នុងចន្លោះអាយុនេះ ឯសេចក្តីទុក្ខ
មានប្រមាណតិច សេចក្តីសុខហ្នឹងឯង មានច្រើនក្រៃលែង
ពួកយើងមិនប្រាស ចាកសេចក្តីត្រេកអរ (ស្រឡាញ់គ្នា)
កាលលះជីវិតទៅ ។

(៦៩០) (កុសលមូលនោះ) ព្រះរាជាព្រះនាមភល្លាតិយៈ លុះទ្រង់ព្រះ
សណ្ដាប់ពាក្យ របស់ពួកកិន្នរនេះហើយ ក៏វិលត្រឡប់
មក (ព្រះរាជនិវេសន៍) ដោយទ្រង់ឃើញថា ជីវិតនេះ មាន
ប្រមាណតិចណាស់ ព្រោះឈប់ត្រាច់ទៅ កាន់ទីជាទីសម្លាប់
ម្រឹគទៀត ទ្រង់បានបរិច្ចាគទាន ទ្រង់បានប្រើប្រាស់ នូវកាម-
សម្បត្តិ (កាមគុណ) ។

(៦៩១) (ព្រះសាស្តាទ្រង់ឲ្យឱវាទថា) សូមព្រះអង្គទ្រង់ព្រះសណ្ដាប់
នូវពាក្យរបស់ពួកកិន្នរនេះហើយ ចូរព្រមព្រៀង កុំធ្វើនូវជម្លោះ
ឡើយ កំហុសនៃអំពើរបស់ខ្លួន កុំផុតកាំដៅនូវព្រះអង្គ ដូច
ជារាត្រីមួយ របស់ពួកកិន្នរ ផុតកាំដៅនូវកិន្នរទាំងនោះ

ឥទញ្ច សុត្វាន អមានុសានំ
សម្មោទថ មា វិវទិត្ថ
មា វោ តបិ អត្តកម្មាបរាធោ
យថាបិមេ កិម្បុរិសា ឯករត្តិំ ។

(៦៤៦) ឥទំ អតិមហា សុណោមហំ
វចនបថំ ឥធ អមនុស្សានំ
មុញ្ចាមិ ខិលំ ជហាមិ វេរំ
សមណ សុខាវហោ ជីវ មេ ចិរន្តិ ។

ភល្លាតិយជាតកំ អដ្ឋមំ ។

## សោមនស្សជាតកំ

(៦៤៧) កោ តំ ហិំសតិ ហេឋេតិ
កិំ ទុម្មនោ សោចសិ អប្បតីតោ
កស្សជ្ជ មាតាបិតរោ រុទន្តុ
ក្វជ្ជ[១] សេតុ និហតោ បថព្យា ។

(៦៤៨) តុដ្ឋាស្មិ ទេវ តវ ទស្សនេន

១ ម. ភាសុ ។



សូមព្រះអង្គ ទ្រង់ព្រះសណ្ដាប់នូវពាក្យ របស់ពួកកិន្នរនេះ ហើយ ចូរព្រមព្រៀង កុំឈ្លោះប្រកែកគ្នាឡើយ កំហុសនៃអំពើរបស់ខ្លួន កុំដុតកំដៅនូវព្រះអង្គ ដូចជាកម្មរបស់ពួកកិន្នរ ដុតកំដៅនូវកិន្នរទាំងនោះ ។

(៦៤៦) (ព្រះបាទភល្លាតិយរាជត្រាស់ថា) ខ្ញុំម្ចាស់មានចិត្តត្រេកអរស្ដាប់ ពាក្យសេចក្ដីមានប្រយោជន៍នេះ នូវពាក្យនៃព្រះតម្រាស់របស់ព្រះអង្គ ប្រកបដោយប្រយោជន៍ ព្រះអង្គបញ្ចេញពាក្យដោយបន្ទោបនូវសេចក្ដី ក្រោលក្រាយរបស់ខ្ញុំម្ចាស់ បពិត្រព្រះសមណៈ ព្រះអង្គនាំ សេចក្ដីសុខមកឲ្យ សូមព្រះអង្គគង់ព្រះជន្មនៅអស់កាលយូរ ។

ចប់ ភល្លាតិយជាតក ទី ៨ ។

## សោមនស្សជាតក

(៦៤៧) (ព្រះបាទរេណុត្រាស់សួរថា) នរណាប្រហារលោក ឬនរ ណាបៀតបៀនលោក ហេតុអ្វីលោកតក់ស្លុតចិត្ត មិនត្រេកអរ សោក សង្រេងរីងរៃ ថ្ងៃនេះ តើមាតាបិតារបស់នរណាខ្លះយំ ថ្ងៃ នេះ តើនរណាត្រូវគេបៀតបៀនដេកលើផែនដី (គឺលោក មិនគួរជាអ្នកជាទុក្ខទេ) ។

(៦៤៨) (កុមារតាបស ឆ្លើយថា) បពិត្រព្រះសម្មតិទេព អាត្មាភាព ត្រេកអរ ដោយការបានឃើញ នូវព្រះអង្គ

ចិរស្សំ បស្សាមិ តំ ភូមិបាល
អហឹសកោ រេណុមនុប្បវិស្ស
បុត្តេន តេ ហេឋយិតោស្មិ ចេវ ។

(៥៤៨) អាយន្តុ ទោវារិកា ខគ្គពទ្ធា
កាសាវិយា យន្តុ[១] អន្តេបុរន្តំ
ហន្ត្វាន តំ សោណនន្ទំ កុមារំ
ឆេត្វាន សីសំ វរមាហរន្តុ ។

បេសិតា រាជិនោ ទូតា កុមារំ ឯតទព្រវុំ
ឥស្សរេន វិតិណ្ណោសិ វធំ បត្តោសិ ខត្តិយ ។

ស រាជបុត្តោ បរិទេវយន្តោ
ទសង្គុលិំ អញ្ជលិំ បគ្គហេត្វា
អហម្បិ ឥច្ឆាមិ ជនិន្ទ ទដ្ឋុំ
ជីវំ មំ នេត្វា បដិទស្សយេថ ។

តស្ស តំ វចនំ សុត្វា រញ្ញោ បុត្តំ អទស្សយុំ
បុត្តោ ច បិតរំ ទិស្វា ទូរតោវជ្ឈភាសថ ។

---
១ ម. ហន្តុ ។





បពិត្រព្រះភូមិបាល អាត្មាភាព ឃើញព្រះអង្គយូរហើយ
បពិត្រព្រះសម្មតិទេពព្រះនាមមនោជ អាត្មាភាព មិនមែនជា
អ្នកបៀតបៀនទេ ប៉ុន្តែអាត្មាភាព ត្រូវព្រះរាជបុត្ររបស់ព្រះ
អង្គចូលមកបៀតបៀនហើយ ។

(៥៤៨) (ព្រះរាជា...) ពួកអ្នកចាំទ្វារ មានព្រះខ័នកាន់ហើយ
ពួករាជ្យឃាតចូរមក ចូរទៅកាន់ក្នុងបុរី ចូរសម្លាប់
សោណនន្ទកុមារនោះ កាត់ក្បាលដ៏ប្រសើរ នាំមកឲ្យអញ ។

ពួករាជទូត ដែលព្រះរាជា ទ្រង់បញ្ជូនទៅហើយ បាននិយាយ
នឹងព្រះរាជកុមារ យ៉ាងនេះថា បពិត្រក្សត្រ ព្រះអង្គទ្រង់ធំជាងអ្នក
ជាឥស្សរៈលះហើយ ព្រះអង្គដល់នូវសេចក្ដីស្លាប់ហើយ ។

ព្រះរាជបុត្រនោះ ក៏ទ្រង់ទ្រហោយំ ផ្គងអញ្ជលីដោយព្រះហស្ត
ទាំង១០ថា បពិត្រព្រះអង្គជាធំជាងជន ចំណែកខ្ញុំព្រះ
បង្គំជាខ្ញុំ ចង់ឃើញព្រះអង្គ អ្នកទាំងឡាយចូរនាំយើងទាំង
រស់ទៅក្រាបបង្គំថ្វាយ (ដល់ព្រះមហាក្សត្រ) ចុះ ។

ពួករាជទូតបានស្ដាប់ពាក្យ របស់ព្រះរាជបុត្រនោះហើយ ក៏នាំ
ព្រះរាជបុត្រទៅថ្វាយព្រះរាជា ចំណែកខាងព្រះរាជបុត្រ លុះ
បានឃើញព្រះរាជបិតាហើយ ក៏ក្រាបបង្គំទូល អំពីចម្ងាយថា

អាកន្តុំ គោករិកា ទក្ខពុទ្ធា
កាសាវិយា ហត្ថុំ ចម ជមិន្ត
អក្ខាហិ មេ បុច្ឆិតោ ឯតមត្ថំ
អបាកោ កោនីដ ឥមជ្ជ អត្ថិ ។

(៦៤៦) សាយញ្ញ ផាតោ ឧទកំ សជាតិ
អគ្គី សទា បរិចរកប្បមត្តោ
តំ តាបសំ សំយតំ ព្រហ្មចារី
កស្មា[១] កុរំ ព្រូសិ គហាបត្តិតំ ។

(៦៤៧) កាលា ច មូលា ច ផលា ច មេវ
បរិក្ខកោ វិដា សន្តិមស្ស
តេ រក្ខតិ គោបយតប្បមត្តោ
កស្មា អយំ ព្រូមិ គហាបត្តិតំ[២] ។

(៦៤៨) សច្ចំ ខោ ឯតំ វទសិ កុមារ
បរិក្ខកា វិដា សន្តិមស្ស
តេ រក្ខតិ គោបយតប្បមត្តោ
ព្រាហ្មណោ គហបតិ តេន ហោតិ ។

១ ឱ. ចស្ស ។ ឆដ្ឋសង្គាយនា កស្មា ។ ២ ឱ. ព្រាហ្មណោ
គហបតិ តេន ហោតិ តាបសោ ។





បពិត្រព្រះជនិន្ទ ខ្ញុំម្ចាស់ជាគ្រូ មានព្រះទ័យទទួលកាន់ហើយ ពួក
គេផ្ទះបាតមក ដើម្បីសម្លាប់ខ្ទួលព្រះបង្គំជាខ្ញុំ ឯបានខ្ទួល
ព្រះបង្គំជាខ្ញុំ ហេតុអ្វីសូចម្តេចក៏ប្រើទៀតទេ ខ្ទួលព្រះបង្គំ
សួរហើយ សូមទ្រង់ប្រាប់សេចក្តីនុះ ។

(៦៤៦) (ព្រះរាជា...) ទិព្វខេត្តតាបស ជាអ្នកមិនខ្វះប្រហែស ធ្វើ
ការស្រោចទឹកបូជាភ្លើង រាល់ពេលល្ងាចព្រឹក ព្រោះហេតុអ្វីបាន
ជាឯងហៅទិព្វខេត្តតាបសនោះ ដែលជាអ្នកមានសេចក្តីសង្រួម
ជាអ្នកប្រព្រឹត្តនូវធម៌ប្រសើរ មានសភាពដូច្នោះ ថាជាគហបតី ។

(៦៤៧) (សោមទត្តកុមារ...) បពិត្រព្រះសម្មតិទេព ដើមចាក់
ឬស្សីកន្លែងនោះ មានច្រើនយ៉ាងណាស់ គឺផ្លែត្នោត
ផង ត្រាវនឹងដំឡូងផង ផ្លែឈើផ្សេងៗ ដំណាំឡាយផង កុលុប-
កតាបស របស់ព្រះអង្គនោះ ជាអ្នកមិនមានសេចក្តីខ្វះ
ប្រហែស តែងគ្រប់គ្រងរក្សានូវដំណាំនោះ ព្រោះហេតុនោះ
បានជាខ្ញុំព្រះបង្គំជាខ្ញុំហៅតាបសនោះថា គហបតី ។

(៦៤៨) (ព្រះរាជា...) នែកុមារ អ្នកនិយាយពាក្យនេះពិតមែន របស់
ដំណាំឡាយនៃកុលុបកតាបសនោះ មានច្រើនយ៉ាង កុលុបក-
តាបសនោះ ជាអ្នកមិនខ្វះប្រហែស តែងគ្រប់គ្រងរក្សានូវ
របស់ទាំងនោះ ព្រោះហេតុនោះ ព្រាហ្មណ៍ក្លាយជាគហបតី

(៦៩៩) សុណន្តុ មយ្ហំ បរិសា សមាគតា
សនេគមា ជានបទា ច សព្វេ
ពាលាយំ ពាលស្ស វចោ និសម្ម
អហេតុនា ឃាតយតេ មំ ជនិន្ទោ ។

(៧០០) ទឡ្ហស្មិ មូលេ វិសដេ វិរូឡ្ហេ
ទុន្និក្ខយោ វេឡុ បសាខជាតោ
វន្ទាមិ បាទានិ តវ ជនិន្ទ
អនុជាន មំ បព្វជិស្សាមិ ទេវ ។

(៧០១) ភុញ្ជស្សុ ភោគេ វិបុលេ កុមារ
សព្វញ្ច តេ ឥស្សរិយំ ទទាមិ
អជ្ជេវ ត្វំ កុរូនំ ហោហិ រាជា
មា បព្វជី បព្វជ្ជា ហិ ទុក្ខា ។

(៧០២) កិន្នូធ ទេវ តវមត្ថិ ភោគា
បុព្វេវហំ ទេវលោកេ រមិស្សំ
រូបេហិ សទ្ទេហិ អថោ រសេហិ
គន្ធេហិ ផស្សេហិ មនោរមេហិ ។



(៦៩៩) (សោមនស្សកុមារ...) ពួកបរិស័ទព្រមទាំងអ្នកនិគម អ្នកជនបទ ដែលបានមកប្រជុំទាំងអស់គ្នា ចូរស្តាប់ពាក្យរបស់ខ្ញុំ ព្រះរាជានេះ ជាបុគ្គលពាល ស្តាប់តែពាក្យរបស់ពាល ប្រើឲ្យសម្លាប់ខ្ញុំ ដោយការមិនសមហេតុ ។

(៧០០) កាលបើឫសមាំ ចំរើនធំ ដុះឡើង ឫស្សីដែលកើតមែកហើយ បុគ្គលមិនងាយនឹងដកចេញបាន បពិត្រព្រះជនិន្ទ ខ្ញុំព្រះបង្គំជាខ្ញុំ សូមថ្វាយបង្គំព្រះបាទព្រះអង្គ បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់អនុញ្ញាតនូវខ្ញុំព្រះបង្គំជាខ្ញុំ ខ្ញុំព្រះបង្គំជាខ្ញុំសូមចេញបួស ។

(៧០១) (ព្រះរាជា...) នែកុមារ អ្នកចូរបរិភោគនូវភោគៈទាំងឡាយដ៏ច្រើនចុះ បិតានឹងប្រគល់ឥស្សរិយយសទាំងអស់ ដល់អ្នក អ្នកចូរសោយរាជ្យជាស្តេចរបស់អ្នកកុរុ ក្នុងថ្ងៃនេះឯង អ្នកកុំបួសឡើយ ព្រោះថា បព្វជ្ជាជាកិច្ចលំបាកណាស់ ។

(៧០២) (សោមនស្សកុមារ...) បពិត្រព្រះសម្មតិទេព ភោគសម្បត្តិរបស់ព្រះអង្គ ក៏ជាមានដូចម្តេចកើត ក្នុងមនុស្សលោកនេះ ក្នុងកាលមុន ខ្ញុំព្រះបង្គំជាខ្ញុំ ធ្លាប់បានត្រេកអរដោយរូប សំឡេង រស ក្លិន ផ្សព្វ ជាទីសំរាលចិត្ត ក្នុងទេវលោកមកហើយ ។

កុក្កុ ច តេ ហោត ពិណិវស្មិំ ចេតេ
ពរិករិកា[១] អដ្ឋកសំ គណេន
កុវេញ្ញ ពលំ បរេយ្យ វិធិត្វា
ន តាទិសេ ករណ្ឌុលេ វសេយ្យំ ។

(៣០៣) សតាហំ កាលោ បរាធេយ្យោ អស្មិ
និវាតកំ ទម បុត្ត មយ្ហំ
ធុរម្បិ តេ បតិសាមិ ករេយ្យ
យថាមតិ សោមទត្តស្ស កាកេហិ ។

(៣០៤) អនិសម្ម កតំ កម្មំ អនវត្ថាយ ចិន្តិតំ
ភេសជ្ជស្សេវ វេភង្គោ វិបាកោ ហោតិ បាបកោ ។
និសម្ម ច កតំ កម្មំ សម្មាវត្ថាយ ចិន្តិតំ
ភេសជ្ជស្សេវ សម្បត្តិ វិបាកោ ហោតិ ភទ្រកោ ។
អលសោ គិហី កាមភោគី ន សាធុ
អសញ្ញតោ បព្វជិតោ ន សាធុ
រាជា ន សាធុ អនិសម្មការី
យោ បណ្ឌិតោ កោធនោ តំ ន សាធុ ។

១ ម. ពរិករិកា ។ ឱ. សាលិកា ។



បពិត្រព្រះសម្មតិទេព ឯការគសម្ប៉ែមពាំងឡាយ ខ្ញុំព្រះបង្គំជាខ្ញុំធ្លាប់យាំអាហារហើយ ក្នុងវេលាណាក៏ឈ្មោះអាត្តនិយ ខ្ញុំព្រះបង្គំជាខ្ញុំ ជាបុគ្គលធ្លាប់មានពួកស្រីអប្សរបោមរោមហើយ ឯខ្ញុំព្រះបង្គំជាខ្ញុំ ស្គាល់ព្រះអង្គថា ជាមនុស្សពាល ដែលត្រូវគេដឹកនាំបាន (ខ្ញុំបាន) ខ្ញុំព្រះបង្គំជាខ្ញុំ មិនត្រូវនៅក្នុងដំណាក្រុលដែលព្រះអង្គទេ ។

(៣០៣) (ព្រះរាជា...) នែកូន បើយើងជាមនុស្សពាល ដែលត្រូវគេដឹកនាំ ក៏សូមអ្នកអត់ទោសកំហុសនូវដែលយើងហ្នឹង ម្នាលសោម-ទត្ត បើទោសយ៉ាងនេះនឹងមានម្ដងទៀត សូមអ្នកឃ្លាំមើលផង ។

(៣០៤) (សោមទត្តក្រាប...) ការធ្វើដែលបុគ្គលមិនបានពិចារណាហើយធ្វើ គឺអំពើដែលបុគ្គលមិនកំណត់ហើយគិត រមែងមានផលអាក្រក់ ដូចជាការស៊ីថ្នាំខុសដូច្នោះ ។ ឯការធ្វើដែលបុគ្គលពិចារណាហើយទើបធ្វើ គឺអំពើដែលបុគ្គលកំណត់ត្រឹមត្រូវហើយទើបគិត រមែងមានផលដ៏ល្អ ដូចជាការស៊ីថ្នាំត្រូវដូច្នោះឯង ។

គ្រហស្ថអ្នកបរិភោគកាម ខ្ជិល មិនល្អ អ្នកបួសមិនសង្រួម មិនល្អ ព្រះរាជា អ្នកមិនពិចារណាហើយធ្វើ មិនល្អ បណ្ឌិតដែលមានសេចក្ដីក្រោធ ការក្រោធនោះ ក៏មិនល្អឡើយ ។

និសម្ម ខត្តិយោ កយិរា នានិសម្ម ទិសម្បតិ
និសម្មការិនោ រាជ យសោ កិត្តិ ច វឌ្ឍតិ ។
និសម្ម ទណ្ឌំ បណយេយ្យ ឥស្សរោ
វេគា កតំ តប្បតិ ភូមិបាល
សម្មាបណីធី ច នរស្ស អត្ថា
អនានុតប្បា តេ ភវន្តិ បច្ឆា ។
អនានុតប្បានិ ហិ យេ ករោន្តិ
វិភជ្ជ កម្មាយតនានិ លោកេ
វិញ្ញុប្បសត្ថានិ សុខុទ្រយានិ
ភវន្តិ ពុទ្ធានុមតានិ[១] តានិ ។
អាគច្ឆុំ ទោវារិកា ខគ្គពទ្ធា
កាសាវិយា ហន្តុ មមំ ជនិន្ទ
មាតុ ច អង្កស្មិំ អហំ និសិន្នោ
អាកឌ្ឍិតោ សហសា តេហិ ទេវ ។
កដុកំ ហិ សម្ពាធំ សុកិច្ឆំ បត្តោ
បតុរំ បិយំ ជីវិតំ លទ្ធ រាជ

១ ម. វុទ្ធានុមតានិ ។



បពិត្រព្រះអង្គជាធំក្នុងទិស ក្សត្រត្រូវពិចារណាហើយសឹមធ្វើ មិនត្រូវធ្វើតាមមិនពិចារណាទេ បពិត្រព្រះរាជា ព្រោះយសនិងសេចក្តីសរសើរ រមែងចំរើន ដល់បុគ្គលអ្នកពិចារណាហើយទើបធ្វើ ។

បពិត្រព្រះភូមិបាល បុគ្គលជាធំ ត្រូវតែពិចារណាហើយសឹមដាក់ទណ្ឌ ការដែលបុគ្គលធ្វើដោយរួសរាន់ រមែងក្តៅក្រហាយ ម្យ៉ាងទៀត ប្រយោជន៍ទាំងឡាយដែលនរជនតម្កល់ទុកដោយត្រឹមត្រូវនោះ រមែងជាប្រយោជន៍ មិនក្តៅក្រហាយខាងក្រោយ ។ ជនទាំងឡាយ ចែកចែងហើយទើបធ្វើការងារទាំងឡាយ ដែលមិនមានសេចក្តីក្តៅក្រហាយក្នុងលោក ការងារទាំងនោះ ជាការដែលអ្នកប្រាជ្ញសរសើរហើយជា មានសេចក្តីសុខជាកំរៃ ជាការដែលអ្នកប្រាជ្ញយល់ព្រមហើយ ។

បពិត្រព្រះអង្គ ជាធំជាងជន ពួកឆ្មាំទ្វារ មានព្រះខ័នកាន់ហើយ ពួកពេជ្ឈឃាត មកដើម្បីសម្លាប់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ អង្គុយលើព្រះភ្លៅនៃមាតា ត្រូវពួកអ្នកទាំងនោះ ទាំងទាញមកដោយរហ័ស ទូលព្រះបង្គំជាខ្ញុំ បានដល់នូវមារណភ័យ ដ៏ក្តៅក្រហាយហើយចង្អៀត លំបាកក្រៃពេក បពិត្រព្រះរាជា ជីវិតដែលជាទីស្រឡាញ់បានរួចមករស់ ទូលព្រះបង្គំជាខ្ញុំបានហើយ

កាំព្ទ្រាហំ អដ្ឋ ភោយ[1] ទុក្ខា
បព្វជេតកំ ធេនោហមស្មិ ។

(៣០៩) ឃុត្តា ឥតយំ ករុណា សុវណ្ណ
អនុកម្បោ សោមនស្សំ កុមារក
ហំ យាចេមា ខ លកាម៌ សុវត្ថ
អស្មាសិ ធំ យាចេតវេ កុម្ស៊ី ។

(៣១០) ធម្មំ ភិក្ខាចរិយាយ បុត្ត
ចិសត្ត ចេត្តសុ បរិច្ចជស្សុ
សព្វស្សុ ក្ខាតស្សុ ជំនាយ ឧណ្ហំ
អចិត្តិតោ ព្រហ្មបុរោហិ ហុំ ។
អច្ចរិយរូបំ វត យាចិសញ្ញ
ទុក្ខិតំ មំ ទុក្ខាបយាសេ សុវណ្ណ
យាចស្សុ បុត្តំ ៩ត រូបមាតា
កិយ្យាវ ឧស្សូហយាសេ កុមារំ ។

(៣១១) យេ វិប្បមុត្តា អនវជ្ជភោជិនោ
បរិនិព្វុតា លោកមិមំ ចរន្តិ
តមរិយមគ្គំ បដិបជ្ជមានំ
ន ឧស្សហេ វារយិតុំ កុមារំ ។

១ ឧ. ម. ពោ ចញ្ញា ។



ថ្ងៃនេះខ្លួនព្រះបង្គំជាខ្ញុំ ចាស់ប្រាកដការស្លាប់ទៅដោយលំបាក
ខ្លួនព្រះបង្គំជាខ្ញុំ មានចិត្តមិនត្រូវទៅក្នុងបព្វជ្ជាតែម្យ៉ាង ។

(៣០៩) (ព្រះរាជា...) ម្នាលសុវណ្ណទៅ លោកមានសម្បុរមាសជាប្រពៃរបស់
នាងនេះ នៅក្នុង ជាអ្នកអនុគ្រោះ ថ្ងៃនេះខ្ញុំអង្វរកុមារនោះ
កុំចេញនោះ ប្រែថាតែនាងតែងរំពឹងអង្វរ ទុកកុមារនោះចុះ ។

(៣១០) (សុវណ្ណទៅ...) ថែបផ្ទុំ ចូរកម្ម ប្រែធម៌ក្នុងចរិយាវត្ត
ចុះ ចូរអ្នកពិចារណាចិត្តដ៏ខ្ជាយហើយ ចូរស៊ូទុះ អ្នកចូរ
ទំលាក់ទោលខ្លួនឯង ក្នុងត្រជាក់ក្តៅដ៏អស់ទៅញ មិនមាន
អ្នកណានិន្ទាបាន ហើយចូលទៅកាន់ឋានព្រហ្មលោកចុះ ។

(ព្រះរាជា...) ម្នាលនាងសុវណ្ណ នាងនិយាយពាក្យណា
(ពាក្យនោះ) ជាអស្ចារ្យក្រៃពេក នាងឈ្មោះថាញុំាងខ្ញុំដែល
ដល់នូវសេចក្តីទុក្ខឲ្យរឹតតែបានទុក្ខទៀត កាលខ្ញុំនិយាយថា
ចូរនាងអង្វរកូនប្រុស នាងបែរជាញុំាងកុមារឲ្យប្រើបែប្រើវិញ ។

(៣១១) (សុវណ្ណទៅ...) ព្រះអរិយៈទាំងឡាយណា រួចស្រឡះ
ហើយ (ចាកកងកិលេស) ជាអ្នកបរិភោគនូវភោជនមិន
មានទោស រលត់ហើយ តែងត្រាច់ទៅកាន់លោកនេះ
ខ្ញុំម្ចាស់មិនអាចហាមឃាត់ព្រះរាជកុមារ ដែលកំពុងដើរទៅ
កាន់ផ្លូវរបស់ព្រះអរិយៈនោះបានទេ ។

(៣០៨) អទ្ធា ហវេ សេវិតព្វា សបញ្ញា
ពហុស្សុតា យេ ពហុឋានចិន្តិនោ
យេសាយំ សុត្វាន សុភាសិតានិ
អប្បោស្សុក្កា វីតសោកា សុខម្ហាតិ ។

សោណនន្ទជាតកំ នវមំ ។

## ចម្បេយ្យជាតកំ

(៣០៩) កា នុ វិជ្ជុរិវាភាសិ ឱសធី វិយ តារកា
ទេវតា នុសិ គន្ធព្វី ន តំ មញ្ញាមិ មានុសឹ ។

(៣១០) នម្ហិ ទេវី ន គន្ធព្វី ន មហារាជ មានុសី
នាគកញ្ញាស្មិ ភទ្ទន្តេ អត្ថេនម្ហិ ឥធាគតា ។

(៣១១) វិព្ភន្តចិត្តា កុបិតិន្ទ្រិយាសិ
នេត្តេហិ តេ វារិគណា សវន្តិ
កឹ តេ នដ្ឋំ កឹ បន បត្ថយានា
ឥធាគតា នារិ តទិង្ឃ ព្រូហិ ។



(៣០៨) (ព្រះរាជា...) ជនទាំងឡាយណា ប្រកបដោយប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុច្រើនប្រការ គាត់សុខុមាទៅ នេះ ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ប្រាសចាកសេចក្តីសោក ព្រោះបានស្តាប់ពាក្យសុភាសិតទាំងឡាយ នៃពួកជនណា ជនទាំងនោះ គួរអ្នកផង គប់រកដោយពិត ។

ចប់ សោណនន្ទជាតក ទី ៩ ។

## ចម្បេយ្យជាតក

(៣០៩) (ព្រះបាទពារាណសីត្រាស់សួរថា) នាងជាអ្វី មានពន្លឺដូចជាផ្លេកបន្ទោរ ឬដូចជាផ្កាយព្រឹក នាងជាស្ត្រីទេវតា ឬជាស្ត្រីគន្ធព្វ យើងមិនសំគាល់នាងថាជាស្ត្រីមនុស្សទេ ។

(៣១០) (នាងនាគក្រាបបង្គំទូលថា) បពិត្រមហារាជ ខ្ញុំម្ចាស់មិនមែនជាស្ត្រីទេវតា មិនមែនជាស្ត្រីគន្ធព្វ មិនមែនជាស្ត្រីមនុស្ស បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់ជានាគកញ្ញា មកក្នុងទីនេះ ដោយសេចក្តីត្រូវការ ។

(៣១១) (ព្រះរាជា ) នាងមានចិត្តតក់ស្លុត មានឥន្ទ្រិយញាប់ញ័រ តំណក់ទឹកភ្នែកទាំងឡាយ ហូរស្រក់ចាកភ្នែកទាំងឡាយរបស់នាង ចុះវត្ថុអ្វីរបស់នាងបាត់ ម្នាលនាង នាងចង់បានរបស់អ្វី បានជាមកក្នុងទីនេះ ចូរនាងប្រាប់ហេតុនោះមកចុះ ។

(៣១៦) យមុគ្គតោ ឧរគោតិ ចាហុ
នាគោតិ នំ អាហុ ជនា ជនិន្ទ
តមគ្គហី បុរិសោ ជីវិកត្ថោ
តំ ពន្ធា មុញ្ច បតី មមេសោ ។

(៣១៧) កថំ នុយំ ពលវិរិយូបបន្នោ
ហត្ថត្តមាគច្ឆិ វនិព្វកស្ស
អក្ខាហិ មេ ញាតកញ្ញេ គមត្ថំ
កថំ វិជានេមុ គហីតនាគំ ។

(៣១៨) នគរំបិ នាគោ ភស្មំ ករេយ្យ
តថាហិ សោ ពលវិរិយូបបន្នោ
តេជស្សី នាគោ អបចាយមានោ
កស្មា បរក្កម្ម គតោ ករេកំ ។

(៣១៩) ចាតុទ្ទសី បណ្ណរសី ច រាជ
ចតុប្បថេ សម្មតិ នាគរាជា
តមគ្គហី បុរិសោ ជីវិកត្ថោ
តំ ពន្ធា មុញ្ច បតី មមេសោ ។



(៣១៦) (នាងនាគី.) បពិត្រព្រះអង្គជាធំជាងជន ពួកជនបាន
ហៅសត្វណាថា ឧរគៈ មានតេជះដ៏ខ្ពង់ខ្ពស់ តែងហៅសត្វ
នោះថា នាគ បុរសអ្នកត្រូវការចិញ្ចឹមជីវិត បានចាប់នាគ
នោះមកហើយ សូមព្រះអង្គលែងនាគនោះ ពីចំណងទៅ
នាគនោះជាប្ដីរបស់ខ្ញុំម្ចាស់ ។

(៣១៧) (ព្រះរាជា...) នាគរាជនេះ ជាប់ប្រកបដោយកម្លាំងនិងព្យាយាម
ដោយដូចម្ដេច ក៏ស្ដេចមកលុះក្នុងកណ្ដាប់ដៃនៃមនុស្សកំសត់
ទៅវិញ ម្នាលនាគកញ្ញា ចូរនាងប្រាប់ហេតុនោះដល់យើង
ធ្វើម្ដេចនឹងយើងស្គាល់នាគដែលគេចាប់មក (នោះ)បាន ។

(៣១៨) (នាងនាគ...) ពិតមែន នាគរាជនោះប្រកបដោយ
កម្លាំងនិងព្យាយាម សាបស្មើនូវនគរឲ្យជាផេះបាន ប៉ុន្តែ
នាគរាជនោះគោរពធម៌ ព្រោះហេតុនោះ ទើបទ្រាំនៅធ្វើតបធម៌

(៣១៩) បពិត្រព្រះរាជា នាគរាជរក្សាចាតុទ្ទសីឧបោសថ និង
បណ្ណរសីឧបោសថ នៅជិតផ្លូវបែកជាបួន បុរសអ្នកត្រូវ
ការចិញ្ចឹមជីវិត បានចាប់នាគរាជនោះមកហើយ សូមព្រះអង្គ
លែងនាគរាជនោះពីចំណង នាគរាជនុ៎ះជាប្ដីរបស់ខ្ញុំម្ចាស់ ។

(៣១៦) សោឡសិត្ថិសហស្សានិ អាមុត្តមណិកុណ្ឌលា

ភរិតហសយា ពារី តាបំតំ សរណំ គតា ។

ធម្មេន ភោគេហិ អសាហសេន

កាមេន ចិត្តេន គតិំ សរេន

និស្សជ្ជកាយោ ឧរគោ ចកតុ

បុញ្ញត្ថិកោ មុញ្ចតុ ពន្ធនស្មា ។

(៣១៧) ធម្មេន ភោគេហិ អសាហសេន

កាមេន ចិត្តេន គតិំ សរេន

និស្សជ្ជកាយោ ឧរគោ ចកតុ

បុញ្ញត្ថិកោ មុញ្ចតុ ពន្ធនស្មា ។

ធម្មំ ចិត្តសតំ លទ្ធំ ជ្វលញ្ច មណិកុណ្ឌលំ

ពត្ថស្សញ្ច ចលត្ថិំ ឧម្មារត្តប្ផសង្កាំ

ទ្វេ ច សាទិសិយោ ភរិយា ឧសភញ្ច គវំ សតំ

និស្សជ្ជកាយោ ឧរគោ ចកតុ

បុញ្ញត្ថិកោ មុញ្ចតុ ពន្ធនស្មា ។



(៣១៦) នាងនារីស្រីស្អាតរបស់ខ្ញុំ ដប់ប្រាំមួយពាន់ ពាក់កុណ្ឌល ជាវិការៈនៃកែវមណី មានខ្លួនដ៏ល្អក្រៃពេក នាងនារីទាំងនោះ ឯង គឺដល់នូវខ្ញុំជាទីពឹង ។ សូមព្រះអង្គដោះលែង (នាគនោះ) ដោយខ្លួនឯងនូវធម៌ ដោយកំពើចិត្តក្រោធ គឺដោយស្រេក ស្ងួត ដោយមាសប្រាក់ ដោយមេទ្រយ ចូរឲ្យនាគមានកាយរួច ស្រឡះហើយ ត្រាច់ទៅចុះ (នាគ) អ្នកត្រូវការដោយបុណ្យ ចូរ រួចពីចំណងចុះ ។

(៣១៧) ព្រះរាជា... ប្រយ៉ើងដោះលែង (នាគនេះ) ដោយខ្លួនឯងនូវធម៌ ដោយ កំពើចិត្តក្រោធ គឺដោយស្រេកស្ងួត ដោយមាសប្រាក់ ដោយ មេទ្រយ ចូរឲ្យនាគមានកាយរួចស្រឡះ ហើយត្រាច់ទៅចុះ (នាគ) អ្នកត្រូវការដោយបុណ្យ ចូររួចពីចំណងចុះ ។ ខ្ញុំប្រគេន យើងឲ្យមាសប្រាក់ ១ រយផង កុណ្ឌលជាវិការៈនៃកែវមណីដ៏ច្រើន ផង បល្ល័ង្កមានជើង ៤ មានពណ៌ដូចផ្កាត្រកៀតផង ភរិយា ស្មើគ្នា (ដោយវ័យជាដើម) ២នាក់ផង គោឧសភ ១ រយផង នាគមានកាយរួចស្រឡះហើយ ចូរត្រាច់ទៅចុះ (នាគ) អ្នកត្រូវ ការដោយបុណ្យ ចូររួចពីចំណងចុះ ។

(៣៥៨) វិតាបំ តាតា តស្ស ចេតំ ផលិត្ថ
បុព្វេបុ តំ នរកំ ពន្ធនស្មា
ទុស្សន្តកាយោ នរកោ ចកតុ
បញ្ញត្តិកោ មុញ្ចតុ ពន្ធនស្មា ។

(៣៥៩) មុត្តោ ចមេយ្យស្សកោ ធាតោ រាជាតំ បិតុឧព្រិ
នមោ តេ កាសិរាជត្ថុ នមោ តេ កាសិវឌ្ឍន
អញ្ជលិំ តេ បគ្គណ្ហាមិ បស្សេយ្យំ មេ និវេសនំ ។

(៣៦០) អទ្ធា ហិ ទុក្ខស្សសមេតមាហុ
យំ មានុសោ វិស្សសេ អមានុសម្ហិ
សចេ ច មំ យាចសិ បុត្តកន្តិ
ធនញ្ញមុ តេ ជាត និវេសនានិ ។

(៣៦១) សចេបិ វាតោ គិរិមាវហេយ្យ
ចន្ទោ ច សុរិយោ ច ឆមា បតេយ្យុំ
សព្វា ច នជ្ជោ បដិសោតំ វជេយ្យុំ
ន ត្វេវហំ រាជ មុសា ភណេយ្យំ ។



(៣៥៨) (អាលម្ពាយ...) បពិត្រព្រះអង្គជាម្ចាស់ដ៏ផែនដី ព្រះរាជទ្រព្យ
របស់ព្រះអង្គនៅរៀវពោលព្រះរាជវាំងណាយកបាន ទូលព្រះបង្គំសូម
លែងនាគនោះអំពីចំណង នាគនោះមានកាយស្ដួចស្ដើងហើយ ចូរ
ត្រឡប់ទៅចុះ (នាគ)ឈ្មោះត្រូវការដោយបុណ្យ ចូររួចអំពីចំណងចុះ ។

(៣៥៩) (អតិសម្មុខតោ...) ចម្បេយ្យកនាគ បានរួចហើយ ក្រាបបង្គំ
ទូលព្រះរាជាថា បពិត្រព្រះរាជាក្នុងដែនកាសី សូមថ្វាយបង្គំព្រះអង្គ
បពិត្រព្រះអង្គ អ្នកញ៉ាំងដែនកាសីឲ្យចំរើន សូមថ្វាយបង្គំព្រះអង្គ
ទូលព្រះបង្គំជាខ្ញុំ សូមផ្គងអញ្ជលីប្រណម្យដល់ព្រះអង្គ ទូលព្រះបង្គំ
ជាខ្ញុំ ចង់បង្ហាញនូវលំនៅរបស់ទូលព្រះបង្គំជាខ្ញុំ (ដល់ព្រះអង្គ) ។

(៣៦០) (ព្រះរាជា...) មនុស្សស្និទ្ធស្នាលនឹងពួកអមនុស្ស ដោយ
ហេតុណា អ្នកប្រាជ្ញទាំងឡាយ តែងពោលនូវហេតុនុ៎ះថា ជា
សេចក្ដីស្និទ្ធស្នាលធ្លាក់ដោយពិត ប៉ុន្តែបើអ្នកអង្វរឿងនុ៎ះ
និងយើង ម្ចាស់នាគ យើងនឹងទៅមើលលំនៅរបស់អ្នក ។

(៣៦១) (នាគរាជ...) បើទុកជាខ្យល់ក្ដីយកភ្នំទៅបាន ព្រះចន្ទនិង
ព្រះអាទិត្យជ្រុះចុះមកលើផែនដី ទោះស្ទឹងទាំងពួងហូរច្រាសបាន
បពិត្រព្រះរាជា ទូលព្រះបង្គំជាខ្ញុំ ក៏មិនពោលពាក្យកុហកទេ ។

នភំ ផលេយ្យ ឧទធិ វិសុស្សេ
សំវដ្ដេយ្យ ភូតធរា វសុន្ធរា
សិលុច្ចយោ មេរុ សមូលមុប្បតេ
ន ត្វេវហំ ភជ មុសា ភណេយ្យំ ។

(៣៦២) អទ្ធា ហិ ទុស្សំវាសមាហុ
យំ មានុសោ វិស្សសេ អមានុសម្ហិ
សចេ ច មំ យាចសិ ឯតមត្ថំ
ទក្ខេមុ តេ នាគ និវេសនានិ ។

(៣៦៣) តុម្ហេត្ថ ឃោរវិសា ឧឡារា
មហាតេជា ខិប្បកោបី ច ហោថ
មមំ ការណា ពន្ធនស្មា បមុត្តោ
អរហាសិ នោ ជានិតវេ(១) កតានិ ។

(៣៦៤) សោ បច្ចតំ និរយេ ឃោររូបេ
មា កាយិកំ សាតមលត្ថ កិញ្ចិ
បេឡាយ ពទ្ធោ មរណំ ឧបេតុ
យោ តាទិសំ កម្មកតំ ន ជានេ ។

---

១-១. ជានិតយេ ។ ម. ជានិតុយេ ។



ផ្ទៃអាកាសបែកធ្លាយក្តី សមុទ្ររីងស្ងួតក្តី ផែនដីជាទីទ្រសត្វ ទ្រទ្រង់ គប្បីវិលក្តី ទាំងភ្នំមេរុសណ្តោកឡើង ព្រមទាំងឫសក្តី បពិត្រព្រះរាជា ទូលព្រះបង្គំជាខ្ញុំ មិនពោលពាក្យកុហកទេ ។

(៣៦២) (ព្រះរាជា...) មនុស្សស្និទ្ធស្នាលនឹងពួកអមនុស្ស ដោយហេតុណា អ្នកប្រាជ្ញទាំងឡាយ ពោលនូវហេតុនុះថាជាសេចក្តីស្និទ្ធស្នាលអាក្រក់ ដោយពិត ប៉ុន្តែបើអ្នកអង្វររឿងនុះនឹងយើង ម្នាលនាគ យើងនឹងទៅមើលលំនៅរបស់អ្នកដែរ ។

(៣៦៣) ពួកអ្នកនោះ គឺជាសត្វមានពិសខ្លាំងក្លាក្រៃពេកណាស់ មានតេជះច្រើន ឆាប់ខឹង អ្នករួចអំពីចំណងបាន ព្រោះហេតុនៃយើង អ្នកគួរដឹងនូវឧបការគុណ ដែលយើងបានធ្វើហើយ ។

(៣៦៤) (នាគរាជ...) បុគ្គលណាមិនស្គាល់នូវបុគ្គលមានកុសលកម្មធ្វើហើយ (ធ្វើគុណ) ប្រាកដដូចព្រះអង្គ បុគ្គលនោះចូរធ្លាក់ក្នុងនរកមានសភាពគួរស្បើម កុំឲ្យបានសេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ បន្តិចបន្តួចឡើយ ចូរជាប់នៅក្នុងទ្រុងដល់នូវសេចក្តីស្លាប់ចុះ ។

(៣៦៥) សច្ចប្បដិញ្ញា តវមេស ហោតុ
អក្កោធនោ ហោហិ អនុបនាហី
សព្វញ្ច តេ នាគកុលំ សុបណ្ណា
អគ្គឹវ[១] គិម្ហាសុ វិវជ្ជយន្តុ ។

(៣៦៦) អនុកម្បសិ នាគកុលំ ទិជិន្ទ
មាតា យថា សុប្បិយមេកបុត្តំ
អហញ្ច តេ នាគកុលេន សទ្ធឹ
កាហាមិ វេយ្យាវដិកំ[២] ឧឡារំ ។

(៣៦៧) យោជេន្តុ វេ រាជរថេ សុចិត្តេ
កម្ពោជកេ អស្សតរេ សុទន្តេ
នាគេ ច យោជេន្តុ សុវណ្ណកប្បនេ
ទក្ខេមុ នាគស្ស និវេសនានិ ។

(៣៦៨) ភេរី មុទិង្គា បណវា ច សង្ខា
អាវជ្ជយឹសុ ឧគ្គសេនស្ស រញ្ញោ
បយាសិ រាជា ពហុ សោភមានោ
បុរក្ខតោ នារិគណស្ស មជ្ឈេ ។

---

១ ឱ. ម. អគ្គី ។ ២ ឱ. វេយ្យាវដិំ ។



(៣៦៥) (ព្រះរាជា...) ពាក្យប្ដេជ្ញារបស់អ្នកនុ៎ះ ជាពាក្យសច្ច អ្នក
ចូរកុំមានសេចក្ដីក្រោធ អ្នកចូរកុំចងសេចក្ដីក្រោធទុក ពួក
គ្រុឌក៏ចូរវៀរលែងត្រកូលនាគ ទាំងអស់របស់អ្នក ដូចពួក
មនុស្សវៀរចាកគំនរភ្លើង ក្នុងគិម្ហសម័យដូច្នោះចុះ ។

(៣៦៦) (នាគរាជ...) បពិត្រព្រះអង្គជាធំជាងទិជ ព្រះអង្គអនុគ្រោះ
នូវត្រកូលនាគ ដូចជាមាតាអនុគ្រោះកូនប្រុសតែម្នាក់ដែល
ជាទីស្រឡាញ់ស្មោះ ចំណែកខាងទូលព្រះបង្គំជាខ្ញុំ ព្រម
ទាំងត្រកូលនាគ នឹងធ្វើនូវការខ្វល់ខ្វាយបំរើ ចំពោះព្រះអង្គ
ដ៏លើសលុប ។

(៣៦៧) (ព្រះរាជា...) នែវៃយ ពួកភ្នាក់ងារគ្រប់តំណែង ចូរទឹមរាជរថ
ដ៏វិចិត្រដោយប្រពៃ ចូរទឹមអស្សតរដែលកើតក្នុងដែនកម្ពុជៈ
ជាពាហនៈទូន្មានបានចប់ល្អហើយ ចូររៀបដំរី ប្រដាប់
ដោយគ្រឿងមាស យើងនឹងទៅមើលលំនៅរបស់នាគ ។

(៣៦៨) (អភិសម្ពុទ្ធគាថា) ពួកស្គរធំ ស្គរតូច ត្រែ ស័ង្ខរបស់ព្រះរាជា
ព្រះនាមឧគ្គសេន ក៏លាន់ឮឡើង ព្រះរាជាទ្រង់ព្រះលំអ
ច្រើនប្រការ ទ្រង់ស្ដេចយាងទៅ ក្នុងកណ្ដាលនៃពួកនារី
ដែលហែហមជុំវិញ ។

(៣៦៩) សុវណ្ណចិត្តកំ ភូមឹ អន្វគា កាសិវឌ្ឍនោ
សោវណ្ណមយេ ច បាសាទេ វេឡុរិយផលកត្ថតេ ។
ស រាជា បាវិសិ ព្យម្ហំ ចម្បេយ្យស្ស និវេសនំ
អាទិច្ចវណ្ណសន្និភំ[១] កំសវិជ្ជុបភស្សរំ ។
នានារុក្ខេហិ សញ្ឆន្នំ នានាគន្ធសមេរិតំ
សោ បាវេក្ខិ កាសិរាជា ចម្បេយ្យស្ស និវេសនំ ។
បវិដ្ឋស្មឹ កាសិរញ្ញោ ចម្បេយ្យស្ស និវេសនេ
ទិព្វា តុរិយា បវជ្ជិំសុ នាគកញ្ញា ច នច្ចិំសុ ។
តំ នាគកញ្ញា ចរិតំ គណេន
អន្វារុហី កាសិរាជា បសន្នោ
និសីទិ សោវណ្ណមយម្ហិ បីឋេ
សាបស្សយេ ចន្ទនសារលិត្តេ ។
(៣៧០) សោ តត្ថ ភុត្វា ច អថោ រមិត្វា
ចម្បេយ្យកំ កាសិរាជា អវោច
វិមានសេដ្ឋានិ ឥមានិ តុយ្ហំ
អាទិច្ចវណ្ណានិ បភស្សរានិ
នេតាទិសំ អត្ថិ មនុស្សលោកេ

១ ម. អាទិច្ចវណ្ណូបនិភំ ។





(៣៦៩) ព្រះរាជាអ្នកញ៉ាំងដែនកាសីឲ្យចំរើន បានទតឃើញផែនដី ដ៏វិចិត្រដោយមាស និងប្រាសាទទាំងឡាយជាវិការៈនៃមាស ដែលក្រាលដោយបន្ទះកែវពិទូរ្យ ។ ព្រះរាជាអង្គនោះទ្រង់ចូលទៅកាន់នាគ-ពិភពដ៏សម្បើម ជាទីនៅនៃចម្បេយ្យនាគរាជ ដ៏ភ្លឺស្វាងដូចជាពណ៌នៃព្រះអាទិត្យ មានរស្មីផ្លេកៗ ដូចផ្លេកបន្ទោរពណ៌មាស ។ ព្រះបាទកាសីនោះ ទ្រង់ទតនិវេសនដ្ឋាន របស់ចម្បេយ្យនាគរាជ ដ៏ដេរដាសដោយឈើទាំងឡាយផ្សេងៗ ដ៏ផ្សព្វផ្សាយ ដោយក្លិនក្រអូបផ្សេងៗ ។ កាលដែលព្រះបាទកាសី ទ្រង់ចូលទៅហើយ តូរ្យតន្ត្រីទាំងឡាយជាទិព្វ ក៏លាន់ឮឡើង នាគកញ្ញាទាំងឡាយក៏រាំថ្វាយ ក្នុងរាជនិវេសន៍នៃចម្បេយ្យនាគរាជ ។

ព្រះរាជនិវេសន៍នោះ ដេរដាសដោយពួកនៃនាគកញ្ញា ព្រះរាជាកាសីទ្រង់ជ្រះថ្លា ឡើងគង់លើបល្ល័ង្ក ជាវិការៈនៃមាស មានបង្អែកដ៏លាបលាប ដោយខ្លឹមចន្ទន៍ ។

(៣៧០) ព្រះបាទកាសីនោះ ទ្រង់សោយ ទ្រង់ត្រេកអរក្នុងនាគពិភព នោះហើយមានព្រះរាជឱង្ការនឹងចម្បេយ្យនាគរាជថា វិមានដ៏ប្រសើរទាំងឡាយរបស់អ្នកនេះ មានពណ៌ដូចព្រះអាទិត្យដ៏ភ្លឺផ្លេកៗ ធម្មជាតប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ

កិមត្ថិយំ[១] តាត តុវំ ករោសិ ។
តា កម្ពុកាយូរធរា សុវត្ថា
វដ្ដង្គុលី តម្ពតលូបបន្នា
បគ្គយ្ហ តាយេន្តិ អនោមវណ្ណា
នេតាទិសំ អត្ថិ មនុស្សលោកេ
កិមត្ថិយំ តាត តុវំ ករោសិ ។
នជ្ជោ ច ខេមា បុថុលោមបន្នា
នានាសកុណាភិរុតា សុតិត្ថា
នេតាទិសំ អត្ថិ មនុស្សលោកេ
កិមត្ថិយំ តាត តុវំ ករោសិ ។
កោញ្ចា មយូរា ទិវិយា ច ហំសា
វគ្គុស្សរា កោកិលា សម្បតន្តិ
នេតាទិសំ អត្ថិ មនុស្សលោកេ
កិមត្ថិយំ តាត តុវំ ករោសិ ។
អម្ពា ច សាលា តិលកា ច ជម្ពុយោ
ឧទ្ទាលកា បាដលិយោ ច ផុល្លា
នេតាទិសំ អត្ថិ មនុស្សលោកេ

---
១ ម. កិំបត្ថយំ ។



ម្នាលតាត អ្នកធ្វើតបធម៌ ដើម្បីអ្វី ។ ពួកនាងនាគកញ្ញានោះ ពាក់នូវគ្រឿងប្រដាប់មាស មានសម្លៀកបំពាក់ដ៏ល្អ មានម្រាមដៃមូល ប្រកបដោយផ្ទៃ (ដៃនិងជើង) ដ៏ក្រហម មានសម្បុរមិនអន់ថយ លើក (នូវចិត្តជនៈ) ហៅថ្វាយដើម្បីសោយ ធម្មជាតប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលតាត អ្នកធ្វើតបធម៌ ដើម្បីអ្វី ។ ស្ទឹងទាំងឡាយមានទឹកត្រជាក់ មានត្រីមានស្រកាក្រាស់ មាននានាសបក្សីយំពីរោះ មានកំពង់ល្អ ធម្មជាតប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលតាត អ្នកធ្វើតបធម៌ ដើម្បីអ្វី ។ ហ្វូងក្រៀល ក្ងោក ហង្ស តាកើ ដ៏ជាទិព្វ ស្រែកនូវសម្រែកដ៏ពីរោះ ហើរចេញពីព្រឹក្សមួយ ទៅកាន់ព្រឹក្សមួយ ធម្មជាតដែលប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលតាត អ្នកធ្វើតបធម៌ ដើម្បីអ្វី ។ ដើមស្វាយ ដើមសាលព្រឹក្ស ដើមរមៀត ដើមព្រីង ដើមកដព្រឹក្ស ដើមប្រទៀងដ៏ទាំងឡាយ មានផ្ការីកស្គុះស្គាយ ធម្មជាត ដែលប្រាកដដូច្នេះ មិនមាន ក្នុងមនុស្សលោកទេ

កិំបត្ថយំ នាគ តបោ ករោសិ ។

ឥមា ច តេ បោក្ខរញ្ញោ សមន្តតោ
និច្ចោ ច គន្ធោ សតតំ សម្បវាយន្តិ
ន តាទិសំ អត្ថិ មនុស្សលោកេ
កិំបត្ថយំ នាគ តបោ ករោសិ ។

(៣៣១) ន បុត្តហេតុ ន ធនស្ស ហេតុ
ន អាយុនោ ចាបិ ជនិន្ទ ហេតុ
មនុស្សយោនិំ អភិបត្ថយានោ
តស្មា បរក្កម្ម តបោ ករោមិ ។

(៣៣២) ត្វំ លោហិតក្ខោ វិហតន្តរំសោ
អលង្កតោ កប្បិតកេសមស្សុ
សុរោសិតោ លោហិតចន្ទនេន
គន្ធព្វរាជាវ ទិសា បភាសសិ ។
ទេវិទ្ធិបត្តោសិ មហានុភាវោ
សព្វេហិ កាមេហិ សមង្គិភូតោ
បុច្ឆាមិ តំ នាគរាជេតមត្ថំ
សេយ្យោ ឥតោ កេន មនុស្សលោកោ ។





ម្នាលនាគ អ្នកធ្វើតបធម៌ ដើម្បីអ្វី ។ ក្លិនដ៏ជាទិព្វទាំងឡាយ រមែងបក់ផ្សាយជុំវិញស្រះបោក្ខរណីទាំងនេះជានិច្ច គន្ធជាត ប្រាកដដូចនេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ ដើម្បីអ្វី ។

(៣៣១) (នាគរាជ...) បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះបង្គំជាខ្ញុំ ធ្វើតបធម៌ មិនមែនព្រោះហេតុបានកូន មិនមែនចង់បាន ទ្រព្យ ឬក៏ មិនមែនព្រោះហេតុចង់បានអាយុទេ ខ្ញុំព្រះបង្គំជាខ្ញុំ ចង់បានកំណើតជាមនុស្ស ព្រោះហេតុនោះ ទើបខំប្រឹងធ្វើតបធម៌ ។

(៣៣២) (ព្រះរាជា...) អ្នកមានភ្នែកក្រហម មានស្មាត្រលាស់ មានខ្លួនប្រដាប់ហើយ មានសក់និងពុកមាត់កោរកាត់ហើយ ប្រស់ព្រំយ៉ាងល្អ ដោយចន្ទន៍ក្រហម ក្លិនផ្សាយទៅសព្វទិស ដូចជាគន្ធព្វរាជ ។ អ្នកមានឫទ្ធិដូចជាទេវតា មានអានុភាពច្រើនបរិបូណ៌ ដោយកាមទាំងឡាយគ្រប់យ៉ាង ។ ម្នាលនាគរាជ មនុស្សលោកប្រសើរដោយវិសេសជាងនាគពិភពនេះ ដោយហេតុអ្វី យើងសូមសួរអ្នកចំពោះហេតុនុ៎ះឯង ។

(៣៣៣) ជជ្ជិត្វ ទាញ្ញជ្រ មនុស្សលោកេ
សុចី ច សំវិជ្ជតិ សំយមោ ច
អហញ្ច លទ្ធាន មនុស្សយោនឹ
កាហាមិ ជាតិមរណស្ស អន្តំ ។

(៣៣៤) អទ្ធា ហវេ សេវិតព្វា សបញ្ញា
ពហុស្សុតា យេ ពហុឋានចិន្តិនោ
នារិយោ ច និស្វាន តុវញ្ច នាគ
កាហាមិ បុញ្ញានិ អនប្បកានិ ។

(៣៣៥) អទ្ធា ហវេ សេវិតព្វា សបញ្ញា
ពហុស្សុតា យេ ពហុឋានចិន្តិនោ
នារិយោ ច និស្វាន មមញ្ច រាជ
ករោហិ បុញ្ញានិ អនប្បកានិ ។

(៣៣៦) ឥទញ្ច មេ ជាតរូបំ បហូតំ
រាសី សុវណ្ណស្ស ច តាលមត្តា
ឥតោ ហរិត្វា សោវណ្ណឃរានិ ការយ
រូបិយស្ស ច ទាការំ ករោន្តុ ។



(៣៣៣) (នាគរាជ...) បពិត្រព្រះអង្គជាធំជាងជន សេចក្តីបរិសុទ្ធិក្តី ការសង្រួមក្តី បើនៅលោកមនុស្សលោកនេះហើយ ផង មានមែន បើខ្ញុំព្រះបង្គំជាខ្ញុំ បានកើតជាមនុស្សហើយ នឹងធ្វើនូវទីបំផុតនៃជាតិនិងមរណៈ ។

(៣៣៤) (ព្រះរាជា...) ពួកជនដែលប្រកបដោយប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុច្រើនប្រការ គេត្រូវតែគប់រកដោយពិត ម្នាលនាគរាជ ចំណែកខាងយើង បានឃើញនូវពួកនាងនារីផង នូវអ្នកផង នឹងធ្វើបុណ្យទាំងឡាយយ៉ាងច្រើន ។

(៣៣៥) (នាគរាជ...) ពួកជនដែលប្រកបដោយប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុច្រើនប្រការ គេត្រូវតែគប់រកដោយពិត បពិត្រព្រះរាជា ព្រះអង្គទ្រង់ទតឃើញ នូវពួកនាងនារីផង នូវខ្ញុំព្រះបង្គំជាខ្ញុំផង សូមព្រះអង្គធ្វើនូវបុណ្យទាំងឡាយ យ៉ាងច្រើនចុះ ។

(៣៣៦) ប្រាក់របស់ខ្ញុំព្រះបង្គំជាខ្ញុំនេះច្រើនណាស់ ទាំងគំនរមាស ក៏ប្រវែងហ្លួតកំពស់ដើមត្នោត សូមព្រះអង្គ ឲ្យគេបម្រើនាំ អំពីនាគពិភពនេះ ទៅកសាងព្រះរាជដំណាក់ ជាវិការៈនៃមាស ពួកជាង ចូរធ្វើកំពែងជាវិការៈនៃប្រាក់ចុះ ។

មុត្តា ចេត្ថ កហាសហស្សានិ បហូ
វេឡុរិយមណិស្សានិ ឥតោ ហរិត្វា
អរក្ខមុរ ភូមិយំ សន្ថរត្តុ
និក្ខិប្បមា ហេហិតិ នីរជា ច ។
និកាមនិវេសំ អាវស រាជសេដ្ឋ
វិមានសេដ្ឋំ ពហុ សោភមានំ
ពារាណសឹ ចការិ ន ខុំ ជីតំ
រជ្ជំ ការេហិ អនោមបញ្ញាតិ ។

ចម្ប៉េយ្យជាតកំ ទសមំ ។

## មហាបលោភនជាតកំ

(៣៦៧) ព្រហ្មលោកា ចវិត្វាន ទេវបុត្តោ មហិទ្ធិកោ
រញ្ញោ បុត្តោ ឧទបាទិ សព្វកាមសមិទ្ធិសុ ។
កាមា វា កាមសញ្ញា វា ព្រហ្មលោកេ ន វិជ្ជតិ
ស្វាស្សុ តាយេវ សញ្ញាយ កាមេហិ វិជិគុច្ឆថ ។
តស្ស ចន្តេបុរេ អាសិ ឈានាគារំ សុមាបិតំ
សោ តត្ថ បដិសល្លីនោ ឯកោ រហសិ ឈាយថ ។



និងកែវមុក្តា មានប្រាំកាត់ហោះ (កហបណៈ) និងកែវពៃទូរ្យ (ប្រាំកាត់ហោះ) នេះ សូមពួកខ្ញុំនាំទៅទុកក្នុងកន្លែងនេះ ហើយក្រាលលើផែនដីតាំងក្នុងបុរី ឲ្យជាទីមិនមានភក់ មិនមានធូលី ។ បពិត្រព្រះរាជាដ៏ប្រសើរ សូមព្រះអង្គគ្រប់គ្រងក្រុងពារាណសីឲ្យជាវិមានប្រសើរ មានលំអច្រើនអន្លើ ជានគរស្តុកស្តម្ភ ទូលំទូលាយមានសភាពដូច្នេះចុះ បពិត្រព្រះអង្គមានប្រាជ្ញាមិនថោកថយ សូមព្រះអង្គសោយរាជ្យចុះ ។

ចប់ ចម្ប៉េយ្យជាតក ទី ១០ ។

## មហាបលោភនជាតក

(៣៦៧) (ព្រះមានព្រះភាគទ្រង់ត្រាស់សំដែងជាតកនេះថា) ទេវបុត្រមានឫទ្ធិច្រើន ច្យុតចាកព្រហ្មលោកបានកើតជាបុត្រនៃព្រះរាជា ទ្រង់មិនរវៅក្នុងសម្បត្តិជាគ្រឿងញ៉ាំងសេចក្តីប្រាថ្នាទាំងពួងឲ្យសម្រេចបាន កាមទាំងឡាយក្តី កាមសញ្ញាក្តី មិនមានក្នុងព្រហ្មលោកទេ ព្រះរាជបុត្រនោះខ្ពើមណាយចាកកាមទាំងឡាយ ព្រោះឈានសញ្ញា (ដែលកើតក្នុងព្រហ្មលោក) នោះឯង ។ ក៏ក្នុងព្រះរាជវាំង នៃព្រះរាជានោះ មានព្រះរាជដំណាក់សម្រាប់ចំរើនឈាន ដែលគេកសាងហើយដោយល្អ ព្រះរាជបុត្រនោះ ទ្រង់សម្ងំតែមួយព្រះអង្គឯង ចំរើនឈានក្នុងទីកំបាំង ក្នុងព្រះរាជដំណាក់នោះ ។

សា កថំ បរិណេស្សតិ   វុត្តសោតេន អន្តិកោ

បរិភុត្តោ កយំ បញ្ញំ   ឥ ច អាហារំ កុញ្ជរំ ។

គោធុទ្ធគុទ្ធយោសោ   គោណា ជាតាតិ កិញ្ចិ

យោ មេ បុត្តំ បលោភេយ្យ   យថា តោ មានំ បត្តយេ ។

(៣៣៨) អហុ កុមារី តត្ថេវ   វណ្ណរូបសមាហិតា

កុសលា នច្ចគីតស្ស   គណេ ច បទក្ខិណា

សា តត្ថ ឧបសង្កម្ម   រាជានំ ឯតទព្រវិ

អហំ ខោ នំ បលោភេយ្យំ   សចេ ភត្តា ភវិស្សតិ ។

(៣៣៩) តំ តថាវាទិនឹ   កញ្ញា   កុមារី ឯតទព្រវិ

ភូតោ វ នំ បលោភេហិ   តវ ភត្តា ភវិស្សតិ ។

(៣៤០) សា ច អន្តេបុរំ គន្ត្វា   ពហុំ ភាមួបសញ្ហិតំ

ហទយង្គមា ពេមនីយា   ចិត្រា គាថា អភាសថ ។



ព្រះបាទកាសីនោះ ទ្រង់បរិភោគការដើរក្នុងខ្ពស់ ដោយសេចក្តី

សោក ព្រោះព្រះរាជបុត្រថា ព្រះរាជបុត្រតែមួយ របស់យើងនេះ

មិនបរិភោគភាព ។ ចុះយកកូនក្រៀលនេះ ដូចម្តងហ្នឹង ម្តង ទៀ

ណាហ្នឹង ទេទ្រង់ក្លាយ កូនក្រៀលនេះ អ្នកណាតាបប្រលោមកូន

គេ ឲ្យប្រាប់តាមតាំងព្រាយបាន ។

(៣៣៨) កូនព្រះរាជាដ៏នោះឯង មានកុមារីម្នាក់ ជាស្ត្រីមានសម្បុរ

នឹងរូបល្អ ជាស្ត្រីឈ្លាសវៃ ក្នុងការរាំច្រៀង ចាំនឹងបានសំគាល់

ក្នុងការប្រគំ កុមារីនោះ ចូលទៅគាល់ក្នុងទីនោះហើយ ក្រាប

បង្គំទូល (ព្រះរាជា) ថា បើព្រះរាជបុត្រនឹងបានជាព្រះភស្តានៃខ្ញុំ

ម្ចាស់ ខ្ញុំម្ចាស់គង់នឹងប្រលោមព្រះរាជបុត្រនោះឲ្យបានពិតបាន ។

(៣៣៩) ព្រះរាជា ទ្រង់មានព្រះរាជឱង្ការថា ចំពោះនឹងកុមារីដែលនិយាយ

ដូច្នោះនោះថា ចូរនាងប្រលោមព្រះរាជបុត្រនោះចុះ ព្រះរាជបុត្រ

នោះ នឹងជាភស្តារបស់នាង ។

(៣៤០) កុមារីនោះ ក៏ទៅកាន់ក្នុងព្រះរាជវាំងហើយ (ច្រៀង) នូវចម្រៀង

ដែលប្រកបដោយកាមច្រើនប្រការ ពោលគាថា ដ៏វិចិត្រជាទី

ស្រឡាញ់ ជ្រួតជ្រាបក្នុងហឫទ័យ ។

(៣៦១) តស្សា ច គាយមានាយ សទ្ទំ សុត្វាន នារិយា
កាមច្ឆន្ទស្ស ឧប្បជ្ជិ ជនំ សោ បរិបុច្ឆថ ។
កស្សេសោ សទ្ទោ កោ វា សោ ភណតិ ឧច្ចាវចំ ពហុំ
ហទយង្គមំ បេមនីយំ អហោ(១) កណ្ណសុខំ មម ។

(៣៦២) ឯសា ខោ បមទា(២) ទេវ ខិឌ្ឌា ឯសា អនប្បិកា
សចេ ត្វំ កាមេ ភុញ្ជេយ្យ ភិយ្យោ ភិយ្យោ ឆាទយេយ្យុំ(៣) តំ ។

(៣៦៣) ឥង្ឃ អាគច្ឆតោរេន អវិទូរម្ហិ គាយតុ
អស្សមស្ស សមីបម្ហិ សន្តិកេ មយ្ហំ គាយតុ ។

(៣៦៤) តិរោកុឌ្ឌម្ហិ គាយិត្វា ឈានាគារម្ហិ បាវិសិ
ពន្ធិ នំ អនុបុព្វេន អារញ្ញមិវ កុញ្ជរំ ។

(៣៦៥) តស្ស កាមរសំ ញត្វា ឥស្សាធម្មោ អជាយថ
អហមេវ កាមេ ភុញ្ជេយ្យំ មា អញ្ញោ បុរិសោ អហុ ។
តតោ អសឹ គហេត្វាន បុរិសេ ហន្តុំ ឧបក្កមិ
អហមេវេកោ ភុញ្ជិស្សំ មា អញ្ញោ បុរិសោ សិយា ។

---

១ ឱ. អហោ ។ ២ ម. បមទា ។ ៣ ឱ. ឆាទេយ្យុំ ។ ម. ឆាទេយ្យុំ តំ ។



(៣៦១) ចំណង់ក្នុងកាមក៏កើតឡើង ដល់ព្រះរាជបុត្រនោះ ព្រោះបានស្ដាប់សម្លេងរបស់នារីច្រៀងថ្វាយនោះឯង ព្រះរាជបុត្រនោះទ្រង់សាកសួរជនថា យីអើ នុ៎ះជាសម្លេងនរណា ឬថា នរណានោះពោលពាក្យខ្ពស់ទាបច្រើន ដ៏ជ្រួតជ្រាបក្នុងហឫទ័យជាទីស្រឡាញ់ ជាសុខត្រចៀករបស់អញ ។

(៣៦២) បពិត្រព្រះសម្មតិទេព នុ៎ះឯងជាស្ត្រី ស្ត្រីនុ៎ះលេងល្បែងច្រើនប្រការ បើព្រះអង្គទ្រង់សោយនូវកាមទាំងឡាយណា កាមទាំងឡាយនោះ នឹងញ៉ាំងព្រះអង្គឲ្យរឹតតែគាប់ព្រះទ័យ ។

(៣៦៣) អើបើដូច្នោះ ចូរកុមារីមកតាមនេះ ចូរច្រៀងក្នុងទីជិតចុះ ចូរច្រៀងក្នុងទីជិតអាស្រម ក្នុងសំណាក់នៃយើងចុះ ។

(៣៦៤) កុមារីនោះ ច្រៀងក្នុងទីខាងក្រៅជញ្ជាំង ហើយចូលទៅក្នុងព្រះរាជដំណាក់សំរាប់ធ្វើឈាន ដើម្បីចងព្រះរាជកុមារនោះតាមលំដាប់ ដូចជាហ្មដំរីចងដំរីក្នុងព្រៃ ។

(៣៦៥) ធម៌ប្រចណ្ឌបានកើតព្រោះដឹងនូវកាមរសនៃកុមារីនោះ យើងត្រូវតែបរិភោគកាមទាំងឡាយតែម្នាក់ឯងប៉ុណ្ណោះ កុំឲ្យមានបុរសដទៃឡើយ ។ តពីនោះទៅ ព្រះរាជកុមារទ្រង់កាន់ដាវក្របយាម ដើម្បីសម្លាប់បុរសទាំងឡាយ ដោយគិតថា អញត្រូវបរិភោគកាមតែម្នាក់ឯងប៉ុណ្ណោះ កុំឲ្យមានបុរសដទៃ ។

(៣៦៦)តតោ ជាលបថា សត្ថា វិក្កន្ទិត្វា សមាគតា
ឧបត្ថា ត្យាយំ មហាភរំ ជលំ ហោមេត្យុទ្ធសតំ ។

(៣៦៧)តញ្ច រាជា និកហោសំ[1] សព្ធារដ្ឋា[2] ច ទុក្ខិយោ
យោគោ វិជិតា ឧយ្យំ ឱ តេ វត្ថុ ការេធ ។

(៣៦៨)តតោ សោ ករិយមានាយ សមុទ្ទំ ឧបសង្កមិ
បណ្ណសាលំ ករិត្វាន វសំ ឧញ្ឆាយ ចារិសំ ។

(៣៦៩)អបេត្វា ឥសិ មាកញ្ចិ សមុទ្ទមុបរិ
សោ អស្ស ពេលាំ ចាវេត្វា កត្តកាលេ ឧបដ្ឋិតេ ។

(៣៧០)តញ្ច ករិយា បលោកេសិ បស្ស យានំ សុធាវុណំ
ធុតោ សោ ព្រហ្មចរិយម្ហា ឥត្ថិយា បរិហាយតិ ។

(៣៧១)រាជបុត្តោ ច ឧញ្ញាតោ វិនមុលដលំ ពយុំ
សាយំ ការេន កាយាយ អស្សមំ ឧបសង្កមិ ។

(៣៧២)ឥសិ ច ទុក្ខិយំ និស្វា សមុទ្ទំ ឧបសង្កមិ
ទោយសិ កបស្សន្តិ សីឃតេ សោ មហាណ្ណវេ ។

---
១ ឱ. វិភាហោសំ ។ ២. និហោសំ ។ ២ ឱ. ឋម្ហា ។



(៣៦៦) ក្នុងកាលនោះ អ្នកដំណើរទាំងអស់ មកប្រជុំគ្នា ភន្តាំងភាំង
ថា បរិក្រមហាភរ ព្រោះដល់ទ្រព្យរបស់ព្រាហ្មណ៍នេះ រៀបរៀងខ្លួន
ដែលមិនប្រហុស្ម ។

(៣៦៧) ព្រះរាជាជាក្សត្រ ទ្រង់ប៉ះបើព្រះរាជទ្រព្យចេញចាកដែនដោយ
ទីដែនរបស់អញមានត្រើមណា ឯងមិនត្រូវនៅ ត្រើមនោះទេ ។

(៣៦៨) លំដាប់នោះព្រះរាជកុមារនោះ ទ្រង់តាំងកាយាហែលទៅនឹងសមុទ្រ
ធ្វើខ្លួនបណ្ណសាលា ហើយហែលទៅកាន់ក្រុងមិថិលាស្មើកដែលតាំងនោះ ។

(៣៦៩) លំដាប់នោះ ដល់មកខាងលើសមុទ្រដល់ក្នុងទីខ្ពុះ ត់សី
នោះក៏ឃើញផ្ទះរបស់ព្រះរាជកុមារនោះក្នុងកាលគួរដល់ហើយ ។

(៣៧០) ឯករិយាក៏ប្រលោមនាបសនោះ (ព្រាហ្មណ៍) អ្នកឃ្លាំមើល
តាំពីតាក្រក់ខ្លួនស្ទើរ (នោះ) ចុះ តបសនោះឃ្លាតចាកព្រហ្មចរិយ-
ធម៌ហើយ ក៏សាបសូន្យចាកឫទ្ធិ ។

(៣៧១) ចំណែកខាងព្រះរាជបុត្រ ដល់វេលាល្ងាចក៏តាំងយកមើមឈើ
និងផ្លែឈើជាច្រើន មកកាន់ទីស្ងួតដែលផល ដោយមាំប្រែក
ហើយហែលទៅកាន់អាស្រម ។

(៣៧២) ឯតសីបានឃើញស្ងួតហើយ ក៏ចូលទៅឯសមុទ្រដោយគិត
ថា អញនឹងទៅកាន់អាកាស តែឥសីនោះលិចចុះក្នុងសមុទ្រ ។

[៣៨៣] ខត្តិយោ ច ឥសឹ ទិស្វា សីទន្តំ មហណ្ណវេ
តាបសេ អនុកម្បាយ ឥមា គាថា អភាសថ ។

[៣៨៤] អភិជ្ជមានេ វារិស្មឹ សយំ អាគម្ម ឥទ្ធិយា
មិស្សីភាវិត្ថិយា គន្ត្វា សំសីទសិ មហណ្ណវេ ។
អាវដ្ដនី មហាមាយា ព្រហ្មចរិយវិកោបនា
សីទន្តិ នំ វិទិត្វាន អារកា បរិវជ្ជយេ ។
(១)អនលា មុទុសម្ភាសា ទុប្បូរា តា នទីសមា
សីទន្តិ នំ វិទិត្វាន អារកា បរិវជ្ជយេ ។
យំ ឯតា ឧបសេវន្តិ ឆន្ទសា វា ធនេន វា
ជាតវេទោវ សំ ឋានំ ខិប្បំ អនុទហន្តិ នំ ។

[៣៨៥] ខត្តិយស្ស វចោ សុត្វា ឥសិស្ស និព្វិទា អហុ
លទ្ធា បោរាណកំ មគ្គំ គតោ សោ វិហាយសំ ។

[៣៨៦] ខត្តិយោ ច ឥសឹ ទិស្វា គច្ឆមានំ វិហាយសំ
សំវេគំ អលភី ធីរោ ព្រហ្មចេរំ សមាទយិ ។

---
១ ម. ឋ អនលោ ។



(៣៨៣) មហាក្សត្របានឃើញឥសីកំពុងលិចក្នុងសមុទ្រ ហើយពោលពាក្យនេះ ដោយសេចក្តីអនុគ្រោះដល់តាបសនោះថា

(៣៨៤) តាបសមកលើទឹកមិនលិច ដោយឫទ្ធិខ្លួនឯង ហើយលិចក្នុងសមុទ្រ ព្រោះដល់នូវសេចក្តីប្រែប្រួល ដោយស្ត្រី ។ ពួកស្ត្រី ជាអ្នកតាំងនៅលោភណាស់ មានមាយាច្រើន ជាអ្នកញុំាងព្រហ្មចរិយឲ្យកម្រើក តែងតែកុហក បុគ្គលដឹងច្បាស់នូវទោសនោះហើយ គប្បីវៀរឲ្យឆ្ងាយ ។ ពួកស្រីមានសំដីផ្អែមពីរោះ មានសំដីទន់ភ្លន់ ស្មើដោយស្ទឹង ព្រោះមិនពេញបាន ដោយកាម តែងតែកុហក បុគ្គលអ្នកដឹងច្បាស់នូវទោសនោះហើយ គប្បីវៀរចេញឲ្យឆ្ងាយ ។ ស្រីតាំងខ្លួន ចូលទៅសេពគប់បុរសណា ព្រោះសេចក្តីពេញចិត្តក្តី ព្រោះទ្រព្យក្តី រមែងដុតបំផ្លាញបុរសនោះ យ៉ាងឆាប់ ដូចភ្លើងដែលដុតនូវទីរបស់ខ្លួន ។

(៣៨៥) សេចក្តីនឿយណាយ ក៏កើតមានឡើងដល់ឥសី ព្រោះបានស្តាប់ព្រះរាជបន្ទូលរបស់មហាក្សត្រ ហើយត្រឡប់បាននូវផ្លូវចាស់ (ឈានវិសេស) ក៏ទៅតាមអាកាសវិញ ។

(៣៨៦) ព្រះមហាក្សត្រជាអ្នកប្រាជ្ញ លុះបានឃើញឥសីទៅតាមអាកាសហើយ ក៏បាននូវសេចក្តីតក់ស្លុត ទ្រង់តាំងព្រះរាជហឫទ័យសមាទាន ព្រហ្មចរិយា ។

តតោ សោ ចវិត្វាន កាមរាគំ វិរាជយិ

កាមរាគំ វិរាជេត្វា ព្រហ្មលោកូបគោ អហូតិ ។

មហាបលោភនជាតកំ ឯកាទសមំ ។

---

## បញ្ចបណ្ឌិតជាតកំ

(៣៩៧) បញ្ច បណ្ឌិតា សមាគតា(១)

បញ្ហា មេ បដិភាតិ តំ សុណាថ

និន្ទិយមត្ថំ បសំសិយំ វា

កស្សេវាវិករេយ្យ(២) គុយ្ហមត្ថំ ។

(៣៩៨) ត្វំ អាវិករោហិ ភូមិបាល

ភត្តា ភារសហោ តុវំ វទេតំ

តវ ឆន្ទរុចីនិ សម្មសិត្វា

អថ វក្ខន្តិ ជនិន្ទ បញ្ច ធីរា ។

(៣៩៩) យា សីលវតី អនញ្ញធេយ្យា

ភត្តុ ឆន្ទវសានុគា បិយា មនាបា

១ ម. សមាគតត្ថ ។ ២ ម. កស្សាវិករេយ្យ ។



លំដាប់នោះ ព្រះមហាសត្វនោះក៏ទ្រង់បព្វជាហើយ ក៏នឿយណាយចាកកាមរាគ លុះនឿយណាយចាកកាមរាគហើយ បានចូលទៅកើតក្នុងព្រហ្មលោក ។

ចប់ មហាបលោភនជាតក ទី ១១ ។

---

## បញ្ចបណ្ឌិតជាតក

(៣៩៧) (ព្រះបាទវិទេហៈត្រាស់ថា) អ្នកប្រាជ្ញទាំងប្រាំនាក់មកជួបជុំគ្នាហើយ ប្រស្នាក៏ច្បាស់ដល់យើង អ្នកទាំងឡាយចូរស្តាប់ប្រស្នានោះ អ្នកគប្បីសំដែង (ប្រាប់) នូវសេចក្តីដែលគួរតិះដៀល ឬគួរសរសើរ ដែលជាការបិទកំបាំង ដល់នរណា ។

(៣៩៨) (អាចារ្យសេនកៈទូលថា) បពិត្រព្រះភូមិបាល សូមព្រះអង្គធ្វើឲ្យជាក់ច្បាស់ដល់ខ្ញុំព្រះបង្គំទាំងឡាយ ព្រះអង្គជាអ្នកចិញ្ចឹម ជាអ្នកអត់ធន់នូវភារកិច្ចទាំងពួង សូមព្រះអង្គទ្រង់ពោលប្រស្នានុ៎ះមុន បពិត្រព្រះជនិន្ទ អ្នកប្រាជ្ញទាំងប្រាំនាក់ពិចារណានូវរបស់ជាទីស្រឡាញ់ និងជាទីគាប់ព្រះទ័យរបស់ព្រះអង្គ ហើយនឹងក្រាបទូល ក្នុងកាលជាខាងក្រោយ ។

(៣៩៩) (ព្រះរាជា...) ស្ត្រីណា មានសីលពិត ដែលបុរសដទៃលួច (សម្លឹង) មិនបាន ជាស្រីប្រព្រឹត្តតាមអំណាចនៃសេចក្តីប្រាថ្នារបស់ស្វាមី ជាទីស្រឡាញ់ ជាទីពេញចិត្តនៃស្វាមី

និន្ទិយមត្ថំ បសំសិយំ វា

ភរិយាយាវិករេយ្យ គុយ្ហមត្ថំ ។

(៣៦០) យោ កិច្ចកស្ស អាតុរស្ស

សរណំ ហោតិ គតិ បរាយណញ្ច

និន្ទិយមត្ថំ បសំសិយំ វា

សខិនោ វាវិករេយ្យ គុយ្ហមត្ថំ ។

(៣៦១) យោ ជេដ្ឋោ អថ មជ្ឈិមោ កនិដ្ឋោ

សោ ចេ សីលសមាហិតោ ឋិតត្តោ

និន្ទិយមត្ថំ បសំសិយំ វា

ភាតុនោ វាវិករេយ្យ គុយ្ហមត្ថំ ។

(៣៦២) យោ វេ បិតុ ហទយស្ស បទ្ធគូ

អនុជាតោ បិតរំ[*] អហីនបញ្ញោ

និន្ទិយមត្ថំ បសំសិយំ វា

បុត្តស្សាវិករេយ្យ គុយ្ហមត្ថំ ។

(៣៦៣) មាតា ទ្វិបទជនិន្ទសេដ្ឋ

យា តំ បោសេតិ ឆន្ទសា បិយេន

និន្ទិយមត្ថំ បសំសិយំ វា

មាតុយាវិករេយ្យ គុយ្ហមត្ថំ ។

* បច្ចត្តេ ទុតិយាវិភត្តិ ហោតិ ។ បិតាតិ បទំ អត្ថការយំ ទស្សេតិ ។



បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាការលាក់កំបាំង ដល់ភរិយា (នោះ) ឬ ។

(៣៦០) (កាលយោ សខក:..) សំឡាញ់ណាជាទីរលឹក ជាគតិ ជាទីពឹង របស់អ្នកដែលដល់នូវសេចក្តីលំបាក អ្នកដែលក្តៅក្រហាយ បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាការលាក់កំបាំង ដល់សំឡាញ់ (នោះ) ។

(៣៦១) (កាលយោ ជេដ្ឋោ...) បងប្អូនណា ទោះបីជាបងបង្អស់ក្តី កណ្តាលក្តី ជាប្អូនពៅក្តី បើបងប្អូននោះដំកល់នៅស៊ប់ក្នុងសីល មានចិត្តតាំងនឹង បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាការលាក់កំបាំង ដល់បងប្អូន (នោះ) ។

(៣៦២) (កាលយោ វេ...) កូនប្រុស អ្នកប្រព្រឹត្តទៅក្នុងចំណងចិត្ត ហឫទ័យរបស់បិតា ជាអ្នកកើតតាមពាក្យ ជាអនុជាតបុត្រ មានប្រាជ្ញាមិនថយជាងបិតា បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរដែលជាការលាក់កំបាំង ដល់កូនប្រុស (នោះ) ។

(៣៦៣) (កាលមាតា...) បពិត្រព្រះអង្គជាធំជាងជន ដ៏ប្រសើរជាងមនុស្ស មាតាណាចិញ្ចឹមកូននោះ ដោយសេចក្តីស្រឡាញ់ពេញចិត្ត បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាការលាក់កំបាំង ដល់មាតា(នោះ) ។

[៣៦៤] កុច្ឆិស្ស ហិ កុច្ឆិមេវ សាធុ
ន ហិ កុច្ឆិស្ស ឧសត្ថុកោភិកម្មិ
អនុប្បន្នកាយ សាហេយ្យ ចិតេ
ឧប្បន្នកោ យថាសុខំ ករោយ្យ ។

[៣៦៥] កិំ ត្វំ វិមនោសិ រាជសេដ្ឋ
ទិបទិន្ទ[១] វចនំ សុណោម តេ ត្វំ
កិំ ចិន្តយមានោ ទុម្មនោសិ
ន ហិ នូន អបរាធោ អត្ថិ មយ្ហំ ។

[៣៦៦] បញ្ហោ វជ្ឈោ មហោសធោ
អាណត្តោ មេ វធាយ ភូរិបញ្ញោ
តំ ចិន្តយមានោ ទុម្មនោស្មិ
ន ហិ ទេវិ អបរាធោ អត្ថិ តុយ្ហំ ។

[៣៦៧] អភិទោសគតោ ទានិ ឯហិសិ
កិំ សុត្វា កិំ សង្កតេ មនោ តេ
កោ តេ កិមវោច ភូរិបញ្ញ

១ ម. ទូបទត្ដិន្ទ ។



[៣៦៤] (មហាសមណភូតិក ) សេចក្តីពិតថា ការលោក ខ្ញុំកាថា
កំបាំង ជាការប្រពៃ ការប្រាប់នូវគាថាកំបាំង សេមិនសរសើរ
ទេ អ្នកប្រាជ្ញ កាលៈបើសេចក្តីប្រាជ្ញាមិនទាន់សម្រេចនៅ
ឡើយ ត្រូវគស់សង្កត់ទុក លុះសម្រេចប្រយោជន៍ហើយ
ទើបគួរនិយាយ តាមសប្បាយចុះ ។

[៣៦៥] (នានិច្ចេត្តលោទេ...) បពិត្រព្រះរាជាដ៏ប្រសើរ ព្រះអង្គ
ទេវីមានព្រះទ័យប្រែប្រួលទេឬ បពិត្រព្រះអង្គជាធំជាងមនុស្ស
ខ្ញុំម្ចាស់ស្តាប់ព្រះតម្រាស់របស់ព្រះអង្គនោះហើយ តើព្រះ
អង្គទ្រង់ព្រះចិន្តាដូចម្តេច បានជាទ្រង់តូចព្រះទ័យ បពិត្រ
ព្រះសម្មតិទេព ខ្ញុំម្ចាស់មិនមានកំហុសទេឬ ។

[៣៦៦] (ព្រះរាជា...) មហោសធ ត្រូវគេសម្លាប់ព្រោះតែប្រស្នា
មហោសធ ជាអ្នកមានប្រាជ្ញាដូចផែនដី ខ្ញុំបង្គាប់គេឲ្យសម្លាប់
ហើយ ខ្ញុំគិតរឿងនោះ បានជាតូចចិត្ត ម្នាលនាងទេវី
កំហុសរបស់នាងមិនមានទេ ។

[៣៦៧] (ព្រះរាជា...) អ្នកឯង ទើបតែនាំផ្ទះកន្លងកាលព្រលប់សោះ
ឥឡូវនេះ ស្រោបនៃមកវិញភ្លាម អ្នកឯងឮដំណឹងដូចម្តេច
ចិត្តរបស់អ្នកឯង កើតឡើងដូចម្តេច ម្នាលអ្នកមានប្រាជ្ញា
ដូចផែនដី នរណាបានប្រាប់ដំណឹងដូចម្តេច ដល់អ្នក

កិំ ផុស្សំ ចេតិ សុណោម ព្រូហិ មេតំ ។

(៣៦៨) បត្តោ វជ្ឈោ មហោសធោ
យទិ តេ មន្តយិតំ ជនិន្ទ ទោសំ
ភរិយាយ(១) រហោគតោ អសំសិ
គុយ្ហំ បាតុកតំ សុតំ មមេតំ ។

(៣៦៩) យំ សាលវនស្មិំ សេនកោ
បាបកម្មមកាសិ អសព្ភិរូបំ
សខិនោវ រហោគតោ អសំសិ
គុយ្ហំ បាតុកតំ សុតំ មមេតំ ។

(៣៧០) បុក្កុសបុរិសស្ស តេ ជនិន្ទ
ឧប្បន្នោ រោគោ អរាជយុត្តោ
ភាតុ រហោគតោ អសំសិ
គុយ្ហំ បាតុកតំ សុតំ មមេតំ ។

(៣៧១) អាពាធោយំ អសព្ភិរូបោ
កាមិន្ទោ នរទេវេន ផុដ្ឋោ

១ ម. ភរិយា ។



យើងចង់ស្ដាប់ពាក្យនោះ ចូរលោកប្រាប់ពាក្យនោះដល់យើង ។

(៣៦៨) (មហោសធ...) បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គស្ដេចទៅក្នុងទីស្ងាត់ បានប្រាប់នូវការថាកំបាំង ដែលព្រះអង្គប្រឹក្សាហើយក្នុងពេលព្រលប់ ដល់ព្រះអគ្គមហេសីថា មហោសធ គួរតែសម្លាប់ ព្រោះតែប្រស្នា ក្នុងកាលណា សេចក្តីកំបាំង ឈ្មោះថាព្រះអង្គធ្វើឲ្យប្រាកដហើយ ក្នុងកាលនោះ សេចក្តីកំបាំងនុះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។

(៣៦៩) អាចារ្យសេនកៈបានធ្វើអំពើអាក្រក់ ជាអំពើមានសភាពមិនល្អ ក្នុងឧទ្យាន ដ៏ដេរដាសដោយដើមសាលព្រឹក្ស បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់សំឡាញ់ សេចក្តីកំបាំងណាដែលអាចារ្យសេនកៈធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំងនុះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។

(៣៧០) បពិត្រព្រះអង្គជាធំជាងជន រោគ(ឃ្លង់) កើតឡើងដល់បុក្កុសបុរស របស់ព្រះអង្គ រោគនោះមិនសមគួរដល់ព្រះរាជាទេ គាត់បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់បងប្អូនប្រុស សេចក្តីកំបាំងណា ដែលអាចារ្យបុក្កុសៈ ធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំងនុះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។

(៣៧១) អាចារ្យកាមិន្ទនេះ មានអាពាធដ៏អាក្រក់ គឺត្រូវនរទេវយក្សចូល

បុត្តស្ស រហោគតោ អសំសិ
គុយ្ហំ បាតុកតំ សុតំ មមេតំ ។

(៣៧៦) អឌ្ឍរត្តិំ មណិរតនំ ឧឡារំ
សក្កោ មេ អទទា បិតាមហស្ស
ទេវិន្ទស្ស គតំ តទជ្ជ ហត្ថេ
មាតុ ច រហោគតោ អសំសិ
គុយ្ហំ បាតុកតំ សុតំ មមេតំ ។

(៣៧៧) គុយ្ហស្ស ហិ គុយ្ហមេវ សាធុ
ន ហិ គុយ្ហស្ស បសត្ថមាវិកម្មំ
អនិប្ផន្នតាយ សហេយ្យ ធីរោ
និប្ផន្នត្ថោ យថាសុខំ ភណេយ្យ ។

ន គុយ្ហមត្ថំ វិវរេយ្យ រក្ខេយ្យ នំ យថា និធឹ
ន ហិ បាតុកតោ សាធុ គុយ្ហោ អត្ថោ បជានតា ។
ថិយា គុយ្ហំ ន សំសេយ្យ អមិត្តស្ស ច បណ្ឌិតោ



បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់កូនប្រុស សេចក្តីកំបាំង ណា ដែលអាចារ្យកាមិន្ទធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំង នុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។

(៣៧៦) ព្រះឥន្ទ្របានថ្វាយមណិរតន៍មានជ្រុង ៨ ដ៏ថ្លៃថ្លា (ដល់ព្រះបាទកុសរាជ) ជាព្រះអយ្យកោរបស់ព្រះអង្គ ថ្ងៃនេះមណិរតន៍នោះទៅនៅក្នុងកណ្តាប់ដៃ នៃអាចារ្យទេវិន្ទហើយ អាចារ្យទេវិន្ទទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់មាតា សេចក្តីកំបាំង ណា ដែលអាចារ្យទេវិន្ទធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំង នុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។

(៣៧៧) សេចក្តីពិតថា ការលាក់នូវអាថ៌កំបាំង ជាការប្រពៃ ការប្រាប់នូវអាថ៌កំបាំង នេះមិនសរសើរទេ អ្នកប្រាជ្ញ កាលបើសេចក្តីប្រាថ្នាមិនទាន់សម្រេច គួរតែអត់សង្កត់ទុក លុះសម្រេចប្រយោជន៍ហើយ ទើបគួរនិយាយ តាមសប្បាយចុះ ។

បុគ្គលមិនគប្បីបើក នូវអាថ៌កំបាំង គប្បីរក្សា នូវអាថ៌កំបាំងនោះ ដូចជារក្សា នូវកំណប់ ព្រោះថា អាថ៌កំបាំងដែលបុគ្គលអ្នកដឹងច្បាស់ មិនធ្វើឲ្យប្រាកដ ជាការប្រពៃ ។ អ្នកប្រាជ្ញមិនគប្បីនិយាយប្រាប់ នូវអាថ៌កំបាំង ដល់ស្រី ដល់ជនជាសត្រូវ

យោ ចាមិសេន សំហីរោ ហទយត្ថេនោ ច យោ នរោ

គុយ្ហមត្ថមសម្ពុទ្ធំ សម្ពោធយតិ យោ នរោ

មន្តភេទភយា តស្ស ទាសភូតោ តិតិក្ខតិ ។

យាវន្តោ បុរិសស្សត្ថំ គុយ្ហំ ជានន្តិ មន្តិនំ

តាវន្តោ តស្ស ឧព្វេគា តស្មា គុយ្ហំ ន វិស្សជេ ។

វិវិច្ច ភាសេយ្យ ទិវា រហស្សំ

រត្តិំ គិរំ នាតិវេលំ បមុញ្ចេ

ឧបស្សុតិកា ហិ សុណន្តិ មន្តំ

តស្មា មន្តោ ខិប្បមុបេតិ ភេទន្តិ ។

បញ្ចបណ្ឌិតជាតកំ ទ្វាទសមំ ។

# ហត្ថិបាលជាតកំ

(៣៧៤) ចិរស្សំ វត បស្សាម ព្រាហ្មណំ ទេវវណ្ណិនំ

មហាជដំ ខារិធរំ បង្កទន្តំ រជស្សិរំ ។

ចិរស្សំ វត បស្សាម ឥសិំ ធម្មគុណេ រតំ

កាសាយវត្ថវសនំ វាកចីរំ បដិច្ឆទំ ។



ដល់ជនទៀបរឡប់ដោយអាមិស ដល់ជនលួចគំនិតគ្នា ជនណា តែងញុំាងដំណើរកំបាំង ដែលមិនទាន់មានគេដឹងឲ្យគេដឹង អ្នកប្រាជ្ញ តែងអត់សង្កត់មិនប្រាប់ដល់ជននោះ ព្រោះខ្លាចបែកការដែលគិតទុក ដូចជាមនុស្សខ្ញុំគេ ។ ជនទាំងឡាយប៉ុន្មាននាក់ដឹងនូវមន្តជាការកំ-បាំងរបស់បុរស សេចក្ដីតក់ស្លុតប៉ុណ្ណោះ តែងកើតឡើងដល់បុរសនោះ ព្រោះហេតុនោះ អ្នកប្រាជ្ញមិនគប្បីផ្សាយ នូវការកំបាំង ។

កាលបើថ្ងៃ អ្នកប្រាជ្ញ គប្បីនិយាយការកំបាំងក្នុងទីស្ងាត់ មិនគប្បីបញ្ចេញសម្ដីក្នុងវេលាយប់ឲ្យហួសកម្រិត ព្រោះថា ពួកអ្នកលួចស្ដាប់ តែងឮនូវការកំបាំង ដែលប្រឹក្សាគ្នា ព្រោះហេតុនោះ គំនិតនឹងដល់នូវការបែកធ្លាយយ៉ាងឆាប់ ។

ចប់ បញ្ចបណ្ឌិតជាតក ទី ១២ ។

# ហត្ថិបាលជាតក

(៣៧៤)(ពួកហត្ថិបាលកុមារពោលថា)យូរណាស់ហើយយើងទើបនឹងឃើញព្រាហ្មណ៍ មានភេទដូចទេវតា មានជដាសក់ធំ មានធូលីលើព្រះសិរ ។ យូរណាស់ហើយ យើងទើបនឹងឃើញឥសី អ្នកត្រេកអរក្នុងធម្មគុណ ស្លៀកដណ្ដប់សំពត់កាសាយៈ មានសំពត់សំបកឈើជាគ្រឿងបិទបាំង ។

អាសនំ ឧទកំ បជ្ជំ បដិគ្គណ្ហាតុ នោ ភវំ
អគ្ឃេ ភវន្តំ បុច្ឆាម អគ្ឃំ កុរុតុ នោ ភវំ ។

(៣៧៥) អធិច្ច វេទេ បរិយេស វិត្តំ
បុត្តេ គេហេ តាត បតិដ្ឋបេត្វា
គន្ធេ រសេ បច្ចនុភោត្វា សព្វំ
អរញ្ញំ សាធុ មុនិ សោ បសត្ថោ ។

(៣៧៦) វេទា ន សច្ចា ន ច វិត្តលាភោ
ន បុត្តលាភេន ជរំ វិហន្តិ
គន្ធេ រសេ មុច្ចនមាហុ សន្តោ
សកម្មុនា ហោតិ ផលូបបត្តិ ។

(៣៧៧) អទ្ធា ហិ សច្ចំ វចនំ តវេតំ
សកម្មុនា ហោតិ ផលូបបត្តិ
ជិណ្ណា ច មាតាបិតរោ តវយិមេ
បស្សេយ្យុំ តំ វស្សសតំ អរោគ្យំ ។



សូមលោកដ៏ចំរើន ទទួលនូវអាសនៈទឹកនិងប្រេងសម្រាប់លាបជើង របស់យើងខ្ញុំចុះ យើងខ្ញុំសូមសួរនូវរបស់មានតម្លៃ ចំពោះលោកដ៏ចំរើន សូមលោកដ៏ចំរើន ប្រាប់នូវរបស់មានតម្លៃដល់យើងខ្ញុំ ។

(៣៧៥) (បុរោហិតជាដើម...) ហៃបា អ្នកចូររៀននូវវេទទាំងឡាយ ហើយស្វែងរកទ្រព្យ ដំកល់កូនទុកក្នុងផ្ទះ សោយនូវក្លិននិងរសទាំងឡាយផង នូវវត្ថុកាមគ្រប់បែបផង ហើយព្រៃប្រាកដល់អ្នកបួសឯណាស់ បុគ្គលនោះជាអ្នកប្រាជ្ញដែលព្រះអរិយៈទាំងឡាយសរសើរហើយ ។

(៣៧៦) (ហត្ថិបាលកុមារ...) វេទទាំងឡាយជាសភាវៈមិនទៀង ការបាននូវទ្រព្យ ក៏មិនទៀងដែរ ជនទាំងឡាយឃាត់ជរា ដោយការបាននូវកូនមិនបានទេ សប្បុរសទាំងឡាយសរសើរ នូវការរួចចាកក្លិននិងរស កិរិយាសម្រេចផល រមែងមាន តាមកម្មរបស់ខ្លួន ។

(៣៧៧) (ព្រះបាទឯសុការីជាដើម...) ពាក្យរបស់អ្នកនុ៎ះ ជាពាក្យពិត ទៀតផង កិរិយាសម្រេចផល រមែងមានតាមកម្មរបស់ខ្លួន ប៉ុន្តែ មាតានិងបិតារបស់អ្នកនេះ ចាស់ហើយ លោកនៅតែចង់ឃើញនូវអ្នក ជាបុគ្គលមិនមានរោគ អស់មួយរយឆ្នាំ ។

(៣៧៨) យស្សស្សុ សក្ខី មរណេន រាជ
ជរាយ មេត្តី នរវីរសេដ្ឋ
យោ ចាបិ ជញ្ញា ន មរិស្សំ កទាចិ
បស្សេយ្យុ តំ វស្សសតំ អរោគំ ។
យថាបិ នាវំ បុរិសោ ទកម្ហិ
ឯរេតិ ចេនំ ឧបនេតិ តីរំ
ឯវម្បិ ព្យាធិ សសតំ[1] ជរា ច
ឧបនេតិ មច្ចុវសមន្តកស្ស[2] ។

(៣៧៩) បង្កោ ច កាមា បលិបោ ច កាមា
មនោហរា ទុត្តរា មច្ចុធេយ្យា
ឯតស្មិំ បង្កេ បលិបេ វិសន្នា
ហីនត្តរូបា ន តរន្តិ បារំ ។
អយំ បុរេ លុទ្ទមកាសិ កម្មំ
ស្វាយំ គហីតោ ន ហិ មោក្ខិតោ មេ

១ ឱ. ម សតតំ ។ ២ ឱ. មច្ចុំវសមន្តកស្ស ម. មច្ចុវសមន្តកស្ស ។



(៣៧៨) (ហត្ថិបាលកុមារ...) បពិត្រព្រះរាជា អ្នកប្រសើរដោយនូវសេចក្តីក្លាហានលើសជាងជន ភាពជាសំឡាញ់ ដោយមរណៈ សេចក្តីមេត្រីដោយជរា គប្បីមានដល់ជនណា មួយទៀត ជនណា គប្បីដឹងថា អាត្មានឹងមិនស្លាប់ ក្នុងកាលណាមួយទេ មានការចាំបាច់គួរឃើញនូវជននោះ ជាបុគ្គលមិនមានរោគ អស់រយឆ្នាំ ។ បុរសចែវទូកក្នុងទឹក នាំទូកនុះទៅកាន់ត្រើយ (ខាងនាយ) យ៉ាងណា សេចក្តីឈឺចាប់នឹងសេចក្តីគ្រាំគ្រា រមែងនាំសត្វលោកទៅ កាន់អំណាចនៃសេចក្តីស្លាប់ អ្នកធ្វើនូវទីបំផុតជាញឿយៗ យ៉ាងនោះដែរ ។

(៣៧៩) (អស្សបាលកុមារ...) កាមទាំងឡាយជាភក់ផង កាមទាំងឡាយជាល្បាប់ផង ជាគ្រឿងនាំមកនូវសេចក្តីពេញចិត្ត ជាគ្រឿងឆ្លងបានដោយកម្រ ជាលំនៅនៃមច្ចុ ពួកសត្វដែលលិចចុះក្នុងភក់ ក្នុងល្បាប់នេះ ជាសត្វមានចិត្តថោកទាប ជាសភាវៈឆ្លងទៅកាន់ត្រើយ(ព្រះនិព្វាន)ពុំបានឡើយ ។ អត្តភាពរបស់ខ្លួនព្រះបង្គំជាខ្ញុំនេះ បានធ្វើនូវអំពើអាក្រក់ក្នុងកាលមុន ផលនៃកម្មនោះ ខ្លួនព្រះបង្គំជាខ្ញុំបានកាន់យកហើយ ការរួចចាកផលអកុសលនោះ មិនមានដល់ខ្លួនព្រះបង្គំជាខ្ញុំឡើយ ។

ទុរុត្តិយា មំ បរិភាសិ ត្វំ
មាយិ ចុត លុទ្ទមកាសិ កម្មំ ។

(៣៨០) ការ ឆដ្ឋំ បុរិសោ យថា តេន
អាទ្ទសតិ(១) ពជំ អបស្សមានោ
ឃរិ ឆណ្ឌោ បិសុកាវិ ខនោត្ថា
សោហំ កាជំ ន អភិសេយ្យំ ពជ ។

(៣៨១) ហរិយោក្ខតិ ហិយ្យតិ តោសោ បរេតិ បរិហាយតិ
អនាគតំ នេតមត្ថីតិ ញត្វា
ឧប្បន្នឆន្ទំ កោ បនុទេយ្យ ធីរោ ។

(៣៨២) បស្សាមិ តេហំ ធរាវិ កុមារិ
មត្តូបមំ កេតកបុប្ផនេត្តំ
អកុត្វា តោនេ ឋបាយ វេយស្មឹ
អាកាយ មច្ចុ វេទេក កុមារិ ។
យុវា សុជាតោ សុមុខោ សុទស្សនោ
សាមោ កុសុម្ភបរិកិណ្ណមស្សុ
ហិត្វាន គោនេ បជិតោ តេហំ

១ ឱ. បរិយេសតិ ។



ខ្ញុំព្រះបង្គំនឹងមិនទៅកាន់ទីអន្តរាយនោះ កុំឲ្យអន្តរាយនេះ ធ្វើអើពើកាន់ទៀតឡើយ ។

(៣៨០) (គោបាលកុមារ...) បពិត្រព្រះរាជា ដូចបុរសកាលមិនឃើញគោ ស្វែងរកគោដែលបាត់ក្នុងព្រៃ យ៉ាងណា បពិត្រព្រះរាជាប្រសើរព្រះនាមឯសុការី ប្រយោជន៍ (បព្វជ្ជា) របស់ខ្ញុំព្រះបង្គំជាទីវិនាសបាត់ទៅ ក៏យ៉ាងនោះដែរ បពិត្រព្រះរាជា ខ្ញុំព្រះបង្គំមិនគប្បីស្វែងរក ដូចម្ដេចបាន ។

(៣៨១) បុរសបន្ទន់ (នូវការងារដែលគួរធ្វើ)ថា ចាំថ្ងៃស្អែកៗ ដូច្នេះ រមែងសាបសូន្យ អ្នកប្រាជ្ញដឹងថាអនាគតនោះមិនមានដូច្នេះហើយ អ្នកប្រាជ្ញណា នឹងបន្ទោបង់នូវសេចក្ដីពេញចិត្តដែលកើតឡើងហើយបាន ។

(៣៨២) (អជបាលកុមារ...) ខ្ញុំព្រះបង្គំ បានឃើញកុមារី នៅក្មេង (ទេវរាជក្សត្រ) ដូចជាមនុស្សឆ្កួត មានភ្នែកដូចត្របកនៃផ្កាកេតកី បើកនៅក្នុងបឋមវ័យ មិនទាន់បរិភោគនូវភោគៈ ទាំងឡាយស្រាប់តែមច្ចុនាំយកកុមារី(នោះទៅ)។ បុរសកំលោះ មានកំណើតល្អ មានមុខស្រស់បស់ គួរជាទីមើលមើល មានសម្បុរល្មើដូចមាស មានពុកមាត់រលោងដូចកេសរនៃផ្កាផែកកំ (មច្ចុបាននាំយកនូវបុរសកំលោះនោះទៅ) ខ្ញុំព្រះអង្គនឹងលះបង់នូវកាមទាំងឡាយ ហើយចេញបួសពីផ្ទះ (ទៅបួស)

អនុជាន មំ បព្វជិស្សាមិ ទេវ ។

(៣៨៣) សាខាហិ រុក្ខោ លភតេ សមញ្ញំ
បហីនសាខំ បន ខាណុមាហុ
បហីនបុត្តស្ស មមជ្ជ ហោតិ
វាសេដ្ឋិ ភិក្ខាចរិយាយ កាលោ ។

(៣៨៤) អឃស្មិ កោញ្ចាវ យថា ហិមច្ចយេ
កតានិ ជាលានិ បទាលិយ ហំសា
គច្ឆន្តិ បុត្តា ច បតី ច មយ្ហំ
សាហំ កថំ នានុវជេ បជានំ ។

(៣៨៥) ឯតេ ភុត្វា វមិត្វា ច បក្កមន្តិ វិហង្គមា
យេ ច ភុត្វា ន វមិំសុ តេ មេ ហត្ថត្តមាគតា ។
អវមី ព្រាហ្មណោ កាមេ សោ ត្វំ បច្ចាវមិស្សសិ
វន្តាទោ បុរិសោ រាជ ន សោ ហោតិ បសំសិយោ ។



បពិត្រព្រះសម្មតិទេព សូមព្រះអង្គ អនុញ្ញាតខ្លួនព្រះបង្គំ ចាស់ខ្ញុំ ខ្លួនព្រះបង្គំជាខ្ញុំនឹងបួស ។

(៣៨៣) (បុរោហិត...) អនុបាទិន្នកសង្ខារ បានឈ្មោះថា ដើមឈើ ព្រោះតែមែកទាំងឡាយ មួយទៀត ជនទាំងឡាយ ហៅនូវដើមឈើ ដែលមានមែកលះបង់អស់ហើយថា ដង្គត់ ម្នាលនាងវាសេដ្ឋី ថ្ងៃនេះជាកាលគួរ ដើម្បីត្រាច់ទៅ ស្វែងរកភិក្ខា របស់ខ្ញុំ ដែលមានកូនលះបង់ហើយ ។

(៣៨៤) (ព្រាហ្មណីបន្លឺឧទានថា) ក្ងោកក្រៀល ហើរទៅក្នុងអាកាស ក្នុងវេលាអស់ទឹកភ្លៀង ហង្សទាំងឡាយ ទំលាយនូវមងដែល គេដាក់ហើយ យ៉ាងណា កូនទាំងឡាយផង ប្ដីផងរបស់ អញ (ទំលាយមងគឺកាមហើយ) ក៏ទៅ យ៉ាងនោះដែរ អញ នោះ កាលបើដឹងច្បាស់ហើយ មិនទៅតាមផ្លូវម្ដេចកើត ។

(៣៨៥) (ព្រះរាជទេពី...) បក្សី(ត្មាត)ទាំងឡាយនេះ ចឹកកាត(ខ្ចីសាច់) ហើយខ្ជាក់ចេញ ទើបហើរចៀសចេញទៅវិញ ចំណែកពពួកត្មាតទាំង ឡាយណា ចឹកកាតហើយមិនខ្ជាក់ចេញទេ ត្មាតទាំងនោះ មកធ្លាក់ក្នុង កណ្ដាប់ដៃរបស់ខ្ញុំម្ចាស់ហើយ ។ ព្រាហ្មណ៍បានខ្ជាក់ចោលនូវកាម ទាំងឡាយចេញហើយ ព្រះអង្គនោះត្រឡប់ជាលេបវិញ បពិត្រ ព្រះរាជា បុរសណា ស៊ីនូវកម្អួត បុរសនោះមិនគួរគេសរសើរទេ ។

(៣៨៦) បន្តេ ច តោសំ បលិបេ ព្យសន្នំ
ពលី យថា ទុព្វលមុទ្ធរេយ្យ
ឯវម្បិ មំ ត្វំ ឧទតារិ ភោតិ
បញ្ញាសិ តថាហិ សុភាសិតេហិ ។

(៣៨៧) ឥទំ វត្វា មហារាជា ឯសុការី ទិសម្បតិ
រដ្ឋំ ហិត្វាន បព្វជិ នាគោ ឆេត្វាវ ពន្ធនំ ។

(៣៨៨) រាជា ច បព្វជ្ជមរោចយិត្ថ
រដ្ឋំ បហាយ នរវីរសេដ្ឋោ
ត្វំបិ ភោ ហោហិ យថេវ រាជា
អម្ហេហិ គុត្តា អនុសាស រដ្ឋំ ។

(៣៨៩) រាជា ច បព្វជ្ជមរោចយិត្ថ
រដ្ឋំ បហាយ នរវីរសេដ្ឋោ
អហំបិ ឯកា ចរិស្សាមិ លោកេ
ហិត្វាន កាមានិ មនោរមានិ ។



(៣៨៦) (ព្រះរាជា ..) បុរសអ្នកមានកំឡាំង គាចស្រង់នូវបុរស មានកំឡាំងខ្សោយ ដែលលិចក្នុងភក់ល្បាប់បាន យ៉ាងណា ម្នាលរាជធីតារបស់ព្រះបាទបញ្ចាលដ៏ចំរើន នាងឯងក៏ញុំាងយើងឲ្យឆ្លងឡើង (ពាក្កាម) ដោយគាថាទាំងឡាយ ជាសុភាសិត យ៉ាងនោះដែរ ។

(៣៨៧) មហារាជទ្រង់ព្រះនាមឯសុការី ជាម្ចាស់ក្នុងទិស ទ្រង់ត្រាស់គាថានេះហើយ ទ្រង់លះបង់នូវដែនចេញទៅ ទ្រង់ព្រះផ្នួស ដូចដំរីធំប្រសើរ ផ្តាច់នូវចំណងដូច្នោះ ។

(៣៨៨) (មហាជន...) ព្រះរាជាមានព្យាយាមវិសេសជាងជន ទ្រង់សព្វព្រះរាជហឫទ័យចំពោះបព្វជ្ជា លះបង់នូវដែន ចំណែកខាងព្រះនាង សូមដូចជាព្រះរាជារបស់យើងខ្ញុំ ព្រះនាងដែលពួកយើងគ្រប់គ្រងហើយ ចូរសោយរាជសម្បត្តិចុះ ។

(៣៨៩) (ព្រះរាជទេវី...) ព្រះរាជាមានព្យាយាមវិសេសជាងជន ទ្រង់សព្វព្រះរាជហឫទ័យ ចំពោះបព្វជ្ជា ទ្រង់លះបង់នូវដែន ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំងឡាយ ដែលញុំាងចិត្តឲ្យត្រេកអរចេញ ហើយជាស្ត្រីម្នាក់ឯង ត្រាច់ទៅក្នុងលោក ។

គាថា ៤ បច្ឆិមៈគាថាយោ

រជ្ជំ បហាយ នរាសភោ

អហំបិ ឯកា ចរិស្សាមិ លោកេ

ហិត្វាន កាមានិ យថោធិកានិ ។

អច្ចេន្តិ កាលា តរយន្តិ រត្តិយោ

វយោគុណា អនុបុព្វំ ជហន្តិ

អហំបិ ឯកា ចរិស្សាមិ លោកេ

ហិត្វាន កាមានិ មនោរមានិ ។

អច្ចេន្តិ កាលា តរយន្តិ រត្តិយោ

វយោគុណា អនុបុព្វំ ជហន្តិ

អហំបិ ឯកា ចរិស្សាមិ លោកេ

ហិត្វាន កាមានិ យថោធិកានិ ។

អច្ចេន្តិ កាលា តរយន្តិ រត្តិយោ

វយោគុណា អនុបុព្វំ ជហន្តិ

អហំបិ ឯកា ចរិស្សាមិ លោកេ

សីតិភូតា សព្វមតិច្ច សង្គំ ។

ហត្ថិបាលជាតកំ និដ្ឋិតំ ។

---





ព្រះរាជាមានព្យាយាម វិសេសជាងផង ទ្រង់សព្វព្រះរាជហឫទ័យ ចំពោះបព្វជ្ជា ទ្រង់លះបង់នូវផែនដី ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំងឡាយតាមចំណែក ហើយជាស្ត្រីម្នាក់ឯង ត្រាច់ទៅក្នុងលោក ។ កាលទាំងឡាយ រមែងកន្លងហួសទៅ រាត្រីទាំងឡាយ រមែងញ៉ាំង (អាយុសង្ខារ)ឲ្យកន្លងទៅ គុណនៃវ័យទាំងឡាយ រមែងលះទៅតាមលំដាប់ ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំងឡាយ ជាទីញ៉ាំងចិត្តឲ្យត្រេកអរ ហើយជាស្ត្រីម្នាក់ឯងត្រាច់ទៅក្នុងលោក ។ កាលទាំងឡាយ រមែងកន្លងហួសទៅ រាត្រីទាំងឡាយ រមែងញ៉ាំង(អាយុសង្ខារ)ឲ្យកន្លងទៅ គុណនៃវ័យទាំងឡាយ រមែងលះបង់ទៅជាលំដាប់ ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំងឡាយ តាមចំណែក ហើយជាស្ត្រីម្នាក់ឯង ត្រាច់ទៅក្នុងលោក ។ កាលទាំងឡាយ រមែងកន្លងហួសទៅ រាត្រីទាំងឡាយ រមែងញ៉ាំង (អាយុ-សង្ខារ)ឲ្យកន្លងទៅ គុណនៃវ័យទាំងឡាយ រមែងលះបង់ទៅជាលំដាប់ ចំណែកខាងខ្ញុំ នឹងកន្លងបង់នូវគ្រឿងជាប់ទាំងអស់ ហើយជាស្ត្រីត្រជាក់ម្នាក់ឯង ត្រាច់ទៅក្នុងលោក ។

ចប់ ហត្ថិបាលជាតក ទី ១៣ ។

## អយោឃរជាតកំ

(៣៩០) យមេករត្តិំ បឋមំ គព្ភេ វសតិ មាណវោ
អព្ភុដ្ឋិតោវ សោ យាតិ ស គច្ឆំ ន និវត្តតិ ។

(៣៩១) ន យុជ្ឈមានា ន ពលេន វិស្សិតា
នរា ន ជីរន្តិ ន ចាបិ មីយរេ
សព្វញ្ហិ តំ ជាតិជរាយុបទ្ទុតំ
តំ មេ មតី ហោតិ ចរាមិ ធម្មំ ។

(៣៩២) ចតុរង្គិនឹ សេនំ សុភឹសរូបំ
ជយន្តិ រដ្ឋាធិបតី បសយ្ហ
ន មច្ចុនោ ជយិតុមុស្សហន្តិ
តំ មេ មតី ហោតិ ចរាមិ ធម្មំ ។

(៣៩៣) ហត្ថីហិ អស្សេហិ រថេហិ បត្តិហិ
បរិកិរិតា មុច្ចរេ ឯកច្ចេយ្យា
ន មច្ចុនោ មុច្ចិតុមុស្សហន្តិ
តំ មេ មតី ហោតិ ចរាមិ ធម្មំ ។



## អយោឃរជាតក

(៣៩០) (អយោឃរកុមារពោធិសត្វ...) សត្វនៅក្នុងគភ៌ អស់រាត្រីណា មួយជាដំបូង សត្វនោះប្រព្រឹត្តទៅ ដូចពពក ដែលតាំងឡើង សត្វនោះកាលទៅ រមែងមិនត្រឡប់វិញទេ ។

(៣៩១) មិនមែនពួកនរៈកាលច្បាំង មិនមែនពួកនរៈជាប់ប្រណី ដោយកំលាំង មិនចាស់ជរា មិនស្លាប់ទេ ព្រោះថា ធរណី-មណ្ឌលទាំងអស់នោះ គឺជាតិ និងជរា តែងខ្ចាត់ខ្ចាយ បៀតបៀន ហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

(៣៩២) ព្រះរាជាទាំងឡាយ ជាធំលើដែនគ្រប់សង្កត់សង្កិនសេនាប្រកប ដោយអង្គ ៤ ជាសេនា មានសភាពគួរខ្លាច ព្រោះតែរមែងឈ្នះបាន ប៉ុន្តែមិនអាចឈ្នះនូវសេចក្តីស្លាប់បានទេ ព្រោះហេតុនោះ គំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

(៣៩៣) ព្រះរាជាទាំងឡាយអង្គខ្លះ ដែលមានពលដំរី ពលសេះ ពលរថ ពលថ្មើរជើងហែហមហើយ រួច (អំពីកណ្តាប់ដៃ ពួកបច្ចាមិត្ត) បាន ប៉ុន្តែមិនអាចរួចចាកសេចក្តីស្លាប់បាន ព្រោះហេតុនោះ បានជាគំនិត របស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌ ។

(៣៨៤) ហត្ថីហិ អស្សេហិ រថេហិ បត្តិហិ
សូរា[១] បភញ្ជន្តិ បធំសយន្តិ
ន មច្ចុនោ ភញ្ជិតុមុស្សហន្តិ
តស្មា មតី ហោតិ ចរាមិ ធម្មំ ។

(៣៨៥) មត្តា គជា ភិន្នគឡា បភិន្នា
នគរានិ មទ្ទន្តិ ជនំ ហនន្តិ
ន មច្ចុនោ មទ្ទិតុមុស្សហន្តិ
តស្មា មតី ហោតិ ចរាមិ ធម្មំ ។

(៣៨៦) ឥស្សាសិនោ កតហត្ថាបិ វីរា
ទូរេបាតី អក្ខណវេធិនោបិ
ន មច្ចុនោ វិជ្ឈិតុមុស្សហន្តិ
តស្មា មតី ហោតិ ចរាមិ ធម្មំ ។

(៣៨៧) សរានិ ខីយន្តិ សសេលកាននា
សព្វំបិ តំ ខីយតិ ទីឃមន្តរំ

---

១ ម. [illegible] ។



(៤៧៥) ព្រានព្រៃនោះ ក្រោកឈរឡើង ហើយកាន់ដាវ កាត់ភ្លុកនៃដំរីប្រសើរ ហើយក៏យកភ្លុកដ៏ល្អស្អាត មិនមានភ្លុកឯទៀតប្រៀបផ្ទឹមបាននៅលើផែនដី រួចដើរចៀសចេញទៅអំពីទីនោះ យ៉ាងរហ័ស ។

(៤៧៦) (អភិសម្ពុទ្ធគាថា) ពួកដំរី ត្រូវភ័យ (អំពីសេចក្ដីស្លាប់) បៀតបៀនហើយ ដល់នូវសេចក្ដីទុក្ខព្រួយ ព្រោះតែសម្លាប់នូវដំរីប្រសើរ បានស្ទុះទៅគ្រប់ទិសទាំង ៨ លុះមិនឃើញបុរសជាសត្រូវនៃដំរី ក៏ត្រឡប់មកកាន់ទីរបស់ស្ដេចដំរីប្រសើរវិញ ។

(៤៧៧) ដំរីប្រសើរទាំងនោះ ក៏ទ្រហោយំ កន្ទក់កន្ទេញ ក្នុងទីនោះ ហើយកោយកាយ នូវធូលីដី លើក្បាល របស់ខ្លួន

អាគមិស្សុ តេ សរេ សតំ និកេតំ

បុរក្ខត្វា បតោសី សត្តកម្មំ ។

(៥៧៨) អាទាយ ឧត្តមំ កណ្ឌកស្ស

វត្វា សុរេ អច្ឆរិយេ បវេយ្យា

សុវណ្ណកដិហំ សមគ្គោ ធារេ

សោ លុទ្ធកោ កាសិបុរំ ឧបាគមំ

ឧបាគមិ សោ ភគវាញ្ញាយ ឧត្តិ

ទាតោ ទាតោ ហត្ថ ផលស្ស ឧក្កា ។

(៥៧៩) ឆិត្វាន ឧត្តមំ កណ្ឌកស្ស

ភត្តុ បិយស្ស បុរិមាយ ជាតិយា

តស្សេវ តស្សា ហរិយំ ឥជាសិ

ពោធេសិ សា កាលមកាសិ ពាលា ។

(៥៨០) សម្ពោធិបត្តោ ច មហានុភាវោ

សិតំ អកាសិ បរិសាយ មជ្ឈេ

បុច្ឆិសុ ភិក្ខូ សុវិមុត្តចិត្តា

នាការណោ បាតុករោន្តិ ពុទ្ធា ។





ដែលទាំងអស់នោះ កំឡុងដ៏ ជាមហេសី ឈ្មោះសុភទ្ទា

អើរហុន មកកាន់ទីនៅរបស់ខ្លួន ។

(៥៧៨) ព្រានព្រៃនោះ បានកាត់យកភ្លុកទាំងឡាយនៃដំរីដ៏ប្រសើរ ជាភ្លុកល្អ ស្អាត មិនមានភ្លុកឯទៀតប្រៀបផ្ទឹមបាន ហើយដែលវីភ្លឺសព្វរាយស្មើ មានពណ៌ដូចជាមាស ហើយចូលទៅកាន់កាសីបុរី ព្រានព្រៃនោះ ក៏បង្ហាញនូវភ្លុកទាំងឡាយថ្វាយព្រះរាជកញ្ញា ដំរីដ៏ប្រសើរ ទូលព្រះបង្គំជាខ្ញុំសម្លាប់បានហើយ សូមព្រះនាងទទួលយក នេះជាភ្លុករបស់ដំរីនោះ ។

(៥៧៩) ព្រះរាជកញ្ញានោះ ទតឃើញភ្លុកទាំងឡាយនៃដំរីដ៏ប្រសើរ ដែលធ្លាប់ជាប្តីជាទីស្រឡាញ់ក្នុងកាលជាតិមុន ក៏បែកបេះដូងក្នុងទីនោះឯង ហេតុនោះ ព្រះនាង ជាស្រីល្ងង់ បានសោយទ្រៀលហាល័យទៅ ។

(៥៨០) (ព្រះធម្មសង្គាហកាចារ្យ...) ព្រះពុទ្ធព្រះអង្គបានសម្តែងនូវសម្ពោធិញាណផង មានអានុភាពច្រើនផង បានធ្វើនូវការញញឹម ក្នុងកណ្តាលពុទ្ធបរិស័ទ ភិក្ខុទាំង មានចិត្តផុតស្រឡះ ក៏ក្រាបបង្គំទូលសួរថា ព្រះពុទ្ធទាំងឡាយ មិនដែលធ្វើ នូវការញញឹមឥតប្រយោជន៍ ដោយឥតហេតុទេ ។

យមទ្ទសាថ ទហរី កុមារី
កាសាវវត្ថំ អនគារិយំ ចរន្តិំ
សា ខោ តទា រាជកញ្ញា អហោសិ
អហំ តទា នាគរាជា អហោសឹ ។
អាទាយ ទន្តានិ គជុត្តមស្ស
ទ្វេ សុភេ អប្បដិមេ បថព្យា
យោ លុទ្ទកោ កាសិបុរំ ឧបាគមិ
សោ ខោ តទា ទេវទត្តោ អហោសិ ។
អនាវសូរំ ចិររត្តសំសិតំ
ឧច្ចាវចំ ចរិតមិទំ បុរាណំ
វីតទ្ទរោ វីតសោកោ វិសល្លោ[១]
សយំ អភិញ្ញាយ អភាសិ ពុទ្ធោ ។
អហំ វោ តេន កាលេន អហោសឹ តត្ថ ភិក្ខវោ
នាគរាជា តទា ហោមិ ឯវំ ធារេថ ជាតកន្តិ ។

ឆទ្ទន្តជាតកំ ចតុត្ថំ ។

## សម្ភវជាតកំ

[៤៨១] រជ្ជញ្ច បដិបន្នាស្មា អាធិបច្ចំ សុចីរត
មហត្តំ បត្តុមិច្ឆាមិ វិជេតុំ បថវឹ ឥមំ ។

១ ម. វិសល្លោ ។



អ្នកទាំងឡាយ បានឃើញនាងកុមារិកានៅជំទង់ ស្លៀកសំពត់កាសាវៈ ជាអ្នកបួស នាងកុមារិកានោះ ក្នុងកាលនោះ គឺព្រះរាជកញ្ញា ឯស្ដេចដំរីក្នុងកាលនោះ គឺតថាគតឯង ព្រានព្រៃណា កាន់យកនូវភ្លុកទាំងឡាយនៃដំរីប្រសើរ ជាភ្លុកដ៏ល្អស្អាត មិនមានភ្លុកឯទៀតប្រៀបផ្ទឹមបានលើផែនដី ហើយចូលទៅកាន់កាសីបុរី ព្រានព្រៃនោះក្នុងកាលនោះ គឺទេវទត្ត ។ ព្រះពុទ្ធ ព្រះអង្គប្រាសចាកសេចក្ដីក្រវល់ក្រវាយ ប្រាសចាកសេចក្ដីសោក ប្រាសចាកនូវកូនសរគឺកិលេសៈ បានត្រាស់ដឹងដោយព្រះអង្គឯង ហើយទ្រង់សំដែង នូវដំណើរចាស់ពីដើមនេះ ដែលមានខ្ពស់ទាប អស់កាលដ៏យូរ ហាក់ដូចមិនកន្លងហួស ។

ម្នាលភិក្ខុទាំងឡាយ កាលនោះ តថាគតនៅក្នុងទីនោះ កាលនោះ តថាគតជាស្ដេចដំរី អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

ចប់ ឆទ្ទន្តជាតក ទី ៤ ។

## សម្ភវជាតក

(៤៨១) (ព្រះបាទធនញ្ជយកោរព្យៈ ត្រាស់សួរថា) នែសុចីរតៈ យើងបាននូវរាជសម្បត្តិផង បាននូវភាពជាធំផង យើងប្រាថ្នា ដើម្បីដល់នូវភាពជាធំ ប្រាថ្នាដើម្បីឈ្នះ នូវផែនដីនេះ ។

ធម្មេន នោ អធម្មេន    អធម្មោ មេ ន រុច្ចតិ

កិច្ចោវ ធម្មោ ចរិតោ    រញ្ញោ ហោតិ សុចីរត ។

ឥធ ចេវ អនិន្ទិតា យេន    បេច្ច យេន អនិន្ទិតា

យសំ ទេវមនុស្សេសុ    យេន បប្បោមុ ព្រាហ្មណ ។

យោហំ អត្ថញ្ច ធម្មញ្ច    កាតុមិច្ឆាមិ ព្រាហ្មណ

តំ ត្វំ អត្ថញ្ច ធម្មញ្ច    ព្រាហ្មណក្ខាហិ បុច្ឆិតោ ។

(៦៨៦) នាញ្ញត្រ វិទុរា រាជ    ឯតទក្ខាតុមរហតិ

យំ ត្វំ អត្ថញ្ច ធម្មញ្ច    កាតុមិច្ឆសិ ខត្តិយ ។

(៦៨៧) ឯហិ ខោ បហិតោ គច្ឆ    វិទុរស្ស ឧបន្តិកំ

និក្ខញ្ចិមំ សុវណ្ណស្ស    ហរំ គច្ឆ សុចីរត

អភិហារំ ឥមំ ទជ្ជា    អត្ថធម្មានុសិដ្ឋិយា ។

(៦៨៨) ស្វាធិប្បាគា ភារទ្វាជោ    វិទុរស្ស ឧបន្តិកំ

តមទ្ទស មហាព្រហ្មា    អសមានំ សកេ ឃរេ ។



(យើងប្រកប) ដោយធម៌ មិនប្រកបដោយអធម៌ទេ ព្រោះអធម៌មិនគាប់ចិត្តដល់យើងឡើយ ម្នាលសុចីរតៈ ធម៌ជាចរិតរបស់ព្រះរាជាក្នុងដំណើរគ្រប់តែធ្វើ ។ នែព្រាហ្មណ៍ យើងដែលបុគ្គលមិនតិះដៀល ក្នុងលោកនេះ ដោយអត្ថនិងធម៌ណាផង មិនតិះដៀលក្នុងបរលោក ដោយអត្ថនិងធម៌ណាផង គប្បីដល់នូវយសក្នុងទេវលោកនិងមនុស្សលោក ដោយអត្ថនិងធម៌ណាផង ។ នែព្រាហ្មណ៍ យើងប្រាថ្នាដើម្បីធ្វើនូវអត្ថនិងធម៌នោះ នែព្រាហ្មណ៍ អ្នកដែលយើងសួរហើយ ចូរប្រាប់នូវអត្ថនិងធម៌នោះ ។

(៦៨៦) (សុចីរតព្រាហ្មណ៍ ក្រាបទូលថា) បពិត្រព្រះខត្តិយរាជ ព្រះអង្គប្រាថ្នាដើម្បីធ្វើនូវអត្ថនិងធម៌ណា វៀរលែងតែវិធុរព្រាហ្មណ៍ហើយ បុគ្គលដទៃ មិនគួរនឹងប្រាប់នូវអត្ថនិងធម៌នោះបានទេ ។

(៦៨៧) (ព្រះរាជា ..) នែសុចីរតៈ អ្នកចូរមកនេះ អ្នកឯងត្រូវយើងប្រើទៅ អ្នកចូរទៅកាន់សំណាក់នៃវិធុរព្រាហ្មណ៍ ចូរនាំយកនូវនិក្ខនៃមាសនេះទៅចុះ អ្នកចូរឲ្យនូវគ្រឿងនៃមាសនេះ ជាគ្រឿងជូនដល់ការប្រៀនប្រដៅនូវអត្ថនិងធម៌ ។

(៦៨៨) (អភិសម្ពុទ្ធគាថា) សុចីរតព្រាហ្មណ៍ ជាភារទ្វាជគោត្រនោះ ក៏បានទៅកាន់សំណាក់នៃវិធុរព្រាហ្មណ៍ សុចីរតៈ ជាមហាព្រាហ្មណ៍ ក៏បានឃើញវិធុរព្រាហ្មណ៍នោះ កំពុងតែបរិភោគភត្តក្នុងផ្ទះរបស់ខ្លួន ។

(៤៨៥) រញ្ញោហំ បហិតោ ទូតោ កោរព្យស្ស យសស្សិនោ

អត្ថំ ធម្មញ្ច បុច្ឆេសិ ឥច្ចព្រវិ យុធិដ្ឋិលោ

តំ ត្វំ អត្ថញ្ច ធម្មញ្ច វិធុរក្ខាហិ បុច្ឆិតោ ។

(៤៨៦) គង្គំ មេ បិធហិស្សន្តិ ន តំ សក្កោមិ ព្រាហ្មណ

អបិធេតុំ មហាសិន្ធុំ តំ កថំ សោ ភវិស្សតិ

ន តេ សក្កោមិ អក្ខាតុំ អត្ថំ ធម្មញ្ច បុច្ឆិតោ ។

ភទ្រការោ ច មេ បុត្តោ ឱរសោ មម អត្រជោ

តំ ត្វំ អត្ថញ្ច ធម្មញ្ច គន្ត្វា បុច្ឆស្សុ ព្រាហ្មណ។

(៤៨៧) ស្វាធិប្បាគា ភារទ្វាជោ ភទ្រការស្ស សន្តិកំ

តមព្រវិ មហាព្រហ្មា និសិន្នំ សម្ហិ វេស្មនិ ។

(៤៨៨) រញ្ញោហំ បហិតោ ទូតោ កោរព្យស្ស យសស្សិនោ

អត្ថំ ធម្មញ្ច បុច្ឆេសិ ឥច្ចព្រវិ យុធិដ្ឋិលោ

តំ ត្វំ អត្ថញ្ច ធម្មញ្ច ភទ្រការ បព្រូហិ មេ ។



(៤៨៥) (សុចីរតព្រាហ្មណ៍...) ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទធនញ្ជយកោរព្យៈ ជាយុធិដ្ឋិលគោត្រ ទ្រង់មានព្រះបន្ទូលថា អ្នកចូរសួរនូវអត្ថនិងធម៌ បពិត្រវិធុរ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថនិងធម៌នោះ ។

(៤៨៦) (វិធុរព្រាហ្មណ៍ .) ម្នាលព្រាហ្មណ៍ ខ្ញុំ (គិតថា) អញនឹងបិទនូវទន្លេគង្គា តែមិនអាចបិទនូវទន្លេធំនោះបាន ព្រោះហេតុនោះ ទុក្ខសោកនោះ នឹងមានដូចម្ដេចកើត ខ្ញុំដែលអ្នកសួរហើយមិនអាចដើម្បីប្រាប់នូវអត្ថនិងធម៌បានទេ ។ តែខ្ញុំមានកូនប្រុសមួយឈ្មោះភទ្រការ ជាឱរស ជាកូនបង្កើតរបស់ខ្ញុំ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរអត្ថនិងធម៌ ចំពោះភទ្រការនោះចុះ ។

(៤៨៧) (អភិសម្ពុទ្ធគាថា) សុចីរតព្រាហ្មណ៍ ជាភារទ្វាជគោត្រនោះ បានទៅកាន់សំណាក់ភទ្រការកុមារ សុចីរតៈ ជាមហាព្រាហ្មណ៍ បានឃើញភទ្រការកុមារនោះ កំពុងអង្គុយនៅក្នុងផ្ទះរបស់ខ្លួន ។

(៤៨៨) (សុចីរតព្រាហ្មណ៍...) ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទកោរព្យៈ ជាយុធិដ្ឋិលគោត្រ ទ្រង់ត្រាស់ថា អ្នកចូរសួរនូវអត្ថនិងធម៌ ម្នាលភទ្រការកុមារ ព្រោះហេតុនោះ អ្នកចូរប្រាប់នូវអត្ថនិងធម៌ ដល់ខ្ញុំ ។

(៦៨៩) មំសកាជំ អវហាយ គោធំ អនុបតាមហំ

ន តេ សក្កោមិ អក្ខាតុំ អត្ថំ ធម្មញ្ច បុច្ឆិតោ ។

សញ្ជយោ នាម មេ ភាតា កនិដ្ឋោ មេ សុចីរត

តំ ត្វំ អត្ថញ្ច ធម្មញ្ច គន្ត្វា បុច្ឆស្សុ ព្រាហ្មណ ។

(៦៩០) ស្វាធិប្បាគា ភារទ្វាជោ សញ្ជយស្ស ឧបន្តិកំ

តមព្រុវិ មហាព្រហ្មា និសិន្នំ សម្ហិ បរិសតិ ។

(៦៩១) រញ្ញាហំ បហិតោ ទូតោ កោរព្យស្ស យសស្សិនោ

អត្ថំ ធម្មញ្ច បុច្ឆេសិ ឥច្ចព្រវិ យុធិដ្ឋិលោ

តំ ត្វំ អត្ថញ្ច ធម្មញ្ច សញ្ជយក្ខាហិ បុច្ឆិតោ ។

(៦៩២) សទា មំ គិលតេ មច្ចុ សាយំ បាតោ សុចីរត

ន តេ សក្កោមិ អក្ខាតុំ អត្ថំ ធម្មញ្ច បុច្ឆិតោ ។

សម្ភវោ នាម មេ ភាតា កនិដ្ឋោ មេ សុចីរត

តំ ត្វំ អត្ថញ្ច ធម្មញ្ច គន្ត្វា បុច្ឆស្សុ ព្រាហ្មណ ។



(៦៨៩) (ភទ្រការកុមារ...) ខ្ញុំទើបទម្លាក់ចោលនូវទ្រែកសាច់ហើយ ដេញតាមនូវទន្សង ខ្ញុំដែលអ្នកសួរហើយ មិនអាចនឹងប្រាប់ នូវអត្ថនិងធម៌បានទេ ។ បពិត្រសុចីរតព្រាហ្មណ៍ ខ្ញុំមានប្អូនប្រុសម្នាក់ ឈ្មោះសញ្ជ័យ បពិត្រសុចីរតព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរ នូវអត្ថនិងធម៌ ចំពោះសញ្ជ័យនោះចុះ ។

(៦៩០) (អភិសម្ពុទ្ធគាថា) សុចីរតព្រាហ្មណ៍ ជាភារទ្វាជគោត្រនោះ បានទៅកាន់សំណាក់សញ្ជ័យកុមារ សុចីរតៈជាមហាព្រាហ្មណ៍ បានឃើញនូវសញ្ជ័យកុមារនោះ អង្គុយក្នុងកណ្ដាលបរិស័ទរបស់ខ្លួន ។

(៦៩១) (សុចីរតព្រាហ្មណ៍...) ខ្ញុំជាទូត ព្រះបាទធនញ្ជ័យកោរព្យៈ ដ៏មានយសប្រើមក ព្រះបាទធនញ្ជ័យកោរព្យៈ ជាយុធិដ្ឋិលគោត្រ មានព្រះឱង្ការថា អ្នកចូរសួរនូវអត្ថនិងធម៌ នូវសញ្ជ័យកុមារ ព្រោះហេតុនោះ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថនិងធម៌ ។

(៦៩២) (សញ្ជ័យកុមារ...) បពិត្រសុចីរតព្រាហ្មណ៍ មច្ចុតែងលេបខ្ញុំ ពេលល្ងាចពេលព្រឹក សព្វៗកាល ខ្ញុំដែលអ្នកសួរហើយ មិនអាចនឹងប្រាប់នូវអត្ថនិងធម៌ ដល់អ្នកបានទេ ។ បពិត្រសុចីរតព្រាហ្មណ៍ ខ្ញុំមានប្អូនប្រុសម្នាក់ ឈ្មោះសម្ភវៈ បពិត្រព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរ នូវអត្ថនិងធម៌ ចំពោះសម្ភវៈនោះចុះ ។

(៤៩៣) អត្តោ តេ កោ ចេយ្យោ ជាយំ អស្មាក វុទ្ធតិ
តយោ ជនា បិតាបុត្តា តេ សុបញ្ញាយ គោចរា ។
ន តំ សក្កោថ អក្ខាតុំ អត្ថំ ធម្មញ្ច បុច្ឆិតា
កោ ជំ នុ ទហរោ ជញ្ញា អត្ថំ ធម្មញ្ច បុច្ឆិតោ ។

(៤៩៤) មា នំ ទហរោតិ មញ្ញាសិ អបុច្ឆិត្វាន សម្ភវំ
បុច្ឆិត្វា សម្ភវំ ជញ្ញា អត្ថំ ធម្មញ្ច ព្រាហ្មណ ។
យថាបិ ចន្ទោ វិមលោ គច្ឆំ អាកាសធាតុយា
សព្វេ តារគណេ លោកេ អាភាយ អតិរោចតិ
ឯវម្បិ ទហរូបេតោ បញ្ញាយោគេន សម្ភវោ
មា នំ ទហរោតិ មញ្ញាសិ អបុច្ឆិត្វាន សម្ភវំ
បុច្ឆិត្វា សម្ភវំ ជញ្ញា អត្ថំ ធម្មញ្ច ព្រាហ្មណ ។
យថាបិ រម្មកោ មាសោ គិម្ហានំ ហោតិ ព្រាហ្មណ
អតេវញ្ញេហិ មាសេហិ ទុមបុប្ផេហិ សោភតិ ។
ឯវម្បិ ទហរូបេតោ បញ្ញាយោគេន សម្ភវោ



(៤៩៣) សុចីរតព្រាហ្មណ៍..) ម្នាលអ្នកដ៏ចំរើន បញ្ហាធម៌ ក៏អស្ចារ្យម៉្លេះ សម្ភកុមារនេះ យើងមិនពេញចិត្តទេ ព្រោះជន ៣ នាក់ ឪពុកនឹងកូនទាំងនោះ មិនដឹងច្បាស់ដោយប្រាជ្ញាទៅហើយ ។ អ្នកទាំងឡាយដែលខ្ញុំសួរហើយ មិនអាចប្រាប់នូវអត្ថនិងធម៌បាន ចំណង់បើកូនក្មេង ដែលខ្ញុំសួរអត្ថនិងធម៌ហើយ គប្បីដឹងដូចម្តេចកើត ។

(៤៩៤) (សព្វេយកុមារ...) បពិត្រសុចីរតព្រាហ្មណ៍ លោកកុំសំគាល់សម្ភកុមារនោះថា នៅក្មេង ហើយមិនសួរ គួរតែសួរនូវសម្ភកុមារ ទើបដឹងនូវអត្ថនិងធម៌ ។ ព្រះចន្ទ្រ ប្រាសចាកមន្ទិល កាលដើរទៅតាមអាកាសធាតុ រុងរឿងកន្លងនូវពួកផ្កាយទាំងអស់ក្នុងលោក ដោយរស្មី យ៉ាងណាមិញ បពិត្រសុចីរតព្រាហ្មណ៍ សម្ភកុមារ ពិតជានៅក្មេងមែន (តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញានិងការព្យាយាម ក៏យ៉ាងនោះដែរ លោកកុំសំគាល់នូវសម្ភកុមារនោះថានៅក្មេង ហើយមិនសួរ គួរតែសួរនូវសម្ភកុមារ ទើបដឹង នូវអត្ថនិងធម៌ ។ បពិត្រព្រាហ្មណ៍ បណ្តាខែទាំងគិម្ហរដូវទាំងឡាយ ខែចេត្ររុងរឿង ដោយផ្កាឈើទាំងឡាយ ជាងខែទាំងឡាយដទៃទៀត យ៉ាងណាមិញ ។ សម្ភកុមារ ពិតមែនតែនៅក្មេង (តែរុងរឿងកន្លង នូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញានិងការព្យាយាម ក៏យ៉ាងនោះដែរ

មា នំ ធាវហេកិ មញ្ញាសិ   អប្បដិក្ខាយ សត្តុំ
បុច្ឆិត្វា សត្តុំ ជញ្ញា   អត្ថិ ឧទ្ធញ្ញ ព្រាហ្មណ ។
យថាបិ ហិមវា ព្រហ្មេ   បព្វតោ គន្ធមាទនោ
នានារុក្ខេហិ សញ្ឆន្នោ   មហាភូតគណាលយោ
ឱសធេហិ ច ទិព្វេហិ   ទិសា ភាតិ បវាតិ ច ។
ឯវម្បិ ឧហាភូបតោ   បញ្ញាយោគេន សត្តុកេ
មា នំ ឧហារេកិ មញ្ញាសិ   អប្បដិក្ខាយ សត្តុំ
បុច្ឆិត្វា សត្តុំ ជញ្ញា   អត្ថិ ឧទ្ធញ្ញ ព្រាហ្មណ ។
យថាបិ ទាវកោ ព្រហ្មេ   អច្ចិមាលី យសស្សិមា
ជលមានោ វនេ គច្ឆេ   អនលោ កណ្ហវត្តនី
ឃតាសនោ ធូមកេតុ   ឧត្តមាហេវនន្ទហោ
និស្សិថេ[១] បព្វតគ្គស្មិំ   បហុតេជោ វិរោចតិ ។
ឯវម្បិ ឧហាភូបតោ   បញ្ញាយោគេន សត្តុកេ
បុច្ឆិត្វា សត្តុំ ជញ្ញា   អត្ថិ ឧទ្ធញ្ញ ព្រាហ្មណ ។

១ ម. និស្សិត្វា ។



បពិត្រព្រាហ្មណ៍ លោកកុំសំគាល់សម្តេចកុមារនោះថា នៅក្មេង ហើយមិនសួរ ត្រៀតសួរនូវសម្តេចកុមារ ទើបដឹងនូវអត្ថនិងធម៌ ។ បពិត្រព្រាហ្មណ៍ ភ្នំគន្ធមាទនៈមានទឹកសសៀម ដាស់នៅនៃពពួកទេវតា រដេរដាសដោយដើមឈើផ្សេងៗ ជាទីឡាយផង ដោយឱសថជាទិព្វ ជាទីឡាយផង រមែងញុំាងទិសជាទីឡាយឲ្យភ្លឺច្បាស់ផង ផ្សាយទៅកាន់ទិសជាទីឡាយ(ដោយក្លិនក្រអូប)ផង យ៉ាងណាមិញ ។ សម្តេច-កុមារ ពិតមែនតែនៅក្មេង (តែទ្រង់រៀនគន្ថនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញានិងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់នូវសម្តេចកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្តេចកុមារ ទើបដឹងនូវអត្ថនិងធម៌ ។ បពិត្រព្រាហ្មណ៍ ភ្លើងព្រៃឆេះ ប្រកបដោយអណ្តាត មានសំណាប កាលនេះនូវគុម្ពឈើក្នុងព្រៃ មិនចេះផ្អាក រមែងញុំាងគណៈទៅឲ្យប្រព្រឹត្តទៅ ជាសភាពនេះនូវផ្លូវខ្មៅ មានផ្សែងជាទង់ នេះនូវដងព្រៃស្ងួត មានរបស់សម្រាប់ធ្វើដើមច្រើន រមែងរុងរឿងលើកំពូលភ្នំ ក្នុងវេលាយប់ យ៉ាងណាមិញ ។ សម្តេចកុមារ ពិតមែនតែនៅក្មេង (តែទ្រង់រៀនគន្ថនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញានិងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់នូវសម្តេចកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្តេចកុមារ ទើបដឹងនូវអត្ថនិងធម៌ ។

ជវេន ភទ្រំ ជានន្តិ  ពលិពទ្ទញ្ច វាហិយេ[១]
ទោហេន ធេនុំ ជានន្តិ  ភាសមានញ្ច បណ្ឌិតំ ។
ឯវម្បិ ទហរូបេតោ  បញ្ញាយោគេន សម្ភវោ
មា នំ ទហរោតិ មញ្ញាសិ  អបុច្ឆិត្វាន សម្ភវំ
បុច្ឆិត្វា សម្ភវំ ជញ្ញា  អត្ថំ ធម្មញ្ច ព្រាហ្មណ ។

(៤៨៥) ស្វាធិប្បាត ការត្តោ  សម្ភវស្ស ឧបន្តិកំ
តមទ្ទស មហាព្រហ្មា  កីឡមានំ ពហីបុរេ ។

(៤៨៦) រញ្ញាហំ បហិតោ ទូតោ  កោរព្យស្ស យសស្សិនោ
អត្ថំ ធម្មញ្ច បុច្ឆេសិ  ឥច្ចព្រវិ យុធិដ្ឋិលោ
តំ ត្វំ អត្ថញ្ច ធម្មញ្ច  សម្ភវក្ខាហិ បុច្ឆិតោ ។

(៤៨៧) តគ្ឃ តេ អហមក្ខិស្សំ  យថាបិ កុសលោ តថា
រាជា ច ខោ តំ ជានាតិ  យទិ កាហតិ វា ន វា ។

១ ម. វាហនេ ។



ជនតាំងឡាយ ស្គាល់សេះដ៏ចំរើនដោយល្បឿនផង ស្គាល់គោបម្រើក្នុងការដឹកផង ស្គាល់មេគោដោយរឹតនូវទឹកដោះផង ស្គាល់អ្នកប្រាជ្ញកាលនិយាយផង យ៉ាងណាមិញ ។ សម្ភវកុមារ ទុកជានៅតែនៅក្មេង (តែរុងរឿងកន្លងនូវពួកបណ្ឌិតដទៃសេស) ដោយបញ្ញានឹងការព្យាយាម ក៏យ៉ាងនោះដែរ ម្នាលព្រាហ្មណ៍ លោកកុំសំគាល់នូវសម្ភវកុមារនោះថា នៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថនឹងធម៌ ។

(៤៨៥) (អភិសម្ពុទ្ធគាថា) សុចីរតព្រាហ្មណ៍ ជាការទូតនៃក្រុងនោះ បានទៅកាន់សំណាក់នៃសម្ភវកុមារ សុចីរតៈ ជាមហាព្រាហ្មណ៍ បានឃើញនូវសម្ភវកុមារនោះ កំពុងលេងខាងក្រៅទីលំនៅ ។

(៤៨៦) (សុចីរតព្រាហ្មណ៍...) ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈ ដ៏មានយស ទ្រង់ប្រើមក ព្រះបាទកោរព្យៈ ជាយុធិដ្ឋិលគោត្រ ទ្រង់ត្រាស់ថា អ្នកចូរសួរនូវអត្ថនឹងធម៌ នៃសម្ភវកុមារ ព្រោះហេតុនោះ នាងឯង ដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថនឹងធម៌ ។

(៤៨៧) (សម្ភវកុមារ...) បើដូច្នោះ អ្នកឈ្លាសវៃ (និយាយ) យ៉ាងណា ខ្ញុំនឹងប្រាប់អ្នក យ៉ាងនោះ ព្រះរាជានឹងទ្រង់ជ្រាប នូវប្រស្នានោះ ទោះបីព្រះអង្គធ្វើតាមក្តី មិនធ្វើតាមក្តី ។

(៥៤៣) អទ្ធា សុវាតិ សីសេយ្យ   រញ្ញោ បុត្តោ សុចីរត

មាតាត្វា អសី កជា   អគ្គេ ជាតេ យុធិដ្ឋិលោ

អជ្ឈត្តញ្ញោវ សីសេយ្យ   រញ្ញោ បុត្តោ សុចីរត

ការុម្ភំ ច ទិវសេយ្យ   យថាតុណ្ហោ អចេតសោ ។

អត្តានំ នាតិវត្តេយ្យ   អធម្មំ ច សមាចរេ

អតិត្ថេ នប្បតារេយ្យ   អនត្ថេ ន យុតោ សិយា ។

យោ ច ឯតានិ ឋានានិ   កាតុំ ជានាតិ ខត្តិយោ

សទា សោ វឌ្ឍតេ រាជា   សុក្កបក្ខេវ ចន្ទិមា ។

ញាតីនញ្ច បិយោ ហោតិ   មិត្តេសុ ច វិរោចតិ

កាយស្ស ភេទា សប្បញ្ញោ   សគ្គំ សោ ឧបបជ្ជតីតិ ។

សម្ភវជាតកំ បញ្ចមំ ។

## មហាកបិជាតកំ

(៥៤៤) ពារាណស្សំ អហុ រាជា   កាសីនំ រដ្ឋវឌ្ឍនោ

មិត្តាមច្ចបរិព្យូឡ្ហោ   អគមាសិ មិគាជិនំ ។



(៥៤៣) បពិត្រសុចីរតព្រាហ្មណ៍ បុគ្គលដែលព្រះរាជាសួរថា (យើងរៀ
កុសល) គួរនិងឆ្លើយ គប្បីក្រាបទូលថា គួរតែខ្ញុំសួរវិញ ការរ
សេចក្ដីត្រេកអរកើតឡើងហើយ ព្រះបាទកោរព្យៈ ជាយុធិដ្ឋិលគោត្រ
កុំធ្វើតាមពាក្យ(នោះ)ហើយនៅស្ងៀមឡើយ បុគ្គលដែលព្រះរាជ
សួរហើយ គប្បីក្រាបបង្គំទូលនូវអត្ថបញ្ហៈ ជាមនុស្សដែលប្រាជ្ញ
សូមព្រះរាជាកុំសេពនូវផ្លូវខុស ដូចបុគ្គលល្ងង់ដើរដោយអត់លេចនា ។
ព្រះរាជាកុំប្រព្រឹត្តកន្លងនូវអត្តភាព កុំប្រព្រឹត្តនូវអធម៌ កុំចម្លងនូវគង្គ
មិនមែនជាកំពង់ កុំប្រកបក្នុងសេចក្ដីវិនាសឡើយ ។ លុះតែក្សត្រិយ៍
ណា ទ្រង់ជ្រាបហើយធ្វើនូវហេតុទាំងឡាយនេះ ព្រះរាជានោះនឹង
ចំរើនរាល់ពេល ដូចជាព្រះចន្ទក្នុងសុក្កបក្ស ។ ព្រះរាជានោះប្រាកដ
ដោយប្រាជ្ញ រមែងជាទីស្រឡាញ់នៃពួកញាតិផង ទ្រង់រុងរឿងក្នុង
ពួកមិត្តផង លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងឋានសួគ៌ ។

ចប់ សម្ភវជាតក ទី ៥ ។

## មហាកបិជាតក

(៥៤៤) (ព្រះសាស្ដាទ្រង់សំដែងថា) ព្រះរាជា ក្នុងក្រុងពារាណសី ព្រ
អង្គញុំាងដែន របស់ពួកជនអ្នកដែនកាសីឲ្យចំរើន ព្រះអង្គមាន
ពួកមិត្តនិងអាមាត្យចោមរោមហើយ ស្ដេចទៅកាន់មិគាជិនឧទ្យាន ។

ទទ្ទុ ព្រាហ្មណមទ្ទក្ខិ   សេតំ ចិត្រំ កិលាសិនំ

វិទ្ធស្តំ គោវិក្ខាវិំ   កិសំ ធមនិសន្ថតំ ។

ឧបមកាត្វាតំ បត្តិ   ទិស្វា ភិក្ខុគតិ ឥវំ

អវច ព្យម្ហិតោ ភជា   យក្ខានំ កតមោនុសិ ។

មាតុតាណា ច តេ សេនា   តតោ សេតតរំ សិរោ

ពត្តិ កម្មាសវណ្ណាន្តិ   កិលាសគហុលោ កសិ ។

វេជ្ជាវលិសន្ថាសា   ចិជ្ជិ តេ ធិន្នគន្ធតា

កាលប្បច្ចា ច តេ អដ្ឋិ   បញ្ចិ ចសព្ភមិ សិធិសំ ។

ចក្ខុដ្ឋាតោ តសិតោ   កិសោ ធមនិសន្ថតោ

ជាតោ អតិត្តរូតាសិ   ក្រុតាសិ កក្ខ កច្ចសិ ។

ឧទ្ទិសិ អបរាគោសិ   ឧទ្ទណ្ណោ ពីមឧស្សុតោ

ជេនត្តិ យាចិ តេ មាតា   ឧ តំ វិន្ទេយ្យ ចស្សិតុំ ។

កិំ កម្មមកោ បុរេ   កិំ អវិជ្ជំ អយោកយំ

កិច្ចិសំ យំ ការិត្វាន   វតិ ឧទ្ទិំ ឧទាកមំ ។





បានទតឃើញព្រាហ្មណ៍ម្នាក់ កើតឃ្លង់ស ឃ្លង់ពពាល កើតស្រែង មានសាច់ស្ញៀវរោញ ដូចជាផ្កាល្ហុងស្អុំ ស្គមស្គាំងសរសៃ កន្ធិមិនាធិនខ្សោយតោះ ។ ព្រះពុទ្ធក្រឡេកឃើញ ផែនមាន សេចក្តីលំបាក ដល់នូវភាពគួរតាណិតក្រៃលែង ទ្រង់ស្ញើប ទ្រង់ ត្រាស់សួរថា បណ្តាពួកយក្ស អ្នកជាយក្សអ្វី ? ដៃនឹងជើងរបស់អ្នកស ផង ក្បាលរបស់អ្នក សលើសជាងដៃនឹងជើងនោះផង ខ្នងរបស់អ្នក មានសម្បុរពព្រុះផង មានស្រែងដ៏ច្រើនផង ។ ខ្នងរបស់អ្នក ហើយ ផង ដូចជាល្អសរដែលរៀញផង អវយវៈរបស់អ្នក ដូចល្ងើ ដែន កែនផង យើងមិនដែលឃើញបុគ្គលដែលមានរាងបែបនេះឡើយ ។ អ្នក មានជើងប្រឡាក់ដោយធូលី ជាអ្នកអត់ស្អុក ស្គម ឡើងសរសៃ ពេញ ស្រេកឃ្លាន មានសភាពជាអ្នកមិនន្ទែន តើអ្នកមកអំពីទីណា នឹងទៅកាន់ទីណា ។ អ្នកជាបុគ្គលលំបាកមើល មិនមានទ្រង់ ទ្រាយ មានសម្បុរមិនល្អ មើលទៅគួរខ្លាច សូម្បីតែមាតាបង្កើត របស់អ្នក ក៏មិនបានឃើញអ្នកដែរ ។ អ្នកបានធ្វើនូវអំពើដូចម្តេច ក្នុងកាលមុន អ្នកបានបៀតបៀន នូវសត្វដែលមិនគួរសម្លាប់ដូច ម្តេច អ្នកធ្វើនូវអំពើអាក្រក់ណា ក៏បាននូវសេចក្តីទុក្ខនេះ ។

[៨០០] តស្ស តេ អភោមត្តិស្ស យថាបិ កុសលោ តថា

សច្ចញ្ហិ វចំ លោកស្មឹ បសំសន្តិធ បណ្ឌិតា ។

ឯកោ ចរំ គោគវេសោ មូឡ្ហោ អច្ចសរឹ វនេ

អរញ្ញេ ឥរីណេ វិវនេ នានាកុញ្ជរសេវិតេ ។

វាឡមិគានុចរិតេ វិប្បនដ្ឋោស្មិ កាននេ

អចរឹ តត្ថ សត្តាហំ ខុប្បិបាសសមប្បិតោ ។

តត្ថ តិន្ទុកមទ្ទក្ខឹ វិសមដ្ឋំ ពុភុក្ខិតោ

បបាតមភិលម្ពន្តំ សម្បន្នផលធារិនំ ។

វាតស្សិតានិ ភក្ខេសឹ តានិ រុច្ចឹសុ មេ ភុសំ

អតិត្តោ រុក្ខមារុយ្ហ តត្ថ ហេស្សាមិ អាសិតោ ។

ឯកំ មេ ភក្ខិតំ អាសិ ទុតិយំ អភិបត្ថិតំ

តតោ សា ភញ្ជថ សាខា ឆិន្នា ផរសុនា វិយ ។

សោហំ សហាវ សាខាហិ ឧទ្ធំបាទោ អវំសិរោ

អប្បតិដ្ឋេ អនាលម្ពេ គិរិទុគ្គស្មិំ បាបតឹ[១] ។

---

១ ម. គិរិទុគ្គស្មិំ បបតឹ ។



(៨០០) (ព្រាហ្មណ៍ក្រាបបង្គំទូលថា) បើដូច្នោះ អ្នកឈ្លាសវៃ (និយាយ) យ៉ាងណា ទូលព្រះបង្គំជាខ្ញុំនឹងទូល យ៉ាងនោះ ព្រោះថា ក្នុងលោកនេះ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរបុគ្គលអ្នកនិយាយពាក្យពិត ។ ទូលព្រះបង្គំជាខ្ញុំតែម្នាក់ឯង កាលដើររកគោ ក៏វង្វេងដើរហួសទៅ ក្នុងព្រៃស្ងប់ស្ងាត់ ជាព្រៃគ្មានទឹក ព្រៃស្ងាត់ឈឹង ដែលពួកដំរីផ្សេងៗនៅហើយ ។ ទូលព្រះបង្គំជាខ្ញុំ វង្វេងផ្លូវក្នុងព្រៃ ដែលពួកម្រឹគកាចដើរទៅមក ជាអ្នកមានសេចក្តីស្រេកឃ្លាន អស់៧ថ្ងៃ ដើរទៅក្នុងព្រៃនោះ ។ ទូលព្រះបង្គំជាខ្ញុំ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ ក៏បានឃើញដើមទន្លាប់ក្នុងព្រៃនោះ ដុះនៅក្នុងទីមិនរាបស្មើ សំយុងទៅកាន់ជ្រោះ ជាឈើប្រកបព្រមដោយផ្លែមានរសផ្អែម ។ ទូលព្រះបង្គំជាខ្ញុំ បានបរិភោគផ្លែឈើទាំងឡាយ ដែលខ្យល់បក់ធ្លាក់ចុះមក ផ្លែឈើទាំងនោះ គាប់ចិត្តទូលព្រះបង្គំជាខ្ញុំយ៉ាងក្រៃលែង ទូលព្រះបង្គំជាខ្ញុំមិនឆ្អែត ក៏ឡើងលើដើម ដោយគិតថានឹងស៊ីឲ្យឆ្អែតស្កប់ស្កល់លើដើមនោះ ។ ទូលព្រះបង្គំជាខ្ញុំបរិភោគផ្លែទន្លាប់មួយហើយ ប្រាថ្នាផ្លែជាគំរប់ពីរទៀត លំដាប់នោះ មែកឈើនោះក៏បាក់ ហាក់ដូចជាគេកាប់នឹងពូថៅ ។ ទូលព្រះបង្គំជាខ្ញុំនោះ ក៏ធ្លាក់មកជាមួយនឹងមែកឈើ មានជើងឡើងលើ មានក្បាលចុះក្រោម ធ្លាក់ចុះទៅក្នុងជ្រោះភ្នំ ដែលមិនមានទីពឹង មិនមានទីតោង ។

យស្មា ច ភវំ កម្មំ    តស្មា ច សមបជ្ជិសំ
តត្ថ សេសឹ និរាលម្ពោ    អនស្សា ទសរត្តិយោ ។
អថេត្ថ កបិ មាគញ្ឆិ    គោនង្គុលោ ទរីចរោ
សាខាហិ សាខំ វិចរន្តោ    ខាទមានោ ទុមប្ផលំ
សោ មំ ទិស្វា កិសំ បណ្ឌុំ    ការុញ្ញមការំ មយិ ។
អម្ភោ កោ នាម សោ ឯត្ថ    ឯវំ ទុក្ខេន អដ្ដិតោ
មនុស្សោ អមនុស្សោ វា    អត្តានំ មេ បវេទយ ។
តស្សញ្ជលឹ បណាមេត្វា    ឥទំ វចនមព្រវឹ
មនុស្សោហំ ព្យសនប្បត្តោ    ន មេ នត្ថិ ឥតោ គតិ
តំ តេ វទាមិ ភទ្ទន្តេ    ត្វញ្ច មេ សរណំ ភវ ។
គរុំ សិលំ គហេត្វាន    វិចរី បព្វតេ កបិ
សិលាយ យោគ្គំ កត្វាន    និសភោ ឯតទព្រវិ ។
ឯហិ មេ បិដ្ឋិមារុយ្ហ    គីវំ គណ្ហាហិ ពាហុភិ
អហំ តំ ឧទ្ធរិស្សាមិ    គិរិទុគ្គត វេគសា ។
តស្ស តំ វចនំ សុត្វា    វានរិន្ទស្ស សិរីមតោ
បិដ្ឋិមារុយ្ហ ធីរស្ស    គីវំ ពាហាហិ អគ្គហិំ ។



ទឹកជ្រៅ មានត្រឹមណា ទូលព្រះបង្គំជាខ្ញុំមិនធ្លាក់ដល់ត្រឹមណោះទេ មិនមានសេចក្តីត្រេកអរ មិនមានទីពឹង ដេកកន្លែងជ្រោះនោះអស់ ១០ រាត្រីគត់ ។ គ្រានោះស្វាមានកន្ទុយដូចជាកន្ទុយគោ ត្រាច់ទៅតាមព្រៃភ្នំ មកដល់ទីនោះ លោតពីមែកមួយ ទៅកាន់មែកមួយ បានស៊ីផ្លែឈើ ស្វានោះបានឃើញនូវទូលព្រះបង្គំជាខ្ញុំ ដែលស្គមស្លេកស្លាំង ក៏ធ្វើនូវសេចក្តីករុណាចំពោះទូលព្រះបង្គំជាខ្ញុំ ។ ស្វាថា ម្នាលអ្នកដ៏ចំរើន អ្នកឯណានេះជាអ្វី ត្រូវទុក្ខព្រួយសក្តិកន្លែងទីនេះយ៉ាងនេះ អ្នកជាមនុស្ស ឬមិនមែនមនុស្ស ចូរប្រាប់ខ្លួនដល់យើង ។ ទូលព្រះបង្គំជាខ្ញុំ ក៏ប្រណម្យអញ្ជលី ចំពោះស្វានោះ ហើយពោលនូវពាក្យនេះថា ខ្ញុំជាមនុស្សដល់នូវវិណាបាន (សេចក្តីនាស) ខ្ញុំទៅអំពីទីនេះមិនបានទេ ព្រោះហេតុនោះ ខ្ញុំជំរាបអ្នក សូមសេចក្តីចំរើន មានដល់អ្នក សូមអ្នកជាទីពឹងរបស់ខ្ញុំ ។ ស្វាដ៏ប្រសើរ ត្រាច់ទៅលើភ្នំ ក៏យកនូវថ្មធ្ងន់ ចងនឹងខ្សែនឹងថ្ម ហើយពោលនូវពាក្យនេះថា អ្នកចូរមក ចូរឡើងជិះខ្នងខ្ញុំ ហើយតោងកខ្ញុំដោយដៃទាំងពីរ ខ្ញុំនឹងស្រង់អ្នកចាកជ្រោះភ្នំ ដោយកម្លាំង ។ ទូលព្រះបង្គំជាខ្ញុំ បានឮពាក្យស្តេចស្វាដ៏មានសិរីនោះ ក៏ឡើងជិះខ្នង នៃស្វាជាអ្នកប្រាជ្ញ ហើយតោងកដោយដៃទាំងពីរ ។

សោ មំ កាកោ សមុទ្ទាសិ   ទេវសី កលភិ ការិ
វិហញ្ញមានោ តាំទេឧ   តិរិទុក្ខុ បេតសោ ។
ទុក្ខិត្វាន មំ សន្តោ   និសេកោ បតឧត្រៅ
ឥធ្យ មំ សម្ពរក្ខស្ស   បស្សុបិស្សុំ មុហុត្តកំ ។
សីហា ព្យគ្ឃា ច ទីបិ ច   អច្ឆកោកតរច្ឆយោ
តេ មំ បមត្តំ ហឹសេយ្យុំ   តេ ត្វំ ទិស្វា និវារយ ។
ឯវំ មេ បរិត្តាតូន   បស្សុបិ សោ មុហុត្តកំ
កដាហំ តាបិតំ ទិដ្ឋំ   បដិលទ្ធំ អយោនិសោ ។
កញ្ចោ អយំ មនុស្សានំ   យថា ចញ្ញេ វនេ មិគា
យន្នូនិមំ វធិត្វាន   ឆាតោ ខាទេយ្យ វានរោ ។
អសិតោ ច គមិស្សាមិ   មំសមាទាយ សម្ពលំ
កន្តារំ និត្ថរិស្សាមិ   បាថេយ្យំ មេ ភវិស្សតិ ។
តតោ សិលំ គហេត្វាន   មត្ថកំ សន្និតាឡយិ
មម គត្តកិលន្តស្ស   បហារោ ទុព្វលោ អហុ ។
សោ ច វេគេនុទប្បត្តោ   កាមំ រុហិរមក្ខិតោ
អស្សុបុណ្ណេហិ នេត្តេហិ   រោទន្តោ មំ ឧទិក្ខតិ ។



ស្វានោះ មានសេចក្ដីករុណា ទើបលោត ដោយសេចក្ដីលំបាក បានស្រង់ខ្លួនព្រះបង្គំជាខ្ញុំចាកជ្រោះភ្នំ ដោយរហ័ស ។ ស្វាជាសត្វ-សេដ្ឋប្រសើរ លុះស្រង់ខ្លួនព្រះបង្គំជាខ្ញុំរួចហើយ ក៏ពោលនូវពាក្យនេះថា នែសំឡាញ់ អ្នកចូរក្រាញ់ខ្ញុំផង ខ្ញុំនឹងសម្រាកមួយភ្លែត ។ បើពួកសត្វកាចសីហក្ដី ពួកខ្លាធំក្ដី ពួកខ្លាដំបងក្ដី ពួកខ្លាឃ្មុំក្ដី ពួកឆ្កែព្រៃក្ដី ពួកខ្លារខិនក្ដី ពួកសត្វកាចទាំងនោះ មកបៀតបៀនខ្ញុំ ដែលធ្វេសប្រហែសហើយ បើអ្នកឃើញនូវសត្វសាហាវទាំងនោះ ចូរការពារផង ។ ស្វានោះ ត្រូវខ្លួនព្រះបង្គំជាខ្ញុំការពារយ៉ាងនេះ ហើយក៏ដេកលក់មួយស្របក់ទៅ គ្រានោះខ្លួនព្រះបង្គំជាខ្ញុំ បានចិត្តដ៏លាមក ដោយមិនត្រូវទំនងថា ស្វានេះ ជាអាហាររបស់ពួកមនុស្ស ដូចពួកម្រឹគដទៃ ក្នុងព្រៃដែរ បើដូច្នោះ កាលអញឃ្លានហើយ គប្បីសម្លាប់នូវស្វានេះស៊ី ។ អញស៊ីហើយ នឹងយកសាច់ជាស្បៀង ដើរទៅនឹងឆ្លងផ្លូវឆ្ងាយ ស្បៀងអញក៏មានគ្រប់ ។ លំដាប់នោះ ខ្លួនព្រះបង្គំជាខ្ញុំ ចាប់យកដុំថ្មគប់ក្បាល(ស្វានោះ) កាលខ្លួនព្រះបង្គំជាខ្ញុំ លំបាកដោយឃ្លាន ការប្រហារ ក៏មានកំឡាំងថយ ។ ឯស្វានោះ ក៏ស្ទុះក្រោកឡើងដោយរហ័ស ប្រឡាក់ដោយឈាម មានភ្នែកពេញដោយទឹកភ្នែក យំសម្លឹងមើលខ្លួនព្រះបង្គំជាខ្ញុំ ។

មាយ្យោ មំ ករី ភទ្ទន្តេ ត្វញ្ច ខោ នាមេទិសំ ការិ
ត្វញ្ច ខោ នាម ទីឃាវុ អញ្ញេ វារេតុមរហសិ ។
អហោ វត រេ បុរិស តាវ ទុក្ករការក
ឯទិសា វិសមា ទុគ្គា បបាតា ឧទ្ធដោ មយា ។
អានីតោ បរលោកាវ ទុព្ភេយ្យំ មំ អមញ្ញថ
តន្តេន បាបធម្មេន បាបំ បាបេន ចិន្តិតំ ។
មា ហេវ ត្វំ អធម្មដ្ឋ វេទនំ កដុកំ ផុសិ
មា ហេវ បាបកម្មន្តំ ផលំ វេឡុំវ តំ វធិ ។
តយិ មេ នត្ថិ វិស្សាសោ បាបធម្ម អសញ្ញត
ឯហិ មេ បិដ្ឋិតោ គច្ឆ ទិស្សមានោវ សន្តិកេ ។
មុត្តោសិ ហត្ថា វាឡានំ បត្តោសិ មានុសឹ បទំ
ឯស មគ្គោ អធម្មដ្ឋ តេន គច្ឆ យថាសុខំ ។
ឥទំ វត្វា គិរិចរោ រុហិរំ បក្ខលិយ មត្ថកំ
អស្សូនិ សម្បមជ្ជិត្វា តតោ បព្វតមារុហិ ។



និយាយថា បពិត្រអ្នកដ៏ចំរើន អ្នកជាម្ចាស់ កុំធ្វើបាបខ្ញុំឡើយ អ្នកឯងធ្វើអំពើអាក្រក់បែបនេះ ព្រោះអ្នកមានអាយុវែង អ្នកឯងគួរតែហាមឃាត់នូវបុគ្គលដទៃ ។ ឱហ្ន៎ នែបុរសចង្រៃ ជាមនុស្សធ្វើអំពើអាក្រក់ផលលំបាក អញបានស្រង់ឯងឲ្យរួចពីជ្រោះជ្រៅស្រឡូងបែបនេះ ។ អញនាំអ្នកឯងមក(នេះ) ដូចជានាំមកពីបរលោក អ្នកឯងសំគាល់ឃើញថា គួរប្រទូស្ត គំនិតលាមកនោះ អ្នកឯងនោះជាមនុស្សលាមក ជាមនុស្សបាប គិតហើយ ។ នែអ្នកមិនប្រព្រឹត្តក្នុងធម៌ អ្នកឯងកុំប៉ះពាល់នូវទុក្ខវេទនា ដ៏ខ្លាំងក្លាឡើយ គំនិតលាមកនោះ កុំសម្លាប់អ្នកឯងដូចជាផ្លែឫស្សី ដែលសម្លាប់ដើមឯងវិញឡើយ ។ នែអ្នកជាមនុស្សមានធម៌លាមក មិនសង្រួម យើងលែងមានសេចក្ដីទុកចិត្តចំពោះអ្នក អ្នកឯងចូរមក អ្នកឯងចូរមានសភាវៈប្រាកដក្នុងទីជិត ដើរតាមក្រោយយើងចុះ ។ អ្នកឯងរួចផុតពីកណ្ដាប់ដៃ នៃពួកម្រឹគកាចហើយ អ្នកឯងបានដល់នូវបទៈ ជារបស់នៃមនុស្សហើយ នែអ្នកមិនប្រព្រឹត្តក្នុងធម៌ នុ៎ះផ្លូវអ្នកឯង ចូរដើរទៅឲ្យស្រួលសប្បាយតាមផ្លូវនោះចុះ ។ ស្វាដែលត្រាច់ទៅលើភ្នំ លុះបានពោលពាក្យនេះហើយ ទើបលាងឈាមក្បាលរបស់ខ្លួន ហើយជូតទឹកភ្នែកឲ្យជ្រះ លោតចាប់តោងកោនឡើងទៅលើភ្នំ ។

សោហំ តេនាភិសត្តស្ស បរិព្យូហេន អដ្ដិតោ

ឧយ្ហមានេន គត្តេន ភរឹ ចាគុំ ឧទាគមឹ ។

អត្ថិធា វិយ សន្តត្តោ វិហតោ រុហិរមក្ខិតោ

ពុព្វលោហិតសញ្ញោសោ សរេញ្ញ មេ សមប្បជ ។

យាវត្ថា ឧឧតិទ្ធំ កាយស្មឹ និបតិសុ មេ

តាវត្ថា គណ្ឌា ជាយេថ អឌ្ឍវេលុវសាទិសា ។

បភិន្នា បគ្ឃរីសុ មេ កុណបា បុព្វលោហិតា

យេន យេនេវ គច្ឆាមិ គាមេសុ និគមេសុ ច ។

ទណ្ឌហត្ថា និវារេន្តិ ឥត្ថិយោ បុរិសា ច មំ

ឱក្កិតា បូតិគន្ធេន មាស្សុ តេន អាគមា ។

ឯតាទិសំ ឥទំ ទុក្ខំ សត្តវស្សានិ ទានិ មេ

អនុភោមិ សកំ កម្មំ បុព្វេ ទុក្កដមត្តនោ ។

តំ វោ វទាមិ ភទ្ទន្តេ យាវន្តេត្ថ សមាគតា

មាស្សុ មិត្តាន ទុព្ភិត្ថោ មិត្តទុព្ភោ ហិ បាបកោ ។



ទូលព្រះបង្គំជាខ្ញុំនោះ ជាបុគ្គលដែលស្វានោះផ្ដាសាហើយ ត្រូវសេចក្តីក្តៅក្រហាយបៀតបៀន មានខ្លួនក្តៅអន្ទះអន្ទែង បានចូលទៅកាន់ទួលមានទឹក ។ អន្លង់ទឹកទាំងអស់ក៏ក្តៅសព្វ ហាក់ដូចជាភ្លើងនេះ ជាអន្លង់ហាក់ដូចជាប្រឡាក់ឈាម ហាក់ដូចជាខ្ទុះនឹងឈាមប្រាកដដល់ខ្ញុំ ។ ដំណក់ទឹកមានចំនួនប៉ុន្មាន ស្រក់លើកាយរបស់ទូលព្រះបង្គំជាខ្ញុំ បូសមានចំនួនប៉ុណ្ណោះ ប្រាកដស្មើដោយផ្លែព្នៅមួយចំហៀង ក៏កើតឡើង ។ ទូលព្រះបង្គំជាខ្ញុំ ទៅក្នុងស្រុកនិងនិគមទាំងឡាយ ណាមួយណា ៗ បូសទាំងឡាយក៏បែកធ្លាយខ្ទុះនឹងឈាម ដ៏ស្អុយ ហូរចេញ (កុណបៈ) របស់ទូលព្រះបង្គំជាខ្ញុំ (តាមផ្លូវនោះៗ) ។ ពួកស្ត្រីនិងបុរស កាន់ដំបងក្នុងដៃ ដែលត្រូវក្លិនស្អុយគ្របសង្កត់ហើយ ឃាត់ទូលព្រះបង្គំជាខ្ញុំថា អ្នកឯងកុំចូលមកខាងអាយឡើយ ។ សេចក្តីទុក្ខលំបាកនេះប្រាកដដូច្នេះ មានដល់ទូលព្រះបង្គំជាខ្ញុំ អស់ ៧ ឆ្នាំ ហើយដល់មកឥឡូវនេះ ទូលព្រះបង្គំជាខ្ញុំ នៅតែទទួលផលកម្មរបស់ខ្លួនដែលខ្លួនធ្វើអាក្រក់ហើយក្នុងកាលមុន ។ ព្រោះហេតុនោះ ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលចំពោះព្រះអង្គ សូមសេចក្តីចំរើនមានដល់ព្រះអង្គ ពួកអ្នកដែលមកប្រជុំគ្នាក្នុងទីនេះ សូមកុំប្រទូស្តក្នុងមិត្តឡើយ ព្រោះថា បុគ្គលប្រទូស្តមិត្ត ជាមនុស្សអាក្រក់ ។

កុដ្ឋី កិលាសី ភវតិ យោ មិត្តានិធ ទុព្ភតិ

កាយស្ស ភេទា មិត្តទុព្ភី និរយំ សោ ឧបបជ្ជតិ ។

មហាកបិជាតកំ ឆដ្ឋំ ។

## ទករក្ខសជាតកំ

(៨០១) សចេ វោ វុយ្ហមានានំ សត្តន្នំ ឧទកណ្ណវេ

មនុស្សពលិមេសានោ នាវំ គណ្ហាយ រក្ខសោ

អនុបុព្វំ កថំ ទត្វា មុញ្ចេសិ ទករក្ខសា ។

(៨០២) មាតរំ បឋមំ ទជ្ជំ ភរិយំ ទត្វាន ភាតរំ

តតោ សហាយំ ទត្វាន បញ្ចមំ ទជ្ជំ ព្រាហ្មណំ

ឆដ្ឋាហំ ទជ្ជមត្តានំ នេវ ទជ្ជំ មហោសធំ ។

(៨០៣) បោសេតា តេ ជនេត្តី ច ទីឃរត្តានុកម្បិកា

ឆព្ភី តយិ បទុស្សតិ(១) បណ្ឌិតា អត្ថទស្សិនី

អញ្ញំ ឧបនិសំ កត្វា វធា តំ បរិមោចយិ

១ ម. បទុស្សតិ ។



(អភិសម្ពុទ្ធគាថា) បុគ្គលណា ប្រទូស្តមិត្តទាំងឡាយ ក្នុងលោកនេះ បុគ្គលនោះ រមែងកើតឃ្លង់ផង កើតស្រែងផង បុគ្គលអ្នកប្រទូស្តមិត្តនោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។

ចប់ មហាកបិជាតក ទី ៦ ។

## ទករក្ខសជាតក

(៨០១) (នាងកេវីចៅក្រាមិកាសួរថា) កាលពួកយើងទាំង៧នាក់(១) របស់ព្រះអង្គ រសាត់ទៅក្នុងសមុទ្ទទឹកជ្រៅ អារក្សទឹកកាលស្វែងរកគ្រឿងបូជារបស់មនុស្ស គប្បីចាប់ទូក (ព្រះអង្គព្រះរាជទានខ្ញុំវិញ) តាមលំដាប់ដូចម្តេច ទើបរួចអំពីអារក្សទឹកបាន ។

(៨០២) (ព្រះបាទចូឡនីត្រាស់ថា) ខ្ញុំឲ្យមាតាជាមុន រួចឲ្យភរិយា ឲ្យប្អូន លំដាប់អំពីនោះ ឲ្យសំឡាញ់ ទីឲ្យព្រាហ្មណ៍ជាគំរប់៥ ទើបឲ្យខ្លួនជាគំរប់៦ មិនឲ្យមហោសធទេ ។

(៨០៣) (នាងកេវី...) ព្រះមាតាជាអ្នកចិញ្ចឹមព្រះអង្គផង ជាអ្នកបង្កើតផង អនុគ្រោះព្រះអង្គអស់កាលដ៏យូរផង កាលបើឆព្ភិព្រាហ្មណ៍ប្រទូស្តចំពោះព្រះអង្គ ព្រះមាតាជាបណ្ឌិត ជាអ្នកស្គាល់ប្រយោជន៍ ធ្វើឧបាយដទៃជាគ្រឿងបន្លំ ហើយដោះព្រះអង្គឲ្យរួចអំពីការសម្លាប់

១ គឺមាតា១ នាងនន្ទាទេវី១ តិក្ខិណមន្តីកុមារ១ សំឡាញ់ឈ្មោះធនុសេខ១ បុរោហិត១ មហោសធ១ ស្តេចចូឡនី១ ។ អដ្ឋកថា ។

តំ តាទិសំ ហាលាហលំ ទិស្សំ កណ្ហជាតំធី

មាតរំ តេន ពោសេន ឧជ្ឈាសំ ឧទកកុម្ភិយោ ។

(៨០៤) ឧហាក វិយលញ្ឆាវី ជាបេតិ អមិលទ្ធិំ

ពោភិកោ អធិកាជេ អតិវេលំ បជគ្ឃតិ [១]

អជោមិ មដកជុំ សយំ ទូតាទិ សាសតិ

មាតរំ តេន ពោសេន ឧជ្ឈាហំ ឧទកកុម្ភិយោ ។

(៨០៥) ឥត្ថីគុម្ពស្ស បវរា អច្ចន្តំ បិយភាណិនី

អនុព្វតា សីលវតី ឆាយាវ អនុបាយិនី

អក្កោធនា បុញ្ញវតី បណ្ឌិតា អត្ថទស្សិនី

ទូតាំ តេន ពោសេន ឧជ្ឈាសំ ឧទកកុម្ភិយោ ។

(៨០៦) ខិឌ្ឌារតិសមាបន្នំ អនត្ថវសមាគតំ

សា មំ សកាន បុត្តានំ អយាចំ យាចតេ ធនំ

សោហំ ទទាមិ សារត្តោ ពហុំ ឧច្ចាវចំ ធនំ

១ ម. សំពិឡុតិ ។



ព្រះអង្គព្រះរាជទានដល់ការក្បទឹកឱ្យព្រះមាតា ដែលមានព្រះគុណ ច្រើនដល់ខ្លួន ជាអ្នកឱ្យនូវជីវិត ជាអ្នកឱ្យព្រះអង្គកើតអំពីគេ ជា អ្នកទ្រទ្រង់នូវគភ៌នោះ តើព្រោះហេតុដូចម្ដេច ។

(៨០៤) (ព្រះរាជា...) ព្រះមាតាខ្ញុំ ទ្រទ្រង់គ្រឿងក្រអូបផ្កាដែលមិនល្អ ជាក់តែងដូចស្រីកញ្ញា ហើយក្អកក្អាយហួសវេលា (ជាមួយ) នឹង ងាយញ៉ាំញីនឹងពពួកពលសេនា មិនតែប៉ុណ្ណោះ ថែមទាំងបញ្ជូននូវ ខ្ទឹមទាំងឡាយដល់ពួកបរិវារ (ព្រះរាជាទៅក្រោមសំណាប) ហើយ ខ្លួនឯង ខ្ញុំឱ្យព្រះមាតាដល់ការក្បទឹក ព្រោះហេតុនោះឯង ។

(៨០៥) (នាងនោះ..) ឧត្តមមហេសី ជាស្ត្រីប្រសើរជាងពួកស្ត្រី ពោល ពាក្យជាទីស្រឡាញ់ដល់ក្រៃលែង ជាស្ត្រីមានសណ្ដាប់ធ្នាប់ មាន សីលធម៌ ជាប់ជាប់តាម(ព្រះអង្គ) ដូចជាស្រមោល ជាស្ត្រីមិនក្រៅ ក្រោធ ជាអ្នកមានបុណ្យ ជាបណ្ឌិតឃើញនូវប្រយោជន៍ ព្រះអង្គ ព្រះរាជទានឧទ្ទកញ្ញាដល់ការក្បទឹក តើព្រោះហេតុដូចម្ដេច ។

(៨០៦) (ព្រះរាជា...) នាងនេះទៀតនោះ (ចាញ់មិនឡាស់) ខ្ញុំជាប់ជា អ្នកប្រកបដោយសេចក្ដីត្រេកអរក្នុងល្បែង ទាំងជាអ្នកលុះអំណាច នៃកិលេស ដែលមិនមានប្រយោជន៍ នាងបានសូមចំពោះខ្ញុំ នូវ ទ្រព្យនៃកូនទាំងឡាយរបស់ខ្លួន ដែលជាទ្រព្យមិនគួរសូម ខ្ញុំនោះ កំពុងតែត្រេកត្រអាល ក៏បានឱ្យទ្រព្យប្រសើរនិងថោកទាបច្រើនយ៉ាង

សុទុច្ចជំ ចជិត្វាន បច្ឆា សោចាមិ ទុម្មនោ

ទុក្ខី តេន ទោសេន ឧដ្ឋាហំ ឧការក្ខិតោ ។

(៥០៧) យេ ទោធិតា ជានបទា អាមិតា ច បដិគ្គហំ

អាកដំ បាររដ្ឋកំ អភិដ្ឋាយ ពហុធនំ

ឧត្តុក្កហានំ បរំ សុរំ ភិទ្ធិណាមត្តិនំ

កាកំ តេន ទោសេន ឧដ្ឋាសិ ឧការក្ខិតោ ។

(៥០៨) យេ[1] ទោធិតា ជានបទា អាគតា ច បដិគ្គហំ

អាកដំ បាររដ្ឋកំ អភិដ្ឋាយ ពហុធនំ

ឧត្តុក្កហានំ បរេក សុរេក ភិទ្ធិណាមត្តិ ច[2]

មយាយំ សុទិតោ កថា នត្តិ[3] មញ្ញតិ ឆារកោ

ខុបដ្ឋានំ មេ អយ្យេ ន សោ បត្តិ យថាបុរេ

កាកំ តេន ទោសេន ឧដ្ឋាហំ ឧការក្ខិតោ ។

---

១ ម. យោធិកា ។ អដ្ឋកថា ។ ២ ម. តោ ។ ៣ ម. នត្ថិ ។



លុះខ្ញុំលះបង់នូវទ្រព្យដែលគេលះបង់បានដោយក្រហើយ ក៏មានចិត្តអាក់អន់សោកស្ដាយក្នុងកាលជាខាងក្រោយ ខ្ញុំឲ្យតាមនឹងក្ដីផល់ ការក្សត់ ព្រោះទោសនោះឯង ។

(៥០៧) (នាងទេវី...) ក្នុងអ្នកជនបទចំរើនហើយ ព្រោះព្រះកនិដ្ឋកាណា តាំងព្រះអង្គដែលព្រះកនិដ្ឋកាណា នាំមកកាន់ព្រះរាជដំណាក់វិញ ព្រះរាជទ្រព្យជាច្រើនយ៉ាង ដែលព្រះកនិដ្ឋកាណា រៀបចំនាំមកអំពីក្នុងស្តេចដទៃ ព្រះអង្គព្រះរាជទានព្រះកនិដ្ឋកា ជាបុគ្គលប្រសើរជាងក្នុងក្នុងទ័ព ជាអ្នកក្លៀវក្លា មានប្រាជ្ញាដ៏មុត (នោះ) ដល់ការក្សត់ តើព្រោះទោសដូចម្ដេច ។

(៥០៨) (ព្រះរាជា...) ក្នុងអ្នកជនបទចំរើនហើយ ព្រោះកនិដ្ឋកាណា តាំងខ្ញុំ (ដែលកនិដ្ឋកាណា) នាំមកកាន់ដំណាក់វិញ ព្រះរាជទ្រព្យជាច្រើនយ៉ាង (ដែលកនិដ្ឋកាណា) រៀបចំហើយនាំមកអំពីក្នុងស្ដេចដទៃ កនិដ្ឋកានោះ មើលងាយថា អញប្រសើរជាងក្នុងក្នុងទ័ព ជាអ្នកក្លៀវក្លា មានប្រាជ្ញាដ៏មុត ឯព្រះរាជានេះដូចជាក្មេង បានសេចក្ដីសុខ ព្រោះតែអញ បពិត្រនាងជាម្ចាស់ មិនតែប៉ុណ្ណោះ កនិដ្ឋកានោះ មិនមកកាន់ទីបំរើខ្ញុំដូចក្នុងកាលពីដើមទេ ខ្ញុំឲ្យកនិដ្ឋកា (នោះ) ដល់ការក្សត់ ព្រោះទោសនោះឯង ។

(៨០៩) ឯកាគារេ ឧភយោ ត្វញ្ច ឧទ្ទាលក

ឧភោ ជាតេត្ថ បញ្ចាលា សហាយា សុសមាវយា

ចរិយា តំ អនុពន្ធិត្ថោ[1] បរិចារកសុតោ តវ

ឧស្សុក្កោ តេ ទិវារត្តិ សព្វកិច្ចេសុ ព្យាវដោ

សហាយំ កេន ទោសេន ឧជ្ឈាសិ ឧការត្តិតោ ។

(៨១០) ភរិយា មំ អយំ អយ្យេ សញ្ញគ្ឃិត្វា[2] មយា សហ

អជ្ជាបិ តេន វណ្ណេន អតិវេលំ សញ្ញគ្ឃតិ

ទុតិយាចិហំ អយ្យេ មន្តយាមិ រហោគតោ

អនាមន្តោ បវិសតិ បុព្វេ អប្បដិវេទិតោ

លទ្ធទ្វារោ កតោកាសោ អហិរិកំ អនាទរំ

សហាយំ តេន ទោសេន ឧជ្ឈាហំ ឧការត្តិតោ ។

(៨១១) កុសលោ សព្វនិមិត្តានំ រុតញ្ញូ អាគតាគមោ

ឧប្បាតេ សុបិនេ យុត្តោ និយ្យានេ ច បវេសនេ

---

១ ម. អនុពន្ធោ ។ ២ ម. សញ្ញគ្ឃតោ ។



(៨០៩) (ភរិយា...) ជនទាំងពីរនាក់ គឺព្រះអង្គនឹងឧទ្ទាលកកុមារ ជាសំឡាញ់មានវ័យស្មើគ្នា ធ្លាប់នៅក្នុងបញ្ចាលនគរ ជាបុគ្គលពីរនាក់ កើតក្នុងបញ្ចាលនគរនេះ ក្នុងត្រកូលតែមួយ ឧទ្ទាលកកុមារ មានទុក្ខសុខជាមួយគ្នានឹងព្រះអង្គ ជាប់តាមព្រះអង្គ ក្នុងការត្រាច់ទៅកាន់(ជនបទ) ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចទាំងពួង ដើម្បីព្រះអង្គ ទាំងថ្ងៃទាំងយប់ ព្រះអង្គព្រះរាជទានសំឡាញ់នេះដល់ការក្រទឹក តើព្រោះហេតុដូចម្តេច ។

(៨១០) (ព្រះរាជា...) បពិត្រនាងម្ចាស់ ឧទ្ទាលកកុមារនេះ (ជាប់តាម) ខ្ញុំ ក្នុងការត្រាច់ទៅ (កាន់ជនបទ) ហើយភ្លាភ្លាយជាមួយនឹងខ្ញុំ ក្នុងកាលមុន សូម្បីក្នុងថ្ងៃនេះ ក៏នៅតែសើចភ្លាភ្លាយ ហួសវេលា តាមទំនងនោះដែរ បពិត្រនាងម្ចាស់ ខ្ញុំនៅក្នុងទីស្ងាត់ កំពុងប្រឹក្សាជាមួយនឹងនាងទេវី ឯឧទ្ទាលកុមារខ្ញុំមិនបានហៅ មិនបានឲ្យដំណឹងខ្ញុំជាមុនទេ ស្រាប់តែចូលមក ជាបុគ្គលមានទ្វារបានហើយ មានឱកាសធ្វើរួចហើយ ខ្ញុំឲ្យនូវសំឡាញ់ ជាមនុស្សមិនមានសេចក្តីអៀនខ្មាស មិនអើពើ ដល់ការក្រទឹក ព្រោះទោសនោះឯង ។

(៨១១) (ភរិយា...) ព្រាហ្មណ៍បុរោហិត ជាអ្នកឈ្លាសវៃក្នុងនិមិត្តទាំងពួង ជាអ្នកដឹងនូវសំឡេងនៃសត្វ ជាអ្នកឈ្លាសក្នុងគម្ពីរ ជាអ្នកចេះកាត់សុបិន ជាអ្នកឈ្លាសវៃក្នុងការចេញនិងការចូលផង

ចរេហ ភុម្មន្តលិក្ខស្មឹ    ឧក្កដ្ឋបរសោភិតោ
ព្រាហ្មណំ កេន ហេតុនា    ឆឌ្ឌេសិ ទការក្ខិនោ ។
(៩១២) បរិសាយំ ច មេ អយ្យេ    ទុម្មិលក្ខា ទុមិក្ខតិ
តស្មា អក្ខកំ លុម្ពំ    ឆឌ្ឌាហំ ទការក្ខិនោ ។
(៩១៣) សសមុទ្ទបរិយាយំ    មហឹ សាគរកុណ្ឌលំ
វសុន្ធរំ អាវសសិ    អមច្ចបរិវារិតោ
ចាតុរន្តោ មហារដ្ឋោ    វិជិតាវី មហព្វលោ
បថព្យា ឯករាជាសិ    យសោ តេ វិបុលំ គតោ
សោឡសិត្ថីសហស្សានិ    អាមុត្តមណិកុណ្ឌលា
នានាជនបទា នារី    ទេវកញ្ញូបមា សុភា
ឯវំ សព្វង្គសម្បន្នំ    សព្វកាមសមិទ្ធិនំ
សុខិតានំ បិយំ ទីឃំ    ជីវិតំ អាហុ ខត្តិយ
អថ ត្វំ កេន វណ្ណេន    កេន វា បន ហេតុនា
បណ្ឌិតំ អនុរក្ខន្តោ    បាណំ ចជសិ ទុច្ចជំ ។



លើផែនដីនិងលើអាកាសផង ជាអ្នកណាសៅ ក្នុងចំណោមពួកតត្ត-ឫក្ស ព្រះអង្គព្រះរាជទានព្រាហ្មណ៍បុរោហិត ដល់អារក្សទឹក តើព្រោះហេតុដូចម្តេច ។

(៩១២) (ព្រះរាជា...) បពិត្រនាងម្ចាស់ ព្រាហ្មណ៍បុរោហិត បើកភ្នែកសំឡក់ចំពោះខ្ញុំក្នុងកណ្តាលបរិស័ទ ព្រោះហេតុនោះ ទើបខ្ញុំឲ្យបុរោហិតអាក្រក់ មានចិញ្ចើមក្រញូវ ដល់អារក្សទឹក ។

(៩១៣) (នាងទេវី...) ព្រះអង្គគ្រប់គ្រងនូវផែនដីនេះ មានសមុទ្រព័ទ្ធជុំវិញ ជាកុណ្ឌលរបស់សាគរ ព្រះអង្គមានអាមាត្យចោមរោម ជាឥស្សរៈលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត មានផែនដីច្រើន ជាអ្នកឈ្នះសង្គ្រាម មានពលច្រើន ជាព្រះរាជាឯក លើផែនដី យសរបស់ព្រះអង្គក៏ដល់នូវភាពដ៏ធំទូលាយ មានពួកនារីមកអំពីជនបទផ្សេងៗ ១ ជាស្រីស្នំ ១៦ពាន់ ពាក់គ្រឿងកុណ្ឌលជាវិការៈនៃកែវមណី ល្អល្អដូចស្រីទេពកញ្ញា បពិត្រក្សត្រ អ្នកប្រាជ្ញទាំងឡាយបាន ពោលចំពោះជីវិតដែលវែង បរិបូណ៌ដោយអង្គទាំងពួង សម្រេចនូវសេចក្តីប្រាថ្នាទាំងពួងថា ជាទីស្រឡាញ់របស់សត្វទាំងឡាយ អ្នកដល់នូវសេចក្តីសុខយ៉ាងនេះ កាលបើដូច្នោះ ព្រះអង្គរក្សានូវបណ្ឌិត ទ្រង់លះបង់ព្រះជន្ម ដែលគេលះបង់បានដោយកម្រ តើដោយអំណាចដូចម្តេច ឬក៏ដោយហេតុដូចម្តេច ។

(៥០៦) យោ តេសំ អាគតោ អយ្យោ មម ហត្ថិ មហោសធោ

ញាតិជាតា ឥរស្ស   អណុមត្តម្បិ ទុក្កដំ

សាមេប៉ំ កាម្ហិចិ កាលេ មរណំ មេ ចុរេ សិយា

បុត្តេ ច មេ បបុត្តេ[១] ច សុខាបេយ្យ មហោសធោ

អនាគតំ បច្ចុប្បន្នំ   សព្វមត្ថំ វិបស្សតិ

អនាបរាធកម្មន្តំ   ន ទណ្ឌំ ធារយាមិ តេ ។

(៥០៧) ឥតិ សុណាថ បញ្ចាលា ចូឡនេយ្យស្ស ភាសិតំ

បណ្ឌិតំ អនុកម្បន្តោ   ទារំ ជេតិ ទុក្ខជំ

ធាតុ ភរិយា ភាតុ ច   សខិនោ ព្រាហ្មណស្ស ច

អត្តនោ ចាបិ បញ្ចាលោ   ធម្មំ ជេតិ ជីវិតំ

ឯវំ មហត្ថិយា[២] បញ្ញា   និបុណា សាធុចិន្តិនី

ទិដ្ឋធម្មហិតត្ថាយ   សម្បរាយសុខាយ ចាតិ ។

ទសព្រាហ្មណជាតកំ សត្តមំ ។

១ ម. សោតេ បុត្តេ បបុត្តេច ។ ២ ម. មហិទ្ធិកា ។



(៥០៦) (ព្រះរាជា..) បពិត្រនាងម្ចាស់ តាំងអំពីកាលដែលមហោសធបណ្ឌិត មកតាំងនៅក្នុងកណ្ដាលនៃខ្ញុំ ខ្ញុំក៏មិនដែលឃើញនូវអំពើអាក្រក់ សូម្បីបន្តិចបន្តួចរបស់មហោសធបណ្ឌិតជាអ្នកប្រាជ្ញទេ ជាបើសេចក្ដីស្លាប់គប្បីមានដល់ខ្ញុំមុនក្នុងកាលណាមួយ មហោសធបណ្ឌិត គប្បីញ៉ាំងបុត្រទាំងឡាយ នឹងចៅទាំងឡាយរបស់ខ្ញុំឲ្យសុខ មហោសធបណ្ឌិត តែងពិចារណាឃើញនូវប្រយោជន៍ទាំងពួង ក្នុងអនាគតនឹងបច្ចុប្បន្ន (ព្រោះហេតុនោះ) ខ្ញុំមិនឲ្យនូវមហោសធបណ្ឌិតជាអ្នកមានការងារមិនដែលមានកំហុស (ដល់អាជ្ញាទឹកទេ)។

(៥០៧) (តាំងពី...) ពួកអ្នកនគរបញ្ចាលទាំងឡាយ ចូរស្ដាប់នូវភាសិតនេះរបស់ព្រះបាទចូឡនីយ ព្រះរាជាទ្រង់អនុគ្រោះនូវបណ្ឌិត ស្ដីលះបង់នូវព្រះជននីដែលកើតអំពីព្រះអាត្មាឯង ព្រះរាជាក្នុងបញ្ចាលនគរលះបង់នូវជីវិតរបស់ជន ៦ រូបគឺ ព្រះមាតា១ ព្រះមហេសី១ ព្រះកនិដ្ឋភាតា១ សំឡាញ់១ ព្រាហ្មណ៍១ ព្រះអង្គ១ បញ្ញាជាគុណជាតិដ៏ល្អិត សម្រាប់គិតនូវប្រយោជន៍ដ៏ល្អ មានឫទ្ធិច្រើនយ៉ាងនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ននេះផង ដើម្បីសេចក្ដីសុខក្នុងបរលោកផង ។

ចប់ ទសព្វសជាតក ទី ៨ ។

## បណ្ឌរកជាតកំ

(៨១៦) វិកិណ្ណវាចំ អនិគ្គយ្ហមន្តឹ
អសញ្ញតំ អបរិចក្ខិតារំ[១]
ភយន្តមន្វេតិ សយំ អពោធំ
នាគំ យថា បណ្ឌរកំ សុបណ្ណោ ។
យោ គុយ្ហមន្តំ បរិរក្ខណេយ្យំ
មោហា នរោ សំសតិ ហាសមានោ
តំ ភិន្នមន្តំ ភយមន្វេតិ ខិប្បំ
នាគំ យថា បណ្ឌរកំ សុបណ្ណោ ។
នានុមិត្តោ គរុំ អត្ថំ គុយ្ហំ វេទិតុមរហតិ
សុមិត្តោ ច អសម្ពុទ្ធំ សម្ពុទ្ធំ វា អនត្ថវា ។
វិស្សាសមាបជ្ជិមហំ អចេលំ
សមណោ អយំ សម្មតោ ភាវិតត្តោ
តស្សាហមក្ខឹ វិវរឹ គុយ្ហមត្ថំ
អតីតមត្ថោ កបណំ រុទាមិ ។
តស្សាហំ បរមំ ព្រហ្មេ គុយ្ហំ
វាចញ្ហិមំ នាសក្ខឹ សំយមេតុំ

១ ម. អបរិក្ខិតារំ ។



## បណ្ឌរកជាតក

(៨១៦) (បណ្ឌរកនាគរាជពោលថា) ភ័យទាំងឡាយ រមែងជាប់តាម នូវបុគ្គលដែលមានពាក្យហាច មានមន្តមិនលាក់ទុក ជាអ្នកមិនសង្រួម មិនចេះពិចារណា ជាអ្នកល្ងង់នោះ ដូចជាគ្រុឌចាប់យកនាគឈ្មោះបណ្ឌរកៈ ។ ជនណាក៏ដោយ ប្រាប់មន្ត ដែលគួរលាក់ គួររក្សាទុក ព្រោះសេចក្តីវង្វេង ភ័យរមែងជាប់តាម នូវជននោះដែលមានមន្តបែកធ្លាយនោះដោយឆាប់ ដូចជាគ្រុឌចាប់យកនាគ ឈ្មោះ បណ្ឌរកៈ ។ មិត្តគ្រាន់តែបណ្តោយតាម គេមិនគួរឲ្យដឹងនូវហេតុជាចម្បងដែលគួរលាក់ ទាំងមិត្តល្អ ជាអ្នកមិនយល់ការ ឬយល់ការដែរ តែជាអ្នកមិនប្រព្រឹត្តប្រយោជន៍ (ក៏គេមិនគួរឲ្យដឹងដែរ) ។ អាត្មាអញដល់នូវសេចក្តីទុកចិត្តអាចេល អាចេលនេះ ជាសមណៈ គេលើកតម្កើងហើយ មានចិត្តចំរើនហើយ អាត្មាអញក៏ប្រាប់បើកនូវហេតុដ៏កំបាំងដល់អាចេលនោះ ព្រោះជាអាត្មាអញមានប្រយោជន៍កន្លងហួសហើយខ្ញុំ ក៏កំព្រាម្នាក់ឯង ។ បពិត្រព្រាហ្មណ៍ប្រសើរ ព្រោះខ្ញុំមិនអាចនឹងសង្រួមពាក្យដ៏ប្រសើរកំបាំងនេះ ដល់អាចេលនោះ

តប្បក្ខតោ ហិ ភយមាគតំ មម
អតីតមត្ថោ កបណំ រុទាមិ ។
យោ វេ នរោ សុហទំ មញ្ញមានោ
គុយ្ហមត្ថំ សំសតិ ទុក្កុលីនេ
ទោសា ភយា អថវា រាគរត្តោ
បលិត្តោ ពាលោ អសំសយំ សោ ។
តិរោក្ខវាចោ អសតំ បវិដ្ឋោ
យោ សង្គតីសុ មុទីរេតិ វាក្យំ
អាសីវិសោ ទុម្មុខោត្យាហុ តំ នរំ
អារា អារា សំយមេ តាទិសម្ហា ។
អន្នំ បានំ កាសិកចន្ទនញ្ច
មនាបិត្ថិយោ មាលមុច្ចាទនញ្ច
ឱហាយ គច្ឆាមសេ សព្វកាមេ
សុបណ្ណ បាណូបគតាវ ត្យម្ហា ។
[៥១៧] កោ នីធ តិណ្ណំ គរហំ ឧបេតិ
អស្មិំធ លោកេ បាណភូ នាគរាជ
សមណោ សុបណ្ណោ អថវា ត្វមេវ
កិំការណា បណ្ឌរកំ គហីតោ ។



បានជាភ័យមកដល់ខ្ញុំ អំពីចំណែកនៃអចេលកនោះ ទើបខ្ញុំជាបុគ្គលមានប្រយោជន៍កន្លងហួស កំព្រា ហើយយំ ។ ជនណាសំគាល់នូវបុគ្គលថា មានចិត្តល្អ ប្រាប់នូវការបិទកំបាំង ចំពោះជនមានត្រកូលអាក្រក់ ព្រោះតែទោសាគតិ ភយាគតិ ឬត្រេកអរដោយតណ្ហារាគៈ ជនោះជាមនុស្សល្ងង់ឈ្មោះថា ភ្លាត់ហើយដោយឥតសង្ស័យ ។ ជនណាមានវាចាចេញទៅខាងក្រៅ កប់ចូលក្នុងពួកអសប្បុរស ពោលនូវពាក្យ (កំបាំងរបស់គេ)ក្នុងទីប្រជុំ អ្នកប្រាជ្ញទាំងឡាយ ហៅជនោះថាជាអ្នកមានមាត់អាក្រក់ ដូចអាសិរពិស បុគ្គលគប្បីថយចាកបុគ្គលបែបនោះ ឲ្យឆ្ងាយចេញអំពីចម្ងាយ ។ យើងលះបង់នូវកាមទាំងពួង គឺ បាយ ទឹក សំពត់កន្សែងកាសី ខ្លឹមចន្ទន៍ ពួកស្រីជាទីគាប់ចិត្ត កម្រងផ្កានិងគ្រឿងប្រស់ព្រំ ម្នាលសុបណ្ណៈ យើងសូមដល់នូវលោក (ជាទីពឹង) ស្មើដោយជីវិត ។

(៥១៧) (សុបណ្ណកជសួរថា) ម្នាលនាគរាជ បណ្ដាជនទាំង ៣ នាក់ ក្នុងទីនេះ តើសត្វណានី សមណៈ ឬគ្រុឌ ឬអ្នកឯង គួរដល់នូវសេចក្ដីតិះដៀលបាន ក្នុងលោកនេះ ម្នាលបណ្ឌរកៈ (អ្នកឯងត្រូវខ្ញុំ) ចាប់បាន ព្រោះហេតុដូចម្ដេច ។

(៨០៨) សមណោ ហិ មេ សម្មតត្តោ អហោសិ
បិយោ ច មេ មនសា ភាវិតត្តោ
តស្សាភិសត្តោ វិវរិំ គុយ្ហមត្ថំ
អតីតមត្ថោ កបណំ រុទាមិ ។

(៨០៩) ន ចត្ថិ សត្តោ អមរោ បថព្យា
បញ្ញាវិធា នត្ថិ ន និន្ទិតព្វា
សច្ចេន ធម្មេន ធិតិយា ទមេន
អលព្ភមព្យាហរតី នរោ ឥធ ។
មាតាបិតា បរមា ពន្ធវានំ
នាស្ស តតិយោ អនុកម្បកត្ថិ
តេសម្បិ គុយ្ហំ បរមំ ន សំសេ
មន្តស្ស ភេទំ បរិសង្កមានោ ។
មាតាបិតា ភគិនី ភាតរោ ច
សហាយា វា យស្ស ហោន្តិ សបក្ខា
តេសម្បិ គុយ្ហំ បរមំ ន សំសេ
មន្តស្ស ភេទំ បរិសង្កមានោ ។



(៨០៨) (សេនកៈ.) ព្រោះថាសមណៈ ជាបុគ្គលមានសភាពដែលខ្ញុំរាប់អានហើយ ជាទីស្រឡាញ់ដោយចិត្តរបស់ខ្ញុំ មានខ្លួនចំរើនហើយ ខ្ញុំជាប់ចិត្តបើកការកំបាំងដល់សមណៈនោះ ទើបខ្ញុំជាបុគ្គលមានប្រយោជន៍កន្លងហួស កំព្រាហើយខ្ញុំយំ ។

(៨០៩) (សុវណ្ណកដ..) ធម្មតាសត្វលើផែនដី ឈ្មោះថា មិនស្លាប់ មិនមានទេ ចំណែកនៃបញ្ញា ជាធម្មជាតិដែលបុគ្គលមិនគួរតិះដៀល នរជនក្នុងលោកនេះ រមែងនាំមកនូវគុណវិសេសដែលបុគ្គលមិនគួរបាន ដោយសច្ចៈ១ ដោយសុចរិតធម៌១ ដោយធិតិបញ្ញា១ ដោយការទូន្មានខ្លួនឲ្យត្រូវ១ ។ មាតាបិតា ជាបុគ្គលប្រសើរជាងផៅពង្សទាំងឡាយ សត្វជាគំរប់ ៣ (ក្រៅពីមាតាបិតា) ឈ្មោះថាជាអ្នកអនុគ្រោះដល់បុគ្គលនោះមិនមានទេ បុគ្គលកាលរង្កៀសនូវការបែកធ្លាយនៃមន្ត មិនគប្បីប្រាប់ការស្ងាត់កំបាំងដ៏ក្រៃលែងដល់មាតាបិតា ។ មាតាបិតា បងប្អូនស្រី បងប្អូនប្រុស និងសំឡាញ់ ឬញាតិជាទីពឹងពាក់ របស់បុគ្គលនោះ បុគ្គលកាលរង្កៀសនូវការបែកធ្លាយមន្ត មិនគប្បីប្រាប់ នូវការស្ងាត់កំបាំងដ៏ក្រៃលែង ដល់មាតាបិតា ជាដើមនោះឡើយ ។

ភរិយា ចេ បុរិសំ វជ្ជា   កោមារី បិយភាណិនី
បុត្តរូបយសូបេតា   ញាតិសង្ឃបុរក្ខតា
តស្សាបិ គុយ្ហំ បរមំ ន សំសេ
មន្តស្ស ភេទំ បរិសង្កមានោ ។

(៨៦០) ន គុយ្ហមត្ថំ វិវរេយ្យ   រក្ខេយ្យ នំ យថា និធឹ
ន ហិ បាតុកតោ សាធុ   គុយ្ហោ អត្ថោ បជានតា ។
ថិយា គុយ្ហំ ន សំសេយ្យ អមិត្តស្ស ច បណ្ឌិតោ
យោ ចាមិសេន សំហីរោ ហទយត្ថេនោ ច យោ នរោ ។
គុយ្ហមត្ថមសម្ពុទ្ធំ   សម្ពោធយតិ យោ នរោ
មន្តភេទភយា តស្ស   ទាសភូតោ តិតិក្ខតិ ។
យាវន្តោ បុរិសស្សត្ថំ   គុយ្ហំ ជានន្តិ មន្តិនំ
តាវន្តោ តស្ស ឧព្វេគា   តស្មា គុយ្ហំ ន វិស្សជេ ។
វិវិច្ច ភាសេយ្យ ទិវា រហស្សំ
រត្តឹ គិរំ នាតិវេលំ បមុញ្ចេ



បើទុកជាភរិយា ជាស្រីក្មេង ពោលពាក្យជាទីស្រឡាញ់ មានបុត្រ មានរូប មានយស ដែលពួកញាតិហែហម ជាស្ត្រីរៀបបុរស

(៨៥៩) បុគ្គលកាលបើរៀរនូវការបែកធ្លាយនៃមន្ត មិនគប្បីប្រាប់នូវការសម្ងាត់កំបាំងដ៏ក្រៃលែង ដល់ភរិយានោះទេ ។

(៨៦០) បុគ្គលមិនគប្បីបើកនូវការជាទីកំបាំងទេ គប្បីរក្សានូវការជាទីកំបាំងឲ្យដូចជាកេរ្តិ៍កំណប់ ព្រោះការជាទីកំបាំងដែលបុគ្គលអ្នកដឹងច្បាស់ មិនប្រាប់គេ ជាការប្រពៃ ។ អ្នកប្រាជ្ញ មិនគប្បីនិយាយប្រាប់ការជាទីកំបាំងដល់ស្ត្រី ដល់ជនជាសត្រូវ ដល់ជនឡោះឡប់ដោយអាមិសៈ ដល់ជនលួចគំនិតគ្នា ។ ជនណាញុំាងគេឲ្យដឹងការជាទីកំបាំងដែលគេមិនទាន់ដឹង អ្នកប្រាជ្ញតែងអត់សង្កត់មិនប្រាប់ដល់ជននោះ ព្រោះខ្លាចបែកការដែលគិតទុក ដូចមនុស្សខ្ញុំគេ ។ ជនទាំងឡាយមានចំនួនប៉ុន្មាននាក់ ដឹងនូវមន្តជាការជាទីកំបាំងរបស់បុរស សេចក្តីតក់ស្លុតមានចំនួនប៉ុណ្ណោះ តែងកើតឡើងដល់បុរសនោះ ព្រោះហេតុនោះ អ្នកប្រាជ្ញមិនគប្បីផ្សាយនូវការជាទីកំបាំងឡើយ ។

នៅវេលាថ្ងៃ អ្នកប្រាជ្ញគប្បីនិយាយការជាទីកំបាំង ក្នុងទីដ៏ស្ងាត់
នៅវេលាយប់ មិនគប្បីបញ្ចេញសម្លេង ឲ្យហួសកម្រិត

ឧបស្សុតិកា ហិ សុណន្តិ មន្តំ
តស្មា មន្តោ ខិប្បមុបេតិ ភេទំ ។

(៥២១) យថាបិ អស្ស នគរំ មហន្តំ
អទ្វារកំ អាយសំ ភទ្ទសាលំ[១]
សមន្តខាតបរិខាឧបេតំ
ឯវម្បិ មេ តេ ឥធ គុយ្ហមន្តា ។
យេ គុយ្ហមន្តា អវិកិណ្ណវាចា
ទឡ្ហា សទត្ថេសុ នរា ទុជិវ្ហ
អារា អមិត្តា ព្យវជន្តិ តេហិ
អាសីវិសា វារិវ សត្តសង្ឃា ។

(៥២២) ហិត្វា ឃរំ បព្វជិតោ អចេលោ
នគ្គោ មុណ្ឌោ ចរតិ ឃាសហេតុ
តស្មិំ នុ ខោ វិវរេ គុយ្ហមត្ថំ
អត្ថា ច ធម្មា ច អបេតកម្មា ។
កថំការោ ហោតិ សុបណ្ណរាជ
កិំសីលោ កេន វតេន វត្តំ

១ អដ្ឋកថា ភទ្ទសាលំ ។



ព្រោះថា ពួកជនអ្នកលួចស្តាប់ រមែងឮនូវមន្ត[១] ព្រោះហេតុនោះ មន្តក៏រមែងដល់នូវការបែកធ្លាយដោយឆាប់ ។

(៥២១) ក្រុងប្រកបដោយកំពែងដែកធំមិនមានទ្វារ (ចេញចូលមិនបាន) ល្អើតក៏ដែលប្រកបដោយសាលា ដ៏ចំរើនល្អ ប្រកបដោយគូដែលគេជីកដោយជុំវិញ យ៉ាងណា បុរសមានមន្តដែលខ្ញុំលាក់ទុកក្នុងលោកនេះ ប្រាកដដល់ខ្ញុំយ៉ាងនោះដែរ ម្នាលអ្នកមានអណ្តាតពីរ ពួកជនណាជាអ្នកមានមន្តលាក់ទុក មានវាចាមិនល្ហល្ហាច ជាអ្នកមាំមួនក្នុងប្រយោជន៍របស់ខ្លួន សត្រូវទាំងឡាយ រមែងចៀសចេញឆ្ងាយអំពីពួកជននោះ ដូចពួកនៃសត្វ ចៀសចេញអំពីអាសិរពិស ។

(៥២២) (បណ្ឌារកៈ...) អចេល ជាអ្នកបួសលះបង់ផ្ទះ អាក្រាត ត្រងោល ប្រព្រឹត្ត ព្រោះហេតុតែអាហារ ខ្ញុំបើកបង្ហាញនូវការបិទបាំងដ៏ចំពោះអចេលនោះឯង (ព្រោះហេតុនោះ) បានជាប្រយោជន៍ឃ្លាតចាកអាត្មាខ្ញុំហើយ ។ បពិត្រសុបណ្ណរាជ បុគ្គលធ្វើដូចម្តេច មានសីលដូចម្តេច ប្រព្រឹត្តវត្តដូចម្តេច

១ ពាក្យថា មន្តក្នុងទីនេះ សំដៅយកការប្រឹក្សាគ្នានឹងកិច្ចការស្ងាត់កំបាំង ឬសំដៅយកមន្តអាគម ដែលគេរៀនហើយលាក់ទុក ។ អដ្ឋកថា ។

សមណោ ចរំ ហិត្វា មមាយិតានិ
កាជំការេ សគ្គមុបេតិ ឋានំ ។

(៤៦៣) ហិរិយា តិតិក្ខាយ ទមេន ខន្តិយា[១]
អក្កោធនោ បេសុណិយំ បហាយ
សមណោ ចរំ[២] ហិត្វា មមាយិតានិ
ឋិតាការេ សគ្គមុបេតិ ឋានំ ។

(៤៦៤) មាតាវ បុត្តំ តរុណំ តនុជ្ជំ
សម្ផស្សតា សព្វគត្តំ ផរេតិ
ឯវម្បិ មេ ត្វំ បាតុរហុ ទិជិន្ទ
មាតាវ បុត្តំ អនុកម្បមានោ ។

(៤៦៥) ហន្ទជ្ជ ត្វំ មុញ្ច វទា ទុជិវ្ហ
តយោ ហិ បុត្តា នហិ អញ្ញោ[២] អត្ថិ
អន្តេវាសី ទិន្នកោ អត្រជោ ច
រជស្សុ បុត្តញ្ញតរោ មេ អហោសិ ។

(៤៦៦) ឥច្ចេវ វាក្យំ វិសជ្ជិ សុបណ្ណោ
ភូមឹ បតិដ្ឋាយ ទិជោ ទុជិវ្ហំ
មុត្តជ្ជ ត្វំ សព្វភយាតិវត្តោ

១ ម. ចរមនុបេតោ ។ អដ្ឋកថា ចរំ ។ ២ ម. អញ្ញោ ។



ឈ្មោះថាសមណៈ ប្រព្រឹត្តលះបង់នូវសេចក្តីប្រកាន់ (តណ្ហា)
សមណៈនោះរមែងដូចម្តេច ទើបទៅកាន់ឋានសួគ៌ ។

(៤៦៣) (សុវណ្ណរាជ...) បុគ្គលប្រកបដោយហិរិ ដោយខន្តិ គឺសេចក្តីអត់ធន់ ដោយការទូន្មាន (នូវខ្លួនឯង) ជាអ្នកមិនខឹង លះបង់នូវពាក្យញុះញង់ ទើបឈ្មោះថាសមណៈប្រព្រឹត្តលះបង់នូវសេចក្តីប្រកាន់ ឯសមណៈនោះរមែងយ៉ាងនេះឯង ទើបចូលទៅកាន់ឋានសួគ៌បាន ។

(៤៦៤) (បណ្ឌរកៈ) មាតាឃើញកូនខ្ចី ដែលកើតអំពីខ្លួន ហើយប៉ះពាល់នូវសព៌ាង្គកាយ យ៉ាងណាមិញ បពិត្រលោកជាធំជាងបក្សី លោកជាអ្នកអនុគ្រោះ ប្រាកដដល់ខ្ញុំ ដូចជាមាតា (អនុគ្រោះ) នូវបុត្រ យ៉ាងនោះ ។

(៤៦៥) (សុវណ្ណរាជ...) នែអ្នកមានអណ្តាតពីរ អ្នកចូររួចអំពីការស្លាប់ក្នុងថ្ងៃនេះចុះ ព្រោះថាបុត្តមាន៣ពួក គឺ សិស្ស១ កូនចិញ្ចឹម១ កូនកើតអំពីខ្លួន១ បុត្រក្រៅពីនេះមិនមានឡើយ អ្នកចូរត្រេកអរចុះ អ្នកទុកជាបុត្រណាមួយ របស់ខ្ញុំហើយ ។

(៤៦៦) (អភិសម្ពុទ្ធគាថា) ស្តេចគ្រុឌមានកំណើតពីរ(លុះពោលពាក្យ) យ៉ាងនេះហើយ ក៏ហើរទៅលើផែនដីលែងនាគមានអណ្តាតពីរ ដោយពាក្យថា អ្នកចូររួចក្នុងថ្ងៃនេះ កន្លងនូវភ័យទាំងពួងហើយ

ជលុធពេ ឃោរាហិ ភយាតិតុណ្ណា ។
តាតន្និធិំ យថា កុសលោ ពិសណ្ណា
បិបាសិតានំ រហទោវ សីតោ
វេស្មំ យថា ហិមសីតដ្ដិតានំ
ឯវម្បិ តេ សរណមហំ ភវាមិ ។

(៤៦៧) សទ្ធិំ កត្វា អមិត្តេន អណ្ឌជេន ជលាពុជ
វិវរិយ ទាឋំ សេស្សសិ[១] កុតោ តំ ភយមាគតំ ។

(៤៦៨) សត្តុស្សេវ អមិត្តស្មិំ មិត្តស្មិម្បិ ន វិស្សសេ
អភយា ភយមុប្បន្នំ អបិ មូលានិ កន្តតិ ។
កថំ នុ វិស្សសេ ត្យម្ហិ យេនាសិ កលហោ កតោ
និច្ចយត្តេន ឋាតព្វំ សោ ទិសព្ភិ ន រជ្ជតិ ។
វិស្សាសយេ ន ច នំ វិស្សសេយ្យ
អសង្កិតោ សង្កិតោ ច ភវេយ្យ
តថា តថា វិញ្ញូ បរក្កមេយ្យ
យថា យថា ភាវំ បរោ ន ជញ្ញា ។

១ អដ្ឋកថាយំ បន វិវរិយ ទាឋំ សេស្សសីតិ បាឋោ ទិស្សតិ ។





ព្រោះត្រូវតែខ្ញុំគ្រប់គ្រងក្នុងទីគោកនឹងទឹកហើយ ។
ខ្ញុំជាទីពឹងរបស់អ្នក ដូចជាកោះដ៏ល្អ (ជាទីពឹង) របស់ពួកអ្នកមានភ័យ ឬដូចជាអន្លង់ទឹកត្រជាក់ (ជាប្រយោជន៍) របស់ពួកអ្នកស្រេកទឹក ឬក៏ដូចផ្ទះ (ជាទីត្រូវការ) របស់ពួកបុគ្គលដែលលំបាក ដោយសារសន្សើមត្រជាក់ ។

(៤៦៧) សុបណ្ណរាជ...) ម្នាលអ្នកជាជលាពុជៈ អ្នកធ្វើសេចក្តីស្និទ្ធស្នាល ជាមួយនឹងអណ្ឌជៈជាសត្រូវ ហើយនៅបើកបង្ហាញចង្កូម (ដេកទៀត) ភ័យនឹងមកដល់អ្នក អំពីទីណា ។

(៤៦៨) (បណ្ឌរកៈ ) បុគ្គលត្រូវតែរង្កៀសចាកបុគ្គលជាសត្រូវ មិនត្រូវទុកចិត្តបុគ្គលសូម្បីជាមិត្ត (ព្រោះ) ភ័យតែងកើតឡើងអំពីបុគ្គលដែលមិនគួរភ័យ តែងកាត់សូម្បីឫសគល់ (ផង) ។ បុគ្គលធ្វើការឈ្លោះនឹងជនណា គប្បីទុកចិត្តជននោះដោយរបៀបដូចម្តេចកើត បុគ្គលគប្បីឋិតនៅ ដោយប្រុងប្រយ័ត្នជានិច្ច បុគ្គលនោះ តែងមិនត្រេកអរនឹងសត្រូវ ។

បុគ្គលគប្បីធ្វើឱ្យគេទុកចិត្ត ប៉ុន្តែមិនត្រូវទុកចិត្តគេ បុគ្គលដែលគេមិនរង្កៀសហើយ ប៉ុន្តែគប្បីរង្កៀសនឹងគេ បុគ្គលដទៃ មិនដឹងនូវភាព (របស់ខ្លួន) យ៉ាងណា ។ វិញ្ញូបុរស គប្បីប្រឹងប្រែង ដោយប្រការយ៉ាងនោះ ។ ។

(៤២៩) តេ ហេមវណ្ណា សុខុមាលរូបា
ឧភោ សមា សុជយា បុញ្ញក្ខន្ធា
ឧបាគមុំ ការម្បិយំ (១) អចេលំ
មិស្សីកតា អស្សុកហារ ជាតា ។

(៤៣០) គតោ ហវេ បណ្ឌរកោ អចេលំ
សយមេវ កតកម្មំ កតំ អហេច
មុត្តជ្ជហិ សព្វភយាតិវត្តោ
ន ហិ នូន តុយ្ហំ មនសោ បិយម្ហា ។

(៤៣១) បិយោ ហិ មេ អាសិ សុបណ្ណរាជា
អសំសយំ បណ្ឌរកេន សទ្ធឹ
សោ រាគរត្តោ ច អកាសិ មិត្តំ
បាបកម្មំ សម្បជានោ ន មោហា ។

(៤៣២) ន មេ បិយំ អប្បិយំ វាបិ ហោតិ
សម្បស្សតោ លោកមិមំ បរញ្ច
សុសញ្ញតានញ្ហិ វិយញ្ជនេន
អសញ្ញតោ លោកមិមំ ចរសិ ។
អរិយាវកាសោសិ អនរិយោវ ហោសិ

• អដ្ឋកថាយំ បន ការម្ពិយន្តិ បាឋោ ទិស្សតិ ។



(៤២៩) (អភិសម្ពុទ្ធគាថា) ពួកសត្វទាំងពីរនោះ មានវណ្ណៈដូចជាមាស មានសភាពជាសុខុមាលជាតិស្មើគ្នា មានជ័យដ៏ល្អ មានគំនរនៃបុណ្យ ទៀតផង ដូចជាសេះអាជាម បានចូលទៅកាន់សំណាក់នៃអចេល ឯកតិតកាឃៀយៈ ។

(៤៣០) លំដាប់នោះឯង បណ្ឌរកនាគរាជ បានចូលទៅកាន់សំណាក់នៃអចេលកដោយខ្លួនឯង ហើយពោលពាក្យនេះថា ខ្ញុំរួច (អំពីការសំឡាប់) កន្លងនូវភ័យទាំងពួងក្នុងថ្ងៃនេះហើយ យើងមិនជាទីស្រឡាញ់របស់លោកដោយចិត្តពិតប្រាកដទេ ។

(៤៣១) (អចេល...) សុបណ្ណរាជ ជាទីស្រឡាញ់របស់ខ្ញុំ ជាងបណ្ឌរកនាគរាជនោះ ដោយឥតសង្ស័យ (ទេ) ជាពាក្យពិត ខ្ញុំនោះ ជាអ្នកត្រេកអរដោយរាគៈ ជាអ្នកដឹងច្បាស់ បានធ្វើនូវអំពើអាក្រក់នុ៎ះ មិនមែនព្រោះមោហៈទេ ។

(៤៣២) (បណ្ឌរកៈ...) បព្វជិត កាលឃើញច្បាស់នូវលោកនេះ និងលោកខាងមុខ រមែងមិនមានគំនិតថា វត្ថុជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់ របស់អញទាំងពីរទេ អ្នកជាបុគ្គលមិនសង្រួមប្រព្រឹត្តក្នុងលោកនេះ ដោយភេទ របស់បុគ្គលអ្នកសង្រួមល្អ ។ អ្នកឯងឈ្មោះថាអរិយៈ តែមិនមែនជាអរិយៈទេ

អសញ្ញតោ សញ្ញតសន្និកាសោ
កណ្ហាភិជាតិកោ អនរិយរូបោ
ពាឡំ ពលុំ ទុព្ភិកំ អទាសិ ។

[៥៣៣] អទុដ្ឋស្ស តុវំ ទុព្ភិ ទុព្ភី ច បរិសុណោ ចសិ
ឯតេន សច្ចវជ្ជេន មុទ្ធា តេ ផលតុ សត្តធា ។

[៥៣៤] តស្មា ហិ មិត្តានំ ន ទុព្ភិតព្វំ
មិត្តទុព្ភា ហិ បាបិយោ នត្ថិ អញ្ញោ
អាសិត្តសត្តោ និហតោ បថព្យា
ឥន្ទស្ស វាក្យេន ហិ សំវរោ ហតោតិ ។

បណ្ឌរកជាតកំ អដ្ឋមំ ។

## សម្ពុលាជាតកំ

[៥៣៥] កា វេធមានា គិរិកន្ទរាយំ
ឯកា តុវំ តិដ្ឋសិ សញ្ញតូរុ
បុដ្ឋាសិ មេ បាណិបមេយ្យមជ្ឈេ
អក្ខាហិ មេ នាមញ្ច ពន្ធវេ ច ។





អ្នកមិនសង្រួម តែមានភាពហាក់ដូចជាអ្នកសង្រួម មានជាតិខ្មៅ មានសភាពមិនប្រសើរ បានប្រព្រឹត្តខុសអំពើដ៏លាមក ទុច្ចរិតច្រើនយ៉ាង ។

[៥៣៣] ម្នាលអ្នកប្រទូស្ត អ្នកជាបុគ្គលប្រទូស្តមិត្ត ដែលមិនបានប្រទូស្តនឹងឯង ជាអ្នកញុះញង់ផង ដោយពាក្យសច្ចៈនេះ សូមឲ្យក្បាលរបស់អ្នកឯង បែកជា ៧ ភាគ ។

[៥៣៤] (អភិសម្ពុទ្ធគាថា) ព្រោះហេតុនោះ បុគ្គលមិនគួរប្រទូស្តមិត្រទាំងឡាយឡើយ ព្រោះថា សភាវៈដទៃ លាមកជាងការប្រទូស្តមិត្ត មិនមានទេ ពស់ដែលអ្នកសង្រួម ត្រូវសកុណស័ក្តិសប្រហារផ្តួល ក៏ធ្លាក់ចេញអំពីផែនដី វិនាស តាមពាក្យរបស់ឥន្ទកដ៏ប្រសើរ ។

ចប់ បណ្ឌរកជាតក ទី ៨ ។

## សម្ពុលាជាតក

[៥៣៥] (ទានវៈសួរថា)[១] ម្នាលនាងមានភ្លៅល្អ នាងឈ្មោះអ្វី ញ័ររលើរត្រោះនៃភ្នំ ឈរនៅតែម្នាក់ឯង ម្នាលនាងមានស្រយោះត្រង់កណ្តាលគួរកំណត់ដោយដៃ (បាតដៃ) យើងសួរហើយ នាងចូរប្រាប់ ឈ្មោះនិងផៅពង្ស ដល់យើង ។

[១] តស្សាសាទ្ធា ។

ទុកាសយំ វត ម្ហេ    សីហព្យគ្ឃនិសេវិតំ

តាក ចុម្ពសិ កល្យាណី    កស្ស ក ត្វំ សុមជ្ឈិមេ

អភិភុំមេ តំ កន្ទេ    ធាននិហំ ឧមត្តុ ភេ ៗ

(៥៣៦) យោ បុត្តោ កាសិកដស្ស    សោត្ថិសេនោតិ តំ វិទូ

តស្សាហំ សម្ពុលា ភរិយា    ឯវំ ជានាហិ ទានវ

អភិភុំមេ កន្ទន្តេ    សម្ពុលាហំ ឧមត្តុ ភេ ៗ

វេទេហបុត្តោ កន្ទន្តេ    វនេ វសតិ អាតុរោ

តមហំ រោគសម្មត្តំ    ឯកា ឯកំ ឧបដ្ឋហំ ៗ

អហញ្ច វនមុញ្ឆាយ    មធុមំសំ មិគាតិលំ

យទាហរាមិ តំ ភក្ខោ    តស្ស នូនជ្ជ ឆាតិ ៗ



ម្នាលនាងកល្យាណី នាងជាអ្វី ម្នាលនាងមានអវយវៈកណ្ដាលដ៏ល្អ នាងជាធីតា របស់អ្នកណា នាងញ៉ាំងព្រៃជាទីកោយ ដែលសីហៈនិងខ្លាធំអាស្រ័យនៅ ឲ្យត្រេកត្រៀង ម្នាលនាងដ៏ចំរើន យើងឈ្មោះទានវៈ សូមសំពះនាង សូមនមោចំពោះនាង ៗ

(៥៣៦) (នាងសម្ពុលាឆ្លើយថា) អ្នកណាជាបុត្រ របស់ព្រះរាជាក្នុងដែនកាសី អ្នកទាំងឡាយស្គាល់អ្នកនោះថា ព្រះនាម សោត្ថិសេន ខ្ញុំឈ្មោះនាងសម្ពុលា ជាភរិយា របស់ព្រះរាជបុត្រ ព្រះនាមសោត្ថិសេននោះ បពិត្រទានវៈ លោកចូរដឹងយ៉ាងនេះចុះ បពិត្រលោកដ៏ចំរើន ខ្ញុំឈ្មោះសម្ពុលា សូមសំពះ សូមនមោចំពោះលោក ៗ បពិត្រលោកដ៏ចំរើន ព្រះរាជបុត្ររបស់ព្រះរាជាវិទេហៈ ប្រឈួនក្តៅក្រហាយ គង់នៅក្នុងព្រៃ ខ្ញុំជាស្ត្រីម្នាក់ឯង បំរើព្រះរាជបុត្រដែលមានរោគបៀតបៀន មួយអង្គឯងនោះ ៗ មិនតែប៉ុណ្ណោះ ខ្ញុំ (ត្រាច់ទៅ) ដើម្បីស្វែងរកផ្លែឈើ ក្នុងព្រៃ នាំមកនូវទឹកឃ្មុំនិងសាច់ដែលជាសម្ភាររបស់ម្រឹគណា (ស្វាមីរបស់ខ្ញុំ) មានទឹកឃ្មុំនិងសាច់ ជាសម្ភាររបស់ម្រឹគនោះ ជាអាហារ(កាលបើមិនមានអាហារទេ សរីរៈ)របស់ស្វាមីខ្ញុំនោះ នឹងក្រៀមក្រំមិនខាន ក្នុងថ្ងៃនេះ ដោយពិត ៗ

[៤៣៧] កឹ វនេ កដុបុត្តេន   វកុវេន ការិស្សសិ

សម្ពុលេ បរិចិណ្ណេន   អហំ ភត្តា ភរាមិ តេ ។

សោកដ្ឋាយ ទុរត្តាយ   កឹ រូបំ វិជ្ជតេ មម

អញ្ញំ បរិយេស ភទ្ទន្តេ   អភិរូបតរំ មយា ។

ឯហំមិ តិរិតារុក្ខេ   ភរិយា មយ្ហំ ចតុស្សតា

តាសំ ត្វំ បវរា ហោហិ   សព្វកាមសមិទ្ធិនី ។

ទនុ តារការណ្ណាភេ   យង្កិញ្ចិ មនសិច្ឆសិ

សព្វំ បចុរំ មយ្ហំ   រមស្សុ ច មយា សហ ។

នោ ចេ តុវំ មហេសយ្យំ   សម្ពុលេ ការយិស្សសិ

អលំ ត្វំ ពាកកសាយ   ឧណ្ហា ភត្តា ករិស្សសិ ។

តញ្ច សត្តជដោ លុទ្ទោ   កណ្ឌោក បរិសាធកោ

វនេ ជាតំ អបស្សន្តិ   សម្ពុលំ អគ្គហី កុដេ ។

អដ្ឋប្បា បិសាចេន   លុទ្ទេនាមិសចក្ខុនា

សា ច សត្តុវសម្បត្តា   បតិមេវានុសោចតិ ។



(៤៣៧) (ទានវៈ...) ម្នាលនាងសម្ពុលា នាងធ្វើ (នូវការមូលមិត្ត) នឹងព្រះរាជបុត្រ ប្រាណ្ឌូនក្តៅក្រហាយ ដែលកេងកោះកាល់នៅក្នុងព្រៃ ធ្វើអ្វី ខ្ញុំសូមជាភស្តារបស់នាង ។

(នាងសម្ពុលា...) ខ្ញុំកប់ជាមានរូបដូចម្តេចកើត ព្រោះខ្ញុំជាស្ត្រីមានសេចក្តីសោកគ្របសង្កត់ មានខ្លួនដ៏លំបាក បពិត្រលោកដ៏ចំរើន លោកចូរស្វែងរកស្ត្រីឯទៀត ដែលល្អជាងខ្ញុំចុះ ។

(ទានវៈ...) នាងចូរមកចុះ ចូរឡើងភ្នំនេះ ប្រពន្ធរបស់ខ្ញុំមាន ៤០០នាក់ នាងចូរជាស្ត្រីដ៏ប្រសើរជាងគេទាំងនោះ ចូរសម្រេចកាមសេចក្តីប្រាថ្នា គ្រប់យ៉ាង ។ ម្នាលនាង មានពន្លឺដូចផ្កាយ នាងប្រាថ្នាក្នុងចិត្ត ចំពោះវត្ថុណាមួយ វត្ថុទាំងអស់នោះរបស់ខ្ញុំ មានច្រើនក្រៃ ចូរនាងត្រេកអរ ជាមួយនឹងយើង ក្នុងថ្ងៃនេះចុះ ។ ម្នាលនាងសម្ពុលា បើនាងមិនធ្វើនូវភាពជាមហេសីរបស់ខ្ញុំទេ នាងនឹងជាអាហារក្នុងពេលព្រឹក នឹងជាចំណីរបស់ខ្ញុំអំពីព្រហាម ។

ចំណែកទានវៈ មានក្តិសក់៧ជាន់ ជាជាតិកាក្រក់ មានចង្កូម ជាភក្សិនូវបាស បានចាប់នាងសម្ពុលានោះ ត្រង់ដើមដៃ ដែលមិនឃើញនូវទីពឹង ក្នុងព្រៃ ។ នាងសម្ពុលា ដែលបិសាចកាក្រក់ មានភ្នែកប្រកបដោយអាមិសគ្របសង្កត់ ជាស្ត្រីលុះក្នុងអំណាច នៃសត្រូវហើយ ក៏សោកសៅ រកតែស្វាមីជា

ន មេ ឥទំ តថា ទុក្ខំ យំ មំ ខាទេយ្យ រក្ខសោ

យញ្ច មេ អយ្យបុត្តស្ស មនោ ហេស្សតិ អញ្ញថា ។

ន សន្តិ ទេវា បវសន្តិ នូន

ន ហិ នូន សន្តិ ឥធ លោកបាលា

សហសា ករោន្តានមសញ្ញតានំ

ន ហិ នូន សន្តិ បដិសេធិតារោ ។

(៤៣៨) ឥត្ថីនមេសា បវរា យសស្សិនី

សន្តា សមា អគ្គិរិវុគ្គតេជា

តញ្ចេ តុវំ រក្ខសាទេសិ ភក្ខំ

មុទ្ធា ច ហិ សត្តធា តេ ផលេយ្យ

មា ត្វំ ទហិ មុញ្ច បតិព្វតាយ ។

(៤៣៩) សា ច អស្សមមាគញ្ឆិ បមុត្តា បុរិសាទកា

និឌ្ឌំ ផលិនំ សកុណី[១] គតសិង្គំវ អាលយំ ។

សា តត្ថ បរិទេវេសិ រាជបុត្តី យសស្សិនី

សម្ពុលា ឧតុមត្តក្ខា វនេ នាថំ អបស្សន្តី ។

១ ម. នីឡំវ សកុណី ។



អាក្រក់ស៊ីខ្ញុំដោយហេតុណា ហេតុនេះ មិនមែនជាទុក្ខនៃខ្ញុំទេ ចិត្តនៃព្រះស្វាមី នៃអយ្យបុត្ត របស់ខ្ញុំ ទៅជាបការៈដទៃ (ប្រែចិត្ត) ដោយហេតុណា ហេតុនោះ (ទើបជាទុក្ខនៃខ្ញុំ) ។

មិនមានពួកទេវតា នៅប្រចាំប្រទេសដោយពិត ទាំងពួកទេវតា អ្នករក្សាលោក ក្នុងលោកនេះ ក៏មិនមានដោយពិត ទេវតា ទាំងឡាយ អ្នកហាមឃាត់ នូវពួកជនជាអ្នកមិនសង្រួម ជាអ្នក ធ្វើដោយការកំហែង ក៏មិនមានដោយពិត ។

(៤៣៨) (សក្កៈ...) ស្ត្រីនេះជាស្ត្រីមានយស ជាស្ត្រីប្រសើរជាងស្ត្រី ទាំងឡាយ ជាស្ត្រីស្ងប់ស្ងៀម មានកិរិយាដ៏ស្មើ មានតេជះ ក្រៃលែងដូចជាភ្លើង បើអ្នកឯងស៊ីនាងកញ្ញានោះ ក្បាលអ្នកឯង នឹងបែកជា ៧ ភាគមិនខាន អ្នកឯងកុំស៊ី(នូវនាងសម្ពុលា) អ្នកឯង ចូរលែងនាងទៅ ព្រោះនាង ជាស្ត្រីគោរពប្តី ។

(៤៣៩) (អភិសម្ពុទ្ធគាថា) នាងសម្ពុលារួចអំពីបុរិសាទ បានត្រឡប់ មកកាន់អាស្រមវិញ ដូចជាមេបក្សីដែលកូនតូច ហើរមកកាន់ទ្រនំ ឬដូចជាមេគោ មកកាន់សំណាក់ (ដែលមានកូនទៅបាត់ហើយ) ។ ព្រះរាជបុត្រីនោះ ជាស្ត្រីមានយស ព្រះនាមសម្ពុលា មានភ្នែក ស្រវាំង ព្រោះរដូវ កាលមិនឃើញព្រះស្វាមី ជាទីពឹង ក្នុង ព្រៃហើយ ក៏ទ្រង់ព្រះកន្សែង ក្បែរអាស្រមនោះថា

សមណេ ព្រាហ្មណេ វន្ទេ សម្បន្នចរណេ ឥសេ

រាជបុត្តំ អបស្សន្តី តុម្ហេ សរណំ គតា ។

វន្ទេ សីហេ ច ព្យគ្ឃេ ច យេ ច អញ្ញេ វនេ មិគា

រាជបុត្តំ អបស្សន្តី តុម្ហេ សរណំ គតា ។

តិណលតានិ ឱសធ្យោ បព្វតានិ វនានិ ច

រាជបុត្តំ អបស្សន្តី តុម្ហេ សរណំ គតា ។

វន្ទេ ឥន្ទីវរីសាមំ រត្តិនក្ខត្តមាលិនី[១]

រាជបុត្តំ អបស្សន្តី តុម្ហេ សរណំ គតា ។

វន្ទេ ភគីរសី គង្គំ សវន្តីនំ បដិគ្គហំ

រាជបុត្តំ អបស្សន្តី តុម្ហេ សរណំ គតា ។

វន្ទេ អហំ បព្វតរាជ- (សេដ្ឋំ) ហិមវន្តំ សិលុច្ចយំ

រាជបុត្តំ អបស្សន្តី តុម្ហេ សរណំ គតា ។

(៨៤០) អតិសាយំ វតាគច្ឆិ រាជបុត្តី យសស្សិនី

កេន នុជ្ជ សមាគច្ឆិ កោ តេ ទិយតរោ មយា ។

---

១ ម. រត្តិនក្ខត្តមាលិនី ។



ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំពួកសមណព្រាហ្មណ៍ និងឥសីទាំងឡាយ ដែលមានការប្រព្រឹត្តិបរិបូណ៌ ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំនូវពួកសីហៈ ខ្លាធំ និងពួកម្រឹគដទៃ ក្នុងព្រៃ ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំ ស្មៅ វល្លិ ឈើជាឱសថ ភ្នំ និងព្រៃទាំងឡាយ ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំនូវរាត្រីបៀបផ្កាយកុះករ ដែលមានពណ៌ដូចផ្កាកញ្ជ្រៀត ខ្ញុំសូមដល់នូវលោកជាទីពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំនូវស្ទឹងឈ្មោះភាគីរសី ជាទីទទួលនូវស្ទឹងទាំងឡាយដែលហូរមក ខ្ញុំសូមដល់នូវលោកជាទី ពឹង ។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំនូវភ្នំហិមពាន្ត ជាស្តេចភ្នំដ៏ប្រសើរ ខ្ញុំសូមដល់នូវលោកជាទីពឹង ។

[៨៤០] (វេស្សន្តរ...) រាជបុត្រី ជាស្ត្រីមានយស មកក្នុងវេលាល្ងាចម្ល៉េះ តើថ្ងៃនេះ នាងជួបប្រទះនឹងអ្នកណាហ្ន៎ អ្នកណា ជាទីស្រឡាញ់ របស់នាង ជាងខ្ញុំ ។

(៤៦១) ឥទំ ខោ ហំ អនាគតំ គហិតា តេន សត្តុនា
ន មេ ឥទំ តថា ទុក្ខំ យំ មំ ខាទេយ្យ រក្ខសោ
យញ្ច មេ អយ្យបុត្តស្ស មនោ ហេស្សតិ អញ្ញថា ។

(៤៦២) ចោរីនំ ពហុពុទ្ធីនំ យាសុ សច្ចំ សុទុល្លភំ
ថីនំ ភាវោ ទុរាជានោ មច្ឆស្សេវោទកេ គតំ ។

(៤៦៣) តថា មំ សច្ចំ ពាលេតិ ពាលយិស្សតិ ចេ មមំ
យថាហំ នាភិជានាមិ អញ្ញំ បិយតរំ តយា
ឯតេន សច្ចវជ្ជេន ព្យាធិ តេ វូបសម្មតុ ។

(៤៦៤) យេ កុញ្ជរា សត្តសតា ឧឡារា
រក្ខន្តិ រត្តិន្ទិវមុយ្យុតាវុធា
ធនុគ្គហានញ្ច សតានិ សោឡស
កថំវិធេ បស្សសិ ភទ្ទេ សត្តវោ ។

(៤៦៥) អលង្កតាយោ បទុមុត្តរត្តចា
វិរាគិតា បស្សតិ ហំសគគ្គរា



(៤៦១) (នាងសម្ពុលា...) ខ្ញុំម្ចាស់ដែលសត្រូវនោះចាប់បាន ក៏បានពោលពាក្យនេះថា យក្សទំពាស៊ីខ្ញុំម្ចាស់ដោយហេតុណា ហេតុនោះមិនមែនជាទុក្ខនៃខ្ញុំម្ចាស់ទេ ក្រែងតែព្រះហឫទ័យព្រះអយ្យបុត្ររបស់ខ្ញុំម្ចាស់ទៅជាប្រការដទៃ ដោយហេតុណា ហេតុនោះ (ទើបជាទុក្ខនៃខ្ញុំម្ចាស់) ។

(៤៦២) (សោត្ថិសេន...) ពាក្យសច្ចៈ ក្នុងពួកស្រីចោរ មានមាយាច្រើន គេរកបានដោយក្រណាស់ ភាពនៃពួកមារយាទរបស់ស្ត្រីទាំងឡាយ គេដឹងបានដោយក្រ ដូចដំណើរនៃត្រីក្នុងទឹក ។

(៤៦៣) (នាងសម្ពុលា...) ខ្ញុំម្ចាស់ មិនធ្លាប់ស្គាល់នូវបុគ្គលដទៃជាទីស្រឡាញ់ជាងព្រះអង្គយ៉ាងណា បើ(ដំណើរ) របស់ខ្ញុំម្ចាស់(នោះ) ជាសច្ចៈ យ៉ាងនោះ សូមសច្ចៈ រក្សាព្រះអង្គទាំងរក្សានូវខ្ញុំម្ចាស់ ដោយពាក្យសច្ចៈនេះ សូមព្យាធិរបស់ព្រះអង្គស្ងប់រម្ងាប់ ។

(៤៦៤) (តាបស...) ដំរីទាំងឡាយច្រើនប្រមាណ៧០០ មានកម្លាំង ដែលរយោធាប្រកបហើយ ពួកខ្មាន់ធ្នូមួយពាន់ប្រាំមួយរយ តែងរក្សាទាំងយប់ទាំងថ្ងៃ ម្នាលនាងដ៏ចំរើន តើនាងនៅឃើញពួកសត្រូវ ដូចម្ដេច ។

(៤៦៥) (នាងសម្ពុលា...) ស្វាមី ឃើញពួកស្ត្រី ដែលតាក់តែងកាយ មានសម្បុរស្បែកល្អ ដូចស្រទាប់ផ្កាឈូក មានចង្កេះរៀវ មានសំឡេងដូចហង្ស

តាសំ សុណិត្វា មិគគីតកុជិតំ
ឥច្ឆាមិ ទេ តាត កថា យថា បុរេ ។
សុវណ្ណសង្កច្ចធរា សុវិគ្គហា
អលង្កតា មានុសិយច្ឆរូបមា
សេនោបិយា តាត អនិន្ទិតង្គិយោ
ខត្តិយកញ្ញា បដិលោភយន្តិ តំ ។
សចេ អហំ តាត តថា យថា បុរេ
បតី អនុញ្ញាយ ពុធា វនេ ករេ
សម្មានយេ មំ ន ច មំ វិមានយេ
ឥតោបិ ទេ តាត តតោ វរំ សិយា ។
យមន្នបានេ វិបុលស្មិំ ឱហិតេ
នារី វិមដ្ឋាភរណា អលង្កតា
សព្វង្គុបេតា(១) បតិនោ ច អប្បិយា
អវជ្ឈ កស្សា មរណំ តតោ វរំ ។

១ ឱ. បច្ចុបេតា ។



ទ្រង់ព្រះសណ្ដាប់នូវចម្រៀងនិងពិណប្រគំផ្សេងៗគ្មានគួរពប់ របស់ពួកស្ត្រីទាំងនោះ បពិត្រព្រះបិតា ដល់ខ្ញុំនេះ ព្រះស្វាមីរបស់ខ្ញុំម្ចាស់ មិនប្រព្រឹត្តដូចកាលមុន យ៉ាងនោះទេ ។ បពិត្រព្រះបិតា ពួកស្ត្រីមានរូបល្អ ទ្រទ្រង់នូវប្រដាប់សម្រាប់កដោះជាវិការៈនៃមាស តាក់តែងខ្លួន ជាស្ត្រីមនុស្ស ដូចស្ត្រីទេពអប្សរ ជាទីស្រឡាញ់នៃព្រះរាជព្រះនាម សោភ័ណ ជាស្ត្រីមានរាងកាយ ឥតខ្ចោះមិនបាន ជាខត្តិយកញ្ញា តែងប្រលោមព្រះរាជានោះ ។ បពិត្រព្រះបិតា ប្រសិនបើខ្ញុំម្ចាស់ចិញ្ចឹមព្រះស្វាមីនោះ ដោយការស្វែងរកនូវផ្លែឈើក្នុងព្រៃ ដូចក្នុងកាលមុនយ៉ាងនោះទៀត ព្រះស្វាមីគប្បីរាប់អានខ្ញុំម្ចាស់ ទាំងមិនមើលងាយខ្ញុំម្ចាស់ទេ បពិត្រព្រះបិតា ព្រោះហេតុនោះ (ព្រៃ) របស់ខ្ញុំម្ចាស់ (នោះឯង) ប្រសើរជាងរាជសម្បត្តិ ក្នុងក្រុងពារាណសីនេះ ។ នារីណា (កើតក្នុងផ្ទះត្រកូល) មានបាយនិងទឹកច្រើនបរិបូណ៌ ដែលគេតាក់តែងហើយ ជាស្ត្រីមានគ្រឿងប្រដាប់ដ៏ល្អក្រៃលែង តាក់តែងខ្លួនប្រកបដោយអង្គគ្រប់យ៉ាង តែមិនជាទីស្រឡាញ់របស់ប្ដី បានសំឡាប់ (ខ្លួន) ហើយ សេចក្ដីស្លាប់របស់នារីនោះ ប្រសើរជាងការរស់នៅ ដោយកសាងនោះ ទៅទៀត ។

អយំ ចេ ធលិដ្ឋា ការុណា អនាថិយា
ការាធុតិយា ចរិតោ ច សា បិយា
សព្វត្ថុបេតាយបិ អចរិយាយ
អយាមេវ សេយ្យោ ការុណាបិ យា បិយា ។

(៤៦៦) សុទុល្លភិត្ថី បុរិសស្ស យា ហិតា
ភត្តិត្ថិយា ទុល្លភោ យោ ហិតោ ច
ហិតា ច តេ សីលវតី ភរិយា
ជនិន្ទ ធម្មំ ចរ សម្ពុលាយ ។

(៤៦៧) សចេ តុវំ វិបុលេ លទ្ធភោគេ
ឥស្សាវតិណ្ណា មរណំ ឧបេសិ
អហញ្ច តេ ភទ្ទេ ឥមា រាជកញ្ញា
សព្វេ តេ វចនករា ភវាម ។

សម្ពុលាជាតកំ នវមំ ។

## ភណ្ឌុតិណ្ឌុកជាតកំ

(៤៦៨) អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា ។



បើស្ត្រីណា ទំលក់ កំព្រា មិនមានបុរសពឹងពាក់ មានតែការខ្វល់ ជាគំរប់ពីរ តែស្ត្រីនោះជាទីស្រឡាញ់របស់ប្តី ស្ត្រីណានោះកំព្រា តែជាទីស្រឡាញ់(របស់ប្តី) ស្ត្រីនេះឯងប្រសើរ ជាងស្ត្រីដែល ប្រកបដោយទ្រព្យគ្រប់យ៉ាង តែមិនជាទីស្រឡាញ់ (របស់ប្តី) ។

(៤៦៦) (តាបស...) ស្ត្រីណាជាគុណរបស់បុរស ស្ត្រីនោះរកបាន ក្រៃក្រៃលែង ភស្តាណាជាគុណរបស់ស្ត្រី ភស្តានោះរកបាន ដោយក្រ ម្នាលបពិត្រជនជាធំជាងជន ភរិយារបស់អ្នក ជាគុណ (ដល់អ្នក) ផង ជាស្ត្រីមានសីលផង អ្នកចូរប្រព្រឹត្តធម៌ចំពោះនាងសម្ពុលា ។

(៤៦៧) (ព្រះរាជាសោត្ថិសេន...) ម្នាលនាងសម្ពុលា បាននូវភោគៈធំ ហើយដ៏ច្រើន បើនាងនឹងផុតពាក់សេចក្តីច្រណែន ដល់នូវមរណៈ អញនឹងពួករាជកញ្ញាទាំងអស់ របស់នាងនេះ នឹងធ្វើតាមពាក្យ របស់នាង ។

ចប់ សម្ពុលាជាតក ទី ៩ ។

## ភណ្ឌុតិណ្ឌុកជាតក

(៤៦៨) (ភណ្ឌុតិណ្ឌុកទេវតាពោធិសត្វពោលថា) សេចក្តីមិនប្រមាទ ជាទីបាយឲ្យបាន នូវព្រះនិព្វានឈ្មោះអមតៈ សេចក្តីប្រមាទ ជា ផ្លូវនៃសេចក្តីស្លាប់ ពួកជនអ្នកមិនប្រមាទ ឈ្មោះថា មិនស្លាប់ ពួកជនណា ជាអ្នកប្រមាទ ពួកជននោះដូចជាស្លាប់ហើយ ។

មទា បមាទោ ជាយេថ  បមាទា ជាយតេ ខយោ
ខយា បទោសា ជាយន្តិ  មា មទោ ភរតូសភ ។
តេ ហិ ខត្តិយា ផីតា  អត្ថំ រដ្ឋំ បមាទិនោ
អថោបិ គាមិនោ គាមា  អនគារា អគារិនោ ។
ខត្តិយស្ស បមត្តស្ស  រដ្ឋស្មឹ រដ្ឋវឌ្ឍន
សព្វេ ភោគា វិនស្សន្តិ  រញ្ញោ តំ វុច្ចតេ អឃំ ។
នេស ធម្មោ មហារាជ  អតិវេលំ បមជ្ជសិ
ឥទ្ធំ ផីតំ ជនបទំ  ចោរា វិទ្ធំសយន្តិ នំ ។
ន តេ បុត្តា ភវិស្សន្តិ  ន ហិរញ្ញំ ន ធានិយំ
រដ្ឋេ វិលុប្បមានម្ហិ  សព្វភោគេហិ ជីយសិ ។
សព្វភោគបរិជិណ្ណំ  រាជានំ វាបិ ខត្តិយំ
ញាតិមិត្តា សុហជ្ជា ច  ន តំ មញ្ញន្តិ មន្តិយំ[១] ។

១ ម. ឆារិយំ ។ ឱ. វុឌ្ឍិយំ ។



សេចក្តីប្រមាទ រមែងកើតឡើង ព្រោះសេចក្តីស្រវឹង ការអស់ទៅ (នៃញាតិជាដើម) រមែងកើតឡើងព្រោះសេចក្តីប្រមាទ សេចក្តីប្រទូស្តទាំងឡាយ រមែងកើតឡើង ព្រោះការអស់ទៅ (នៃញាតិជាដើម) បពិត្រព្រះអង្គដ៏ប្រសើរ ជាងភារតៈ (ក្សត្រ) ព្រះអង្គកុំប្រមាទឡើយ ។ ពួកក្សត្រិយ៍ច្រើនអង្គ មានសេចក្តីប្រមាទ ញុំាងសេចក្តីចំរើននិងញុំាងដែនឲ្យវិនាស ចំណែកពួកមេស្រុក អ្នកស្រុក អ្នកបួស គ្រហស្ថ ក៏វិនាស ។ បពិត្រព្រះករុណា ព្រះអង្គញុំាងដែនឲ្យចំរើន ពោរៈទាំងអស់ក្នុងដែនរបស់ក្សត្រជាអ្នកប្រមាទ រមែងវិនាស សេចក្តីវិនាសនោះ ជាទុក្ខរបស់ព្រះរាជា ។ បពិត្រមហារាជ សេចក្តីប្រមាទនេះ មិនមែនជាធម៌ (របស់ពួកព្រះរាជាបុរាណទេ) ព្រះអង្គប្រមាទហួសប្រមាណ ពួកចោរកំចាត់នូវដែនបរិបូណ៌ សម្បូណ៌ទាំងនោះ ។ ពួកបុត្ររបស់ព្រះអង្គមិនមាន ទ្រព្យប្រាក់ក៏មិនមាន ទ្រព្យស្រូវក៏មិនមាន កាលបើគេប្លន់ស្រុក (យ៉ាងនេះ) ព្រះអង្គនឹងសាបសូន្យចាកភោគៈគ្រប់យ៉ាង ។ ពួកញាតិមិត្រនឹងសំឡាញ់ រមែងមិនទទួលដឹង នូវក្សត្រនោះ ដែលជាព្រះរាជាសាបសូន្យចាកភោគៈទាំងពួង ជាបុគ្គលដែលគួរទទួលដឹងទេ ។

ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
តមេវ ឧបជីវន្តិ ន តំ មញ្ញន្តិ មន្តិយំ ។
អសំវិហិតកម្មន្តំ ពាលំ ទុម្មន្តិ មន្តិនំ
សិរី ជហាតិ ទុម្មេធំ ជិណ្ណំវ ឧរគោ តចំ ។
សុសំវិហិតកម្មន្តំ កាលុដ្ឋាយឹ អតន្ទិតំ
សព្វេ ភោគាភិវឌ្ឍន្តិ គាវោ សឧសភាមិវ ។
ឧបស្សុតឹ មហារាជ រដ្ឋេ ជនបទេ ចរ
តត្ថ ទិស្វា ច សុត្វា ច តតោ តំ បដិបជ្ជសិ ។

(៨៤៩) ឯវំ វេទេតុ បញ្ចាលោ សង្គាមេ សរមប្បិតោ
យថាហមជ្ជ វេទេមិ កណ្ដកេន សមប្បិតោ ។

(៨៥០) ជិណ្ណោ ទុព្វលចក្ខូសិ ន រូបំ សាធុ បស្សសិ
កឹ តត្ថ ព្រហ្មទត្តស្ស យន្តំ មគ្គេយ្យ កណ្ដកោ ។



ពួកពលដំរី ពួកសេនា ពលរថ ពលថ្មើរជើងនឹងពួកកម្មករ ដែលអាស្រ័យចិញ្ចឹមជីវិតនឹងព្រះរាជានោះឯង ក៏មិនទទួលដឹងនូវព្រះរាជាដែលគួរទទួលដឹងនោះ ។ សិរីនិយសសម្បត្តិ រមែងលះបង់នូវបុគ្គលពាល អ្នកមិនចាត់ចែងនូវការងារ មានគំនិតអាក្រក់ អាប់ឥតប្រាជ្ញា ដូចជាពស់លះបង់នូវសំណកចាស់ ។ ភោគៈទាំងអស់ រមែងចំរើនដល់បុគ្គលអ្នកចាត់ចែងការងារដោយល្អ ក្រោកឡើងតាមកាល ជាអ្នកមិនខ្ជិលច្រអូស ដូចជាគោប្រព្រឹត្តទៅមួយអន្លើដោយគោឧសភ ។ បពិត្រមហារាជ សូមព្រះអង្គយាងទៅកាន់ទីជាទីចាំស្ដាប់ ក្នុងជនបទ ក្នុងដែន លុះទតឃើញនឹងទ្រង់ព្រះសណ្ដាប់ ក្នុងដែននោះហើយ ក៏យកការណ៍ តាមជាកិច្ចនោះ តាមដំណើរនោះ ។

(៨៤៩) (បុរសចាស់ទាក់ជើងថា) ខ្ញុំអញត្រូវបន្លាមុតហើយ វេទនាក្នុងថ្ងៃនេះយ៉ាងណា សូមឲ្យព្រះបាទបញ្ចាល ត្រូវសរក្នុងសង្គ្រាម ហើយវេទនាយ៉ាងនោះដែរ ។

(៨៥០) (បុរោហិតសួរថា) អ្នកជាមនុស្សចាស់ មានភ្នែកទុព្វល មើលរូបមិនឃើញដោយស្រួលទេ បន្លាមុតអ្នកឯង ដោយហេតុណា (ទោស) របស់ព្រះរាជាព្រហ្មទត្តចំពោះហេតុនោះ តើដូចម្ដេច ។

(៨៨១) ពហ្វេ ព្រហ្មទត្តស្ស យោហំ[១] មគ្គស្មិ ព្រាហ្មណ

អរក្ខិតា ជានបទា អធម្មពលិនា ហតា ។

រត្តិញ្ហិ ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា

រដ្ឋស្មិំ កូដរាជស្ស ពហុ អធម្មិកោ ជនោ ។

ឯតាទិសេ ភយេ ជាតេ ភយដ្ដា តាត មាណវ

និល្វេន តានិ កុព្វន្តិ វនេ អាហត្វ[២] កណ្ណកំ ។

(៨៨២) កទាស្សុ នាមយំ រាជា ព្រហ្មទត្តោ មរិស្សតិ

យស្ស រដ្ឋស្មិំ ជិយ្យន្តិ អបតិកា កុមារិកា ។

(៨៨៣) ទុព្ភាសិតញ្ហិ តេ ជម្មិ អនត្ថបទកោវិទេ

កុហិំ រាជា កុមារីនំ ភត្តារំ បរិយេសតិ ។

(៨៨៤) ន មេ ទុព្ភាសិតំ ព្រហ្មេ កោវិទត្ថបទា អហំ

អរក្ខិតា ជានបទា អធម្មពលិនា ហតា ។

---

១ អដ្ឋកថាយំ ចរ សោហន្តិ បាឋោ ទិស្សតិ ។ ២ ម. អាហត្វា ។



(៨៨១) (បុរសចាស់...) ម្នាលព្រាហ្មណ៍ កូនហេតុនេះជារបស់ព្រះរាជាព្រហ្មទត្ត មានច្រើន (បានជា) ខ្ញុំនោះ (ឮក៏) កូនស្រី (មានបញ្ញា) ព្រោះពួកអ្នកជនបទ ព្រះរាជាមិនរក្សា ឲ្យគេបៀតបៀនដោយពលិកម្ម (ស្នួយសារអាករ) មិនប្រកបដោយធម៌ ។ កូនវេលាយប់ ពួកចោរស៊ី(ប្លន់) កូនវេលាថ្ងៃ ពួកអ្នកកាន់ការ បៀតបៀនស៊ី ក្នុងដែនរបស់ព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌ មានច្រើន ។ ម្នាលអ្នក កាលបើភ័យបែបនេះ កើតហើយ មនុស្សទាំងឡាយដែលត្រូវភ័យគ្របសង្កត់ តែងនាំយកឈ្លួចព្នាក្នុងព្រៃ មកធ្វើជាទីសម្រាប់ពីងពួន ។

(៨៨២) (ស្ត្រីខ្វិតម្នាក់ពោល) ពួកកុមារី ជាស្ត្រីគ្មានប្ដី រហូតចាស់ ក្នុងដែននៃព្រះរាជាព្រហ្មទត្តណា កាលណាហ្ន៎ ព្រះរាជាព្រហ្មទត្តនេះ នឹងស្លាប់ទៅ ។

(៨៨៣) (បុរសពិតយាត់ថា) នែនាងលាមក ជាស្ត្រីមិនឈ្លាស ក្នុងប្រយោជន៍នៃសេចក្ដីចំរើន ពាក្យនាង ជាពាក្យអាក្រក់ ព្រះរាជានឹងស្វែងរកប្ដីឱ្យពួកនាងកុមារី ក្នុងទីណា ។

(៨៨៤) (ស្ត្រីចាស់...) នែព្រាហ្មណ៍ ពាក្យរបស់ខ្ញុំមិនអាក្រក់ទេ ខ្ញុំជាស្ត្រីឈ្លាសវៃ ក្នុងប្រយោជន៍ ព្រោះពួកអ្នកជនបទ ស្ដេចមិនរក្សា ឲ្យគេបៀតបៀន ដោយសារស្នួយអាករ មិនប្រកបដោយធម៌ ។

រត្តិញ្ហិ ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា
រដ្ឋស្មឹ កូដរាជស្ស ពហុ អធម្មិកោ ជនោ
ទុជ្ជីវេ ទុក្ករេ ទារេ កុតោ ភត្តា កុមារិយា ។

(៨៨៥) ឯវំ សយតុ បញ្ចាលោ សង្គាមេ សត្តិយា ហតោ
យថាយំ កបណោ សេតិ ហតោ ផាលេន សាលិយោ ។

(៨៨៦) អធម្មេន តុវំ ជម្ម ព្រហ្មទត្តស្ស កុជ្ឈសិ
យោ ត្វំ សបសិ រាជានំ អបរជ្ឈិត្វាន អត្តនោ ។

(៨៨៧) ធម្មេន ព្រហ្មទត្តស្ស អហំ កុជ្ឈាមិ ព្រាហ្មណ
អរក្ខិតា ជានបទា អធម្មពលិនា ហតា ។
រត្តិញ្ហិ ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា
រដ្ឋស្មឹ កូដរាជស្ស ពហុ អធម្មិកោ ជនោ ។
សា នូន បុន រេ បក្កា វិកាលេ ភត្តមាហរិ
ភត្តហារី អបេក្ខន្តោ ហតោ ផាលេន សាលិយោ ។





គ្រប់វេលាយប់ ពួកចោរស៊ី (ប្លន់) គ្រប់វេលាថ្ងៃ ពួកអ្នកដកការបៀតបៀនស៊ី គ្រប់ផែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន កាលបើស្ត្រីរស់នៅដោយលំបាក ចិញ្ចឹមប្រពន្ធបានដោយលំបាក តើពួកនាងកុមារីបានប្ដីអំពីណា ។

(៨៨៥) (អ្នកខ្ជួរជេរ) គោឈ្មោះសាលិយៈនេះ ត្រូវចាំលមុតហើយ ដេកស្រពោនយ៉ាងណា សូមឲ្យព្រះរាជា ក្រុងបញ្ចាល ត្រូវគេសម្លាប់ដោយលំពែងក្នុងសង្គ្រាម ដេកយ៉ាងនោះចុះ ។

(៨៨៦) (ចុកចាក...) នែបុរសលាមក អ្នកណាខុសខ្លួនឯង ហើយផ្ដាសាព្រះរាជា អ្នក(នោះ) ឈ្មោះថាទីធំចាំការព្រះរាជព្រហ្មទត្ត ដោយហេតុមិនត្រូវតាមធម៌ទេ ។

(៨៨៧) (អ្នកខ្លួ...) ម្នាលព្រាហ្មណ៍ ខ្ញុំទីធំចាំការព្រះរាជព្រហ្មទត្ត ដោយហេតុត្រឹមត្រូវតាមធម៌ (ព្រោះថា) ពួកអ្នកជនបទ ស្ដេចមិនរក្សា ទ្រង់បៀតបៀនដោយសួយសារអាករ មិនប្រកបដោយធម៌ ។ គ្រប់វេលាយប់ ពួកចោរស៊ី គ្រប់វេលាថ្ងៃ ពួកអ្នកដកការបៀតបៀនស៊ី គ្រប់ផែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន ។ ស្ត្រីជាអ្នកនាំបាយមកនោះ ប្រាកដជាដាំម្ដងទៀត បានជានាំបាយមកក្នុងវេលារសៀល ខ្ញុំក៏ពុំរកមើលនូវស្ត្រីអ្នកនាំបាយមក គោឈ្មោះសាលិយៈ ក៏ត្រូវចាំលមុត ។

(៤៥៨) ឥមិំ ហរញ្ញកំ បញ្ចាលោ សង្គាមេ អសិតា ហតោ
យថា ហាយបដ្ឋំ បហារោ ទិវញ្ញ ទេ បវត្តិតំ ។

(៤៥៩) យំ បស្សុ ឱរំ ឧទ្ធតិ បស្សុ ផលំ វិហឹសតិ
តំ តត្ថ ព្រហ្មទត្តស្ស យំ សោ ការយោគ ករំ ។

(៤៦០) តារយ្ហោ ព្រហ្មា បញ្ចាលោ ព្រហ្មទត្តស្ស កត្តិនោ
អវក្កិតា ផាលបតា អនុម្ភលិតា ហតា ។
វត្ថិញ្ញិ ភោគ ទានន្តិ និត ទានន្តិ កុណ្ឌិយា
វត្ថុស្មិំ ក្ដុដកជស្ស ពហុ អនម្មិតោ ជលោ ។
ចណ្ឌោ អភក្ខិតា តាវ យំ តុវេ ធ ខុហាមសេ
តំ ធាតិ អជ្ជ សោហាម ទិវតា មេ ហុបទ្ទុតា ។

(៤៦១) ឥមិំ កាន្តុំ បញ្ចាលោ វិមុត្តា វិប្បលុត្តកំ
យថា យំ កាបណា តាវ វិមុត្តា បរិតាវតិ ។



(៤៥៨) (អ្នកស្រែកទឹកដោះជូរនិយាយថា) ក្នុងថ្ងៃនេះ ខ្ញុំឲ្យ (ត្រូវបោះបា) ដាក់ចាន់ទឹកដោះរបស់កញ្ញាក៏បប់ទៅ យ៉ាងណា សូមឲ្យព្រះរាជាបញ្ចាលនគរ ត្រូវគេសំឡាប់ដោយដាវក្នុងសង្គ្រាម វិនាសយ៉ាងនោះចុះ ។

(៤៥៩) (ចុះហេតុ...) សត្វចិញ្ចឹមនេះ ដាក់ចោលខ្ទះទឹកដោះ សត្វចិញ្ចឹមបៀតបៀនផ្លែផល អ្នកជំរំការិតបៀតបៀនឃើញ ដោយហេតុណា កិច្ចសម្លាប់ របស់ព្រះរាជាព្រហ្មទត្តនឹងហេតុនោះ ។

(៤៦០) (អ្នកខ្ទះទឹកដោះ...) ចាស់ព្រាហ្មណ៍ ព្រះរាជាបញ្ចាលនគររបស់កិត្តិកុលព្រហ្មទត្ត ពួកអ្នកជនក៏សៀរហើយ ព្រោះថា ពួកអ្នកជនបទ ព្រះរាជាមិនរក្សា ត្រូវគេបៀតបៀនដោយស្លួយសាករ មិនប្រកបដោយធម៌ ។ ក្នុងវេលាយប់ ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នកផ្ដល់ការបៀតបៀនស៊ី ក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន ។ មេភា កាច ចាំង យើងមិនបានខ្ទះទឹកដោះណាក្នុងកាលមុន ក្នុងថ្ងៃនេះ ផង្សៃនេះ ពួកយើងក៏ត្រូវពួកកងខ្ទះសអ្នកក្រុងទឹកដោះមកបំបាន់ ទើបខ្ទះទឹកដោះនោះ ។

(៤៦១) (ពួកក្មេងអ្នកស្រុកនិយាយថា) មេគោក្រោ ដាស់កូនក្រាក់ប្រាស់នេះ ស្វះស្វែង យ៉ាងណា សូមឲ្យព្រះរាជាបញ្ចាលនគរ ព្រាត់ប្រាសចាកលំនៅ ស្ដេចក្នុងការ យ៉ាងនោះចុះ ។

(៩៦២) យំ បសុ បសុបាលស្ស សម្ពមេយ្យ រវេយ្យ វា

កោនីធ អបរាធត្ថិ ព្រហ្មទត្តស្ស រាជិនោ ។

(៩៦៣) អបរាធោ មហាព្រហ្មេ ព្រហ្មទត្តស្ស រាជិនោ

អរញ្ញា ជាតបោសា អជន្មពលិតា ហតា ។

រត្តិញ្ហិ ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា

រដ្ឋស្មឹ កូដរាជស្ស ពហុ អធម្មិកោ ជនោ

កថំ ចេ អសំ កោសន្តា ទីរតា ឥញ្ញកេ ចជា ។

(៩៦៤) ចិរំ ខជ្ជតុ បញ្ចាលោ ហតោ យុទ្ធេ សបុត្តកោ

យថា ហមជ្ជ ខជ្ជាមិ គាមិកេហិ អរញ្ញជោ ។

(៩៦៥) ន សព្វភូតេសុ វិធេន្តិ រក្ខំ

រាជានោ មណ្ឌុក មនុស្សលោកេ

នេត្តាវតា រាជា អធម្មចារី

យំ តាទិសំ ជីវមទេយ្យុ ធង្កា ។





(៩៦២) (បុរោហិត ..) សត្វចិញ្ចឹម របស់អ្នកគង្វាលសត្វចិញ្ចឹម ស្ទុះ ទ្រហោក្តី ស្រែកក្តី ដោយហេតុណា កំហុសដូចម្តេច របស់ព្រះរាជា ព្រហ្មទត្ត ក្នុងហេតុនេះ ។

(៩៦៣) (ពួកកង្កែបក្រែក...) បពិត្រមហាព្រាហ្មណ៍ កំហុសរបស់ ព្រះរាជាព្រហ្មទត្ត (មានពិត) ព្រោះថា ពួកអ្នកដែនរបស់ ព្រះរាជា មិនរក្សា ទ្រង់បៀតបៀនដោយសួយសារាករ មិនប្រកបដោយ ធម៌ ។ ក្នុងវេលាយប់ ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នកយកការ បៀតបៀនស៊ី ក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌ មានច្រើន ហេតុដូចម្តេចហ្ន៎ ក្មួយគោរបស់យើងក៏ក្តៅក្រហាយ នាំ ប្រយោជន៍ដល់ព្រាហ្មណ៍ ត្រៀមដុតសំឡាប់ ។

(៩៦៤) (កង្កែបពោល) អញជាសត្វកើតក្នុងព្រៃ ត្រូវពួកអ្នកក្នុងស្រុក ចាប់ស៊ីក្នុងថ្ងៃនេះយ៉ាងណា សូមឲ្យស្តេចបញ្ចាលនោះ ព្រមទាំង បុត្រត្រូវគេកាប់ក្នុងចម្បាំងដាច់ខ្ទេចខ្ទី យ៉ាងនោះចុះ ។

(៩៦៥) (បុរោហិត...) នែកង្កែប ព្រះរាជាទាំងឡាយ ក្នុងមនុស្ស- លោក មិនបានតាំងទុកការរក្សាក្នុងពួកសត្វទាំងពួងទេ ពួកក្អែក ស៊ីនូវសត្វទាំងរស់ដូចជាឯង ដោយហេតុណា ព្រះរាជាមិន ឈ្មោះថាមិនប្រព្រឹត្តធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះ ។

(៥៦៦) អធម្មរូបោ វត ព្រហ្មចារី
អនុប្បិយំ ភាសសិ ខត្តិយស្ស
វិលុម្បមានាយ បុថុប្បជាយ
បូជេសិ រាជំ បរមប្បមត្តំ ។
សចេ ឥទំ ព្រហ្មេ សុរជ្ជកំ សិយា
ផីតំ រដ្ឋំ ផុសិតំ វិប្បសន្នំ
ភុត្វា ពលិំ អគ្គបិណ្ឌញ្ច កាកា
ន មាទិសំ ដំសេយ្យ ជន្តុន្តិ ។

គណ្ឌតិណ្ឌុជាតកំ ទសមំ ។

## តស្សុទ្ទានំ

កិំឆន្ទ កុម្ភ ជយទ្ទិស ឆទ្ទន្ត
អថ បណ្ឌិតសម្ភវ សិរកបិ
ទករក្ខស បណ្ឌរនាគវរោ
អថ សម្ពុល តិណ្ឌុកទេវសុតោ ។

តឹសនិបាតំ និដ្ឋិតំ ។



(៥៦៦) (កន្ទុប...) ម្នាលព្រហ្មចារី ដែលមានសភាពមិនប្រកបដោយធម៌សោះ លោកនិយាយតែពាក្យសរសើរ ចំពោះក្សត្រិយ៍ កាលបើប្រជាជនជាច្រើន ដែលព្រះរាជាជិះជាន់ អ្នកនៅតែបូជា ចំពោះព្រះរាជា ជាអ្នកមានសេចក្ដីប្រមាទក្រៃលែង ។ ម្នាលព្រាហ្មណ៍ ប្រសិនបើ ដែននេះមានអ្នកការពារល្អ រីកចំរើនដែនស្ដុកស្ដម្ភ មានក្សេមក្សាន្តជ្រះថ្លា ពាំងក្អែកក៏ស៊ីនូវនំពុយដ៏ប្រសើរ ជាគ្រឿងបូជា (របស់មនុស្ស) ពួកក្អែកមិនគប្បីស៊ីសត្វតិច សំគ្រាកដូចជាខ្ញុំទេ ។

ចប់ គណ្ឌតិណ្ឌុជាតក ទី ១០ ។

## ឧទ្ទាននៃតឹសនិបាតនោះគឺ

កិំឆន្ទជាតក ១ កុម្ភជាតក ១ ជយទ្ទិសជាតក ១ ឆទ្ទន្តជាតក ១ សម្ភវជាតក ១ មហាកបិជាតក ១ ទករក្ខសជាតក ១ នាគដ៏ប្រសើរឈ្មោះ បណ្ឌរកៈ ១ សម្ពុលាជាតក ១ តិណ្ឌុកជាតក ១ ។

ចប់ តឹសនិបាត ។

# ចត្តាលីសនិបាតជាតកំ

## តេសកុណជាតកំ

(៨៦៧) វេស្សន្តរំ តំ បុច្ឆាមិ សកុណ ភទ្ទមត្ថុ តេ
រជ្ជំ ការេតុកាមេន កឹសុ កិច្ចំ កតំ វរំ ។

(៨៦៨) ចិរស្សំ វត មំ តាតោ កំសោ ពារាណសិគ្គហោ
បមត្តោ អប្បមត្តំ មំ បិតា បុត្តំ អចោទយិ ។

(៨៦៩) បឋមេនេវ វិតថំ កោធំ ហាសំ និវារយេ
តតោ កិច្ចានិ ការេយ្យ តំ វតំ អាហុ ខត្តិយ ។
យំ ត្វំ តាត តបេ កម្មំ បុព្វេ កតមសំសយំ
រត្តោ ទុដ្ឋោ ច យំ កយិរា ន តំ កយិរា តតោ បុន ។

# ចត្តាលីសនិបាតជាតក

## តេសកុណជាតក

(៨៦៧) (ព្រះបាទព្រហ្មទត្តសួរថា) ម្នាលសកុណៈ អញសូមសួរអ្នក ឈ្មោះវេស្សន្តរៈ សេចក្តីចំរើន ចូរមានដល់អ្នក កិច្ចដូចម្តេចដែល អញជាអ្នកប្រាថ្នា ដើម្បីសោយរាជ្យ ធ្វើហើយប្រសើរ ។

(៨៦៨) (មៀមឈ្មោះវេស្សន្តរៈទូលថា) យូរណាស់ហើយ បិតារបស់ខ្ញុំព្រះអង្គ ព្រះនាម កំសៈ ជាអ្នកសោយក្រុងពារាណសី ប្រទែសប្រហែស ជាបិតាដាស់តឿន ចំពោះទូលខ្ញុំព្រះអង្គ ជាបុត្រមិនប្រហែស ។

(៨៦៩) (ខ្ញុំទូលថា) មុនដំបូង ព្រះរាជាត្រូវហាមឃាត់នូវពាក្យវៀនវៃ សេចក្តីក្រោធនឹងការសើច លំដាប់នោះ គប្បីធ្វើនូវកិច្ចទាំងឡាយ បពិត្រក្សត្រ បុគ្គលគប្បីធ្វើកិច្ចទាំងឡាយ បណ្ឌិតពោលនូវការដែលខ្ញុំព្រះអង្គក្រាបទូលនោះ ជាវត្ត ។ បពិត្រព្រះបិតា កម្មចំពោះមហាតបៈក្តៅក្រហាយណា ដែលព្រះអង្គធ្វើហើយ ក្នុងកាលមុន ជាសំស័យ ព្រះអង្គត្រេកត្រអាលក្តី ប្រទូស្តក្តី ធ្វើនូវកម្មណា ព្រះអង្គមិនគួរធ្វើ នូវកម្មនោះ តទៅទៀតទេ ។

ខត្តិយស្ស បមត្តស្ស រដ្ឋស្មិំ រដ្ឋវឌ្ឍន
សព្វេ ភោគា វិនស្សន្តិ រញ្ញោ តំ វុច្ចតេ អឃំ ។
សិរី ច តាត លក្ខី ច បុច្ឆិតា ឯតទព្រវុំ
ឧដ្ឋានវីរិយេ ពោសេ រមាមហំ អនុសុយ្យកេ ។
ឧស្សុយ្យកេ ទុហទយេ បុរិសេ កម្មទុស្សកេ
កាឡកណ្ណី មហាភាគ រមតិ ចក្កភញ្ជនី ។
សោ ត្វំ សព្វេសុ សុហទយោ សព្វេសំ រក្ខិតោ ភវ
អលក្ខិំ នុទ មហារាជ លក្ខ្យា ភវ និវេសនំ ។
ស លក្ខី ធិតិសម្បន្នោ បុរិសោ ហិ មហគ្គតោ
អមិត្តានំ កាសិបតិ មូលំ អគ្គញ្ច ឆិន្ទតិ ។
សក្កោបិ ហិ ភូតបតិ ឧដ្ឋានេ នប្បមជ្ជតិ
ស កល្យាណេ ធិតិំ កត្វា ឧដ្ឋានេ កុរុតេ មនោ ។



បពិត្រព្រះអង្គអ្នកញុំាងដែនឲ្យចំរើន កាលបើក្សត្រិយ៍ ប្រមាទ ហើយ ភោគសម្បត្តិទាំងអស់ក្នុងដែន នឹងវិនាសទៅ សេចក្ដីវិនាស នោះ លោកពោលថាជាទុក្ខ របស់ព្រះរាជា ។ បពិត្រព្រះបិតា បុគ្គលមានសិរី នឹងបុគ្គលមានបុណ្យ ដែលសួរចំពោះសេដ្ឋីស្រេចហើយ បានពោលពាក្យនេះថា ខ្ញុំត្រេកអរ ចំពោះបុរសមានសេចក្ដីព្យាយាម មានសេចក្ដីប្រឹងប្រែង ជាអ្នកមិនប្រណែន ។ បពិត្រមហារាជ បុគ្គលកាឡកណ្ណី ជាអ្នកកាច់បំបាក់នូវចក្រកុសល តែងត្រេកអរ ក្នុងបុរសជាអ្នកប្រណែន មានចិត្តអាក្រក់ ជាអ្នកប្រទូស្តចំពោះ កល្យាណកម្ម ។ សូមព្រះអង្គ មានព្រះទ័យល្អចំពោះពួកជនទាំង ពួង សូមព្រះអង្គ រក្សានូវពួកជនទាំងពួង បពិត្រមហារាជ សូម ព្រះអង្គបណ្ដេញនូវបុគ្គលឥតបុណ្យចេញ សូមព្រះអង្គយកបុគ្គល មានបុណ្យ មកដាក់ក្នុងលំនៅវិញ ។ បពិត្រព្រះអង្គជាម្ចាស់ដែន កាសី ព្រោះថា បុរសមានបុណ្យ ប្រកបដោយប្រាជ្ញា តាំងនៅ ក្នុងសេចក្ដីព្យាយាម រមែងកាត់បង់នូវគល់នឹងចុង នៃសត្រូវទាំង ឡាយបាន ។ បពិត្រព្រះអង្គ ជាម្ចាស់នៃមនុស្ស សូម្បីព្រះ ឥន្ទ្រក៏មិនប្រហែស ក្នុងការព្យាយាមដែរ លោកធ្វើនូវការព្យាយាម ចំពោះកម្មដ៏ល្អ តាំងធ្វើព្រះហឫទ័យ ក្នុងការព្យាយាម (ជាដរាប) ។

កន្ទា ចិតកោ នេក   សាធិកំ ហោន្តិ តាទិសោ

ទុជ្ជហោ អប្បមជ្ជោ   អនុតិដ្ឋន្តិ នេវតា ។

សោ អប្បមត្តោ អកុទ្ធោ   តាត កិច្ចានិ ការយ

ភយមស្ស សកិច្ចេសុ   ជាលសោ រត្តកេ សុចិ ។

កត្តៅកេ វត្តុបជា   បសាទ អនុសាសនិ

អលំ មេត្តេ សុខាវេក្ខុ   អមិត្តានំ ទុខាយ ច ។

(៨៧០) សក្កិ កុរី កុណ្ឌាលប៉ិ   មញ្ញសិ   ចន្ទកន្នរី

វន្ទិ តាតេកុតាមេន   កឹសុ កិច្ចំ ករិតំ វ៉ំ ។

(៨៧១) នេរំ តាត ចនកានិ   យត្ត សព្វំ   ចកិន្ទិតំ

អលទ្ធស្ស ពលោ លាភោ   លទ្ធស្ស ជានុរក្ខណា ។

អមច្ចេ តាត ជានាហិ   ធីរេ អត្ថស្ស កោវិទេ



ក្ដួកត្តូ ក្ដួកច័រ (ក្រញ) ក្ដួកទៅរោ មានការីរៈការស្រើយនឹងព្រះរាជា ដែលមានអំណរនឹងបុគ្គលប្បយ៉ាងនោះ ក្ដួកទៅកៅកែតការបរិថ (រក្សា) នូវព្រះរាជា ជាអ្នកវិញ្ញាណមិនប្រហែស ។ បពិត្រព្រះបិតា ព្រះអង្គជាអ្នកមិនប្រហែស មិនក្រោធ សូមអ្នកនូវកិច្ចទាំងឡាយចុះ សូមព្រះអង្គប្រើប្រែកិច្ចទាំងឡាយរបស់ព្រះអង្គ បុគ្គលខ្ជិលច្រអូស រមែងមិនបាននូវសេចក្ដីសុខទេ ។ នោះជាផ្លូវ កុំបណ្ដោយដល់ ទុំឯងជាអនុសាសនី (របស់ព្រះអង្គ) ព្រះរាជា ការប្រព្រឹត្តយ៉ាងនេះ ទើបការពារនឹងពួកមិត្រឲ្យបានសុខផង ការពារពួកសត្រូវឲ្យបានទុក្ខផង ។

(៨៧០) (ព្រះរាជា...) នារទកុណាលបក្សី អ្នកពោល (ខ្លឹមសារបានប្រាជ្ញា) អ្នកជាគន្ធព្វនៃមហាសេនគុត្ត ឈ្មោះខន្ធៈ នឹង (ម្ដាយបិតាប្រាជ្ញា) កិច្ចដូចម្ដេចដែលយើងត្រូវធ្វើដើម្បីសោយរាជ្យ ធ្វើហើយប្រសើរ ។

(៨៧១) (សាវិការឈ្មោះកុណាលបក្សី ) បពិត្រព្រះបិតា ប្រយោជន៍នឹងសេចក្ដីសុខទាំងអស់ រាំងនៅក្នុងបុគ្គល បទនោះមានការយ៉ាងនឹការពារនូវរបស់ ដែលមិនធ្លាប់បាន ១ រក្សានូវរបស់ដែលបានមកហើយ ១ ។ បពិត្រព្រះបិតា សូមព្រះអង្គជ្រាប នូវអាមាត្យទាំងឡាយ ដែលមានប្រាជ្ញា ឈ្លាសវៃ ចំពោះប្រយោជន៍

---

• ទៀមជើងទ្រូង ឈ្មោះក្នុងរាជនៈជា មហាសេនគុត្ត ។

អនក្ខាកិតវេ តាត អសោណ្ឌេ អវិនាសកេ ។

យោ ច តាត រក្ខេយ្យ ធនំ យញ្ចេវ តេ សិយា

សូតោវ រថំ សង្គណ្ហេ សោ តេ កិច្ចានិ ការយេ ។

សុសង្គហិតន្តជនោ សយំ វិត្តំ អវេក្ខិយ

និធិញ្ច ឥណទានញ្ច ន ករេ បរបត្តិយា ។

សយំ អាយំ វយំ ជញ្ញា សយំ ជញ្ញា កតាកតំ

និគ្គណ្ហេ និគ្គហារហំ បគ្គណ្ហេ បគ្គហារហំ ។

សយំ ជានបទំ អត្ថំ អនុសាស រថេសភ

មា តេ អធម្មិកា យុត្តា ធនំ រដ្ឋញ្ច នាសយុំ ។

មា ច វេគេន កិច្ចានិ ការេសិ[1] ការយេសិ វា

វេគសា ហិ កតំ កម្មំ មន្ទោ បច្ឆានុតប្បតិ ។

[1] ម. ករោសិ ។



បពិត្រព្រះបិតា សូមព្រះអង្គជ្រាបនូវអាមាត្យទាំងឡាយ ដែលមិនលេងល្បែងភ្នាល់ មិនផឹកស្រា មិនជាអ្នកលេងស៊ីផឹក មិនជាអ្នកបំផ្លាញទ្រព្យ ។ បពិត្រព្រះបិតា អាមាត្យណា គប្បីរក្សានូវទ្រព្យរបស់ព្រះអង្គ ដែលមាន ដូចនាយសារថីប្រុងប្រយ័ត្ននូវរថ អាមាត្យនោះ ព្រះអង្គគប្បីឲ្យធ្វើនូវកិច្ចការទាំងឡាយរបស់ព្រះអង្គ ។ សូមព្រះអង្គ ដែលមានជនទាំងពួងសង្គ្រោះល្អ ត្រួតត្រាមើល នូវព្រះរាជទ្រព្យដោយព្រះអង្គឯង មិនគួរធ្វើនូវកំណប់ទ្រព្យនិងការឲ្យជាបំណុល ដោយជឿអ្នកដទៃ ។ ព្រះអង្គគប្បីជ្រាបនូវសេចក្តីចំរើននិងសេចក្តីវិនាស ដោយព្រះអង្គឯង គប្បីជ្រាបនូវកិច្ចការដែលបានធ្វើ និងមិនបានធ្វើ ដោយព្រះអង្គឯង គប្បីសង្កត់សង្កិននូវបុគ្គលដែលគួរសង្កត់សង្កិន គប្បីលើកតំកើង នូវបុគ្គលដែលគួរលើកតំកើង ។ បពិត្រព្រះអង្គ ជាធំលើរថ សូមព្រះអង្គប្រៀនប្រដៅនូវប្រយោជន៍ដល់អ្នកជនបទ ដោយព្រះអង្គឯង ពួករាជបុរសអ្នកប្រកបការមិនត្រឹមត្រូវតាមធម៌ សូមកុំឲ្យញ៉ាំងទ្រព្យនិងដែន របស់ព្រះអង្គឲ្យវិនាស ។ មួយទៀត សូមព្រះអង្គកុំធ្វើ ឬប្រើគេឲ្យធ្វើនូវកិច្ចទាំងឡាយដោយរួសរាន់ ព្រោះមនុស្សល្ងង់តែងក្តៅក្រហាយរឿយៗ ក្នុងកាលខាងក្រោយ ចំពោះការងារ ដែលខ្លួនធ្វើដោយរួសរាន់ ។

នាគេ អតិសយេ ទន្តេ　សុវណ្ណខចិតភោជិតំ

ភោជនា ហិ ពហុ ជីវា　កុលា អកុលតំ គតា ។

មា តាត បិស្សកេទ្ធិតិ　អនត្ថាយ បការយំ

វត្ថុំ បុរិសាធមំ　នាគេ គាសិ ធុត្តប្បយោ ។

អបេតលោមហំសស្ស　វញ្ញា តាតានុសាសនោ

សព្វេ ភោគា វិនស្សន្តិ　វញ្ញា តំ វុឌ្ឍេ អយំ ។

គន្ធេ តេ វត្ថុបជា　បិសាចំ ទុសាសធិ

ធម្មស្សុតាធិ បុញ្ញកាបេ　អសោណ្ណោ អវិជាសតោ

សីលវន្តស្ស ចយាកជ　ទុស្សីលោ វិជិតាតិកោ ។

(៨៧៦)អមុជ្ជិម្ហា ភោសិយភោត្តិ　ក្ពុណ្ហលំធិ គាថា ៥

ជម្មកា ទុំ ចាតិ វេឧហិ　ពលាជំ ពលមុត្តមំ ។



សូមព្រះអង្គកុំបណ្ដោយ នូវព្រះហឫទ័យក្រោធក្នុងពេល ចំពោះ អកុសល (របស់អ្នកដទៃ) ដែលប្រព្រឹត្តក្នុង (នូវអកុសល) ព្រោះ ថា ត្រកូលជាច្រើនឡាយដែលធ្លាប់ធំហើយ ច្រើនដល់នូវភាពមិន មែនជាត្រកូលទៅវិញ ព្រោះសេចក្ដីក្រោធ ។ បពិត្រព្រះបិតា សូមព្រះអង្គកុំបណ្ដោយ (មហាជន) ឲ្យធ្លាក់ទៅក្នុងសេចក្ដីវិនាស ដោយគិតថា ខ្លួនមិនញ៉ាំងផ្សេងៗ ការកើតឡើងនៃទុក្ខលំបាក កុំ ឲ្យមានដល់ស្ត្រីបុរសទាំងឡាយ ក្នុងដែនរបស់ព្រះអង្គ ។ ភោគ- សម្បត្តិទាំងអស់របស់ព្រះអង្គ ជាអ្នកប្រសើរតាមការព្រឹក្សា (ដែល គេនាំត្រៀម) តាមចំណង់ នឹងវិនាសទៅ (ដោយពិត) ការ វិនាសនោះ លោកពោលថាជាទុក្ខរបស់ព្រះអង្គ ។ នោះជា វត្ថុដែលកើតបញ្ចោះនោះឯង នុ៎ះឯងជាអនុសាសនី ដំឡើងនេះ សូម ព្រះអង្គសង្កត់ឲ្យធ្ងន់ កុំជាអ្នកលេង កុំញ៉ាំងប្រយោជន៍ឲ្យ វិនាស បពិត្រមហារាជ សូមព្រះអង្គមានសីល (ព្រោះថា) បុគ្គលអ្នកទ្រុស្តសីល ឈ្មោះថាជាអ្នកញ៉ាំងខ្លួនឲ្យធ្លាក់ចុះ ។

(៨៧៦) (ព្រះរាជា...) អញបានស្ដាប់ស្បថ្លៃ ជាភោសិយភោត្រ នឹង តាមក្មួយ [illegible] ដោយប្រការដូច្នេះហើយ ផលផ្លែ [illegible] អ្នកឡើងពល នូវកម្លាំងដ៏ខ្ពង់ខ្ពស់ ជាកម្លាំងទាំងឡាយ ។

(៩៩៣) ពលំ បញ្ចវិធំ លោកេ បុរិសស្មឹ មហគ្គតេ

តត្ថ ពាហុពលំ នាម ចរិមំ វុច្ចតេ ពលំ

ភោគពលញ្ច ទីឃាវុ ទុតិយំ វុច្ចតេ ពលំ ។

អមច្ចពលញ្ច ទីឃាវុ តតិយំ វុច្ចតេ ពលំ

អភិជច្ចពលញ្ចេវ តំ ចតុត្ថំ អសំសយំ

យានិ ចេតានិ សព្ពានិ អធិគណ្ហាតិ បណ្ឌិតោ ។

តំ ពលានំ ពលំ សេដ្ឋំ អគ្គំ បញ្ញាពលំ ពលំ

បញ្ញាពលេនុបត្ថទ្ធោ អត្ថំ វិន្ទតិ បណ្ឌិតោ ។

អបិ ចេ លភតិ មន្ទោ ផីតំ ធរណិមុត្តមំ

អកាមស្ស បសយ្ហំ វា អញ្ញោ តំ បដិបជ្ជតិ ។

អភិជាតោបិ ចេ ហោតិ រជ្ជំ លទ្ធាន ខត្តិយោ

ទុប្បញ្ញោ ហិ កាសិបតិ សព្ពេនបិ ន ជីវតិ ។

បញ្ញា សុតវិនិច្ឆិនី បញ្ញា (កិត្តិ) សិលោកវឌ្ឍនី

បញ្ញាសហិតោ នរោ ឥធ (អបិ) ទុក្ខេសុ សុខានិ វិន្ទតិ ។



(៩៩៣) (សេកដម្ពុកពោធិសត្វ...) កំឡាំងក្នុងលោក មាន ៥ យ៉ាង រមែងមានក្នុងបុរសដែលមានអធ្យាស្រ័យធំ បណ្តាកំឡាំងទាំងនោះ កំឡាំងដៃ (កាយ) បណ្ឌិតពោលថាជាកំឡាំងថោកទាប បពិត្រព្រះអង្គមានព្រះជន្មវែង កំឡាំងភោគៈ បណ្ឌិតពោលថាជាកំឡាំងទី ២ ។ បពិត្រព្រះអង្គមានព្រះជន្មវែង កំឡាំងអាមាត្យ បណ្ឌិតពោលថាជាកំឡាំងទី ៣ កំឡាំងជាតិខ្ពស់ ជាកំឡាំងទី ៤ ឥតសង្ស័យ បុគ្គលជាបណ្ឌិត រមែងគ្របសង្កត់នូវកំឡាំងទាំងអស់នេះ ។ កំឡាំងបញ្ញា នោះជាកំឡាំងប្រសើរ ជាកំឡាំងខ្ពង់ខ្ពស់ជាងកំឡាំងទាំងឡាយ បណ្ឌិតដែលមានកំឡាំងបញ្ញាជ្រោមជ្រែងហើយ រមែងបាននូវសេចក្តីចំរើន ។ បុគ្គលមានបញ្ញាទន់ ទោះបើបាននូវផែនដីស្តុកស្តម្ភប្រសើរ កាលបើបុគ្គលមានបញ្ញាទន់នោះ មិនមានប្រាថ្នា បុគ្គលដែលមានបញ្ញាដទៃ ធ្វើនូវការកំហែង ហើយគ្រប់គ្រងនូវផែនដីនោះ ។ បពិត្រព្រះអង្គជាម្ចាស់ផែនកាសី បើទុកជាបុគ្គលមានជាតិខ្ពង់ខ្ពស់ ជាក្សត្របាននូវរាជ្យ តែឥតប្រាជ្ញា ក៏រមែងមិនរស់នៅ ដោយរាជ្យទាំងពួងបាន ។ បញ្ញាជាធម្មជាតិសម្រាប់វិនិច្ឆ័យនូវសេចក្តីដែលបានស្តាប់ បញ្ញាជាគ្រឿងញុំាងកេរ្តិ៍ឈ្មោះនិងលាភសក្ការៈឲ្យចំរើន នរជនប្រកបដោយបញ្ញា ក្នុងលោកនេះ សូម្បីទុក្ខ (កើតឡើង) ក៏រមែងបាននូវសុខទាំងឡាយវិញ ។

បញ្ញញ្ច ខោ អសុស្សូសំ ន កោចិ អធិគច្ឆតិ

ពហុស្សុតំ អនាគម្ម ធម្មដ្ឋំ អវិនិព្ភុជំ ។

យោ ច ធម្មវិភង្គញ្ញូ កាលុដ្ឋាយី អតន្ទិតោ

អនុដ្ឋហតិ កាលេន កម្មផលំ តស្ស ឥជ្ឈតិ ។

អនាយតនសីលស្ស អនាយតនសេវិនោ

ន និព្វិន្ទិយការិស្ស សម្មទត្ថោ វិបច្ចតិ ។

អជ្ឈត្តញ្ច បយុត្តស្ស តថាយតនសេវិនោ

អនិព្វិន្ទិយការិស្ស សម្មទត្ថោ វិបច្ចតិ ។

យោគប្បយោគសង្ខាតំ សម្ភតស្សានុរក្ខណំ

តានិ ត្វំ តាត សេវស្សុ មា អកម្មាយ រន្ធយិ

អកម្មុនា ហិ ទុម្មេធោ នឡាគារំវ សីទតិ ។



មួយទៀត បុគ្គលណាមួយ មិនស្តាប់ដោយគោរព មិនចូលទៅរកបុគ្គលជាពហុស្សូត មិនឈ្វេងយល់នូវកិច្ចការ ដែលឋិតនៅក្នុងសភាវៈ រមែងមិនបាននូវបញ្ញា ។ លុះតែបុគ្គលណាជាអ្នកដឹងនូវចំណែកនៃធម៌ ប្រឹងប្រែងក្នុងកាលគួរ មិនខ្ជិលច្រអូស ប្រឹងប្រែងហើយ ៗ តាមកាលគួរ ផលកើតអំពីការងារ ទើបសម្រេចដល់បុគ្គលនោះ ។ កាលបុគ្គលមិនមានសីលជាទីកើត (នៃលាភ យស សុខ) សេពគប់នូវបុគ្គលទ្រុស្តសីល មិនជាទីកើត(នៃលាភ យស សុខ) ធ្វើការធុញទ្រាន់ ប្រយោជន៍ រមែងមិនឱ្យផលដោយប្រពៃទេ ។ លុះតែបុគ្គលប្រកបក្នុងការក្នុងសន្តាន សេពគប់នូវបុគ្គលមានសីលជាទីកើត (នៃលាភយសសុខ) ដូច្នោះ ធ្វើការមិនធុញទ្រាន់ ប្រយោជន៍រមែងឱ្យផលដោយប្រពៃ ។ បពិត្រពិតា សូមព្រះអង្គគប់រកនូវហេតុទាំងឡាយនោះ និងបញ្ញាជាចំណែកនៃព្យាយាម ក្នុងហេតុដែលគួរប្រកប និងការថែទាំទុក នូវទ្រព្យដែលព្រះអង្គបាន ព្រះអង្គកុំ (ញុំាងទ្រព្យ) ឱ្យវិនាស ដោយការងារមិនគួរ ព្រោះថា បុគ្គលឥតបញ្ញា រមែងលិចចុះ (ក្នុងសេចក្តីវិនាស) ដោយសារហេតុមិនមែនជាការងារ ដូចផ្ទះដែលធ្វើដោយដើមបបុស ។

[៤៧៦] ធម្មំ ចរ មហារាជ    មាតាបិតូសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន    រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ    បុត្តទារេសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន    រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ    មិត្តាមច្ចេសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន    រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ    វាហនេសុ ពលេសុ ច
ឥធ ធម្មំ ចរិត្វាន    រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ    គាមេសុ និគមេសុ ច
ឥធ ធម្មំ ចរិត្វាន    រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ    រដ្ឋេសុ ជនបទេសុ ច
ឥធ ធម្មំ ចរិត្វាន    រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ    សមណព្រាហ្មណេសុ ច
ឥធ ធម្មំ ចរិត្វាន    រាជ សគ្គំ គមិស្សសិ ។



(៤៧៦) បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការបំរើមាតាបិតាទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការសង្គ្រោះចំពោះបុត្តភរិយាទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះមិត្រនិងអាមាត្យទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះពាហនៈ និងពលទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះអ្នកស្រុក និងអ្នកនិគមទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះអ្នកដែននិងអ្នកជនបទទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះពួកសមណៈនិងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។

ធម្មំ ចរ មហារាជ  មិគបក្ខីសុ ខត្តិយ

ឥធ ធម្មំ ចរិត្វាន  រាជ សគ្គំ គមិស្សសិ ៕

ធម្មំ ចរ មហារាជ  ធម្មោ ចិណ្ណោ សុខាវហោ

ឥធ ធម្មំ ចរិត្វាន  រាជ សគ្គំ គមិស្សសិ ៕

ធម្មំ ចរ មហារាជ  ឥន្ទា ទេវា សព្រហ្មកា

សុចិណ្ណេន ទិវំ បត្តា  មា ធម្មំ រាជ បាមទោ(១)

តត្ថេវ តេ វត្តបទា  ឯសា អនុសាសនី

សប្បញ្ញសេវី កល្យាណី សមត្តំ សាម តំ វិទូតិ ៕

តេសកុណជាតកំ បឋមំ ៕

## សរភង្គជាតកំ

(៥៨៥) អលង្កតា កុណ្ឌលិនោ សុវត្ថា

វេឡុរិយមុត្តាថរុខគ្គពទ្ធា

រថេសភា តិដ្ឋថ កេ នុ តុម្ហេ ។

១ ម. បមាទោ ៕



បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ឲ្យស្មើ ចំពោះពួកម្រឹគ និងសត្វបក្សីទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ៕ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ (ព្រោះថា) ធម៌ដែលព្រះអង្គប្រព្រឹត្តហើយ រមែងនាំមកនូវសេចក្តីសុខ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ៕ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ព្រោះពួកព្រះឥន្ទ្រ ទេវតា ព្រមទាំងព្រហ្ម បានដល់នូវទិព្វសម្បត្តិ ដោយធម៌ដែលខ្លួនប្រព្រឹត្តល្អ បពិត្រព្រះរាជា សូមព្រះអង្គកុំប្រមាទធម៌ ៕ នោះជាវត្តបទក្នុងបញ្ហានោះឯង នុះឯងជាអនុសាសនី សូមព្រះអង្គសេពគប់នូវបុគ្គលមានបញ្ញា សូមមានគុណធម៌ល្អ ព្រះអង្គត្រាស់ដឹងនូវធម៌នោះ ដ៏បរិបូណ៌ដោយព្រះអង្គឯង (ប្រែថាព្រះអង្គចូរដឹងចុះ) ៕

ចប់ តេសកុណជាតក ទី ១ ៕

## សរភង្គជាតក

(៥៨៥) (អនុសិស្សរបស់សរភង្គថា) បពិត្រលោក ទាំងឡាយប្រសើរ លោកទាំងឡាយ មានខ្លួនប្រដាប់ហើយ មានកុណ្ឌល មានសំពត់ស្លៀកល្អ សៀតព្រះខ័នមានផ្ទប់ប្រដាប់ដោយកែវពៃទូរ្យនិងកែវមុក្តា ឈរនៅ (លើរថដ៏ប្រសើរ) លោកទាំងឡាយ ឈ្មោះអ្វី

ការំ កេ ជានន្តិ មនុស្សលោកេ ។

(៤៧៦) អហានន្ទកោ កឹនរជា បចាយំ
តាលិន្តកជា បន ឧក្កតោយំ
សុសញ្ញតានំ ឥសីនំ ទស្សនាយ
ឥធាគតា បុច្ឆិតាយេម្ហ បញ្ហេ ។

(៤៧៧) វេហាសយំ តិដ្ឋសិ អន្តលិក្ខេ
បជ្ជុន្នោ បណ្ណរសេវ ចន្ទោ
បុច្ឆាមិ តំ យក្ខ មហានុភាវ
កថន្តំ ជានន្តិ មនុស្សលោកេ ។

(៤៧៨) យមាហុ ទេវេសុ សុជម្បតីតិ
មឃវាតិ តំ អាហុ មនុស្សលោកេ
ស ទេវរាជា ឥទមជ្ជ បត្តោ
សុសញ្ញតានំ ឥសីនំ ទស្សនាយ ។

(៤៧៩) ទូរេ សុតា នោ ឥសយោ សមាគតា
មហិទ្ធិកា ឥទ្ធិគុណូបបន្នា
វន្ទាមិ តេ អយិរេ បសន្នចិត្តោ
យេ ជីវលោកេត្ថ មនុស្សសេដ្ឋា ។



ពួកជនក្នុងមនុស្សលោក ស្គាល់លោកទាំងឡាយដូចម្តេច ។

(៤៧៦) (ព្រះរាជាព្រះនាមអដ្ឋកៈត្រាស់ថា) ខ្ញុំជាព្រះរាជា ឈ្មោះ អដ្ឋកៈ នេះជាព្រះរាជាព្រះនាមភីមរថ នេះជាព្រះរាជាព្រះនាមកាលិង្គ ដែលមានតេជានុភាព មានកិត្តិស័ព្ទល្បីល្បាញ យើងទាំងឡាយមកក្នុងទីនេះ ដើម្បីឃើញនូវឥសីទាំងឡាយ ដែលសង្រួមល្អហើយ ដើម្បីសួរនូវប្រស្នាទាំងឡាយ ។

(៤៧៧) (អនុសិស្សតាបស.) លោកឋិតនៅក្នុងអាកាស ជាទីកកាយ នៃសត្វស្លាប ដូចព្រះចន្ទក្នុងថ្ងៃ១៥កើត ដែលឋិតនៅតាមផ្លូវឆ្ងាយ (អាកាស) បពិត្រយក្ស អាត្មាសូមសួរលោក ដែលមានអានុភាពធំ ពួកជនក្នុងមនុស្សលោក ដឹងស្គាល់លោកដូចម្តេច ។

(៤៧៨) (សក្កទេវរាជ...) ទេវតាទាំងឡាយ ក្នុងពួកទេវតា ហៅខ្ញុំណា ថា មឃវា ខ្ញុំនោះ ជាទេវរាជមកកាន់ទីនេះ ក្នុងថ្ងៃនេះ ដើម្បីឃើញឥសីទាំងឡាយ អ្នកសង្រួមល្អហើយ ។

(៤៧៩) ឥសីទាំងឡាយ របស់យើងខ្ញុំ ដែលជួបជុំគ្នា មានឫទ្ធិធំ ប្រកបដោយគុណគឺឫទ្ធិ ល្បីទៅក្នុងទីឆ្ងាយ ខ្ញុំមានចិត្តជ្រះថ្លា សូមថ្វាយបង្គំលោកម្ចាស់ទាំងឡាយ ដែលប្រសើរក្នុងមនុស្ស ក្នុងជីវលោកនេះ ។

(៤៤០) ករោ ឥសីនំ ចិរទក្ខិតានំ

កាយា ចុតោ គច្ឆតិ មាលុតេន

ឥតោ បដិក្កម្ម សហាស្សនេត្ត

ករោ ឥសីនំ អសុចិ ទេវរាជ ។

(៤៤១) ករោ ឥសីនំ ចិរទក្ខិតានំ

កាយា ចុតោ គច្ឆតុ មាលុតេន

វិចិត្រពុប្ផំ សុរភឹ មាលំ

កម្មញ្ច បីតំ បដិកង្ខាម ភន្តេ

ន ហេត្ថ ទេវ បដិក្កូលសញ្ញិនោ ។

(៤៤២) បុរិន្ទទោ ភូតបតី យសស្សី

ទេវានមិន្ទោ មឃវា សុជម្បតិ

ស ទេវរាជា អសុរ (គណ) ព្យមទ្ទនោ

ឱកាសមាកង្ខតិ បញ្ហ បុច្ឆិតុំ ។

កោ នេវិមេសំ ឥធ បណ្ឌិតានំ

បញ្ហេ បុដ្ឋោ និបុណេ វ្យាករិស្សតិ

តិណ្ណញ្ច រញ្ញំ មនុជាធិបានំ

ទេវានមិន្ទស្ស ច វាសវស្ស ។



(៤៤០) (ករោ ឥសីនំ...) ក្លិនរបស់ឥសីទាំងឡាយ ដែលបួសយូរ

រំពេចផ្សាយចេញអំពីកាយទៅតាមខ្យល់ បពិត្រសហស្សនេត្ត

សូមព្រះអង្គចៀសចេញអំពីទីនេះ បពិត្រទេវរាជ ក្លិនរបស់

ឥសីទាំងឡាយមិនស្អាតទេ ។

(៤៤១) (សុរាទេវរាជ...) ក្លិនរបស់ឥសីទាំងឡាយ ដែលបួសយូរ ចូរ

ផ្សាយចេញអំពីកាយទៅតាមខ្យល់ចុះ បពិត្រលោកដ៏ចំរើន

យើងខ្ញុំប្រាថ្នាប្រាថ្នានូវក្លិននុ៎ះ ដូចបុគ្គលប្រាថ្នានូវកម្រងផ្កា

មានផ្កាដ៏វិចិត្រ មានក្លិនក្រអូប ព្រោះទេវតាទាំងឡាយ ជា

អ្នកមិនមានសេចក្ដីសំគាល់ក្នុងក្លិននុ៎ះ ថាជាបដិក្កូលទេ ។

(៤៤២) (ករោ ឥសីនំ...) ទេវរាជនោះ ឈ្មោះបុរិន្ទទៈ ឈ្មោះភូតបតី

ជាអ្នកមានយស ឈ្មោះទេវានមិន្ទៈ ឈ្មោះមឃវា ឈ្មោះសុជម្បតិ

ជាអ្នកញាំញី(ផ្ចាញ់ផ្ចាល)ពួកអសុរ ទ្រង់ប្រាថ្នានូវឱកាសដើម្បីសួរប្រស្នា

ក្នុងទីនេះ បណ្ដាឥសីជាបណ្ឌិតទាំងឡាយនេះ បណ្ឌិតណាហ្ន៎

ដែលព្រះរាជាទាំង ៣ព្រះអង្គ ជាធំជាងមនុស្ស និងព្រះវាសវៈជា

ធំជាងទេវតា ត្រាស់សួរប្រស្នាដ៏ល្អិតហើយ នឹងដោះស្រាយបាន ។

[៨៤៣] អយំ ឥសី សរភង្គោ តបស្សី

យតោ ជាតោ វិរតោ មេថុនស្មា

អាចេរបុត្តោ សុវិនីតរូបោ

សោ នេសំ បញ្ហានិ វិយាករិស្សតិ ។

[៨៤៤] កោណ្ឌញ្ញ បញ្ហានិ វិយាករោហិ

យាចន្តិ តំ ឥសយោ សាធុរូបា

កោណ្ឌញ្ញ ឯសោ មនុជេសុ ធម្មោ

យំ វុឌ្ឍមាគច្ឆតិ ឯស ភារោ ។

[៨៤៥] កតាវកាសា បុច្ឆន្តុ ភោន្តោ

យំ កិញ្ចិ បញ្ហំ មនសាភិបត្ថិតំ

អហញ្ហិ តំ តំ វោ វិយាករិស្សំ

ញត្វា សយំ លោកមិមំ បរញ្ច ។

[៨៤៦] តតោ ច មឃវា សក្កោ អត្ថទស្សី បុរិន្ទទោ

អបុច្ឆិ បឋមំ បញ្ហំ យញ្ចាសិ អភិបត្ថិតំ ។



[៨៤៣] (អយំ ឥសី...) ឥសីឈ្មោះសរភង្គៈនេះ មានតបៈ ជាអ្នកវៀរចាកមេថុនធម្ម តាំងតែពីកើតមក ជាបុត្តនៃបុរោហិតដែលជាអាចារ្យ (របស់ព្រះរាជាកាលសី) មានសភាពរៀបរយល្អហើយ ឥសីឈ្មោះសរភង្គៈនោះ នឹងឆ្លើយនូវប្រស្នាទាំងឡាយ របស់ព្រះរាជាទាំងនោះបាន ។

[៨៤៤] (កោណ្ឌញ្ញ...) បពិត្រកោណ្ឌញ្ញៈ សូមលោកឆ្លើយនូវប្រស្នាទាំងឡាយ ឥសីទាំងឡាយមានសភាពដ៏ល្អ អារាធនាលោក បពិត្រកោណ្ឌញ្ញៈ ការដោះប្រស្នានុ៎ះ ជាទំនៀមតែងមាន ក្នុងពួកមនុស្ស បុគ្គលណា មកកាន់សេចក្តីចំរើន ប្រស្នានុ៎ះ ជាភារៈរបស់លោក ។

[៨៤៥] (សរភង្គតាបស...) លោកដ៏ចំរើនទាំងឡាយ ខ្ញុំធ្វើឱកាសឱ្យហើយ ចូរសួរនូវប្រស្នាណាមួយ ដែលលោកទាំងឡាយប្រាថ្នាហើយដោយចិត្តចុះ ព្រោះថា ខ្ញុំដឹងនូវលោកនេះ និងលោកខាងមុខ ដោយខ្លួនឯង នឹងឆ្លើយនូវប្រស្នានោះៗ ប្រាប់លោកទាំងឡាយបាន ។

[៨៤៦] (តតោ ច មឃវា) លំដាប់នោះ ទេវរាជ ព្រះនាម មឃវា សក្កៈ អ្នកឃើញនូវប្រយោជន៍ បានសួរប្រស្នាជាដំបូងដែលខ្លួនចង់ដឹងហើយថា

កិំសុ វធិត្វា ន កទាចិ សោចតិ
កិស្សប្បហានំ ឥសយោ វណ្ណយន្តិ
កស្សីធ វុត្តំ ផរុសំ ខមេថ
អក្ខាហិ មេ កោណ្ឌញ្ញ ឯតមត្ថំ ។

(៨៨៧) កោធំ វធិត្វា ន កទាចិ សោចតិ
មក្ខប្បហានំ ឥសយោ វណ្ណយន្តិ
សព្ពេសំ វុត្តំ ផរុសំ ខមេថ
ឯតំ ខន្តឹ ឧត្តមមាហុ សន្តោ ។

(៨៨៨) សក្កា ឧភិន្នំ វចនំ តិតិក្ខិតុំ
សទិសស្ស វា សេដ្ឋតរស្ស វាបិ
កថំ នុ ហីនស្ស វចោ ខមេថ
អក្ខាហិ មេ កោណ្ឌញ្ញ ឯតមត្ថំ ។

(៨៨៩) ភយា ហិ សេដ្ឋស្ស វចោ ខមេថ
សារម្ភហេតុ បន សាទិសស្ស
យោ ចីធ ហីនស្ស វចោ ខមេថ



បុគ្គលសម្លាប់អ្វី ទើបមិនក្រៀមក្រំ ក្នុងកាលណាមួយឡើយ ពួកឥសីតែងសរសើរនូវការលះបង់អ្វី បុគ្គលគប្បីអត់ធន់ចំពោះពាក្យអាក្រក់ ដែលបុគ្គលណាពោលហើយក្នុងលោកនេះ បពិត្រកោណ្ឌញ្ញៈ សូមលោកប្រាប់សេចក្ដីនុ៎ះដល់ខ្ញុំ ។

(៨៨៧) (សរភង្គតាបស...) បុគ្គលសម្លាប់សេចក្ដីក្រោធ រមែងមិនក្រៀមក្រំក្នុងកាលណាមួយឡើយ ពួកឥសីតែងសរសើរនូវការលះបង់នូវសេចក្ដីលុបគុណគេ បុគ្គលគប្បីអត់ធន់ចំពោះពាក្យអាក្រក់ ដែលបុគ្គលទាំងពួងពោលហើយ ពួកសប្បុរសពោលនូវសេចក្ដីអត់ធន់នុ៎ះ ថាជាគុណជាតិដ៏ឧត្តម ។

(៨៨៨) (សក្កទេវរាជ...) បុគ្គលអាចអត់ធន់នូវពាក្យរបស់ជនទាំងពីរពួកបាន គឺបុគ្គលស្មើគ្នានឹងបុគ្គលប្រសើរជាង ចុះបុគ្គលអត់ធន់នូវពាក្យរបស់បុគ្គលថោកទាប តើដូចម្ដេច បពិត្រកោណ្ឌញ្ញៈ សូមលោកប្រាប់សេចក្ដីនុ៎ះដល់ខ្ញុំ ។

(៨៨៩) (សរភង្គតាបស...) បុគ្គលអត់ធន់នូវពាក្យ របស់បុគ្គលដ៏ប្រសើរ ព្រោះសេចក្ដីខ្លាច និងបុគ្គលអត់ធន់នូវពាក្យ របស់បុគ្គលស្មើគ្នា ព្រោះហេតុនៃការប្រណាំងប្រជែង ចំណែកបុគ្គលណា ក្នុងលោកនេះ អត់ធន់នូវពាក្យ របស់បុគ្គលថោកទាបបាន

ឯតំ ទុក្ខំ ទុក្ខមមាហុ សន្តោ ។

(៨៤០) កាមំ វិជញ្ញា ចតុមដ្ឋរូបំ

សេដ្ឋំ សរីរំ អជកាម ហានិ

វិប្បរូបេន ចរន្តិ សន្តោ

តស្មា ហិ សន្តេសុ វិទោ ទមេថ ។

(៨៤១) ន ហេតមត្ថំ មហតិបិ សេនា

សរាជិកា យុជ្ឈមានា លភេថ

យំ ខន្តិមា សប្បុរិសោ លភេថ

ខន្តីពលស្សូបសមន្តិ វេរា ។

(៨៤២) សុភាសិតន្តេ អនុមោទិយាន

អញ្ញំ បុច្ឆាមិ តទិង្ឃ ព្រូហិ

យថា អហុ ទណ្ឌកី នាឡិកេរោ

អថជ្ជុនោ កលាពុ ចាបិ រាជា

តេសំ គតី ព្រូហិ សុបាបកម្មិនំ

កត្ថូបបន្នា ឥសីនំ វិហេឋកា ។



សប្បុរសទាំងឡាយ ពោលនូវសេចក្តីនេះថាទុក្ខ (របស់បុគ្គលនោះ) ថាជាទុក្ខធំជាងទុក្ខទាំងអស់ ។

(៨៤០) ព្រឹទ្ធាចារ្យ បុគ្គលគប្បីដឹងច្បាស់នូវបុគ្គលប្រសើរជាតិ ឬបុគ្គលស្មើខ្លួន ឬក៏បុគ្គលថោកទាប ដែលមានសភាពបំផុតដោយវណ្ណៈទាំង ៤ បាន សប្បុរសទាំងឡាយ តែងប្រព្រឹត្តតាមរបៀបបុគ្គលជម្រះខ្លួន ព្រោះហេតុនោះ បុគ្គលគួរអត់ធន់នូវពាក្យរបស់បុគ្គលទាំងពួង ។

(៨៤១) សប្បុរស អ្នកមានខន្តិ គប្បីបាននូវសេចក្តីចំរើនណា សេនាព្រមទាំងព្រះរាជា កាលច្បាំងគ្នា មិនគប្បីបាននូវសេចក្តីចំរើននុ៎ះទេ ពៀរទាំងឡាយរបស់បុគ្គលអ្នកមានខន្តិជាកំឡាំង រមែងស្ងប់រម្ងាប់បាន ។

(៨៤២) (សក្កទេវរាជ...) ខ្ញុំត្រេកអរនឹងសុភាសិតរបស់លោកហើយ សូមសួរប្រស្នាដទៃនឹងលោកទៀត សូមលោកពោលប្រស្នានោះ ដូចយ៉ាងព្រះបាទទណ្ឌកី ព្រះបាទនាលិកេរៈ ព្រះបាទអជ្ជុនៈ និងព្រះបាទកលាពុ សូមលោកប្រាប់នូវគតិរបស់ស្តេចទាំងនោះ ដែលមានបាបកម្មដ៏ក្រាស់ តើព្រះរាជាទាំងនោះ ជាអ្នកបៀតបៀននូវឥសីទាំងឡាយ ទៅកើតក្នុងទីណា ។

(៨៩៣) កិសំ ហិ វច្ឆំ អវកិរិយ ទណ្ឌកី
ឧច្ឆិន្នមូលោ សជនោ សរដ្ឋោ
កុក្កុឡនាមេ និរយម្ហិ បច្ចតិ
តស្ស ផុលិង្គានិ បតន្តិ កាយេ ។
យោ សញ្ញតេ បព្វជិតេ អវញ្ចយិ
ធម្មំ ភណន្តេ សមណេ អទូសកេ
តំ នាឡិកេរំ សុនខា បរត្ថ
សង្គម្ម ខាទន្តិ វិផន្ទមានំ ។
អថជ្ជុនោ និរយេ សត្តិសូលេ
អវំសិរោ បតិតោ ឧទ្ធំបាទោ
អង្គីរសំ គោតមំ ហេឋយិត្វា ។
ខន្តិំ តបស្សិំ ចិរព្រហ្មចារិំ ។
យោ ខណ្ឌសោ បព្វជិតំ អច្ឆេទយិ
ខន្តិំ វទន្តំ សមណំ អទូសកំ
កលាពុវីចិំ ឧបបជ្ជ បច្ចតិ
មហាបតាបំ កដុកំ ភយានកំ ។
ឯតានិ សុត្វា និរយានិ បណ្ឌិតោ
អញ្ញានិ បាបិដ្ឋតរានិ ចេត្ថ





(៨៩៣) (សក្កទេវរាជ...) ព្រះបាទទណ្ឌកីព្រមទាំងជនទាំងអ្នកដែន
បានស្តោះដាក់តាបសឈ្មោះកិសវច្ឆៈ ព្រះអង្គមានឫសដាច់
ហើយនៅក្នុងនរកឈ្មោះកុក្កុឡៈ រងើកភ្លើងទាំងឡាយធ្លាក់មក
ដាច់លើកាយនៃព្រះអង្គ ។ ព្រះបាទនាឡិកេរៈណា បានបៀត-
បៀនពួកបព្វជិតទាំងឡាយ ជាអ្នកសង្រួម ជាអ្នកពោលធម៌ មិន
ប្រទូស្តក្នុងសំដែងធម៌ ឆ្កែទាំងឡាយតែងនាំស៊ីនូវព្រះបាទ
នាឡិកេរៈនោះ ឲ្យរង្គោះរង្គើក្នុងបរលោក ។ ឯព្រះបាទអជ្ជុនៈ
មានព្រះសិរសាចុះក្រោម មានព្រះបាទឡើងលើ ធ្លាក់ក្នុងនរក
ឈ្មោះសត្តិសូលៈ ព្រោះតែបៀតបៀនឫសីឈ្មោះអង្គីរសៈ
ជាគោតមគោត្រ ជាអ្នកអត់ធន់ មានតបៈ ប្រព្រឹត្តធម៌ដ៏ប្រសើរ
អស់កាលយូរ ។ ព្រះបាទកលាពុណា បានកាត់ឲ្យដាច់ជាកំណាត់
ជាចំណិតកំណាត់ៗ នូវបព្វជិតដែលពោលនូវខន្តិ ជាអ្នកស្ងប់
ស្ងាត់ ជាអ្នកមិនប្រទូស្ត ព្រះបាទកលាពុ (នោះ) ក៏កើតនៅ
នៅក្នុងនរកឈ្មោះកលាពុវីចិ មានកំដៅដ៏ខ្លាំង មានវេទនាដ៏
ក្ដៅ ជាទីគួរខ្លាច ។ បណ្ឌិតបានឮនូវនរកទាំងឡាយនេះផង
នូវនរកទាំងឡាយដទៃ ដ៏លាមក លើសជាងនរកនេះផង

ធម្មញ្ចរេ សាមណព្រាហ្មណេសុ
បរិព្ពជេ សគ្គមុបេតិ ឋានំ ។

(៤៤៦) សុភាសិតន្តេ អនុមោទិយាន
អញ្ញំ បុច្ឆាមិ តទិង្ឃ ព្រូហិ
កថំវិធំ សីលវន្តំ វទន្តិ
កថំវិធំ បញ្ញវន្តំ វទន្តិ
កថំវិធំ សប្បុរិសំ វទន្តិ
កថំវិធំ នោ សិរិ នោ ជហាតិ ។

(៤៤៧) កាយេន វាចាយ ច យោធ សញ្ញតោ
មនសា ច កិញ្ចិ ន ករោតិ បាបំ
ន អត្តហេតុ អលិកំ ភណាតិ
តថាវិធំ សីលវន្តំ វទន្តិ ។
គម្ភីរបញ្ហំ មនសាភិចិន្តយំ
នច្ចាហិតំ កម្ម ករោតិ លុទ្ទំ
កាលាគតំ អត្ថបទំ ន រិញ្ចតិ
តថាវិធំ បញ្ញវន្តំ វទន្តិ ។





នូវប្រព្រឹត្តធម៌ក្នុងសមណព្រាហ្មណ៍ទាំងឡាយ លុះ[illegible] នេះហើយ រមែងកើតក្នុងឋានសួគ៌ ។

(៤៤៦) (សុភាសិតំ...) ខ្ញុំត្រេកអរនឹងសុភាសិតរបស់លោកម្ចាស់ ហើយ សូមសួរនូវប្រស្នាដទៃ ចំពោះលោកម្ចាស់ទៀត សូមលោកម្ចាស់ប្រាប់នូវប្រស្នានោះ បណ្ឌិតទាំងឡាយពោលនូវបុគ្គលបែបដូចម្ដេច ថាជាអ្នកមានសីល ពោលនូវបុគ្គលបែបដូចម្ដេច ថាជាអ្នកមានប្រាជ្ញា ពោលនូវបុគ្គលបែបដូចម្ដេច ថាជាសប្បុរស សិរីមិនលះបង់នូវបុគ្គលបែបដូចម្ដេច ។

(៤៤៧) (កាយេន វាចាយ...) បុគ្គលណាក្នុងលោកនេះ ជាអ្នកសង្រួម ដោយកាយ ដោយវាចា ទាំងមិនធ្វើនូវបាបតិចតួចដោយចិត្ត មិនពោលពាក្យកុហក ព្រោះហេតុនៃខ្លួន បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលបែបនោះ ថាជាអ្នកមានសីល ។ បុគ្គលណា កាលគិតនូវប្រស្នាដ៏ជ្រាលជ្រៅដោយចិត្ត ហើយ មិនធ្វើនូវអំពើអាក្រក់ ដែលគ្មានប្រយោជន៍ មិនលះបង់នូវចំណែកនៃប្រយោជន៍ ដែលមកដល់តាមកាល បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលបែបនោះ ថាជាអ្នកមានបញ្ញា ។

យោ វេ កតញ្ញូ កតវេទិ ធីរោ

កល្យាណមិត្តោ ទឡ្ហភត្តិ ច ហោតិ

ទុក្ខិតស្ស សក្កច្ច ករោតិ កិច្ចំ

តថាវិធំ សប្បុរិសំ វទន្តិ ។

ឯតេហិ សព្វេហិ គុណេហុបេតោ

សទ្ធោ មុទូ សំវិភាគី វទញ្ញូ

សង្គាហកំ សខិលំ សណ្ហវាចំ

តថាវិធំ នោ សិរី នោ ជហាតិ ។

(៨៩៦) សុភាសិតំ តេ អនុមោទិយាន

អញ្ញំ តុ បុច្ឆាមិ តទិង្ឃ ព្រូហិ

សីលំ សិរិញ្ចាបិ សតញ្ច ធម្មំ

បញ្ញញ្ច កំ សេដ្ឋតរំ វទន្តិ ។

(៨៩៧) បញ្ញា ហិ សេដ្ឋា កុសលា វទន្តិ

នក្ខត្តរាជារិវ តារកានំ

សីលំ សិរី ចាបិ សតញ្ច ធម្មោ

អន្វាយិកា បញ្ញវតោ ភវន្តិ ។

(៨៩៨) សុភាសិតំ តេ អនុមោទិយាន

អញ្ញំ តុ បុច្ឆាមិ តទិង្ឃ ព្រូហិ



បុគ្គលណា ជាអ្នកដឹងគុណ មានប្រាជ្ញា មានមិត្រល្អ មានការស្មោះត្រង់មាំ ធ្វើនូវកិច្ចដោយគោរព ចំពោះបុគ្គលអ្នកដល់នូវសេចក្ដីទុក្ខ បណ្ឌិតទាំងឡាយ តែងពោលនូវបុគ្គលបែបនោះថាជាអ្នកសប្បុរស ។ បុគ្គលណា ជាអ្នកប្រកបដោយគុណទាំងពួងនេះ ជាអ្នកមានសទ្ធា មានចិត្តទន់ ជាអ្នកចែករំលែក ជាអ្នកដឹងនូវពាក្យ (របស់ស្មូម) សិរីមិនលះបង់នូវបុគ្គលជាអ្នកសង្គ្រោះ មានពាក្យពីរោះ មានពាក្យស្លូតបែបនោះទេ ។

(៨៩៦) (សក្កទេវរាជ...) ខ្ញុំត្រេកអរនឹងសុភាសិតរបស់លោកហើយ សូមសួរ នូវប្រស្នាដទៃនឹងលោកទៀត សូមលោកត្រាស់ប្រាប់នូវប្រស្នានោះ បណ្ឌិតទាំងឡាយ តែងពោលនូវសីលផង សិរីផង ធម៌របស់សប្បុរសផង ប្រាជ្ញាផង តើគុណជាតិណាប្រសើរបំផុត ។

(៨៩៧) (សោកន្ទីតាបស...) អ្នកឈ្លាសវៃទាំងឡាយ តែងពោលថាប្រាជ្ញាជាគុណជាតិប្រសើរបំផុត ដូចស្ដេចនៃផ្កាយ (ព្រះចន្ទ្រ) ដ៏ប្រសើរជាងផ្កាយទាំងឡាយ ទុកជាសីលក្ដី សិរីក្ដី ធម៌របស់សប្បុរសក្ដី ក៏ប្រព្រឹត្តទៅតាមបុគ្គលអ្នកមានប្រាជ្ញា ។

(៨៩៨) (សក្កទេវរាជ...) ខ្ញុំត្រេកអរនឹងសុភាសិតរបស់លោកហើយ សូមសួរប្រស្នាដទៃនឹងលោកទៀត សូមលោកប្រាប់ប្រស្នានោះ

កថង្ករោ កិន្តិករោ កិមាចរំ
កិំ សេវមានោ លភតីធ បញ្ញំ
បញ្ញាយ ទានិ បដិបទំ វទេហិ
កថង្ករោ បញ្ញវា ហោតិ មច្ចោ ។

(៨៨៤) សេវេថ វុឌ្ឍេ និបុណេ ពហុស្សុតេ
ឧគ្គាហកោ ច បរិបុច្ឆកោ សិយា
សុណេយ្យ សក្កច្ច សុភាសិតានិ
ឯវង្ករោ បញ្ញវា ហោតិ មច្ចោ ។

ស បញ្ចកាមគុណេ អវេក្ខតិ
អនិច្ចតោ ទុក្ខតោ រោគតោ ច
ឯវំ វិបស្សី បជហាតិ ឆន្ទំ
ទុក្ខេសុ កាមេសុ មហព្ភយេសុ ។

ស វីតរាគោ ស វិនេយ្យ ទោសំ
មេត្តំ ចិត្តំ ភាវយេ អប្បមាណំ
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
អនិន្ទិតោ ព្រហ្មុបេតិ ឋានំ ។



បុគ្គលក្នុងលោកនេះ ធ្វើដូចម្ដេច ធ្វើការអ្វី ប្រព្រឹត្តដូចម្ដេច សេពនូវអ្វី ទើបបាននូវប្រាជ្ញា សូមលោកម្ចាស់ ប្រាប់នូវបដិបទា នៃប្រាជ្ញាក្នុងកាលឥឡូវនេះ បុគ្គលធ្វើដូចម្ដេច ទើបជាអ្នកមានប្រាជ្ញា ។

(៨៨៤) (សេវេថ វុឌ្ឍេ...) បុគ្គលគប្បីសេពគប់នូវពួកអ្នកចំរើន(ដោយប្រាជ្ញា) ឈ្លាសវៃនូវតានុសិល្ប៍ ជាពហុស្សូត គប្បីជាអ្នករៀនធម៌ ជាអ្នកសាកសួរធម៌ គប្បីស្ដាប់នូវសុភាសិតទាំងឡាយ ដោយគោរពធម៌ បុគ្គលធ្វើយ៉ាងនេះ ទើបជាអ្នកមានប្រាជ្ញា ។ បុគ្គលជាអ្នកប្រាជ្ញនោះ ឃើញច្បាស់នូវកាមគុណទាំងឡាយ ជាមិនទៀង ជាទុក្ខ ជារោគ បុគ្គលឃើញច្បាស់ យ៉ាងនេះ ទើបលះបង់នូវឆន្ទៈ ក្នុងកាមទាំងឡាយ ដែលជាទុក្ខ ជាភ័យធំបាន ។ បុគ្គលនោះ ប្រាសចាករាគៈ កំចាត់បង់នូវទោសៈហើយ គប្បីចំរើននូវមេត្តាចិត្ត រកប្រមាណមិនបាន ដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងពួង ជាអ្នកដែលបុគ្គលណាមួយ តិះដៀលមិនបាន រមែងទៅកើតក្នុងឋានព្រហ្ម ។

(៦០០) មហិទ្ធិ យំ[១] អាគមំ អហោសិ
តវេមដ្ឋក គិមវជស្ស តាទិ
កាលិង្គកជស្ស ច ខុត្តកស្ស
សព្វេសុ តេ កាមការោ បហោតិ ។

(៦០១) យាចាមិ បរចិត្តវេទិ
សព្វេសុ តោ កាមការោ បហោតិ
ករោហិ ឱកាសមនុគ្គហាយ
យថា គតិំ តេ អភិសម្បរេម ។

(៦០២) ករោមិ ឱកាសមនុគ្គហាយ
តថាហិ ភោ កាមការោ បហោតិ
ផរថ កាយំ វិបុលាយ បីតិយា
យថា គតិំ មេ អភិសម្បរេថ ។

(៦០៣) សព្វំ ករិស្សាម តវានុសាសនិំ
យំ យំ តុវំ វក្ខសិ [illegible]
ផរាម កាយំ វិបុលាយ បីតិយា
យថា គតិំ តេ អភិសម្បរេម ។

---
១ ឱ. មហិទ្ធិយំ ។



(៦០០) បពិត្រព្រះបុត្រអម្ពដ្ឋ: ការយាចន៍ក នៃព្រះអង្គផង នៃព្រះបុត្រ
គីមាវឋ:ផង នៃព្រះបុត្រកាលិង្គ: ដែលមានគតិដូចគ្នាផង
ហើយផង ជាព្រះរាជបំណងមានឫទ្ធិដ៏ច្រើន (ព្រោះ) ការធ្វើ
នៃព្រះអង្គទាំងអស់ បានលះបង់ហើយ ។

(៦០១) (ព្រះរាជាទាំងបួនព្រះអង្គទ្រង់សារសើរថា) លោកម្ចាស់បានដឹង
ច្បាស់នូវចិត្តរបស់បុគ្គលដទៃនុះហើយនេះឯង ឯការធ្វើ យើង
ខ្ញុំទាំងអស់គ្នាបានលះហើយ សូមលោកម្ចាស់ធ្វើឱកាស ដើម្បី
អនុគ្រោះ (ចំពោះ) ឲ្យយើងខ្ញុំបានដល់នូវគតិរបស់លោក ។

(៦០២) (សរភង្គតាបស...) អាត្មាភាពធ្វើឱកាសដើម្បីអនុគ្រោះ ព្រោះ
ថា មហាពិតទាំងឡាយបានលះបង់នូវការធ្វើ ដោយប្រការ
ដូច្នោះមែន មហាពិតទាំងឡាយ ចូរញ៉ាំងកាយឲ្យផ្សព្វផ្សាយ
ដោយបីតិ ដ៏ក្រៃ(ធំក្រៃលែង) ដ៏ទូលាយ ឲ្យមហាពិតទាំង
ឡាយបានដល់ នូវគតិរបស់អាត្មាភាព ។

(៦០៣) (ព្រះរាជាទាំង ៤ ព្រះអង្គ...) បពិត្រលោកអ្នកមានប្រាជ្ញា ដូច
ដែលលោកម្ចាស់ពោលពាក្យណាៗ យើងខ្ញុំនឹងធ្វើតាមពាក្យ
របស់លោកទាំងអស់នោះៗ យើងខ្ញុំនឹងញ៉ាំងកាយឲ្យផ្សព្វផ្សាយ
ដោយបីតិដ៏ទូលាយ ឲ្យយើងខ្ញុំបានដល់នូវគតិរបស់លោក ។

(២០៦) កតាយ វច្ឆស្ស កិសស្ស បូជា
គច្ឆន្តុ ភោន្តោ ឥសយោ សាធុរូបា
ឈានេ រតា ហោថ សទា សមាហិតា
ឯសា រតី បព្វជិតស្ស សេដ្ឋា ។

(២០៧) សុត្វាន គាថា បរមត្ថសញ្ហិតា
សុភាសិតា ឥសិនា បណ្ឌិតេន
តេ វេទជាតា អនុមោទមានា
បក្កាមុ ទេវា ទេវបុរំ យសស្សិនោ ។
គាថា ឥមា អត្ថវតី សុព្យញ្ជនា
សុភាសិតា ឥសិនា បណ្ឌិតេន
យោ កោចិមា អដ្ឋិកត្វា សុណេយ្យ
លភេថ បុព្វាបរិយំ វិសេសំ
លទ្ធាន បុព្វាបរិយំ វិសេសំ
អទស្សនំ មច្ចុរាជស្ស គច្ឆេ ។

(២០៨) សាលិស្សរោ សារីបុត្តោ មេណ្ឌិស្សរោ ច កស្សបោ
បព្វតោ អនុរុទ្ធោ ច កច្ចាយនោ ច ទេវលោ
អនុសិស្សោ ច អានន្ទោ កិសវច្ឆោ ច កោលិតោ



(២០៦) (សរភង្គតាបស...) ការបូជានេះ ពួកឥសីបានធ្វើហើយ ដល់ឥសីឈ្មោះកីសវច្ឆៈ ឥសីទាំងឡាយដ៏ចំរើន មានសភាពល្អ ចូរទៅចុះ អ្នកទាំងឡាយ ចូរត្រេកអរក្នុងឈាន មានចិត្តតាំងមាំ សព្វៗកាលចុះ នេះជាសេចក្តីត្រេកអរដ៏ប្រសើររបស់បព្វជិត ។

(២០៧) (អភិសម្ពុទ្ធគាថា) ទេវតាទាំងឡាយនោះ មានយស បានស្តាប់នូវគាថាទាំងឡាយ ដ៏ប្រកបដោយប្រយោជន៍ដ៏ក្រៃលែង ដែលឥសីជាបណ្ឌិតពោលល្អហើយ ជាអ្នកបានបីតិហើយ អនុមោទនា ចៀសចេញទៅកាន់ទេវបុរី ។ គាថាទាំងឡាយនេះ មានអត្ថ មានព្យញ្ជនៈដ៏ពីរោះ ដែលឥសីជាបណ្ឌិតពោលល្អហើយ បុគ្គលឯណានីមួយ ស្តាប់គាថាទាំងឡាយនេះ ធ្វើឲ្យមានប្រយោជន៍ រមែងបាននូវគុណវិសេសខាងដើម និងខាងចុង លុះបាននូវគុណវិសេស ខាងដើមនិងខាងចុងហើយ គប្បីដល់នូវព្រះនិព្វាន ជាគុណមិនឃើញនូវមច្ចុរាជ ។

